ដំនាហ្យំនខ្ញាពាហ៍ពិពាហ៍
និខ្ញឹ្យៗារ

”ៗ្យវ៉ែភាល៍នាំហារៗិហ្យារតៗៗិៗ្យ



ទំនាក់ទំនងអាពាហ៍ពិពាហ៍ និងគ្រួសារ

ស្បៀវភៅណែនាំការសិក្សារបស់សិស្ស

ពោះពុម្ពដោយ
សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ទីក្រុង សលត៍ លេក រដ្ឋយូថាហ៍

មតិយោបល់ និងសំណូមពរ

យើងសូមថ្លែងនូវអំណរគុណចំពោះមតិយោបល់ និងសំណូមពររបស់អ្នកសំរាប់ស្បៀវភៅណែនាំការសិក្សានេះ។
សូមផ្ញើមតិយោបល់ និងសំណូមពររបស់អ្នកទៅកាន់ ៖

Curriculum Planning
50 East North Temple Street, Floor 24
Salt Lake City, UT 84150-3200
USA

អ៊ីម៉ែល ៖ cur-development@ldschurch.org

សូមមេត្តាសរសេរឈ្មោះ អាស័យដ្ឋាន រួដ និងស្តេករបស់អ្នក។ សូមកុំភ្លេចដាក់ចំណងដើងនៃស្បៀវភៅណែនាំការសិក្សា។
បន្ទាប់មក សូមផ្តល់មតិ និងយោបល់អំពីគុណសម្បត្តិ និងផ្នែកដែលត្រូវការការកែសំរួលនាពេលអនាគត
ដើម្បីធ្វើឱ្យមានភាពប្រសើរឡើងសំរាប់ស្បៀវភៅណែនាំការសិក្សានេះ។

© 2000 ដោយ Intellectual Reserve, Inc.
រក្សាសិទ្ធិគ្រប់យ៉ាង
បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា
អនុមតិជាភាសាអង់គ្លេស 8/97
អនុមតិឱ្យបកប្រែ 8/97
ការបកប្រែនៃ *Marriage and Family Relations: Participant's Study Guide*
Cambodian

មាតិកា

"ក្រុមគ្រួសារ ៖ការប្រកាសដល់ពិភពលោក" iv
សេចក្តីផ្តើម v
ចំណុចសង្ខេបនៅក្នុងវគ្គសិក្សាស្តីអំពីទំនាក់ទំនងអាពាហ៍ពិពាហ៍ និងគ្រួសារ vii

ផ្នែក កៈ ការពង្រឹងអាពាហ៍ពិពាហ៍

1. "គ្រួសារជាផ្នែកសំខាន់មួយនៃផែនការរបស់ព្រះដ៏បង្កបង្កើត" 3
2. ការអភិវឌ្ឍន៍សាមគ្គីភាពក្នុងអាពាហ៍ពិពាហ៍ 8
3. ការចិញ្ចឹមបីបាច់សេចក្តីស្រឡាញ់ និង ចំណងមិត្តភាពនៅក្នុងអាពាហ៍ពិពាហ៍ 12
4. ការឆ្លើយតបទៅនឹងបញ្ហាប្រឈមនៅក្នុងអាពាហ៍ពិពាហ៍. 16
5. ការឆ្លើយតបទៅនឹងឧបសគ្គតាមរយៈទំនាក់ទំនងវិជ្ជមាន 18
6. ការពង្រឹងអាពាហ៍ពិពាហ៍តាមរយៈសេចក្តីជំនឿ និង ការអធិស្ឋាន 21
7. អំណាចព្យាបាលនៃការអភ័យទោស. 25
8. ការគ្រប់គ្រងហិរញ្ញវត្ថុក្រុមគ្រួសារ. 28

ផ្នែក ខៈ ការទទួលខុសត្រូវរបស់ឪពុកម្តាយដើម្បីពង្រឹងដល់ក្រុមគ្រួសារ

9. "កូនៗគឺជាមរតកពីព្រះអម្ចាស់". 35
10. តួនាទីពិសិដ្ឋរបស់ឪពុក និងម្តាយ (ផ្នែកទី 1ៈ តួនាទីរបស់ឪពុក). 40
11. តួនាទីពិសិដ្ឋរបស់ឪពុក និងម្តាយ (ផ្នែកទី 2ៈ តួនាទីរបស់ម្តាយ) 44
12. ការបង្រៀនកូនចៅតាមរយៈគំរូ និងការណែនាំ. 49
13. ការបង្រៀនគោលការណ៍ដំណឹងល្អចំពោះកូនៗ (ភាគទី 1). 55
14. ការបង្រៀនគោលការណ៍ដំណឹងល្អចំពោះកូនៗ (ភាគទី 2). 60
15. ការណែនាំកូននៅពេលដែលពួកគេធ្វើការសំរេចចិត្ត 66
16. ការអធិស្ឋានជាក្រុមគ្រួសារ ការសិក្សាព្រះគម្ពីរជាក្រុមគ្រួសារ និង រាត្រីជួបជុំក្រុមគ្រួសារ. 70

ក្រុមគ្រួសារ

ការប្រកាស ដល់ពិភពលោក

គណៈប្រធានទី១ និងក្រុមប្រឹក្សានៃពួកសាវក១២នាក់ នៃព្រះវិហារសាសនាព្រះយេស៊ូវគ្រីស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

យើង គណៈប្រធានទី១ និងក្រុមប្រឹក្សានៃពួកសាវក១២នាក់ នៃព្រះវិហារសាសនាព្រះយេស៊ូវគ្រីស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ប្រកាសដោយឧឡារិកថា អាពាហិពិពាហិរវាងប្រុសនិងស្រី គឺតែងតាំងឡើងដោយព្រះ ហើយគ្រួសារជាផ្នែកសំខាន់មួយ នៃផែនការណ៍របស់ព្រះដ៏បង្កបង្កើតសំរាប់គោលដៅដ៏អស់កល្បជានិច្ចនៃកូនចៅរបស់ព្រះអង្ត ។

មនុស្សទាំងអស់–ទាំងប្រុសទាំងស្រី–បានបង្កើតមកឲ្យដូចរូបអង្គព្រះ ។ មនុស្សនីមួយៗសុទ្ធតែជាព្រលឹងកូនប្រុសកូនស្រីជាទីស្រឡាញ់នៃព្រះមាតាបិតាសួគិ ដូច្នេះហើយ ម្នាក់ៗមានចរិតនិងគោលដៅព្រះ ។ ភេទប្រុសស្រីជាលក្ខណៈ និងគោលបំណងសំខាន់មួយនៃបុគ្គលម្នាក់ៗចាប់តាំងពីមុនកើតមក នៅជីវិតនេះ ហើយដល់អស់កល្បជានិច្ច ។

នៅពិភពមុននឹកើតមក ព្រលឹងកូនប្រុសកូនស្រីរបស់ព្រះបានស្គាល់ហើយបានថ្វាយបង្គំព្រះជាព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ចរបស់ពួកគេ ហើយបានទទួលផែនការណ៍របស់ព្រះអង្ត ដែលនាំឲ្យកូនចៅទ្រង់ទាំងឡាយ អាចទទួលរូបកាយសាច់ឈាមបាន ហើយអាចទទួល ការពិសោធន៍នៅលើផែនដី ដើម្បីលូតលាស់ដល់ភាពល្អឥតខ្ចោះ ហើយដល់ទីបញ្ចប់អាចបានសំរេចគោលដៅព្រះ ដោយទទួលជីវិតដ៏អស់កល្បជានិច្ចទុកជាមរតក ។ ផែនការណ៍នៃ សុភមង្គលរបស់ព្រះ ធ្វើឲ្យទំនាក់ទំនងជាគ្រួសារចេះតែបន្តរហូតហួសពីសេចក្តីស្លាប់ ។ ពិធីបរិសុទ្ធនិងសេចក្តីសញ្ញាដ៏ពិសិដ្ឋទាំងប៉ុន្មាន ដែលមាននៅក្នុងព្រះវិហារបរិសុទ្ធ ធ្វើឲ្យបុគ្គលនីមួយៗ អាចវិលត្រឡប់ទៅវត្តមាននៃព្រះវិញ ហើយធ្វើឲ្យគ្រួសារបានរួបរួមជួបជុំគ្នា នៅអស់កល្បជានិច្ច ។

ព្រះបញ្ញត្តិទី១ ដែលព្រះទ្រង់បានប្រទានដល់លោកអ័ដាមនិងនាងអេវ៉ា ទាក់ទងទៅនឹងសមត្ថភាពរបស់គេ ដែលអាចធ្វើជាឪពុកម្តាយ និងប្តីប្រពន្ធ ។ យើងប្រកាសថា ព្រះបញ្ញត្តិរបស់ព្រះសំរាប់ឲ្យកូនចៅរបស់ទ្រង់បង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពាសពេញលើផែនដី នោះនៅតែឲ្យប្រតិបត្តិនៅឡើយ ។ ថែមទៅទៀត យើងប្រកាសថា ព្រះទ្រង់បានបញ្ជាឲ្យរក្សាអំណាចដ៏ពិសិដ្ឋនៃការបង្កើតកូនចៅ ប្រើបានសំរាប់តែរវាងប្រុសស្រី ដែលបានរៀបអាពាហិពិពាហិពេញច្បាប់ ជាប្តីប្រពន្ធប៉ុណ្ណោះ ។

យើងប្រកាសថា មធ្យោបាយដើម្បីបង្កើតជីវិតមនុស្ស នោះបានតែងតាំងឡើងដោយព្រះ ។ យើងសូមបញ្ជាក់នូវការពិសិដ្ឋនៃជីវិត និងនូវការសំខាន់នៃជីវិត ក្នុងផែនការណ៍ដ៏អស់កល្បជានិច្ចរបស់ព្រះ ។

ឡូប្រពន្ធមានភារៈកិច្ចដ៏ឧឡារិក ដើម្បីស្រឡាញ់ថែរក្សាគ្នាទៅវិញទៅមក ព្រមទាំងស្រឡាញ់ថែរក្សាកូនចៅរបស់ខ្លួនផង ។ «កូនចៅជាមរតកពីព្រះយេហូវ៉ា» (ទំនុកដំកើង ១២៧:៣) ។ ឪពុកម្តាយមានកាតព្វកិច្ចពិសិដ្ឋ ក្នុងការថែរក្សាអប់រំកូនចៅរបស់ខ្លួន ដោយសេចក្តីស្រឡាញ់និងដោយសេចក្តីសុចរិត ដើម្បីចិញ្ចឹមកូនចៅ ខាងផ្លូវសាច់ឈាមនិងផ្លូវវិញ្ញាណ តាមសេចក្តីត្រូវការរបស់គេ ដើម្បីបង្រៀនកូនចៅឲ្យចេះស្រឡាញ់គ្នា ហើយបំរើគ្នាទៅវិញទៅមក ចេះគោរពតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ហើយធ្វើជាពលរដ្ឋ គោរពច្បាប់នៅទីកន្លែងណាក៏ដោយដែលគេរស់នៅ ។ ប្តីប្រពន្ធ–ឪពុកម្តាយ–នឹងទទួលខុសត្រូវនៅចំពោះព្រះ តាមការ ប្រតិបត្តិនៃភារៈកិច្ចទាំងឡាយនេះ ។

ត្រូសារគឺបានតែងតាំងឡើងដោយព្រះ ។ អាពាហិពិពាហិរវាងប្រុសនិងស្រី គឺជាការសំខាន់ចាំបាច់ណាស់ក្នុងផែនការណ៍ដ៏អស់កល្បជានិច្ចរបស់ព្រះអង្ត ។ កូនចៅមានសិទ្ធិទទួលកំណើតមកក្នុងចំណងនៃអាពាហិពិពាហិ ហើយនិងចញ្ចឹមបីបាច់ដោយឪពុកម្តាយ ដែលគោរពប្រតិបត្តិតាមសច្ចានៃអាពាហិពិពាហិ ដោយស្មោះត្រង់ទាំងស្រុង ។ សុភមង្គលនៅក្នុងជីវិតនៃគ្រួសារ អាចសំរេចបានបំផុត នៅពេលធ្វើតាមការបង្រៀននៃព្រះអម្ចាស់យេស៊ូវគ្រីស្ត ។ គ្រួសារនិងអាពាហិពិពាហិដែលមានជោគជ័យសុភមង្គល គឺបានស្ថាបនានិងរក្សាដោយគោលការណ៍នៃសេចក្តីជំនឿ ការអធិស្ឋានការប្រែចិត្ត ការអភ័យទោស ការគោរពគ្នា សេចក្តីស្រឡាញ់គ្នា សេចក្តីមេត្តាករុណា ការងារនិងកម្មវិធីកំសាន្តល្អៗទាំងឡាយ ។ តាមគំរោងការណ៍ព្រះ ឪពុកបានចាត់ឲ្យធ្វើប្រធានដឹកនាំគ្រួសាររបស់ខ្លួន ដោយសេចក្តីស្រឡាញ់និងសេចក្តីសុចរិត ហើយមានភារៈកិច្ចក្នុងការផ្តល់នូវសេចក្តីត្រូវការក្នុងជីវិត ព្រមទាំងការពារគ្រួសារខ្លួនផង ។ ម្តាយមានភារៈកិច្ចទី១ ដើម្បីថែទាំបីបាច់កូនចៅរបស់ខ្លួន ។ នៅក្នុងភារៈកិច្ចពិសិដ្ឋទាំងនេះ ឪពុកម្តាយមានភារៈកិច្ចឲ្យចេះជួយគ្នាទៅវិញទៅមក ជាគូស្មើគ្នា ។ អសមត្ថភាព មរណៈភាព ឬកាលៈទេសៈផ្សេងៗទៀត អាចធ្វើឲ្យចេះឆ្នែឆ្នៃតាមរៀងខ្លួន ។ គ្រួសារញាតិសន្តានគួរតែជួយគាំទ្រ តាមសេចក្តីត្រូវការ ។

យើងប្រមានថា បុគ្គលណាដែលរំលងលើសេចក្តីសញ្ញានៃព្រហ្មចារីភាព ដែលធ្វើបាបភរិយាឬកូនចៅ ឬមិនបានបំពេញកិច្ចការនៃគ្រួសារ គង់តែថ្ងៃណាមួយ នឹងទទួលខុសត្រូវនៅចំពោះព្រះ។ បន្ថែមទៅទៀត យើងប្រមានថា ការកំចាត់ចោលគ្រួសារ នោះនឹងនាំឲ្យបុគ្គលខ្លួនសង្គម និងសាសន៍ទាំងឡាយ នូវមហន្តរាយដែលបានទាយទុកជាមុន ដោយពួកព្យាការីសម័យបុរាណ និងពួកព្យាការីសម័យបច្ចុប្បន្ននេះ ។

យើងហៅអស់ប្រជាពលរដ្ឋនិងអស់អ្នករដ្ឋការទាំងឡាយ ដែលទទួលខុសត្រូវនៅគ្រប់ទីកន្លែងសូមឲ្យគាំទ្រនូវអ្វីៗទាំងនោះ ដែលបានរៀបចំឡើង ដើម្បីទ្រទ្រង់និងធ្វើឲ្យគ្រួសារមាំមួនដែលជាក្រុមសំខាន់នៃសង្គម ។

ការប្រកាសនេះអានដោយប្រធានគរដុន ប៊ី ហ៊ិងគ្លី ជាផ្នែកនៃសាររបស់លោក ក្នុងការប្រជុំ សមាគមរំដោះទូទៅ ដែលបានធ្វើឡើងនៅថ្ងៃទី ២៣ ខែកញ្ញា ១៩៩៥ នៅឯទីក្រុងសលត៍លេក រដ្ឋយូថាហ៍ ។

សេចក្តីផ្តើម

គោលបំណងសំរាប់វគ្គសិក្សានេះ

វគ្គសិក្សាស្តីអំពីទំនាក់ទំនងអាពាហ៍ពិពាហ៍ និងគ្រួសារ គឺត្រូវបានរៀបចំឡើងដើម្បីជួយសមាជិកសាសនាចក្រនៅក្នុងការពង្រឹង អាពាហ៍ពិពាហ៍ និងគ្រួសារ ហើយស្វែងរកភាពសប្បាយរីករាយនៅក្នុងទំនាក់ទំនងក្រុមគ្រួសាររបស់ពួកគេ។ វគ្គសិក្សានេះ ត្រូវបានចែកចេញជាពីរផ្នែក។ ផ្នែក ក "ការពង្រឹងអាពាហ៍ពិពាហ៍" គឺមានប្រយោជន៍ពិសេសសំរាប់គូស្វាមីភរិយា និងសំរាប់សមាជិកដែលកំពុងរៀបចំខ្លួនដើម្បីរៀបអាពាហ៍ពិពាហ៍។ ផ្នែក ខ "ការទទួលខុសត្រូវរបស់ឱពុកម្តាយដើម្បីពង្រឹងក្រុមគ្រួសារ" គឺជួយដល់ឱពុកម្តាយ និងជីដូនជីតា នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគាត់ដើម្បី "ចិញ្ចឹមបីបាច់ថែរក្សា [កូនៗ] តាមដំបូន្មាន និងសេចក្តីដាស់តឿនរបស់ព្រះអម្ចាស់" (អេភេសូរ 6:4)។

វគ្គសិក្សានេះផ្អែកលើគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលបានបង្រៀននៅក្នុងព្រះគម្ពីរ និងដោយព្យាការី ព្រមទាំងពួកសាវកថ្ងៃចុងក្រោយ។ វគ្គសិក្សានេះធ្វើការសង្កត់ធ្ងន់ជាពិសេសចំពោះ "ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក" ដែលមាននៅក្នុងទំព័រ iv នៃស្បៀវភៅណែនាំការសិក្សានេះ។

ចំពោះចំណុចសង្ខេបនៅក្នុងវគ្គសិក្សានេះ សូមមើលទំព័រ vii–viii ។ សូមយោងទៅលើចំណុចសង្ខេបនេះឱ្យបានញឹកញាប់ ដើម្បីពិនិត្យឡើងវិញនូវគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលអ្នកបានរៀនសូត្រ ហើយរៀបចំខ្លួនសំរាប់មេរៀនបន្ទាប់។

ការចូលរួមនៅក្នុងវគ្គសិក្សានេះដើម្បីឱ្យសមស្របទៅនឹងសេចក្តីត្រូវការផ្ទាល់ខ្លួនរបស់អ្នក

អ្នកមានជំរើសដើម្បីចូលរួមដើម្បីឱ្យសមស្របទៅនឹងសេចក្តីត្រូវការផ្ទាល់ខ្លួនរបស់អ្នករាល់គ្នា។ ឧទាហរណ៍ ប្រសិនបើអ្នករៀបអាពាហ៍ពិពាហ៍ហើយ ប៉ុន្តែមិនទាន់មានបុត្រធីតា អ្នកអាចជ្រើសរើសចូលរួមនៅក្នុងមេរៀនចំនួនប្រាំបីដំបូង ប៉ុន្តែមិនមែនជាមេរៀនប្រាំបីចុងក្រោយនោះទេ។ ប្រសិនបើអ្នកជាឱពុកឬម្តាយទោលអ្នកអាចសំរេចចិត្តចូលរួមតែនៅក្នុងមេរៀនផ្នែក ខ បានហើយ។

ការចូលរួមចំណែកនៅក្នុងវគ្គសិក្សានេះ

ដោយការជ្រើសរើសចូលរួមនៅក្នុងវគ្គសិក្សានេះ អ្នកអាចបង្ហាញនូវបំណងប្រាថ្នាសំរាប់ការពង្រឹងក្រុមគ្រួសាររបស់អ្នក។ ដើម្បីទទួលបានគុណប្រយោជន៍ដ៏ពេញលេញនៅក្នុងវគ្គសិក្សានេះ អ្នកត្រូវជួយផ្តល់ជាយោបល់សំរាប់ការពិភាក្សាក្នុងថ្នាក់ សូមប្រើប្រាស់ស្បៀវភៅណែនាំការសិក្សានេះ ព្រមទាំងព្យាយាមអនុវត្តន៍តាមគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលអ្នកបានរៀន។

ការចូលរួមចំណែកចំពោះការពិភាក្សានៅក្នុងថ្នាក់

នៅពេលអ្នក និងសិស្សផ្សេងទៀត ចូលរួមចំណែកចំពោះការពិភាក្សានៅក្នុងថ្នាក់ នោះអ្នកនឹងមានលទ្ធភាពដើម្បីអញ្ជើញឱ្យមានព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ហើយមានលទ្ធភាពបង្រៀន និងជួយស្តាបនាគ្នាទៅវិញទៅមក។ ព្រះអម្ចាស់ទ្រង់មានបន្ទូលថា ៖ "ចូរតាំងគ្រូបង្រៀនម្នាក់នៅក្នុងចំណោមអ្នករាល់គ្នា ហើយចូរកុំឱ្យទាំងអស់គ្នានិយាយព្រមគ្នាឡើយ ប៉ុន្តែចូរឱ្យនិយាយម្នាក់ម្តង ហើយចូរឱ្យទាំងអស់គ្នាស្តាប់ពាក្យសំដីរបស់អ្នកនោះ ប្រយោជន៍កាលណាអ្នកទាំងអស់គ្នានិយាយ នោះទើបឱ្យទាំងអស់គ្នាបានស្អាងឡើងទាំងអស់គ្នា ហើយប្រយោជន៍ឱ្យមនុស្សគ្រប់រូបបានសិទ្ធិស្មើគ្នា" (ត. និង ស. 88:122)។

អ្នកទាំងឡាយដែលចូលរួមនៅក្នុងវគ្គសិក្សានេះ អាចរៀនពីគ្នាទៅវិញទៅមក ដោយមិនគិតចំពោះបទពិសោធន៍របស់ពួកគេ ដែលទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ឬការចិញ្ចឹមកូនចៅនោះទេ។ បទពិសោធន៍របស់អ្នកនៅក្នុងថ្នាក់រៀនគឺជារង្វាន់ដ៏មានតម្លៃបំផុត នៅពេលអ្នកចែកចាយនូវបទពិសោធន៍ដែលទាក់ទងទៅនឹងមេរៀន ព្រមទាំងយកចិត្តទុកដាក់ស្តាប់ដោយប្រុងប្រយត្ន័ នៅពេលអ្នកផ្សេងទៀតធ្វើការចែកចាយនូវបទពិសោធន៍របស់ពួកគេ។ នៅពេលអ្នកធ្វើទីបន្ទាល់អំពីសេចក្តីពិតដែលបានលើកឡើងយកមកពិភាក្សាការពិភាក្សានៅក្នុងថ្នាក់នោះអ្នកអាចពង្រឹងទីបន្ទាល់របស់អ្នក និងទីបន្ទាល់របស់អ្នកផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ អ្នកគួរមានការប្រុងប្រយត្ន័ផងដែរ ដោយមិនត្រូវធ្វើការពិភាក្សាអំពីបទពិសោធន៍ជាក់ស្តែង ឬបទពិសោធន៍ពិសិដ្ឋផ្ទាល់ខ្លួន ដែលមិនសមរម្យសំរាប់ការលើកមកពិភាក្សានៅក្នុងថ្នាក់នោះឡើយ។ អ្នកគួរដឹងអំពីពេលវេលាកំណត់របស់ថ្នាក់រៀន ហើយត្រូវមានសណ្តានចិត្តចំពោះគ្រូបង្រៀន និងសិស្សផ្សេងទៀត។

ការប្រើប្រាស់ស្បៀវភៅណែនាំការសិក្សានេះ

នៅពេលមេរៀននិមួយៗត្រូវបានបញ្ចាប់ សូមប្រើស្បៀវភៅណែនាំការសិក្សានេះ ដើម្បីពិនិត្យឡើងវិញនូវអ្វីដែលអ្នកបានរៀននៅក្នុងសប្តាហ៍បន្ទាប់។ ស្បៀវភៅណែនាំការសិក្សានេះ រួមមាន "យោបល់សំរាប់ការអនុវត្តន៍" គឺជាសេចក្តីណែនាំទាំងឡាយដែលជួយអ្នករស់នៅតាមគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលអ្នកបានរៀននៅក្នុងមេរៀននិមួយៗ។ បន្ថែមពីលើនេះទៅទៀត ស្បៀវភៅណែនាំការសិក្សានេះ មាននូវអត្ថបទមួយ ឬពីរដែលបានធ្វើឡើងដោយពួកអ្នកមានសិទ្ធិអំណាចទូទៅនៅក្នុងសាសនាចក្រសំរាប់មេរៀននីមួយៗ។ ប្រសិនបើអ្នករៀបអាពាហ៍ពិពាហ៍ហើយ អ្នកអាចទទួលគុណប្រយោជន៍ជាច្រើនពីការអាន និងពិភាក្សាតាមអត្ថបទនានាជាមួយគូស្វាមីភរិយារបស់អ្នក។

អត្ថបទខ្លះគឺដើមឡើយត្រូវបានផ្តល់ជាសុន្ទរកថានៅក្នុងសន្និសីទទូទៅ និងការរៀបចំផ្សេងទៀត ហើយអត្ថបទដទៃទៀតត្រូវបានសរសេរសំរាប់ទស្សនាវដ្តី សាសនាចក្រ។ ដោយសារតែអត្ថបទទាំងនោះ ត្រូវបានយកចេញពីការ ចោះពុម្ពផ្សាយផ្សេងៗគ្នា នោះចាំបាច់ត្រូវមាននូវការកែប្រែបន្តិចបន្តួច ដើម្បីធ្វើឱ្យទ្រង់ទ្រាយនៅក្នុងស្បៀវភៅណែនាំការសិក្សានេះមានភាពរលូន។ ឧទាហរណ៍ នៅក្នុងសុន្ទរកថាសំរាប់សន្និសីទទូទៅ មានមតិយោបល់សេចក្តីផ្តើមខ្លះត្រូវបានគេលុបចោល ហើយចំណងជើង ព្រមទាំងសេចក្តីយោងផ្សេងៗត្រូវបានគេផ្លាស់ប្តូរ។ ប៉ុន្តែការបង្រៀនទាំងនោះនៅតែរក្សាទុកនូវធាតុដើមដដែល។

ការអនុវត្តន៍គោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលអ្នកបានរៀន

ការរៀនសូត្រអំពីដំណឹងល្អតែម្យ៉ាង គឺវាមិនគ្រប់គ្រាន់នោះទេ។ ដើម្បីធ្វើឱ្យដំណឹងល្អមានប្រសិទ្ធភាពនៅក្នុងជីវិតរបស់អ្នក នោះអ្នកត្រូវតែរស់នៅតាមអ្វីដែលអ្នកបានរៀន។ ប្រធាន ហារូល ប៊ីលី ជាប្រធាននៃសាសនាចក្រទី 11 បានទូន្មានថា ៖

"គោលលទ្ធិ និងពិធីបរិសុទ្ធទាំងអស់នៃដំណឹងល្អមានទៅក្នុងរបៀបពិតមួយ ប៉ុន្តែជាការអញ្ជើញឱ្យរៀនដំណឹងល្អ ដោយការអនុវត្តតាមការបង្រៀនរបស់វា។ ត្មានទរណាម្នាក់ស្គាល់អំពីគោលការណ៍នៃដង្វាយមួយភាគក្នុងដប់ទេ រហូតដល់គាត់ធ្វើការបង់ដង្វាយមួយភាគក្នុងដប់។ ត្មានទរណាម្នាក់ស្គាល់អំពីគោលការណ៍នៃពាក្យសំដីនៃប្រាជ្ញាវាងវៃទេ រហូតដល់គាត់ធ្វើតាមពាក្យសំដីនៃប្រាជ្ញាវាងវៃ។ ចំពោះរឿងនោះសំរាប់កុមារ ឬមនុស្សពេញវ័យ មិនត្រូវបានប្រែចិត្តជឿដល់ដង្វាយមួយភាគក្នុងដប់ ពាក្យសំដីនៃប្រាជ្ញាវាងវៃ ការរក្សាថ្ងៃឈប់សំរាកឱ្យបរិសុទ្ធ ឬការអធិស្ឋាន ដោយគ្រាន់តែឲនរណាម្នាក់និយាយអំពីគោលការណ៍ទាំងនេះតែប៉ុណ្ណោះទេ។
យើងរៀនដំណឹងល្អដោយការរស់នៅតាមការបង្រៀនរបស់ដំណឹងល្អ . . . ។

". . . យើងមិនអាចដឹងអ្វីៗសព្វបែបយ៉ាងស្តីអំពីការបង្រៀននៃដំណឹងល្អនោះទេ រហូតដល់យើងបានទទួលបទពិសោធន៍ នៃពរជ័យដែលបានកើតចេញមកពីការរស់នៅតាមគោលការណ៍និមួយៗជាមុនសិន" (*Stand Ye in Holy Places* [ឆ្នាំ 1974], 215)។

ធនធានបន្ថែម

រាល់ធនធានខាងក្រោមដែលបានបោះពុម្ពឡើងដោយសាសនាចក្រ នឹងផ្តល់ឱ្យអ្នកនូវពត៌មានបន្ថែមទៀតចំពោះប្រធានបទដែលបានពិភាក្សានៅក្នុងមេរៀននេះ។ ធនធានទាំងនេះមាននៅតាមមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រ។ អ្នកគួរមានឯកសារបោះពុម្ពទាំងនេះ ហើយសូមប្រើប្រាស់វានៅក្នុងគេហដ្ឋានរបស់អ្នក។

- *សៀវភៅណែនាំក្នុងគ្រួសារ* (31180)។ សៀវភៅណែនាំនេះ ពិពណ៌នាអំពីអង្គភាពគ្រួសារ ផ្តល់ព័ត៌មានអំពីការបង្រៀនដំណឹងល្អនៅក្នុងគេហដ្ឋាន និងបង្ហាញនូវដំណើរការសំរាប់ពិធីបរិសុទ្ធ និងពរជ័យបព្វជិតភាព។
- អត្ថបទអំពីអាពាហ៍ពិពាហ៍ និងគ្រួសារនៅក្នុងទស្សនាវដ្តីសាសនាចក្រ។
- *សៀវភៅណែនាំសំរាប់ការបង្រៀន* (34595)។ សៀវភៅណែនាំនេះ ផ្តល់នូវការណែនាំសំរាប់ធ្វើឱ្យការបង្រៀន និងការរៀនដំណឹងល្អកាន់តែល្អប្រសើរឡើង។
- *សៀវភៅដើម្បីកំលាំងនៃយុវជន* (34285)។ កូនសៀភៅនេះបង្ហាញនូវបទដ្ឋានរបស់សាសនាចក្រ អំពីការដើរលេងជាមួយមនុស្សភេទផ្សេងគ្នា ការស្លៀកពាក់ និងអាការះខាងក្រៅ មិត្តភក្តិ កតញ្ញូតាធម៌ ពាក្យសំដី ប្រព័ន្ធផ្សព្វផ្សាយ សុខភាពខាងសតិអារម្មណ៍ និងខាងរាងកាយ តន្ត្រី និងការរាំកំសាន្ត ភាពបរិសុទ្ធខាងផ្លូវភេទ ការគោរពថ្ងៃសីល ការប្រែចិត្ត សេចក្តីស្មោះត្រង់ និងការបំរើអ្នកដទៃ។

ចំណុចសង្ខេបនៅក្នុងវគ្គសិក្សាស្តីអំពីទំនាក់ទំនងអាពាហ៍ពិពាហ៍ និងគ្រួសារ

ផ្នែក កៈ ការពង្រឹងអាពាហ៍ពិពាហ៍

មេរៀនទី 1៖ “គ្រួសារជាផ្នែកសំខាន់មួយនៃផែនការរបស់ព្រះជ័យង្គបង្កើត”

ព្យាការីថ្ងៃចុងក្រោយប្រកាស អំពីសារៈសំខាន់ដ៏នៅអស់កល្បជានិច្ចស្តីអំពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចអាចនាំមកនូវសេចក្តីអំណរ និងពរជ័យដ៏មហិមានៅក្នុងជីវិតនេះ និងជីវិតដ៏នៅអស់កល្បជានិច្ច ។

វគ្គសិក្សាស្តីអំពីទំនាក់ទំនងអាពាហ៍ពិពាហ៍ និងគ្រួសារគឺត្រូវបានរៀបចំឡើងដើម្បីជួយយើងស្វែងរកនូវសេចក្តីអំណរក្នុងទំនាក់ទំនងគ្រួសាររបស់យើង ។

គេហដ្ឋានអាចជា “ចំណែកនៃស្ថានសួគ៌” នៅពេលយើងសង់ “នៅលើសិលានៃព្រះដ៏ប្រោសលោះនៃយើង”។

មេរៀនទី 2៖ ការអភិវឌ្ឍន៍សាមគ្គីភាពក្នុងអាពាហ៍ពិពាហ៍

ព្រះអម្ចាស់បានបញ្ជាស្វាមី និងភរិយាទាំងឡាយឱ្យក្លាយតែជាមនុស្សតែមួយ ។

ស្វាមី និងភរិយាទាំងឡាយគឺត្រូវលើកតម្លៃគ្នាទៅវិញទៅមកជាដៃគូស្មើគ្នា ។

ស្វាមី និងភរិយាទាំងឡាយគួរធ្វើឱ្យបុគ្គលិកលក្ខណៈ ហើយសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេមានភាពស៊ីសង្វាក់គ្នា ។

ស្វាមី និងភរិយាទាំងឡាយត្រូវតែមានភក្តីភាពចំពោះគ្នាទៅវិញទៅមក។

មេរៀនទី 3៖ ការចិញ្ចឹមបីបាច់សេចក្តីស្រឡាញ់ និងចំណងមិត្តភាពនៅក្នុងអាពាហ៍ពិពាហ៍

ស្វាមី និងភរិយាទាំងឡាយត្រូវចិញ្ចឹមបីបាច់សេចក្តីស្រឡាញ់របស់ពួកគេចំពោះគ្នាទៅវិញទៅមក ។

ការបង្ហាញសេចក្តីស្រឡាញ់ និងសណ្តានចិត្តល្អជួយថែរក្សាសេចក្តីស្រឡាញ់ និងចំណងមិត្តភាពឱ្យមានភាពរស់រវើកនៅក្នុងអាពាហ៍ពិពាហ៍ ។

ការរួមរស់នឹងគ្នាដ៏ត្រឹមត្រូវនៅក្នុងអាពាហ៍ពិពាហ៍ គឺជាការបង្ហាញសេចក្តីស្រឡាញ់ ។

គូស្វាមីភរិយាដែលបានរៀបអាពាហ៍ពិពាហ៍ គួរតែព្យាយាមដើម្បីមានសេចក្តីសប្បុរស ដែលជាសេចក្តីស្រឡាញ់ដ៏សុទ្ធសាធរបស់ព្រះគ្រីស្ទ ។

មេរៀនទី 4៖ ការឆ្លើយតបទៅនឹងឧបសគ្គទាំងឡាយនៅក្នុងអាពាហ៍ពិពាហ៍

គូស្វាមីភរិយាដែលបានរៀបការទាំងអស់នឹងទទួលបទពិសោធអំពីឧបសគ្គទាំងឡាយ ។

ស្វាមី និងភរិយាទាំងឡាយអាចធ្វើការឆ្លងកាត់រាល់ឧបសគ្គ បើពួកគេមើលទៅលើអាពាហ៍ពិពាហ៍ គឺជាទំនាក់ទំនងនៃសេចក្តីសញ្ញា ។

នៅពេលឧបសគ្គទាំងឡាយកើតឡើង យើងអាចជ្រើសរើសដើម្បីឆ្លើយតបដោយការអត់ធ្មត់ និងសេចក្តីស្រឡាញ់ ជាជាងភាពស្មុគស្មាញ ឬកំហឹង។

មេរៀនទី 5៖ ការឆ្លើយតបទៅនឹងឧបសគ្គតាមរយៈទំនាក់ទំនងវិជ្ជមាន

គូស្វាមីភរិយាដែលបានរៀបអាពាហ៍ពិពាហ៍រួចទាំងអស់នឹងមានទូរទស្សន៍ដែលខុសគ្នាមួយចំនួន ។

ស្វាមី និងភរិយាទាំងឡាយគួរតែស្វែងរកគុណសម្បត្តិដែលគួរឱ្យស្ងើចសរសើរអំពីគ្នាទៅវិញទៅមក។

ទំនាក់ទំនងវិជ្ជមានជួយការពារ និងដោះស្រាយការលំបាកទាំងឡាយ។

មេរៀនទី 6៖ ការពង្រឹងអាពាហ៍ពិពាហ៍តាមរយៈសេចក្តីជំនឿ និងការអធិស្ឋាន

ស្វាមី និងភរិយាទាំងឡាយគួរតែធ្វើការរួមគ្នា ដើម្បីបង្កើនសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ ។

ស្វាមី និងភរិយាទាំងឡាយគឺត្រូវបានប្រទានពរជ័យ នៅពេលពួកគេអធិស្ឋានជាមួយគ្នា។

មេរៀនទី 7៖ អំណាចព្យាបាលនៃការអភ័យទោស

វិញ្ញាណនៃការអភ័យទោសរវាងស្វាមី និងភរិយានាំមកនូវសេចក្តីសុខសាន្ត និងអារម្មណ៍នៃទំនុកចិត្ត ហើយសន្តិសុខ ។

ស្វាមី និងភរិយាទាំងឡាយគួរតែស្វែងរកការអភ័យទោស សំរាប់ភាពខ្វះខាតរបស់ពួកគេឱ្យគ្នាទៅវិញទៅមក ហើយខិតខំដ៏ដោយស្មោះអស់អំពីចិត្តដើម្បីធ្វើការអភិវឌ្ឍន៍ ។

ស្វាមី និងភរិយាទាំងឡាយ គួរតែស្វែងរកការអភ័យទោសពីគ្នាទៅវិញទៅមក។

មេរៀនទី 8៖ ការគ្រប់គ្រងហិរញ្ញវត្ថុក្រុមគ្រួសារ

ការគ្រប់គ្រងហិរញ្ញវត្ថុត្រឹមត្រូវ គឺចាំបាច់សំរាប់អាពាហ៍ពិពាហ៍រីករាយ ។

ស្វាមី និងភរិយាទាំងឡាយគួរតែធ្វើការរួមគ្នា ដើម្បីធ្វើតាមគោលការណ៍គ្រឹះនៃការគ្រប់គ្រងលុយ។

មេរៀនទី 9៖ “កូនៗគឺជាមរតកពីព្រះអម្ចាស់”

ព្រះវរបិតាសួគ៌បានទុកព្រះទ័យប្រទានកូនចៅខាងវិញ្ញាណរបស់ទ្រង់មកឱ្យឪពុកម្តាយខាងលោកិយ ។

ឪពុកម្តាយគួរតែស្វែងយល់ដើម្បីបំពេញនូវសេចក្តីត្រូវការរបស់កូនម្នាក់ៗ ។

កូនចៅត្រូវបានទទួលសិទ្ធិមាននូវទំនាក់ទំនងនៃសេចក្តីស្រឡាញ់ជាមួយនឹងឪពុកម្តាយរបស់ពួកគេ ។

ការរំលោភបំពានដល់កុមារគឺធ្វើឱ្យព្រះអាក់អន់ព្រះទ័យ ។

កូនចៅទាំមកនូវសេចក្តីអំណរដ៏មហិមាដល់ជីវិតរបស់ឪពុកម្តាយពួកគេ។

មេរៀនទី 10៖ តួនាទីពិសិដ្ឋរបស់ឪពុក និងម្តាយ (ផ្នែកទី 1៖ តួនាទីរបស់ឪពុក)

ឪពុក និងម្តាយគប្បីធ្វើការរួមគ្នាដើម្បីផ្តល់សេចក្តីជំនឿទុកជាខែលដល់កូនម្នាក់ៗ ។

ឪពុកបានចាត់ឱ្យធ្វើជាប្រធានដឹកនាំគ្រួសាររបស់ខ្លួនដោយសេចក្តីស្រឡាញ់ និងសេចក្តីសុចរិត ។

ឪពុកត្រូវផ្តល់នូវសេចក្តីត្រូវការក្នុងជីវិត និងការការពារដល់គ្រួសារខ្លួន។

មេរៀនទី 11៖ តួនាទីពិសិដ្ឋរបស់ឪពុក និងម្តាយ (ផ្នែកទី 2៖ តួនាទីរបស់ម្តាយ)

ម្តាយចូលរួមចំណែកក្នុងកិច្ចការរបស់ព្រះ ។

ម្តាយមានការទទួលខុសត្រូវជាចំបងចំពោះការចិញ្ចឹមបីបាច់កូនចៅរបស់ខ្លួន ។

ឪពុក និងម្តាយត្រូវជួយគ្នាទេវិញទៅមកជាដៃគូមានសិទ្ធិស្មើគ្នា។

មេរៀនទី 12៖ ការបង្រៀនកូនចៅតាមរយៈគំរូ និងការណែនាំ

ឪពុកម្តាយមានការទទួលខុសត្រូវដើម្បីបង្រៀនកូនចៅរបស់ខ្លួន

ឪពុកម្តាយអាចទទួលនូវការបំផុសគំនិតនៅក្នុងការបង្រៀនកូនចៅរបស់ខ្លួន

ឪពុកម្តាយបង្រៀនតាមរយៈគំរូ និងការបង្រៀន។

មេរៀនទី 13៖ ការបង្រៀនគោលការណ៍ដំណឹងល្អចំពោះកូនៗ (ភាគទី 1)

ការបង្រៀនរបស់ឪពុកម្តាយ អាចជួយកូនៗឱ្យមានភាពរឹងមាំនៅក្នុងសេចក្តីជំនឿ ។

ឪពុកម្តាយត្រូវបង្រៀនកូនៗរបស់ពួកគេអំពីគោលការណ៍ទីមួយ និងពិធីបរិសុទ្ធនៃដំណឹងល្អ ។

ឪពុកម្តាយគប្បី “បង្រៀនកូនចៅរបស់ខ្លួនឱ្យរឹងមាំនៅក្នុងសេចក្តីជំនឿ និងឱ្យដើរដោយឡែងត្រង់នៅចំពោះព្រះអម្ចាស់”។

មេរៀនទី 14៖ ការបង្រៀនគោលការណ៍ដំណឹងល្អចំពោះកូនៗ (ភាគទី 2)

ឪពុកម្តាយបង្ហាញសេចក្តីស្រឡាញ់ចំពោះកូនចៅរបស់ខ្លួន នៅពេលដែលពួកគេបង្រៀនដល់កូនចៅ ។

ឪពុកម្តាយត្រូវតែបង្រៀនកូនចៅអំពីសេចក្តីមេត្តាករុណា និងការបំរើ ។

ឪពុកម្តាយត្រូវបង្រៀនកូនចៅអំពីសេចក្តីស្មោះត្រង់ និងការគោរពចំពោះទ្រព្យសម្បត្តិអ្នកដទៃ ។

ឪពុកម្តាយត្រូវតែបង្រៀនដល់កូនចៅអំពីរង្វាន់នៃការធ្វើការងារដ៏ស្មោះត្រង់។

ឪពុកម្តាយត្រូវបង្រៀនកូនចៅអំពីភាពស្អាតស្អំខាងសីលធម៌។

មេរៀនទី 15៖ ការណែនាំកូននៅពេលដែលពួកគេធ្វើការសំរេចចិត្ត

កូនៗត្រូវការការដឹកនាំពេលដែលពួកគេធ្វើសេចក្តីសំរេចចិត្ត ។

ឪពុកម្តាយអាចជួយកូនឱ្យអនុវត្តសិទ្ធជ្រើសរើសរបស់ពួកគេដោយសុចរិត ។

ឪពុកម្តាយគប្បីអនុញ្ញាតឱ្យកូនចៅរៀនសូត្រមកពីផលវិបាក នៃសេចក្តីសំរេចចិត្តមិនឈ្លាសវៃ ។

ឪពុកម្តាយគប្បីបង្ហាញនូវសេចក្តីស្រឡាញ់ ដែលមិនប្រែប្រួលចំពោះកូនចៅដែលបានដើរខុសផ្លូវ។

មេរៀនទី 16៖ ការអធិស្ឋានជាក្រុមគ្រួសារ ការសិក្សាព្រះគម្ពីរជាក្រុមគ្រួសារ និង រាត្រីជួបជុំក្រុមគ្រួសារ

ការអធិស្ឋាន និងការសិក្សាព្រះគម្ពីរជាគ្រួសារ ព្រមទាំងរាត្រីជួបជុំក្រុមគ្រួសារ ត្រូវមានអាទិភាពខ្ពស់បំផុតសំរាប់គ្រប់គ្រួសារពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ក្រុមគ្រួសារទទួលបានពរជ័យដ៏មហិមា នៅពេលពួកគេអធិស្ឋានរួមគ្នា ។

ការសិក្សាព្រះគម្ពីរជាគ្រួសារជួយក្រុមគ្រួសារឱ្យខិតទៅជិតព្រះ ។

រាត្រីជួបជុំក្រុមគ្រួសារជួយក្រុមគ្រួសារការពារខ្លួនពួកគេប្រឆាំងនឹងឥទ្ធិពលខាងលោកិយ។

ផ្នែក ក

ការពង្រឹងអាពាហ៍ពិពាហ

“ក្រួសារជាផ្នែកសំខាន់មួយនៃផែនការរបស់ព្រះដ៏បង្កបង្កើត” 1

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលៈទេសៈរបស់អ្នកផ្តាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- សូមមើល “ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក” iv ឡើងវិញ។ សូមធ្វើការសំរេចចិត្តចំពោះរបៀប ដែលនឹងធ្វើឱ្យអ្នកមានភាពប្រសើរឡើង នៅក្នុងការធ្វើតាមពាក្យទូន្មានរបស់ព្យាការី។
- សូមរកទិញក្រដាសប្រកាសស្តីអំពី “ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក (35602 ឬ 35538) នៅតាមមជ្ឈមណ្ឌលចែកចាយសាសនាចក្រ។ សូមដាក់តាំងក្រដាសប្រកាសនេះនៅក្នុងគេហដ្ឋានរបស់អ្នក។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

សំរាប់ពេលនេះ និងភាពដ៏នៅអស់កល្បជានិច្ច

ដោយ អែលឌើរ ប៊ិយដ៏ យេ ផាកគី
នៃក្រុមនៃពួកសាវកទាំងដប់ពីរនាក់

ផែនការនៃសុភមង្គលដ៏មហិមា

បងប្អូនប្រុសស្រីជាទីស្រឡាញ់ ព្រះគម្ពីរ ព្រមទាំងការបង្រៀននៃពួកសាវក និងព្យាការីបានទិយាយអំពីពួកយើងនៅក្នុងជីវិត មុនឆាកជីវិតនេះថា ជាវិញ្ញាណកូនប្រុសស្រីរបស់ព្រះ។[1] ភេទប្រុស និងភេទស្រីគឺបានកើតមានតាំងពីដំបូងមកម្ល៉េះ វាពុំមែនទើបតែចាប់ផ្តើមនៅក្នុងជីវិតរមែងស្លាប់នេះទេ។[2]

នៅក្នុងការប្រឹក្សាដ៏ធំនៅស្ថានសួគ៌[3] ផែនការរបស់ព្រះត្រូវបានបង្ហាញឡើង ៖[4] គឺជាផែនការសង្គ្រោះ[5] ផែនការព្រោសលោះ[6] ផែនការនៃសុភមង្គលដ៏មហិមា។[7] ផែនការនេះផ្តល់នូវការប្រព្រឹត្តមួយ ដែលមនុស្សទាំងអស់ត្រូវជ្រើសរើសរវាងល្អ និងអាក្រក់។[8] ផែនការរបស់ទ្រង់ផ្តល់ឱ្យនូវអង្គព្រោសលោះ ដង្វាយធួន ជំណើរឡើងវិញ និងការរំលែកត្រលប់របស់យើងទៅឯវត្តមានរបស់ព្រះវិញ ប្រសិនបើយើងគោរពប្រណិបត្តិតាមផែនការនេះ។

សាតាំងបានប្រឆាំង ព្រមទាំងបានធ្វើតាមផែនការរបស់ខ្លួនវាផ្តាល់។[9] អស់អ្នកទាំងឡាយណាដែលបានធ្វើតាមវាគឺត្រូវបានបដិសេធចេញពីសិទ្ធិមានរូបរាងកាយនៅលើផែនដី។[10] វត្តមានរបស់ពួកយើងនៅទីនេះ បញ្ជាក់ថា យើងព្រមទទួលធ្វើតាមផែនការរបស់ព្រះវរបិតាយើង។[11]

គោលបំណងតែមួយគត់របស់លូស៊ីហ្វើរ គឺដើម្បីប្រឆាំងទៅនឹងផែនការនៃសុភមង្គលដ៏មហិមា ដើម្បីបង្ខូចបទពិសោធន៍ដ៏បរិសុទ្ធដ៏ស្រស់ស្អាត និងទាក់ទាញបំផុតសំរាប់ជីវិតដូចជាៈ មនោសញ្ចេតនា សេចក្តីស្រឡាញ់ អាពាហ៍ពិពាហ៍ និងភាពជាឪពុកម្តាយ។[12] វិញ្ញាណដែលធ្វើតាមសាតាំងនឹងទទួលបាននូវការខូចចិត្ត និងកំហុស។[13] មានតែការកែប្រែចិត្តមួយប៉ុណ្ណោះ ដែលអាចព្យាបាលនូវអ្វីដែលធ្វើឱ្យគាត់ឈឺចាប់បាន។

ផែនការរបស់ព្រះតំរូវឱ្យមានអាពាហ៍ពិពាហ៍ និង ក្រុមគ្រួសារ

ផែនការនៃសុភមង្គល តំរូវឱ្យមានការរួបរួមនៃបុរស និងស្ត្រី ស្វាមី និងភរិយា នៅក្នុងសេចក្តីសុចរិត។[14] គោលលទ្ធិទាំងឡាយបង្រៀនយើង អំពីរបៀបឆ្លើយតបទៅនឹងសន្ទុះបង្កិតបង្កើនខាងធម្មជាតិ ដែលជារឿយៗតែងតែគ្របសង្កត់ពីរបៀបដែលយើងប្រព្រឹត្ត។

រូបរាងកាយមួយត្រូវបានយកលំនាំតាមរូបកាយរបស់ព្រះ បានបង្កើតឡើងសំរាប់អ័ដាម[15] ហើយគាត់ត្រូវបានដាក់នៅក្នុងសួនច្បារ។[16] ជាដំបូង អ័ដាមនៅតែម្នាក់ឯងប៉ុណ្ណោះ។ គាត់កាន់បព្វជិតភាព[17] ប៉ុន្តែ គាត់មិនអាចបំពេញគោលបំណងនៃការបង្កបង្កើតរបស់គាត់តែម្នាក់ឯងបាននោះទេ។[18]

គ្មានបុរសណាផ្សេងទៀត អាចជួយអ័ដាមឱ្យបំពេញគោលបំណង នៃការបង្កបង្កើតរបស់គាត់បានឡើយ។ ហើយក៏ពុំមានន័យថាអ័ដាមតែឯកឯង ឬជាមួយបុរសផ្សេងទៀត អាចធ្វើឱ្យអ័ដាមរីកចំរើនបាននោះដែរ។ ឬសូម្បីតែតែងតាងអេវ៉ាម្នាក់ឯង ជាមួយស្ត្រីផ្សេងទៀតដែរ។ កាលនោះវាគឺដូច្នេះ។ ឥឡូវនេះ វាក៏ដូច្នេះដែរ។

អេវ៉ា ដែលជាអ្នកជំនួយត្រូវបានបង្កើតឡើង។ អាពាហ៍ពិពាហ៍ត្រូវបានចាប់ផ្តើមឡើង[19] ត្បិតអ័ដាមត្រូវបានបញ្ជាឱ្យទៅជាប់នឹងប្រពន្ធរបស់ខ្លួន ហើយ “គ្មានឥរណាម្នាក់ទៀតឡើយ”។[20]

វាអាចត្រូវបានទិយាយថា ការជ្រើសរើសមួយត្រូវបានប្រគល់ចំពោះអេវ៉ា។[21] ទាងគួរត្រូវបានគេកោតសរសើរចំពោះការសំរេចចិត្តរបស់ទាង។ ហើយបន្ទាប់មក “អ័ដាមបានធ្លាក់ខ្លួន ដើម្បីឱ្យមានមនុស្សលោក”។[22]

អែលឌើរ អ័រសិន អេហ៍ វីតនី បានពិណិនាអំពីការធ្លាក់ចុះថា ៖ “គឺជាទិសដៅពីរ—មួយចុះក្រោម ឯមួយទៀតឆ្ពោះទៅមុខ។ ការធ្លាក់នេះបានទាំមនុស្សមកក្នុងលោកិយ ព្រមទាំងដាក់ដើងរបស់ពួកគេនៅលើមហាវិថីដ៏ធំ ដែលនឹងដឹកនាំទៅរកការរីកចំរើន”។[23]

ព្រះបានប្រទានពរដល់អ័ដាម និងអេវ៉ា ហើយ “បានមានព្រះបន្ទូលទៅកាន់ពួកគេ ៖ ចូរបង្កើតកូនឱ្យចំរើនជាច្រើនឡើង ឱ្យមានពាសពេញលើផែនដីចុះ”។[24] ហេតុដូច្នេះហើយ ក្រុមគ្រួសារត្រូវបានបង្កើតឡើង។

ព្រះឱ្យតម្លៃចំពោះបុរស និង ស្ត្រីស្មើភាពគ្នា

គ្មានវិវរណៈណាមួយបានចែងថា ព្រះអង្គសព្វព្រះទ័យមនុស្សប្រុសជាងមនុស្សស្រីនោះទេ ឬថាព្រះអង្គឱ្យតម្លៃបុត្រា ខ្ពស់ជាងបុត្រីនោះឡើយ។

ត្រប់គុណធម៌ដែលមានចែងនៅក្នុងបទព្រះគម្ពីរ—ដូចជា សេចក្តីស្រឡាញ់ សេចក្តីអំណរ សេចក្តីស្ងប់ សេចក្តីជំនឿ ការគោរពព្រះ សេចក្តីសប្បុរស—ត្រូវមានចំណែកសំរាប់ទាំងបុរស និងស្ត្រី[25] ហើយពិធីបរិសុទ្ធនៃបព្វជិតភាពដ៏ខ្ពស់បំផុតនៅក្នុងជីវិតរមែងស្លាប់ត្រូវបានផ្តល់ឱ្យតែបុរស និងស្ត្រីរួមគ្នាតែប៉ុណ្ណោះ។[26]

បន្ទាប់ពីមានការធ្លាក់នៃអ័ដាម ច្បាប់ធម្មជាតិបានគ្រប់គ្រងលើភាពកើតចាស់ឈឺស្លាប់។ នេះហើយគឺជាអ្វីដែលប្រធាន ជេរ៉ូបឹន ក្លាក ជុញ្ញ៉រ បានហៅថា ជា "ការតុបតែង" របស់ធម្មជាតិ[27] ដែលវាបណ្តាលឱ្យមានភាពមិនប្រក្រតី ភាពទន់ខ្សោយ និងភាពខូចខាតទ្រង់ទ្រាយទាំងឡាយនៅចំរុះគ្នា។ ទោះជាយ៉ាងណាក៏ដោយកិច្ចការទាំងនេះត្រូវបានធ្វើឱ្យមនុស្សមានការងឿងឆ្ងល់ ហើយបានគិតថាវាមានភាពអយុត្តិធម៌ណាស់ ប៉ុន្តែការណ៍ទាំងនេះសក្តិសមនឹងគោលបំនងនៃព្រះអម្ចាស់ក្នុងការប្រព្រឹត្តរបស់មនុស្សជាតិ។

រាល់សភាវគតិសក្តិសមបានធ្វើឱ្យកើតមានឡើងនូវការឆ្លើយតបចំពោះរាល់ចំណង់ត្រឹមត្រូវ ហើយការអនុវត្តន៍នូវរាល់ទំនាក់ទំនង ដែលមានការលើកតំកើងរបស់មនុស្សត្រូវបានផ្តល់ឱ្យ និងត្រូវអនុមតិក្នុងគោលលទ្ធិ នៃដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្ទ ហើយត្រូវបានគាំពារដោយបទបញ្ញត្តិដែលបានបើកសម្តែងដល់សាសនាចក្ររបស់ទ្រង់។

ត្លនាទីបុរស និងស្ត្រី

ពីធម្មជាតិ មនុស្សមានភាពខុសគ្នា លើកលែងតែអ័ដាម និងអេវ៉ា ពួកគេមិនអាចបង្កើតកូនឱ្យមានពាសពេញផែនដីទាំងមូលបានទេ។[28] ភាពខុសគ្នាដែលបំពេញឱ្យគ្នាទៅវិញទៅមក គឺជាគន្លឹះដ៏ចំបងចំពោះផែនការនៃសុភមង្គល។

ត្លនាទីខ្លះ គឺសក្តិសមទៅនឹងធម្មជាតិរបស់បុរស ហើយត្លនាទីខ្លះទៀតសក្តិសមនឹងធម្មជាតិរបស់មនុស្សស្រី។ ទាំងព្រះគម្ពីរ និងគំរូខាងធម្មជាតិបានកំណត់ឱ្យបុរសធ្វើជាអ្នកការពារ និងជាអ្នកឧបត្ថមដល់ត្រួសារ។[29]

ការទទួលខុសត្រូវទាំងនោះនៃបព្វជិតភាពគឺជាប់ទាក់ទងនឹងការគ្រប់គ្រងសាសនាចក្រ ដែលជាកិច្ចការចាំបាច់ក្រៅគេហដ្ឋាន។ តាមបញ្ញតិរបស់ព្រះ ការទទួលខុសត្រូវទាំងនោះត្រូវបានប្រគល់ទៅឱ្យបុរស។ វាមានដូច្នេះតាំងតែពីមុនមក ព្រះអម្ចាស់ បានបង្ហាញឱ្យយើញថាះ "ការរៀបចំបព្វជិតភាពនេះ ត្រូវបានធ្វើពិធីបញ្ជាក់ទុកជាកេរមរតកពីឱពុកដល់កូនប្រុស . . . ការរៀបចំនេះត្រូវបានតាំងឡើងនៅក្នុងសម័យលោកអ័ដាម។[30]

បុរសដែលកាន់បព្វជិតភាព ពុំមានគុណសម្បត្តិលើសស្ត្រីនៅក្នុងការកំណត់លក្ខណៈសំរាប់ភាពជំកើងឡើងនោះឡើយ។ តាមធម្មជាតិ ស្ត្រីគឺជាអ្នកបង្កើតរួមគ្នាជាមួយព្រះ និងជាអ្នកចិញ្ចឹមបីបាច់យ៉ាងសំខាន់សំរាប់កូនៗ។ គុណធម៌ និង ឥរិយាបទដែលភាពល្អឥតខ្ចោះ និងភាពជំកើងឡើងកើតមានតាមធម្មជាតិចំពោះស្ត្រីម្នាក់ ហើយបានធ្វើឱ្យបរិសុទ្ធតាមរយះអាពាហ៍ពិពាហ៍ និងភាពជាមាតា។

បព្វជិតភាពត្រូវបានប្រគល់ឱ្យតែបុរសដែលមានភាពសក្តិសម ដើម្បីអនុលោមទៅតាមផែនការ នៃសុភមង្គលរបស់ព្រះវរបិតាយើង។ ដោយមានច្បាប់ធម្មជាតិ និងព្រះបន្ទូលរបស់ព្រះ ដែលបានបើកសម្តែងធ្វើការជាមួយគ្នានៅក្នុងភាពសុខដុមរមូនា នោះវាប្រព្រឹត្តិទៅបានយ៉ាងល្អបំផុតតាមមធ្យោបាយនោះ។

បព្វជិតភាពនាំមកជាមួយនូវការទទួលខុសត្រូវដ៏សំខាន់។ "គ្មានអំណាចឬឥទ្ធិពលណាមួយ *អាច* ឬគប្បីកាន់កាប់ដោយសារបព្វជិតភាពបានឡើយ លើកលែងតែដោយការលួងលោម ដោយការអត់ធ្មត់ ដោយការទន់ភ្លន់ និងការស្លូតបូត និងដោយការស្រឡាញ់ស្មោះត្រង់ ដោយចិត្តល្អ និងដោយការចេះដឹងពេញទី"។[31]

បើបុរសម្នាក់ "អនុវត្តការត្រួតត្រា ឬការគ្រប់គ្រង ឬការបង្ខិតបង្ខំ . . . ដោយនូវសេចក្តីដ៏ឥតសុចរិតណាមួយ"[32] នោះគាត់បំពាន "នូវពាក្យសម្បថ និងសេចក្តីសញ្ញារបស់បព្វជិតភាព"។[33] បន្ទាប់មក "ស្ថានសួគិដកខ្លួនចេញ ព្រះវិញ្ញាណនៃព្រះអម្ចាស់សោកសៅ"។[34] លើកលែងតែគាត់ប្រែចិត្ត នោះគាត់នឹងបាត់បង់ពរជ័យរបស់គាត់។

ខណៈដែលត្លនាទីផ្សេងៗគ្នារបស់បុរស និងស្ត្រី ត្រូវបានបង្កើតឡើងនៅក្នុងការប្រកាសសេឡេស្ទាលដែលបានលើកដំកើង នោះពួកគេត្រូវបានបង្ហាញយ៉ាងល្អប្រសើរនៅក្នុងបទពិសោធន៍ដ៏មានសារះប្រយោជន៍ សាមញ្ញ និងបទពិសោធន៍ខាងលោកិយស្តីអំពីជីវិតត្រួសារ។

ថ្មីៗនេះខ្ញុំបានស្តាប់ពាក្យត្អូញត្អែររបស់អ្នកនិយាយម្នាក់នៅក្នុងការប្រជុំសាក្រាម៉ង់ថា គាត់ពុំយល់ថាហេតុអ្វីបានជាពួកចៅរបស់គាត់ តែងតែនិយាយពីការទៅផ្ទះរបស់លោកយាយ មិនដែលនិយាយពីការទៅផ្ទះរបស់លោកតា។ ខ្ញុំបានដោះស្រាយអាថិកំបាំងអស្ចារ្យនោះសំរាប់គាត់ ៖ ពួកលោកតាពុំចេះធ្វើនំឡើយ!

ច្បាប់ធម្មជាតិ និង ច្បាប់ខាងវិញ្ញាណគឺមានភាពដ៏នៅអស់កល្បជានិច្ច

ច្បាប់ធម្មជាតិ និងច្បាប់ខាងវិញ្ញាណដែលដឹកនាំជីវិត គឺត្រូវបានបង្កើតឡើងតាំងពីមុនការស្ថាបនាឡើងនៃលោកិយនេះមកម្លេ៉ះ។[35] ច្បាប់ទាំងនោះ គឺមានភាពដ៏នៅអស់កល្បជានិច្ច រីឯលទ្ធផលដែលនឹងកើតមានឡើងតាមរយះការប្រណិបត្តិតាម ឬការមិនព្រមប្រណិបត្តិច្បាប់ទាំងនេះក៏ដូច្នោះដែរ។ ច្បាប់ទាំងនេះពុំបានពឹងផ្អែកទៅលើការសំរេចចិត្តខាងសង្គម ឬខាងនយោបាយណាមួយនោះទេ។ ច្បាប់ទាំងនេះពុំអាចផ្លាស់ប្តូរបានឡើយ។ គ្មានការបង្ខិតបង្ខំ ការជំទាស់ និងនីតិកម្មណាមួយអាចផ្លាស់ប្តូរច្បាប់ទាំងនេះបានឡើយ។

កាលពីប៉ុន្មានឆ្នាំមុន ខ្ញុំបានគ្រប់គ្រងថ្នាក់សិក្ខាសាលាសំរាប់ជនជាតិដើមរបស់អាមេរិក។ ពេលដែលខ្ញុំបានទៅទស្សនកិច្ចនៅឯសាលា អាល់ប្ចហ្គើក នោះលោកនាយកសាលាបានប្រាប់ខ្ញុំអំពីឧប្បត្តិហេតុដែលបានកើតឡើងក្នុងថ្នាក់ទីមួយ។

នៅក្នុងពេលបង្រៀនមេរៀនមួយ មានកូនឆ្មាតូចមួយបានដើរចុះឡើងក្នុងបន្ទប់ ហើយបានធ្វើឱ្យពួកកុមារៗបែកអារម្មណ៍។ កូនឆ្មាតូចនោះត្រូវបានគេយកទៅដាក់នៅខាងមុខបន្ទប់ ដើម្បីឱ្យកុមារទាំងអស់គ្នាអាចយើញវា។

មានកុមារម្នាក់បានសួរថាះ "តើវាជាកូនឆ្មាឈ្មោល ឬកូនឆ្មាញី?"

ត្រូបង្រៀនដោយពុំបានរៀបចំសំរាប់ការពិភាក្សានេះ បានឆ្លើយថាះ "វាមិនជាបញ្ហាអ្វីទេ វាគ្រាន់តែជាកូនឆ្មាមួយប៉ុណ្ណោះ"។

ប៉ុន្តែពួកកុមារៗទាំងនោះបានមានៈសួរតទៅទៀត ហើយក៏មានកុមារប្រុសតូចម្នាក់បាននិយាយថាះ "ខ្ញុំដឹងអំពីរបៀបដែលយើងអាចប្រាប់ដឹងថាវាជាកូនឆ្មាឈ្មោល ឬកូនឆ្មាញី។"

ដោយទាល់គំនិត នោះត្រូបង្រៀនក៏បាននិយាយថាះ "អញ្ជឹង សូមប្អូនប្រាប់ពួកយើងអំពីរបៀបដែលយើងអាចដឹងថាវាជាកូនឆ្មាឈ្មោល ឬជាកូនឆ្មាញី"

កុមារប្រុសរូបនោះបានឆ្លើយថាះ "យើងអាចធ្វើការបោះឆ្នោតចំពោះបញ្ហា!"

រៀងខ្លះពុំអាចផ្លាស់ប្តូរ។ គោលលទ្ធិពុំអាចផ្លាស់ប្តូរ។

ប្រធាន វិលហ្ហូឌ រ៉ូឌដ្រូព្ធ បានមានប្រសាសន៍ថាះ "គោលលទ្ធិដែលត្រូវបានបើកសំដែងសំរាប់សេចក្តីសង្ក្រោះ និង ភាពលើកដំកើងនៃកូនចៅមនុស្ស . . . ជាគោលលទ្ធិដែលអ្នកពុំអាចបំផ្លាញបានឡើយ។ *គោលលទ្ធិទាំងនេះ គឺជាគោលលទ្ធិដែលមិនអាចត្រូវបានបំផ្លាញចោល តាមរយះការប្រមូលផ្តុំនៃបុរស [ឬស្ត្រី]ណាមួយនោះឡើយ*។ គោលលទ្ធិទាំងនេះ គឺជាគោលលទ្ធិដែលមិនចេះសាបសូន្យ . . .។ គោលលទ្ធិទាំងនេះ គឺហួសពីការឈោងចាប់ ឬការបំផ្លិចបំផ្លាញពីសំណាក់មនុស្សលោក . . .។ អំណាចនៃពិភពលោកទាំងមូលរួមបញ្ចូលគ្នាក៏មិនអាចបំផ្លាញគោលលទ្ធិទាំងនោះបានដែរ . . .។ ពុំមានអ្វីសូម្បីតែបន្តិចបន្តួចឬក្បៀសមួយ នៃគោលលទ្ធិទាំងនេះនឹងត្រូវបានបំផ្លាញបង់ឡើយ"។[36]

នៅក្នុងសង្ក្រាមលោកលើកទី II បុរសត្រូវបានហៅឱ្យទៅធ្វើចំបាំង។ នៅក្នុងភាពអាសន្ទនេះ ភរិយា និងម្តាយទាំងឡាយនៅទូទាំងពិភពលោកត្រូវបានបង្ខំចិត្តចូលប្រកបការងារដែលពុំធ្លាប់មានពីមុនមក។ ការជះឥទ្ធិពលដ៏គួរឱ្យអំណោចអធមបំផុតនៅក្នុងសង្ក្រាមនេះ គឺកើតមានទៅលើត្រូសារ។ វាបានបន្សល់ទុករហូតមកដល់សម័យនេះ។

បង្កើតកូនឱ្យចំរើនច្រើនឡើង ឱ្យមានពាសពេញលើផែនដី

ក្នុងសន្និសីទទូទៅ ខែតុលា ឆ្នាំ 1942 គណះប្រធានទីមួយបានថ្លែងជាសារលិខិតមួយទៅកាន់ "ពួកបរិសុទ្ធគ្រប់ទិសទី" ដោយពួកលោកបានមានប្រសាសន៍ថា ៖ "ដោយគុណធមិនៃសិទ្ធិអំណាចដែលយើងមាន ក្នុងនាមជាគណះប្រធានទីមួយ នៃសាសនាចក្រ យើងសូមព្រមានដល់សមាជិករបស់យើង"។

រួចហើយពួកលោកក៏បានមានប្រសាសន៍បន្ថែមទៀតថា ៖ "ក្នុងចំណោមព្រះបញ្ញត្តិដំបូងបង្អស់របស់ទ្រង់ទៅកាន់អ័ដាម និងអេវ៉ានោះ ព្រះអម្ចាស់បានមានបន្ទូលថា ៖ ចូរបង្កើតកូនឱ្យចំរើនច្រើនឡើង ឱ្យមានពាសពេញលើផែនដី។ ទ្រង់បានមានបន្ទូលម្តងទៀតចំពោះព្រះបញ្ញត្តិនោះនៅក្នុងសម័យកាលរបស់យើង។ ទ្រង់បានបើកសំដែងម្តងទៀតក្នុងសម័យកាលនេះ ជាសម័យកាលចុងក្រោយ ចំពោះគោលការណ៍ស្តីអំពីភាពដ៏នៅអស់កល្បជានិច្ចនៃសេចក្តីសញ្ញាអាពាហ៍ពិពាហ៍ . . .។

"ព្រះអម្ចាស់បានមានបន្ទូលប្រាប់យើងថា វាជាកាតព្វកិច្ចរបស់ស្វាមី និងភរិយាគ្រប់រូប ដើម្បីគោរពតាមព្រះបញ្ញត្តិដែលបានប្រទានឱ្យអ័ដាម នៅក្នុងការបង្កើតកូនឱ្យចំរើនច្រើនឡើង ឱ្យមានពាសពេញលើផែនដី ដើម្បីឱ្យក្រុមដ៏ធំនៃវិញ្ញាណជំរើសដែលកំពុងរង់ចាំទទួលរូបរាងកាយរបស់ពួកគេនោះ អាចមកកាន់ទីនេះ ហើយឆ្ពោះទៅមុខដោយស្ថិតនៅក្រោមការរៀបចំដ៏អស្ចារ្យរបស់ព្រះ ដើម្បីក្លាយជាព្រលឹងដ៏ល្អឥតខ្ចោះ ព្រោះបើគ្មានរូបកាយខាងសាច់ឈាម ពួកគេពុំអាចរីកចំរើនទៅដល់គោលដៅដែលព្រះបានរៀបចំសំរាប់ពួកគេបានទេ។ ដូច្នេះស្វាមី និងភរិយាគ្រប់រូបត្រូវតែប្រែក្លាយជាមាតាបិតានៅក្នុងអឺស្រាអែលសំរាប់កូនចៅមកចាប់កំណើតក្រោមសេចក្តីសញ្ញាបរិសុទ្ធដ៏នៅអស់កល្បជានិច្ច។

"ដោយការនាំវិញ្ញាណជំរើសទាំងនេះមកផែនដី ឱពុកម្តាយម្នាក់ៗបានគិតឆ្ពោះទៅរករូបកាយខាងវិញ្ញាណ និងព្រះអម្ចាស់ ដោយការក្តាប់យកឱកាសដែលទ្រង់បានប្រទានឱ្យ ជាការទទួលខុសត្រូវដ៏ពិសិដ្ឋបំផុត ព្រោះអនាគតនៃវិញ្ញាណនោះ ក្នុងភាពអស់កល្បជានិច្ចនៅពេលខាងមុខ គឺជាពរជ័យ ហើយក៏ទណ្ឌកម្មនាពេលអនាគត ដោយផ្អែកទៅលើការថែទាំ ការបង្រៀន ការហ្វឹកហ្វឹនដែលឱពុកម្តាយនឹងផ្តល់ឱ្យទៅវិញ្ញាណនោះ។

"ក្មានឱពុកម្តាយណាម្នាក់អាចផ្សេសផុតពីកាតព្វកិច្ច និងការទទួលខុសត្រូវនោះបានឡើយ ហើយសំរាប់ការពិភាក្សាចំពោះកិច្ចការនេះ ព្រះអម្ចាស់នឹងធ្វើឱ្យយើងទទួលខុសត្រូវចំពោះកិច្ចការទាំងនេះដោយខានពុំបាន។ ក្មានកិច្ចការណាមួយនៅលើផែនដីនេះដែលសំខាន់ជាងកិច្ចការនេះឡើយ"។

មាតាភាពគឺជាការហៅដ៏បរិសុទ្ធ

នៅក្នុងការលើកឡើងអំពីមាតា គណះប្រធានទីមួយបានមានប្រសាសន៍ថាះ "ភាពជាមាតាបានក្លាយទៅជាការហៅដ៏បរិសុទ្ធ ជាការឧទ្ទិសដ៏ពិសិដ្ឋមួយសំរាប់ការធ្វើឱ្យសំរេចបានទ្រវផែនការរបស់ព្រះអម្ចាស់ ជាការធ្វើឱ្យបរិសុទ្ធនៃការលះបង់ចំពោះការលើកឡើង និងការចិញ្ចឹមបីបាច់ ការអប់រំក្នុងរូបកាយ គំនិត និងវិញ្ញាណនៃអស់អ្នកដែលរក្សានូវសណ្ឋានទីមួយរបស់ខ្លួន និងអ្នកដែលមកផែនដីនេះសំរាប់សណ្ឋានទីពីរបស់ខ្លួន ដើម្បី'មើលបើសិនជាពួកគេនឹងប្រព្រឹត្តនូវអ្វីៗ គ្រប់យ៉ាងដែលព្រះអម្ចាស់ដ៏ជាព្រះរបស់ពួកគេនឹងបញ្ជាដល់ពួកគេ' (អ័ប្រាហាំ 3:25)។ ដើម្បីដឹកនាំពួកគេឱ្យរក្សានូវសណ្ឋានទីពីរបស់ខ្លួន នោះគឺជាកាតព្វកិច្ចរបស់ម្តាយ ហើយ 'អស់អ្នកណាដែលរក្សាសណ្ឋានទីពីរបស់ខ្លួននោះ នឹងបានសេរីល្អបន្ថែមទៅលើក្សាលរបស់ពួកគេជារៀងដរាបតទៅ'។ (អេប្រាំហាំ 3:26)

"ការបំរើដ៏ទេវភាពនៃភាពជាមាតានេះ អាចត្រូវបានផ្តល់ឱ្យចំពោះតែមាតាប៉ុណ្ណោះ។ វាប្រហែលជាពុំអាចប្រគល់ទៅឱ្យអ្នកដទៃទៀតបានឡើយ។ ពួកគិលានុប្បដ្ឋាយិកាពុំអាចធ្វើកិច្ចការនេះបានឡើយ ពួកគិលានុប្បដ្ឋាយិកាសាធារណះក៏ពុំអាចធ្វើកិច្ចការនេះដែរ អ្នកជំនួយក៏ពុំអាចបំពេញកិច្ចការនេះបានដូចគ្នា—លើកលែងតែម្តាយប៉ុណ្ណោះដែលអាចផ្តល់នូវការបីបាច់ថែរក្សាដ៏ពេញលេញ ដោយមានជំនួយបន្ថែមទៀតពីសំណាក់ដៃដ៏កក់ក្តៅរបស់ឱពុក និងបងប្អូនប្រុសស្រី"។

គណះប្រធានទីមួយបានណែនាំថាះ "ម្តាយដែលប្រគល់កូនរបស់ខ្លួនទៅឱ្យអ្នកដទៃបីបាច់ ដើម្បីនាងអាចធ្វើការងារ ដោយពុំបាច់បំពេញកិច្ចការជាម្តាយនោះ ទោះជាសំរាប់មាសប្រាក់ កិត្តិយស ឬក៏សំរាប់ការបំរើខាងសាធារណះក្តី គួរតែចងចាំថាះ 'កូនណាដែលបណ្តោយឱ្យប្រព្រឹត្តតាមអំពើចិត្ត នោះតែងនាំឱ្យម្តាយមានសេចក្តីខ្មាសវិញ'។ (សុភាសិត 29:15) ក្នុងសម័យកាលយើងបច្ចុប្បន្ន ព្រះអម្ចាស់បានមានបន្ទូលថា លើកលែងតែឱពុកម្តាយបង្រៀនកូនចៅរបស់ខ្លួនទ្រវគោលលទ្ធិនៃសាសនាចក្រ នោះ'អំពើបាបនឹងធ្លាក់មកលើក្សាលរបស់ឱពុកម្តាយវិញ' (គ. និង ស. 68:25)។

"ភាពជាមាតាគឺប្រហាក់ប្រហែលទៅនឹងទេវភាព។ វាជាការបំរើដ៏សំខាន់ និងបរិសុទ្ធបំផុតដែលត្រូវបានកត់សំគាល់ដោយមនុស្សលោក។ ភាពជាមាតានេះតែងតាំងស្ត្រី ដែលគោរពការហៅបរិសុទ្ធនិងការបំរើរបស់ខ្លួនឱ្យនៅបន្ទាប់ពួកទេវតា"។[37]

សារលិខិតនិងពាក្យដាស់តឿនពីសំណាក់គណះប្រធានទីមួយគឺត្រូវការជាចាំបាច់បំផុតសំរាប់បច្ចុប្បន្ទនេះ ពុំតិចជាងពេលដែលសារលិខិតនេះត្រូវបានលើកឡើងនោះឡើយ។ ហើយពុំមានសំលេងមកពីអង្គភាពនានានៃសាសនាចក្រ នៅគ្រប់ថ្នាក់ដឹកនាំស្មើទៅនឹង សំលេងនៃគណះប្រធានទីមួយនោះឡើយ។[38]

ព្រលឹងនៃជនទាំងឡាយណាដែលពុំបានទទួលពរជ័យនៃអាពាហ៍ពិពាហ៍ និងភាពជាឱពុកម្តាយ ដោយធម្មជាតិ ឬក៏ដោយកាលះទេសះ ឬអ្នកដែលត្រូវចិញ្ចឹមបីកូនចៅ ហើយត្រូវប្រកបការងារដើម្បីផ្គត់ផ្គង់ពួកគេតែម្នាក់ឯង នោះនឹងពុំត្រូវបានបដិសេធសំរាប់ពរជ័យណាមួយនោះឡើយក្នុងភាពដ៏នៅអស់កល្បជានិច្ច—រាល់ពរជ័យទាំងនេះ[39] ត្រូវបានផ្តល់ដល់អ្នកដែលគោរពព្រះបញ្ញត្តិ។ ដូចដែលប្រធាន

ឡូនវែនសូ ស្ទ បានសន្យាថា "រឿងនេះគឺមានភាពច្បាស់លាស់ ហើយវិជ្ជមាន"។[40]

រឿងប្រៀបប្រដូចស្តីអំពីសម្បត្តិ និង កូនសោ

ខ្ញុំសូមបញ្ចប់សុន្ទរកថានេះជាមួយនឹងរឿងប្រៀបប្រដូចមួយ

កាលពីដើមឡើយមានបុរសម្នាក់បានទទួលកូនសោពីរធ្វើជាមរតករបស់ខ្លួន។ គាត់ត្រូវបានប្រាប់ថា កូនសោទីមួយគឺទុកសំរាប់បើកទ្វារបន្ទប់ក្រោមដី ហើយគាត់ត្រូវតែការពារវាគ្រប់ពេលវេលា។ កូនសោទីពីរគឺទុកសំរាប់បើកទូដែក ដែលមានសម្បត្តិដ៏មានតម្លៃនៅក្នុងបន្ទប់ក្រោមដី។ គាត់អាចបើកទូដែកនោះ ហើយអាចប្រើប្រាស់នូវរាល់វត្ថុដ៏មានតម្លៃដែលមាននៅក្នុងទូដែកនោះដោយសេរី។ គាត់ត្រូវបានដាស់តឿនថា នឹងមានមនុស្សជាច្រើនចង់បានមរតករបស់គាត់។ គាត់ត្រូវបានសន្យាថា ប្រសិនបើគាត់ប្រើសម្បត្តិទាំងនេះដោយត្រឹមត្រូវ វានឹងត្រូវបានបំពេញឱ្យមានដូចដើមវិញ ហើយនឹងគ្មានពុំមានការកាត់បន្ថយនោះឡើយ រហូតដល់ភាពដ៏នៅអស់កល្បជានិច្ច។ គាត់នឹងទទួលនូវការសាកល្បង។ ប្រសិនបើគាត់ប្រើវាធ្វើជាប្រយោជន៍ដល់អ្នកដទៃ នោះពរជ័យ ហើយនឹងសេចក្តីអំណរផ្ទាល់ខ្លួនរបស់គាត់នឹងកើនឡើង។

បុរសនោះបានធ្វើដំណើរទៅកាន់បន្ទប់ក្រោមដីតែម្នាក់ឯង។ គាត់បានប្រើកូនសោទីមួយរបស់គាត់ដើម្បីបើកទ្វារបន្ទប់ក្រោមដី។ គាត់បានព្យាយាមចាក់សោយកសម្បត្តិដោយប្រើកូនសោមួយផ្សេងទៀត ប៉ុន្តែគាត់មិនអាចបើកទូដែកនោះបានឡើយ ពីព្រោះវាមានមេសោពីរដែលចាក់ជាប់នឹងទូដែកនោះ។ កូនសោតែមួយរបស់គាត់មិនអាចបើកទូដែកនោះបានឡើយ។ គាត់បានមានការងឿងឆ្ងល់យ៉ាងខ្លាំង។ ដោយសារគាត់បានទទួលកូនសោសំរាប់បើកទូដែកនេះ។ គាត់បានដឹងទៀតថាសម្បត្តិនោះ គឺជារបស់គាត់ពេញច្បាប់។ គាត់បានខិតខំធ្វើតាមការណែនាំ ប៉ុន្តែគាត់នៅតែមិនអាចបើកទូដែកនេះបាន។

នៅក្នុងខណៈនោះដែរ មានស្ត្រីម្នាក់បានចូលមកកាន់បន្ទប់ក្រោមដីនេះ។ ដោយនៅក្នុងដៃរបស់នាងមានកាន់កូនសោមួយផងដែរ។ កូនសោនោះ មានភាពខុសប្លែកគួរឱ្យកត់សំគាល់ ពីកូនសោដែលបុរសនោះមាន។ កូនសោរបស់នាងអាចចាក់ត្រូវនឹងមេសោមួយផ្សេងទៀត។ កូនសោនោះបានធ្វើឱ្យគាត់រាបសារ ដោយដឹងថាគាត់មិនអាចទទួលមរតកដ៏ពេញច្បាប់របស់គាត់ដោយគ្មានរូបនាងបានឡើយ។

ពួកគេបានធ្វើសេចក្តីសញ្ញាថា ពួកគេទាំងពីរនាក់នឹងបើកសម្បត្តិនោះ ហើយដូចដែលបានណែនាំ បុរសនោះត្រូវមើល ហើយការពារបន្ទប់ក្រោមដី រីឯស្ត្រីនោះនឹងនៅមើលថែទាំសម្បត្តិ។ នាងមិនបានខ្ចល់ខ្ចាយថា ធ្វើជាអ្នកថែរក្សាបន្ទប់ក្រោមដីបុរសនោះមានកូនសោដល់ទៅពីរនោះទេ ត្បិតបំណងពេញលេញរបស់គាត់គឺមើលថានាងឱ្យមានសុវត្ថិភាព នៅពេលនាងមើលថែរក្សាវត្ថុដ៏មានតម្លៃបំផុតសំរាប់ពួកគេទាំងពីរ។ ពួកគេបានបើកទូដែករួមគ្នា ហើយបានទទួលយកនូវមរតករបស់ខ្លួន។ ពួកគេមានក្តីសប្បាយរីករាយយ៉ាងខ្លាំង ត្បិតវាបានកើតឡើងដោយឯកឯង ដូចដែលបានសន្យា។

ដោយមានសេចក្តីអំណរក្រៃលែង ពួកគេបានរកឃើញាថាពួកគេអាចបន្សល់ទុកសម្បត្តិទាំងនេះដល់កូនចៅរបស់ខ្លួន កូនម្នាក់ៗអាចទទួលបានទ្វារង្ចាល់ដ៏ពេញលេញដែលពុំអាចកាត់បន្ថយបានដល់ជំនាន់ក្រោយ។

ប្រហែលជាកូនចៅជំនាន់ក្រោយរបស់ពួកគេមួយចំនួន នឹងមិនអាចស្វែងរកដៃគូដែលមានកូនសោបង្ត្រប់ ឬក៏អ្នកដែលសក្តិសមម្នាក់ ហើយយល់ព្រមដើម្បីរក្សានូវសេចក្តីសញ្ញា ដែលទាក់ទងទៅនឹងសម្បត្តិនេះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើពួកគេរក្សានូវបទបញ្ញត្តិ ពួកគេនឹងមិនត្រូវបានបដិសេធ ទោះបីជាពរជ័យដ៏តូចបំផុតក៏ដោយ។

ពីព្រោះមានមនុស្សមួយចំនួន បានល្បួងពួកគេឱ្យប្រើសម្បត្តិរបស់ខ្លួនខុស ដូច្នេះពួកគេបានមានការប្រុងប្រយ័ត្នដើម្បីបង្រៀនកូនចៅរបស់ខ្លួនអំពីកូនសោ និងសេចក្តីសញ្ញា។

ពេលវេលាបានមកដល់ ក្នុងចំណោមកូនចៅរបស់ពួកគេ ខ្លះត្រូវបានគេបោកបញ្ឆោត ឬមានភាពឈ្មានីស ឬគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ដោយសារកូនម្នាក់បានទទួលកូនសោពីរ ឯកូនម្នាក់ទៀតបានទទួលតែកូនសោមួយប៉ុណ្ណោះ។ ពួកដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន បានសួរថា "ហេតុអ្វីបានជាសម្បត្តិនោះពុំអាចជារបស់ខ្ញុំតែម្នាក់ឯង ដើម្បីខ្ញុំអាចប្រើប្រាស់វាតាមចិត្តខ្ញុំចង់?"

អ្នកខ្លះបានព្យាយាមកែទម្រង់កូនសោដែលពួកគេត្រូវបានផ្តល់ឱ្យ ដើម្បីធ្វើវាឱ្យដូចនឹងកូនសោមួយទៀត។ ប្រហែលពួកគេគិតថាវានឹងត្រូវមេសោទាំងពីរ។ ហេតុនេះហើយទូដែកត្រូវបានបិទចំពោះពួកគេ។ កូសោដែលបានកែទ្រង់ទ្រាយរបស់ពួកគេគឺគ្មានប្រយោជន៍ ហើយមរតករបស់ពួកគេក៏ត្រូវបានបាត់បង់ដែរ។

អស់អ្នកទាំងឡាយណាដែលបានទទួលសម្បត្តិដោយការដឹងគុណ និងបានគោរពច្បាប់ទាក់ទងនឹងសម្បត្តិនោះ បានស្គាល់នូវសេចក្តីអំណរដ៏ពេញលេញនៅក្នុងជីវិតរបស់ពួកគេ និងនៅក្នុងភាពដ៏នៅអស់កល្បជានិច្ច។

ខ្ញុំធ្វើជាទីបន្ទាល់ចំពោះផែនការនៃសុភមង្គលរបស់ព្រះវរបិតារបស់យើង ហើយសូមធ្វើទីបន្ទាល់ក្នុងព្រះនាមនៃទ្រង់ដែលបាននាំមកនូវដង្ចាយធួន ដើម្បីឱ្យមានការសង្គ្រោះ។

ដកស្រង់ចេញពីសុន្ទរកថារបស់អែលឌើរ ជាកកឺ នៅក្នុងសន្និសីទទូទៅនៃសាសនាចក្រ ខែ តុលា ឆ្នាំ 1993 (សូមមើល Conference Report ខែ តុលា ឆ្នាំ 1993 ទំព័រ 27–31 ឬ *Ensign* ខែ តុលា ឆ្នាំ 1993 ទំព័រ 21–24)។

កំណត់ចំណាំ

1. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 76:24 មើលផងដែរ ជនគណនា 16:22 ហេព្រើរ 12:9។
2. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 132:63 គណៈប្រធានទីមួយ "ដើមកំណើតនៃមនុស្ស" (ខែ វិច្ឆិកា ឆ្នាំ 1909) នៅក្នុង James R. Clark ជាអ្នកចងក្រង *Messages of the First Presidency of The Church of Jesus Christ of Latter-day Saints* វ៉ុលទី 6 (ឆ្នាំ1965–75) 4:203 សូមមើលផងដែរ Spencer W. Kimball "The Blessings and Responsibilities of Womanhood," *Ensign* ខែ មីនា ឆ្នាំ 1976, 71 Gordon B. Hinckley នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1983 ទំព័រ 115 ឬ *Ensign* ខែ វិច្ឆិកា 1983 ទំព័រ 83។
3. សូមមើល *Teachings of the Prophet Joseph Smith* sel. Joseph Fielding Smith (1976) ទំព័រ 348–49, 357, 365។
4. សូមមើលអ័ប្រាហាំ 3:24–27។
5. សូមមើល យ៉ារ៉ុម 1:2 អាលម៉ា 24:14; 42:5 ម៉ូសេ 6:62។
6. សូមមើល យ៉ាកុប 6:8 អាលម៉ា 12:25–36; 17:16; 18:39; 22:13–14; 39:18; 42:11, 13។
7. សូមមើល អាលម៉ា 42:8។
8. សូមមើល អាលម៉ា 42:2–5។
9. សូមមើល នីហ្ចៃទី 2 9:28 អាលម៉ា 12:4–5 ហេលេមិន 2:8 នីហ្ចៃទី 3 1:16 គោលលទ្ធិ និង សេចក្តីសញ្ញា 10:12, 23 ម៉ូសេ 4:3។

10. សូមមើល *Teachings of the Prophet Joseph Smith* ទំព័រ 181, 297។
11. សូមមើល *Teachings of the Prophet Joseph Smith,* 181។
12. សូមមើល នីហ្វៃទី 2 2:18; 28:20។
13. សូមមើល អាលម៉ា 39:5 ម៉ូរ៉ូណៃ 9:9។
14. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 130:2; 131:2 កូរិនថូសទី 1 11:11 អេភេសូរ 5:31។
15. សូមមើល ម៉ូសេ 6:8–9។
16. សូមមើល ម៉ូសេ 3:8។
17. សូមមើល ម៉ូសេ 6:67។
18. សូមមើល ម៉ូសេ 3:18។
19. សូមមើល ម៉ូសេ 3:23–24។
20. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 42:22។
21. សូមមើល ម៉ូសេ 4:7–12។
22. សូមមើល នីហ្វៃទី 2 2:25។
23. *Cowley and Whitney on Doctrine,* អ្នករៀបរៀង Forace Green (1963), 287។
24. សូមមើល ម៉ូសេ 2:28 សូមមើលផងដែរ លោកុប្បត្តិ 1:28; 9:1។
25. សូមមើល កាឡាទី 5:22–23 គោលលទ្ធិ និង សេចក្តីសញ្ញា 4:5–6 អាលម៉ា 7:23–24។
26. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 131:2។
27. សូមមើល “Our Wives and Our Mothers in the Eternal Plan” (សុន្ទរកថាដែលបានថ្លែងនៅក្នុងសន្និសីទ សមាគមសង្គ្រោះទូទៅ ថ្ងៃទី 3 ខែ តុលា ឆ្នាំ 1946) នៅក្នុង *J. Reuben Clark: Selected Papers on Religion, Education, and Youth* ចងក្រងដោយ David H. Yarn Jr. (1984) ទំព័រ 62។
28. សូមមើល លោកុប្បត្តិ 1:28 កំណត់ចំណាំ 28c។
29. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 75:28 ធីម៉ូថេទី 5:8។
30. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 107:40–41 មើលផងដែរ គោលលទ្ធិ និង សេចក្តីសញ្ញា 84:14–16។
31. សូមមើលគោលលទ្ធិ និង សេចក្តីសញ្ញា 121:41–42 អក្សរអត្ថបទជាការបន្ថែម។
32. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 121:37។
33. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 84:39។
34. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 121:37។
35. សូមមើល *Teachings of the Prophet Joseph Smith* 308, 367។
36. *The Discourses of Wilford Woodruff* រៀបរៀងដោយ G. Homer Durham (1946), 25–26 អក្សរអត្ថបទជាការបន្ថែម។
37. នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1942 ទំព័រ 7, 11–12។
38. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 107:8–9, 22, 91។
39. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 137:7–9។
40. “Discourse by President Lorenzo Snow” *Millennial Star* ថ្ងៃទី 31 ខែ សីហា ឆ្នាំ 1899 ទំព័រ 547។

ការអភិវឌ្ឍន៍សាមគ្គីភាពក្នុងអាពាហ៍ពិពាហ៍

2

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលៈទេសៈរបស់អ្នកផ្តាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- សូមអានខគម្ពីរស្តីអំពីសាមគ្គីភាពដូចខាងក្រោម ៖ កូរិនថូសទី1 1:9–10 ភីលីព 1:27 ម៉ូសាយ 18:21 គោលលទ្ធិ និង សេចក្តីសញ្ញា 38:27។ ចូរពិចារណាអំពីរបៀបដែលខគម្ពីរទាំងនេះមានជាប់ទាក់ទិនទឹងទំនាក់ទំនងរវាងស្វាមី និងភរិយា។
- សូមពិភាក្សាជាមួយស្វាមី ឬភរិយារបស់អ្នកនូវតំរូវការចំពោះពេលវេលារបស់អ្នកទាំងពីរ រួមមានទាំងពេលវេលាក្នុងសង្គម មុខរបរ សហគមន៍ និងការបំរើក្នុងសាសនាចក្រ។ សូមចំណាយពេលដើម្បីស្វែងយល់អំពីតំរូវការរបស់អ្នកដទៃទៀត ហើយត្រាកដថាការគាំងចិត្តផ្សេងៗរបស់អ្នក ពុំមានភាពប៉ះពាល់ចំពោះភាពស្មោះត្រង់របស់គ្នាទៅវិញទៅមក។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

ដើម្បីឱ្យយើងអាចរួមគ្នាតែមួយ

អែលឌើរ ហិនរី ប៊ី អារ៉ិង
នៃក្រុមនៃសាវកទាំងដប់ពីរនាក់

“បើសិនអ្នករាល់គ្នាមិនរួមគ្នាតែមួយទេ ឈ្មោះថាអ្នករាល់គ្នាពុំមែនជារបស់ផងយើងឡើយ”

ព្រះអង្គសង្គ្រោះនៃពិភពលោក ព្រះយេស៊ូវគ្រីស្ទបានមានព្រះបន្ទូល អំពីពួកអ្នកដែលទទឹងក្លាយទៅជាផ្នែកនៃសាសនាចក្ររបស់ទ្រង់ថា ៖ “បើសិនអ្នករាល់គ្នាមិនរួមគ្នាតែមួយទេ ឈ្មោះថាអ្នករាល់គ្នាពុំមែនជារបស់ផងយើងឡើយ”(គ. និង ស. 38:27)។ ហើយក្នុងការបង្កើតនៃបុរសនិងស្ត្រី សាមគ្គីភាពសំរាប់ពួកគេក្នុងអាពាហ៍ពិពាហ៍ មិនត្រូវបានប្រទានឱ្យក្នុងលក្ខណៈសេចក្តីសង្ឃឹមនោះ ប៉ុន្តែក្នុងលក្ខណៈជាការដាក់បទបញ្ញត្តិ! “ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅជាប់នឹងប្រពន្ធវិញ ហើយអ្នកទាំងពីរនោះ នឹងត្រឡប់ជាសាច់តែមួយ” (លោកុប្បត្តិ 2:24)។ ព្រះវរបិតាសួគ៌របស់យើងសព្វព្រះទ័យឱ្យមានចិត្តចង់ក្រងរួមគ្នា។ សាមគ្គីភាពនៅក្នុងសេចក្តីស្រឡាញ់ ពុំមែនគ្រាន់តែជាឧត្តមគតិដ៏សាមញ្ញមួយប៉ុណ្ណោះនោះទេ។ វាគឺជាការចំបាច់មួយ។

តំរូវការដើម្បីឱ្យយើងរួមមកតែមួយពុំមែនសំរាប់តែជីវិតនេះប៉ុណ្ណោះទេ។ វាកើតមានឡើងដោយគ្មានទីបញ្ចប់ ។ អាពាហ៍ពិពាហ៍ដំបូង ត្រូវបានធ្វើឡើងដោយព្រះនៅក្នុងសួនច្បារ ពេលអ័ដាម និងអេវ៉ាស្ថិតក្នុងអមតៈភាព។ ទ្រង់បាននៅដាក់ក្នុងដួងចិត្តរបស់បុរស និងស្ត្រីតាំងពីដើមដំបូងមកនូវសេចក្តីត្រាថ្មាមួយដើម្បីរួបរួមជាស្វាមី និងភរិយាជានិរន្តរ៍ ហើយរស់នៅជាក្រុមគ្រួសារក្នុងភាពល្អតប្រសើរ ដែលជាការរួបរួមដ៏សុចរិតមួយ។ ទ្រង់បានដាក់នៅក្នុងដួងចិត្តរបស់កូនចៅទ្រង់នូវសេចក្តីត្រាថ្មាមួយ ដើម្បីរស់នៅដោយសេចក្តីសុខសាន្តជាមួយអ្នកទាំងឡាយ ដែលនៅជុំវិញពួកគេ។

ប៉ុន្តែជាមួយនឹងការធ្លាក់ចុះ វាបានសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា ការរស់នៅក្នុងសាមគ្គីភាពពុំមែនជាការងាយស្រួលនោះទេ។ សោកនាដកម្មបានកើតមានឡើងតាំងតែពីដំបូងមកម្ល៉េះ។ កាអ៊ិនបានសំលាប់អេបិលជាប្អូនរបស់ខ្លួន។ កូនចៅរបស់អ័ដាម និងអេវ៉ាបានទទួលរងនូវការឈ្លូងពីអារក្សសាតាំង។ ដោយដំនាញដោយសេចក្តីស្អប់ខ្ពើម និងដោយភាពប៉ិនប្រសប់ អារក្សសាតាំងបានអនុវត្តន៍នូវគោលបំណងខ្លួន។ គោលបំណងនោះ គឺមានភាពផ្ទុយស្រឡះពីគោលបំណងរបស់ព្រះវរបិតាសួគ៌របស់យើង និងព្រះអង្គសង្គ្រោះ។ ទ្រង់សព្វព្រះទ័យប្រគល់ឱ្យយើងនូវការរួបរួមដ៏ល្អឥតខ្ចោះ ហើយនឹងសុភមង្គលដ៏នៅអស់កល្បជានិច្ច។ អារក្សសាតាំងដែលជាសត្រូវរបស់ព្រះ ហើយក៏ជាសត្រូវរបស់យើងទាំងអស់គ្នាផងដែរនោះ បានដឹងអំពីផែនការសង្គ្រោះ តាំងពីមុនការបង្កបង្កើតមកម្ល៉េះ។ វាបានដឹងថាមានតែនៅក្នុងជីវិតដ៏នៅអស់កល្បជានិច្ចប៉ុណ្ណោះ ទើបទំនាក់ទំនងដ៏សប្បាយរីករាយ ហើយពិសិដ្ឋនៃក្រុមគ្រួសារអាចនៅបន្តទៅទៀតបាន។ អារក្សសាតាំងចង់បំបែកយើងចេញពីអ្នកដែលយើងស្រឡាញ់ ហើយធ្វើឱ្យយើងគ្មានសេចក្តីសុខសាន្ត។ វានេះហើយគឺជាអ្នកបណ្តុះគ្រាប់ពូជនៃការទាស់ទែងគ្នា នៅក្នុងដួងចិត្តនៃមនុស្សគ្រប់រូប ដោយសង្ឃឹមថាយើងអាចត្រូវបានធ្វើឱ្យបែកខ្ញែក និងបែកបាក់គ្នា។

យើងទាំងអស់គ្នាមានបទពិសោធន៍ទាំងសាមគ្គីភាព និងការបែកបាក់គ្នា។ ជួនកាលក្នុងក្រុមគ្រួសារ ហើយក៏ប្រហែលជានៅក្នុងមជ្ឈដ្ឋានផ្សេងទៀតផងដែរ យើងឃើញថា នៅក្នុងជីវិតនេះភាគតិចណាស់ដែលមានមនុស្សម្នាក់គិតអំពីប្រយោជន៍របស់អ្នកដទៃពីលើ ប្រយោជន៍របស់គាត់ ឬនាងផ្តាល់ ដោយសេចក្តីស្រឡាញ់និងការពលិកម្ម។ យើងទាំងអស់គ្នាស្គាល់អ្វីមួយដែលជាទុក្ខសោក និង ភាពឯកកោនៃការបែកបាក់ និងភាពគ្មានទីពឹង។ យើងពុំចាំបាច់ឱ្យគេប្រាប់អំពីអ្វីដែលត្រូវជ្រើសរើសនោះទេ។ យើងដឹងអំពីកិច្ចការទាំងនោះ។ ប៉ុន្តែយើងត្រូវមានសេចក្តីសង្ឃឹមថា យើងអាចទទួលបានបទពិសោធន៍នៃការរួបរួមក្នុងជីវិតនេះ និងមានភាពសក្តិសមដើម្បីទទួលបានអារម្មណ៍នោះជាដរាបតទៅនៅក្នុងលោកខាងមុខ។ ហើយយើងត្រូវដឹងអំពីរបៀបដែលពរជ័យដ៏ធំនោះនឹងកើតមានឡើងនៅក្នុងការធ្វើឱ្យយើងដឹងនូវអ្វីដែលយើងត្រូវធ្វើ។

ព្រះអង្គសង្គ្រោះធ្វើឱ្យសាមគ្គីភាពកើតមានឡើង

ព្រះអង្គសង្គ្រោះនៃពិភពលោកបានមានបន្ទូលអំពីសាមគ្គីភាពនេះ និងអំពីរបៀបដែលយើងនឹងធ្វើឱ្យនិស្ស័យរបស់យើងមានការផ្លាស់ប្តូរ ដើម្បីធ្វើឱ្យសាមគ្គីភាពអាចកើតមានឡើង។ ទ្រង់បានបង្រៀនអំពីសាមគ្គីនេះយ៉ាងច្បាស់ក្នុងការអធិស្ឋានមួយ

ដែលទ្រង់បានធ្វើ ទៅក្នុងការជួបប្រជុំចុងក្រោយជាមួយនឹងពួកសាវកពីមុនការសុគតរបស់ទ្រង់។ ការអធិស្ឋានដ៏ទេវភាពនោះបានកត់ត្រាក្នុងព្រះគម្ពីរយ៉ូហានៈ ទ្រង់ជិតប្រឈមមុខនឹងការពលិកម្មដែលគួរឱ្យភ័យខ្លាចសំរាប់យើងគ្រប់គ្នា ដើម្បីឱ្យជីវិតដ៏នៅអស់កល្បជានិច្ចអាចកើតមានឡើង។ ទ្រង់ជិតចាកចេញពីពួកសាវក គឺជាអ្នកដែលទ្រង់បានតែងតាំង ជាអ្នកដែលទ្រង់ស្រឡាញ់ ហើយជាអ្នកដែលទ្រង់នឹងទុកកូនសោឱ្យដឹកនាំសាសនាចក្ររបស់ទ្រង់។ ដូច្នេះហើយទ្រង់បានអធិស្ឋាន ទៅកាន់ព្រះវរបិតារបស់ទ្រង់ ក្នុងនាមជាបុត្រាដ៏ល្អឥតខ្ចោះពោលទៅកាន់ព្រះវរបិតា ជាព្រះវរបិតាដ៏ល្អឥតខ្ចោះ។ យើងបានកត់សំគាល់នៅក្នុងបទគម្ពីររបស់ទ្រង់ពីរប្បីបដែលក្រុមគ្រួសារអាចរួមគ្នាតែមួយសំរាប់កូនចៅទាំងអស់នៃព្រះវរបិតាសួគ៌ ដែលដើរតាមព្រះអង្គសង្គ្រោះ និងពួកអ្នកបំរើរបស់ទ្រង់ថា ៖

“ទូលបង្គំបានចាត់ឱ្យគេទៅក្នុងលោកិយ ដូចជាទ្រង់ចាត់ទូលបង្គំឱ្យមកក្នុងលោកិយដែរ”។

“ឯទូលបង្គំក៏ញែកខ្លួនចេញជាបរិសុទ្ធដោយយល់ដល់ពួកគេ ដើម្បឱ្យពួកគេបានញែកចេញជាបរិសុទ្ធដោយសារសេចក្តីពិតដែរ”។

“ទូលបង្គំមិនត្រឹមតែអធិស្ឋាន ឱ្យអ្នកទាំងអស់នោះតែប៉ុណ្ណោះទេ គឺដល់ទាំងអ្នកឡាយណាដែលនឹងជឿដល់ទូលបង្គំ ដោយសារពាក្យរបស់ពួកគេថែមទៀតដែរ”។

“ដើម្បីឱ្យទាំងអស់បានរួមមកតែមួយ ឱព្រះវរបិតាអើយ ដូចជាទ្រង់គង់ក្នុងទូលបង្គំ ហើយទូលបង្គំក៏នៅក្នុងទ្រង់ដែរ គឺឱ្យអ្នកទាំងនោះបានរួមគ្នាតែមួយនៅក្នុងយើង ប្រយោជន៍ឱ្យលោកិយបានជឿថា ទ្រង់ចាត់ឱ្យទូលបង្គំមកពិត” (យ៉ូហាន 17:18–21)។

នៅក្នុងបទគម្ពីរប៊ីន្ទានម៉ាត់នេះ ទ្រង់បានបញ្ជាក់យ៉ាងច្បាស់អំពីរប្បីបដែលដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទអាចធ្វើឱ្យយើងរួមគ្នាតែមួយបាន។ អស់អ្នកណាដែលជឿលើសេចក្តីពិតដែលទ្រង់បានបង្រៀន ហើយទទួលស្គាល់ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាដែលបានផ្តល់ឱ្យ ដោយអ្នកបំរើដែលមានសិទ្ធិអំណាចរបស់ទ្រង់។ បន្ទាប់មក តាមរយៈការគោរពតាមពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងនោះ និស្ស័យរបស់ពួកគេនឹងមានការផ្លាស់ប្តូរ។ នៅក្នុងមធ្យោបាយនេះ ទើបដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ អាចធ្វើឱ្យយើងត្រូវបានញែកចេញជាបរិសុទ្ធ។ ហើយយើងអាចរស់នៅក្នុងសាមគ្គីភាព ពេលយើងមានសេចក្តីសុខសាន្តក្នុងជីវិតនេះ ហើយរស់នៅជាមួយនឹងព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ក្នុងភាពអស់កល្បជានិច្ច។

ការបំរើរបស់ពួកសាវក និងពួកព្យាការីក្នុងសម័យកាលនោះ ក៏ដូចជានៅពេលបច្ចុប្បន្ននេះផងដែរ គឺដើម្បីដឹកនាំកូនចៅរបស់អ័ដាម និងអេវ៉ា ទៅរកសាមគ្គីភាពនៃសេចក្តីជំនឿមួយលើព្រះយេស៊ូវគ្រីស្ទ។ គោលបំណងដ៏សំខាន់ចំពោះអ្វីដែលពួកគាត់បានបង្រៀន ហើយនឹងអ្វីដែលយើងបង្រៀន គឺដើម្បីបង្រួបបង្រួមក្រុមគ្រួសារ រួមមាន ៖ ស្វាមី ភរិយា កូនចៅ ជីដូនជីតា ហើយជាចុងក្រោយបំផុត គឺសំរាប់កូនចៅរបស់អ័ដាម និងអេវ៉ាគ្រប់រូបដែលនឹងជ្រើសយកការបង្រៀននេះ។

ព្រះវិញ្ញាណនាំទៅរកសាមគ្គីភាពជាមួយនឹងអ្នកដទៃ

អ្នកបានចងចាំនៅពេលព្រះអង្គសង្គ្រោះបានអធិស្ឋានថា “ដោយយល់ដល់ពួកគេ”—ដោយនិយាយពីពួកសាវក—“ទូលបង្គំក៏ញែកខ្លួនចេញជាបរិសុទ្ធ ដើម្បីឱ្យគេបានញែកចេញជាបរិសុទ្ធដោយសារសេចក្តីពិតដែរ” (យ៉ូហាន 17:19)។ ព្រះវិញ្ញាណបរិសុទ្ធ គឺជាអ្នកញែកចេញជាបរិសុទ្ធ។ យើងអាចមានព្រះវិញ្ញាណបរិសុទ្ធធ្វើជាដៃគូ ដោយសារតែព្រះអម្ចាស់បានស្តារឡើងវិញ នូវបព្វជិតភាពមិលគីស្សាដែកតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ។ កូនសោបព្វជិតភាពនោះមាននៅលើផែនដីសព្វថ្ងៃនេះ។ ដោយសារអំណាចរបស់វា យើងអាចធ្វើសេចក្តីសញ្ញាដែលអនុញ្ញាតឱ្យយើងមានព្រះវិញ្ញាណបរិសុទ្ធគ្រប់ពេលវេលា។

ទីកន្លែងដែលមនុស្សគ្រប់រូបមានព្រះវិញ្ញាណគង់ជាមួយនឹងពួកគេ នោះយើងអាចរំពឹងទុកចំពោះភាពចុះសម្រុងគ្នា។ ព្រះវិញ្ញាណធ្វើទីបន្ទាល់អំពីសេចក្តីពិតនៅក្នុងជួងចិត្តរបស់យើង រួមជាមួយពួកអ្នកដែលចែកចាយនូវទីបន្ទាល់នោះ។ ព្រះវិញ្ញាណនៃព្រះមិនបណ្តាយឱ្យមានការទាស់ទែងគ្នាកើតឡើងនោះឡើយ (សូមមើល នីហ្វៃទី 3 11:29)។ ព្រះវិញ្ញាណនឹងមិនបណ្តាយឱ្យអារម្មណ៍នៃការបែងចែករវាងមនុស្ស ដែលនាំទៅរកភាពឈ្លោះប្រកែកគ្នាកើតឡើងនោះទេ (សូមមើល Joseph F. Smith, *Gospel Doctrine* ការបោះពុម្ពលើកទី 5 [ឆ្នាំ 1939] ទំព័រ 131)។ ព្រះវិញ្ញាណដឹកនាំទៅរកសេចក្តីសុខសាន្តផ្ទាល់ខ្លួន និងអារម្មណ៍សាមគ្គីភាពជាមួយនឹងអ្នកដទៃ។ ព្រះវិញ្ញាណបង្រួបបង្រួមបុគ្គលគ្រប់រូប។ គ្រួសារមួយ ឬសាសនាចក្រមួយអាចមានសាមគ្គីភាព ឬក៏ពិភពលោកនេះអាចមានសេចក្តីសុខសាន្តទៅបាន គឺអាស្រ័យទៅលើបុគ្គលគ្រប់រូបចេះសាមគ្គីគ្នា។

ការគោរពតាមសេចក្តីសន្យាដែលបានធ្វើឡើងក្នុងការអធិស្ឋានសាក្រាម៉ង់

កុមារម្នាក់ក៏អាចយល់អំពីអ្វីដែលត្រូវធ្វើ ដើម្បីឱ្យមានព្រះវិញ្ញាណជាដៃគូដែរ។ ការអធិស្ឋានសាក្រាម៉ង់បានច្រាប់យើងទាំងអស់គ្នាអំពីបញ្ហានេះ។ យើងឮពាក្យទាំងនោះជារឿងរាល់សប្តាហ៍ នៅពេលយើងចូលរួមការប្រជុំសាក្រាម៉ង់។ នៅក្នុងពេលដ៏ពិសិដ្ឋទាំងនោះ យើងធ្វើសេចក្តីសញ្ញាដែលយើងបានធ្វើនៅពេលបុណ្យជ្រមុជទឹកសារជាថ្មី។ ហើយព្រះអម្ចាស់រំលឹកយើងអំពីសេចក្តីសន្យា ដែលយើងបានធ្វើពេលយើងត្រូវបានបញ្ជាក់ជាសមាជិកនៃសាសនាចក្រ ជាសេចក្តីសន្យាដែលយើងអាចទទួលព្រះវិញ្ញាណបរិសុទ្ធ។ នេះគឺជាការអធិស្ឋានសាក្រាម៉ង់ ៖ “ពួកគេនឹងព្រមលើកដាក់មកលើខ្លួនគេនូវព្រះនាមនៃព្រះរាជបុត្រារបស់ព្រះអង្គ ហើយចងចាំទ្រង់ជានិច្ច ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ដែលទ្រង់បានប្រទានដល់ពួកគេ ប្រយោជន៍ឱ្យពួកគេអាចបានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹងពួកគេជាដរាប” (គ. និង ស. 20:77)។

ដោយគោរពតាមសេចក្តីសញ្ញានេះ យើងនឹងអាចមានព្រះវិញ្ញាណរបស់ទ្រង់។ ទីមួយ យើងសន្យាថានឹងលើកដាក់ព្រះនាមរបស់ទ្រង់មកលើខ្លួនយើង។ នោះមានន័យថា យើងត្រូវប្រណិបត្តិខ្លួនឱ្យដូចជាទ្រង់។ យើងនឹងចាត់ទុកទ្រង់ជាអ្នកដំបូងបង្អស់ក្នុងជីវិតរបស់យើង ។ យើងនឹងចង់បាននូវអ្វីដែលទ្រង់សព្វព្រះទ័យ ជាងអ្វីដែលយើងចង់បាន ឬក៏អ្វីដែលលោកិយបង្រៀនឱ្យយើងចង់បានផងដែរ។ ដរាបណា យើងស្រឡាញ់របស់របរខាងលោកិយខ្លាំងពេក នោះយើងនឹងពុំមានសេចក្តីសុខសាន្តឡើយ។ ការប្រកាន់យកនូវឧត្តមគតិនៃការធ្វើឱ្យមានងាយស្រួលដល់គ្រួសារ ឬដល់ប្រទេសជាតិមួយ តាមរយៈការប្រើប្រាស់សំភារៈ នោះវានឹងបំបែកបំបាក់ពួកគេនៅពេលក្រោយ (សូមមើល Harold B. Lee, *Stand Ye in Holy Places* [ឆ្នាំ 1974], 97)។ តាមធម្មតា ឧត្តមគតិនៃការធ្វើអ្វីដែលព្រះអម្ចាស់សព្វព្រះទ័យឱ្យយើងធ្វើចំពោះគ្នាទៅវិញទៅមក ហើយវាកើតចេញមកពីការលើកដាក់មកលើខ្លួនយើងនូវព្រះនាមទ្រង់នោះ អាចដឹកនាំយើងទៅកាន់កិរិតខាងវិញ្ញាណមួយ ដែលជាផ្នែកមួយនៃស្ថានសួគ៌នៅលើផែនដី។

ទីពីរ យើងសន្យាថាចងចាំទ្រង់ជានិច្ច។ យើងធ្វើដូច្នោះគ្រប់ពេលដែលយើងអធិស្ឋានទៅក្នុងព្រះនាមទ្រង់។ ពិសេសជាងនេះទៅទៀត គឺនៅពេលយើងទូលសុំសំរាប់ការអភ័យទោសពីទ្រង់ យើងរលឹកចាំទ្រង់ ពេលយើងធ្វើយ៉ាងនោះជាញឹកញាប់។ នៅខណៈនោះ យើងរំលឹកចាំការពលិកម្មរបស់ទ្រង់ដែលបានធ្វើការប្រែចិត្ត និងការអភ័យទោសកើតមានឡើង។ ពេលយើងប្តូងស្លឹងនោះយើងនឹងរំលឹកចាំទ្រង់ដែលជាអង្គគាំទ្ររបស់យើងនឹងព្រះវរបិតា។ នៅពេលអារម្មណ៍នៃការអភ័យទោស និងសេចក្តីសុខសាន្តកើតមានឡើង នោះយើងនឹងរំលឹកចាំដល់ការអត់ធ្មត់ និងសេចក្តីស្រឡាញ់ដ៏ស្ថានទីបញ្ចប់របស់ទ្រង់។ ការរំលឹកចាំនោះនឹងបំពេញដួងចិត្តរបស់យើងដោយសេចក្តីស្រឡាញ់។

យើងរក្សាការសន្យារបស់យើងដើម្បីចងចាំទ្រង់ ពេលយើងអធិស្ឋានរួមគ្នា និងពេលយើងអានព្រះគម្ពីរជាក្រុមគ្រួសារផងដែរ។ នៅពេលអធិស្ឋានជាគ្រួសារក្នុងការបរិភោគអាហារពេលព្រឹក កូនម្នាក់អាចអធិស្ឋានសំរាប់អ្នកដទៃ ដោយប្រទានពរថា កិច្ចការទាំងអស់នឹងមានជំណើរការល្អក្នុងការប្រលង ឬនៅក្នុងសកម្មភាពផ្សេងៗនៅថ្ងៃនោះ។ ពេលពរជ័យទាំងនោះកើតមានឡើង កូនដែលត្រូវបានប្រទានពរឱ្យនឹងចងចាំនូវសេចក្តីស្រឡាញ់នាព្រឹកនោះ និងសេចក្តីមេត្តាករុណារបស់អង្គគាំទ្រ ដោយសារការអធិស្ឋាននោះបានធ្វើឡើងក្នុងព្រះនាមទ្រង់។ ដួងចិត្តទាំងឡាយនឹងត្រូវចងភ្ជាប់ដោយសេចក្តីស្រឡាញ់។

យើងរក្សាសេចក្តីសញ្ញារបស់យើងដើម្បីនឹកចាំទ្រង់ នៅគ្រប់ពេលយើងជួបជុំក្រុមគ្រួសារអានព្រះគម្ពីរ។ ព្រះគម្ពីរទាំងនោះធ្វើបន្ទាល់អំពីព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ត្បិតជានិច្ចជាកាល ព្រះគម្ពីរគឺជាសារលិខិតរបស់ពួកព្យាការី។ ទោះបីជាកុមារមិនចាំនូវពាក្យពេចន៍ទាំងនោះក៏ដោយ ក៏ពួកគេនឹងចងចាំថា ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកនិពន្ធដ៏ពិតប្រាកដផងដែរ។

គោរពប្រណិបត្តិរាល់ព្រះបញ្ញត្តិទាំងអស់

ទីបី ពេលយើងទទួលទានសាក្រាម៉ង់ យើងបានសន្យាថានឹងគោរពតាមរាល់ព្រះបញ្ញត្តិរបស់ទ្រង់។ ចំពោះប្រធាន ដេ អ៊ើរបិន ស្លាក ជុញ្ញ័រ នៅពេលគាត់បានធ្វើការអង្វរ—ហើយបានធ្វើវាជាច្រើនលើកច្រើនសារ—សំរាប់សាមគ្គីភាពនៅក្នុងការនិយាយទាសន្ទិសិទ្ធទូទៅមួយ នោះគាត់បានដាស់គ្បើនយើង ឱ្យប្រឆាំងចំពោះការជ្រើសរើសអ្វីដែលយើងនឹងគោរពប្រណិបត្តិតាម។ គាត់បានមានប្រសាសន៍បែបនេះថា ៖ “ព្រះអម្ចាស់មិនបានប្រទានអ្វីដែលគ្មានប្រយោជន៍ ឬគ្មានសារៈសំខាន់ដល់យើងនោះទេ។ ទ្រង់បានបំពេញទៅក្នុងព្រះគម្ពីរទាំងឡាយជាមួយនឹងរឿងជាច្រើនដែលយើងគួរធ្វើ ដើម្បីយើងអាចទទួលបានសេចក្តីសង្គ្រោះ”។

ប្រធាន ស្លាក បានបន្តទៀតថា ៖ “ពេលយើងទទួលទានសាក្រាម៉ង់ គឺយើងធ្វើសេចក្តីសញ្ញាដើម្បីប្រណិបត្តិ ហើយគោរពតាមរាល់ព្រះបញ្ញត្តិរបស់ទ្រង់។ គ្មានករណីលើកលែងនោះទេ។ ហើយវាក៏គ្មានការវែកញែក និងភាពខុសប្លែកគ្នាផងដែរ” (នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1955 ទំព័រ 10–11)។ ប្រធានស្លាក បានបង្រៀនថា នៅពេលយើងប្រែចិត្តនូវរាល់អំពើបាប នោះយើងសន្យាថានឹងគោរពប្រណិបត្តិតាមរាល់ព្រះបញ្ញត្តិ។ យើងគិតថា រឿងនេះគឺជាការពិបាក ប៉ុន្តែវាមានភាពងាយស្រួលណាស់ ដោយយើងគ្រាន់តែចុះចូលជាមួយនឹងសិទ្ធិអំណាចរបស់ព្រះអង្គសង្គ្រោះ ហើយធ្វើការសន្យាថានឹងគោរពប្រណិបត្តិតាមអ្វីមួយដែលទ្រង់បញ្ជា (សូមមើល ម៉ូសាយ 3:19)។ វាជាការចុះញ៉ែមរបស់យើងចំពោះសិទ្ធិអំណាចរបស់ព្រះយេស៊ូវគ្រីស្ទ ដែលនឹងអនុញ្ញាតឱ្យយើងត្រូវបានចងភ្ជាប់ជាក្រុមគ្រួសារ ជាសាសនាចក្រ និងជាកូនចៅរបស់ព្រះវរបិតាសួគ៌នៃយើង។

ព្រះអម្ចាស់បានប្រទានសិទ្ធិអំណាចនោះតាមរយៈព្យាការីរបស់ទ្រង់ទៅដល់អ្នកបំរើដ៏សុភាពរាបសារ។ សេចក្តីដំឡើងនោះបានបង្កៃរការហៅរបស់យើងទៅជាគ្រូបង្រៀនតាមផ្ទះ ឬគ្រូសួរសុខទុក្ខតាមផ្ទះទៅជាការហៅទុកជាមុនមកពីព្រះអម្ចាស់។ យើងទៅធ្វើការទាំងនេះដើម្បីទ្រង់ ស្របទៅតាមបទបញ្ជារបស់ទ្រង់។ មានបុរសសាមញ្ញម្នាក់ និងដៃគូវ័យជំទង់របស់គាត់បានធ្វើដំណើរទៅកាន់ផ្ទះជាច្រើនដោយសង្ឃឹមថា អំណាចពីស្ថានសួគ៌នឹងជួយពួកគេឱ្យគ្រាកដថា ក្រុមគ្រួសារមានទូវសាមគ្គីភាព ហើយថាគ្មានទូវភាពរឹងទទឹង ការកុហក ការពោលបង្កាច់ ឬក៏មានការនិយាយអាក្រក់ឡើយ។ សេចក្តីដំឡើងនោះ—ដែលព្រះអម្ចាស់ហៅពួកអ្នកបំរើ—នឹងជួយយើងឱ្យមិនអើពើរនឹងដែនកំណត់របស់ពួកគេ ពេលពួកគេគិះទៀនយើងដូចដែលគេនឹងធ្វើ។ យើងនឹងឃើញពីចំណងល្អរបស់គេកាន់តែច្បាស់ជាងដែនកំណត់ខាងបុគ្គលរបស់គេ។ យើងប្រហែលជាពុំមានអារម្មណ៍អន់ចិត្ត ហើយបែរជាមានអារម្មណ៍ថ្លែងអំណរគុណចំពោះលោកចៅហ្វាយដែលបានហៅពួកគេ។

សេចក្តីសប្បុរស គឺជាកត្តាចាំបាច់សំរាប់សាមគ្គីភាព

មានព្រះបញ្ញត្តិមួយចំនួនទឹងធ្វើឱ្យមានការបែកបាក់ខាងសាមគ្គីភាព ប្រសិនបើយើងមិនគោរពតាមវានោះទេ។ ព្រះបញ្ញត្តិខ្លះទាក់ទងទៅនឹងអ្វីដែលយើងនិយាយ ហើយខ្លះទៀតទាក់ទិននឹងរប្បេបដែលយើងមានប្រតិកម្មចំពោះអ្វីដែលអ្នកដទៃនិយាយ។ យើងមិនគួរនិយាយបញ្ឆិនរណាម្នាក់នោះឡើយ។ យើងត្រូវតែសម្លឹងមើលចំណុចល្អពីគ្នាទៅវិញទៅមក ហើយនិយាយពាក្យល្អៗទៅកាន់គ្នាទៅវិញទៅមក នៅពេលណាមួយដែលយើងអាចធ្វើបាន (សូមមើល David O. McKay នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1967 ទំព័រ 4–11)។

នៅពេលជាមួយគ្នានេះដែរ យើងត្រូវតែក្រោកឈរប្រឆាំងនឹងអស់អ្នកណាដែលនិយាយប្រមាថដល់វត្ថុពិសិដ្ឋ ពីព្រោះការជះឥទ្ធិពលជាក់លាក់នៃកំហុសនោះគឺប្រមាថដល់ព្រះវិញ្ញាណ ហើយវានឹងបង្កើតឱ្យមានការទាស់ទែងគ្នា និងការភ័ន្តច្រឡំ។ ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល បានបង្ហាញអំពីវិធីដើម្បីក្រោកឈរដោយគ្មានការទាស់ទែងគ្នា ពេលលោកសំរាកនៅឯមន្ទីរពេទ្យមួយ ហើយសុំឱ្យអ្នកបំរើការម្នាក់ ដែលស្ថិតនៅក្នុងភាពមួរម៉ៅបានយកព្រះទាមនៃព្រះអម្ចាស់មកប្រើដោយអាសារឥតការ ដោយមានប្រសាសន៍ថា “សូមមេត្តា! សូមមេត្តាផង! នោះជាព្រះទាមរបស់ព្រះអម្ចាស់ខ្ញុំដែលអ្នកបានដេរប្រមាថនោះ”។ ពេលនោះភាពស្ងប់ស្ងាត់ក៏បានកើតមានឡើង ហើយក្រោយមកមានសម្លេងខ្សឹបមួយបានបន្លឺឡើងថា ៖ ឱ្យខ្ញុំសុំទោស” (*The Teachings of Spencer W. Kimball,* ed. Edward L. Kimball [1982], 198)។ ការទូន្មាន ការស្តីបន្ទោសដោយសេចក្តីស្រឡាញ់អាចជាការអញ្ជើញមួយឱ្យមានសាមគ្គីភាព។ ការបរាជ័យនៅក្នុងការធ្វើកិច្ចការនេះ កាលណាបានបណ្តាលដោយព្រះវិញ្ញាណបរិសុទ្ធនោះ នឹងនាំទៅរកការទាស់ទែងគ្នា។

បើយើងព្រាថ្នាចង់បានសាមគ្គីភាព នោះមានព្រះបញ្ញត្តិជាច្រើនដែលយើងត្រូវតែគោរពតាម ហើយព្រះបញ្ញត្តិទាំងនោះទាក់ទងទៅនឹងអារម្មណ៍របស់យើង។ យើងត្រូវចេះអភ័យទោស ហើយកុំបន្សល់ទុកនូវការព្យាបាទចំពោះពួកអ្នកដែលមើលងាយយើង។ ព្រះអង្គសង្គ្រោះបានធ្វើជាគំរូ នៅពេលទ្រង់ត្រូវបានគេឆ្កាងដោយទ្រង់បានមានបន្ទូលថា ៖ “ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ត្បិតគេមិនដឹងជាគេធ្វើអ្វីទេ” (លូកា 23:34)។ យើងមិនអាចយល់ពីដួងចិត្តរបស់ពួកអ្នកដែលមើលងាយដល់យើងនោះឡើយ។ ហើយយើងក៏មិនដឹងរាល់ប្រភពនៃកំហឹង និងការឈឺចាប់ផ្តាល់ខ្លួនរបស់យើងផងដែរ។ សាវកប៉ុលបានគ្រាប់យើងអំពី

វិធីដើម្បីផ្តល់នូវសេចក្តីស្រឡាញ់ទៅក្នុងពិភពលោកមួយ ដែលពោរពេញទៅដោយមនុស្សគ្មានភាពល្អឥតខ្ចោះ រួមមានទាំងខ្លួនយើងផងដែរ ពេលគាត់និយាយថាៈ “ឯសេចក្តីស្រឡាញ់តែងតែអត់ធ្មត់ ហើយក៏សប្បុរស សេចក្តីស្រឡាញ់មិនចេះឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំដង មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស”(កូរិនថូស ទី1 13:4–5)។ ហើយក្រោយមកគាត់បានផ្តល់នូវការណែនាំជាឧទ្ធរិកមួយ ដែលប្រឆាំងនឹងប្រតិកម្មចំពោះកំហុសរបស់អ្នកដទៃ ហើយភ្លេចចំពោះកំហុសរបស់យើង ពេលគាត់បានសរសេរថាៈ “ឥឡូវនេះ យើងមើលឃើញបែបស្រអាប់ ដូចជាដោយសារកញ្ចក់ តែនៅវេលានោះនឹងមានមុខទល់នឹងមុខ ឥឡូវនេះខ្ញុំស្គាល់មិនទាន់អស់ តែនៅវេលានោះខ្ញុំនឹងស្គាល់វិញដូចជា . . . ព្រះទ្រង់ស្គាល់ខ្ញុំ” (កូរិនថូស1 13:12)។

រស់នៅដោយស្អាតស្អំ ហើយផ្សះផ្សាវាងចេញពីអំនួត

ពាក្យអធិស្ឋានក្នុងសាក្រាម៉ង់អាចជួយរំលឹកកយើងជារៀងរាល់ស្តាហ៍ អំពីរបៀបដែលអំណោយទាននៃសាមគ្គីភាពនឹងកើតមានឡើង តាមរយៈការគោរពប្រណិបត្តិចំពោះច្បាប់ និងពិធីបរិសុទ្ធទានានៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ ពេលយើងរក្សាសេចក្តីសញ្ញារបស់យើង ដោយលើកដាក់ព្រះទ័មទ្រង់មកលើយើង ដើម្បីចងចាំទ្រង់ជានិច្ច ហើយរក្សាទូវរាល់ព្រះបញ្ញត្តិទាំងអស់របស់ទ្រង់ នោះយើងនឹងទទួលបានភាពជាដៃគូនៃព្រះវិញ្ញាណរបស់ទ្រង់។ នោះព្រះវិញ្ញាណនឹងបន្ទន់ដួងចិត្តយើង ហើយធ្វើឱ្យយើងចេះសាមគ្គីគ្នា។ ប៉ុន្តែមានការព្រមានចំនួនពីរ ដែលកើតមានឡើងព្រមគ្នាជាមួយនឹងការសន្យានោះ។

ទីមួយ ព្រះវិញ្ញាណបរិសុទ្ធនឹងគង់នៅជាមួយយើង ប្រសិនបើយើងរស់នៅដោយស្អាតស្អំ ហើយផ្សះផ្សាពីសេចក្តីស្រឡាញ់ទៅលើទ្រព្យសម្បត្តិខាងលោកិយ។ ការជ្រើសរើសដែលគ្មានភាពស្អាតស្អំនឹងរុញច្រានព្រះវិញ្ញាណបរិសុទ្ធឱ្យចាកចេញ។ ព្រះវិញ្ញាណគង់នៅតែជាមួយអ្នកដែលជ្រើសរើសយកព្រះអម្ចាស់ជាជាងលោកិយប៉ុណ្ណោះ។ “ចូរញែកខ្លួនចេញឱ្យស្អាតចុះ”(ទីក្បែទី 3 20:41 គ. និង ស. 38:42) ហើយអ្នកត្រូវស្រឡាញ់ដល់ព្រះឱ្យអស់ពី “ចិត្តនៃអ្នក . . . អស់ពីពលំអស់ពីគំនិត ហើយអស់ពីកម្លាំងនៃអ្នក” (គ. និង ស. 59:5) ពុំមែនជាការផ្តល់នូវយោបល់នោះទេ ប៉ុន្តែជាព្រះបញ្ញត្តិ។ ហើយវាគឺជាការចាំបាច់ខ្លាំងណាស់សំរាប់ភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ បើគ្មានភាពស្អាតស្អំនោះទេ យើងមិនអាចប្រែក្លាយទៅជាមនុស្សតែមួយបានឡើយ។

ការព្រមានផ្សេងទៀត គឺត្រូវផ្សះផ្សាវាងចេញពីភាពអំនួត។ សាមគ្គីភាពដែលកើតមានឡើងចំពោះគ្រួសារ ឬមនុស្សមួយក្រុមដែលបានធ្វើឱ្យមានភាពទន់ភ្លន់ដោយព្រះវិញ្ញាណ នោះទឹងទាំមកនូវអំណាចដ៏អស្ចារ្យ។ ជាមួយនឹងអំណាចនោះ វានឹងធ្វើឱ្យការទទួលស្គាល់ពីសំណាក់ពិភពលោកកើតមានឡើង។ មិនថាការទទួលស្គាល់នោះទាំមកនូវការកោតសរសើរ ឬការច្រណែនឈ្នានីសនោះទេ តែវាអាចទាំយើងទៅរកភាពអំនួត។ ការធ្វើរបៀបនោះប្រមាថដល់ព្រះវិញ្ញាណ។ វាមានន័យការការពារប្រឆាំងនឹងភាពអំនួតដែលជាប្រភពពិតនៃការបែកបាក់សាមគ្គីភាព។ វាធ្វើឱ្យឃើញអំពីសេចក្តីល្អដែលព្រះចាក់មកលើយើង ដែលវាមិនត្រាន់តែជាស្នាមនៃព្រះហស្តទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែវាជាឱកាសដើម្បីរួបរួមគ្នាជាមួយនឹងមនុស្សដែលនៅជុំវិញយើងក្នុងការបំរើដ៏អស្ចារ្យបំផុត។ មានបុរសម្នាក់ ហើយនឹងភរិយាគាត់បានរៀនធ្វើជាមនុស្សតែមួយដោយប្រើប្រាស់ភាពស្រដៀងគ្នា ដើម្បីយល់ពីគ្នាទៅវិញទៅមក និងពីភាពខុសប្លែករបស់ពួកគេ ដើម្បីត្រិះរិះទៅក្នុងការបំរើគ្នាទៅវិញទៅមក និងពួកអ្នកដែលនៅជុំវិញខ្លួន។ នៅក្នុងរបៀបដូចគ្នានេះ យើងអាចមានសាមគ្គីភាពជាមួយពួកអ្នកដែលមិនទទួលស្គាល់គោលលទ្ធិរបស់យើង ដោយចែកចាយនូវចេតនាល្អរបស់យើង ដើម្បីប្រទានពរដល់កូនចៅនៃព្រះវរបិតាសួគ៌យើង។

យើងអាចក្លាយជាអ្នកផ្សះផ្សាគេ ដែលសក្តិសមទឹងហៅឱ្យប្រទានពរ និងជាកូនរបស់ព្រះ (សូមមើលម៉ាថាយ 5:9)។

ព្រះជាព្រះវរបិតាយើងមានព្រះជន្មរស់នៅ។ ព្រះរាជបុត្រាជាទីស្រឡាញ់របស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ គឺជាអ្នកដឹកនៃសាសនាចក្រនេះ ហើយទ្រង់ផ្តល់ទង់នៃសេចក្តីសុខសាន្តដល់អស់អ្នកដែលទឹងទទួលយកសាសនាចក្រនេះ។

ដកស្រង់ចេញពីសុន្ទរកថារបស់អែលឌើរ អារ៉ារិង នៅក្នុងសន្និសីទទូទៅនៃសាសនាចក្រ ខែ មេសា ឆ្នាំ 1998 (មើល Conference Report ខែ មេសា ឆ្នាំ 1998 ទំព័រ 85–89 ឬ *Ensign* ខែ ឧសភា ឆ្នាំ 1998 ទំព័រ 66–68)។

ការចិញ្ចឹមបីបាច់សេចក្តីស្រឡាញ់ និង ចំណងមិត្តភាពនៅក្នុងអាពាហ៍ពិពាហ៍ 3

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលះទេសះរបស់អ្នកផ្ទាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- សូមសិក្សា មរ៉ូណៃ 7:45–48។ សូមធ្វើតារាងស្តីអំពីចរិកលក្ខណះនៃសេចក្តីសប្បុរសដែលមាននៅក្នុងខគម្ពីរនេះ។ សូមធ្វើការតាំងចិត្ត មួយដើម្បីអភិវឌ្ឍន៍ចរិកលក្ខណះទាំងនេះនៅក្នុងជីវិតអ្នក។ សូមពិចារណាអំពីរបៀបដែលចរិកលក្ខណះទាំងនេះអាចជួយស្វាមី និងភរិយាឱ្យចិញ្ចឹមបីបាច់សេចក្តីស្រឡាញ់ និងចំណងមិត្តភាពរបស់គេ។
- សូមធ្វើផែនការមួយ ដើម្បីចំណាយពេលនៅជាមួយគ្នាតែពីរនាក់ជារៀងរាល់សប្តាហ៍ ជាមួយនឹងស្វាមី ឬភរិយារបស់អ្នក។ អ្នកគួររៀបចំកាលវិភាគទាំងនេះ ដោយសរសេរវានៅលើប្រតិទិន ឬក៏សៀវភៅសរសេរ។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

ភាពតែមួយនៅក្នុងអាពាហ៍ពិពាហ៍

ប្រធាន ស្តែនស៊ើរ ដបុលយូ ឃឹមបឹល
ប្រធានទី 12 នៃសាសនាចក្រ

អាពាហ៍ពិពាហ៍ដ៏មានកិត្តិយស ពោរពេញដោយក្តីរីករាយ ហើយមានជោគជ័យគឺជាគោលដៅដ៏សំខាន់របស់មនុស្សគ្រប់រូប។ អាពាហ៍ពិពាហ៍ គឺអាចនិយាយបានថាជាការសំរេចចិត្តដ៏សំខាន់បំផុតនៅក្នុងចំណោមការសំរេចចិត្តទាំងអស់ ហើយឥទ្ធិពលរបស់វាគឺមានរយះពេលយូរអង្វែង ត្បិតវាពុំមែនជាប់ទាក់ទិនតែសុភមង្គលបច្ចុប្បន្ននេះប៉ុណ្ណោះនោះទេ ប៉ុន្តែវាជាប់ទាក់ទិននឹងសុភមង្គលដ៏នៅអស់កល្បជានិច្ច។ វាជះឥទ្ធិពលមិនត្រឹមតែមនុស្សពីរនាក់ដែលពាក់ព័ន្ធប៉ុណ្ណោះនោះទេ ប៉ុន្តែក្រុមគ្រួសារគេ និងជាពិសេសកូនចៅរបស់គេរហូតដល់ប៉ុន្មានជំនាន់ក្រោយទៀតក៏ទទួលឥទ្ធិពលនេះផងដែរ។

នៅក្នុងការជ្រើសរើសដៃគូសំរាប់ជីវិតនេះ និងសំរាប់ភាពដ៏នៅអស់កល្បជានិច្ចប្រាកដណាស់គឺវាត្រូវមានផែនការ ការគិតពិចារណាដោយប្រុងប្រយ័ត្ន រួមផ្សំទាំងការអធិស្ឋាន និងការតមអាហារផងដែរ ដើម្បីប្រាកដថារាល់ការសំរេចចិត្តទាំងអស់ការសំរេចចិត្តមួយនេះពុំមែនជាការសំរេចចិត្តខុសនោះទេ។ អាពាហ៍ពិពាហ៍ដ៏ពិតប្រាកដត្រូវមានសាមគ្គីភាព ទាំងគំនិត និងដួងចិត្ត។ មនោសញ្ចេតនាមិនគួររាប់បញ្ចូលថាជាការសំរេចចិត្តនោះទេ ផ្ទុយទៅវិញវាគឺជាគំនិត និងដួងចិត្តដែលបានទទួលការពង្រឹង តាមរយះតមអាហារ និងការអធិស្ឋាន ហើយរួមជាមួយនឹងការគិតពិចារណាដ៏ល្អិតល្អន់ ហើយវានឹងផ្តល់ឱ្យបុគ្គលម្នាក់នូវឱកាសនៃសុភមង្គលដ៏ធំធេងនៅក្នុងអាពាហ៍ពិពាហ៍។ វានាំមកនូវការពលិកម្ម ការចែកចាយ និងតំរូវការចំពោះភាពមិនកំណាញ់។

កម្មវិធីទូរទស្សន៍ និងរឿងប្រលោមលោកបានធ្វើសេចក្តីបញ្ចប់ចំពោះអាពាហ៍ពិពាហ៍ថា ៖ “ក្រោយមកពួកគេបានរស់នៅដោយរីករាយ ជារៀងរហូត”។ យើងបានដឹងថា ដោយគ្រាន់តែធ្វើពិធីការតែម្យ៉ាងនោះ នឹងមិនធ្វើឱ្យសុភមង្គល និងអាពាហ៍ពិពាហ៍ដ៏ជោគជ័យកើតឡើងឡើយ។ សុភមង្គលមិនមែនកើតឡើងដោយការចុចកុងតាក់ ដូចជាភ្លើងអគ្គីសនីនោះទេ សុភមង្គលគឺជាស្ថានភាពនៃគំនិត ហើយវាកើតចេញពីខាងក្នុងមក។ វាទាមទារឱ្យមានការស្វែងរក។ វាមិនអាចទិញដូរដោយប្រាក់ ហើយវាក៏មិនអាចត្រូវកើតឡើងដោយមិនបានធ្វើអ្វីសោះនោះដែរ។

មានមនុស្សមួយចំនួនបានគិតថា សុភមង្គលគឺជាជីវិតដ៏ស្រស់បំព្រងនៃភាពសុខស្រួល ភាពធើតធាយ និងការរំភើបចិត្តជាដរាប ប៉ុន្តែអាពាហ៍ពិពាហ៍ពិតពឹងផ្អែកទៅលើសុភមង្គលដែលច្រើនជាងនោះទៅទៀត គឺវាកើតចេញមកពីការផ្តល់ឱ្យ ការបំរើ ការចែកចាយ ការពលិកម្ម និងភាពមិនអត្មានិយម។

មានមនុស្សពីរនាក់ចេញមកពីមជ្ឈដ្ឋានខុសគ្នា បានរៀនយ៉ាងឆាប់រហ័សក្រោយពីពិធីមង្គលការមួយត្រូវបានធ្វើឡើង ដោយបានសម្លឹងមើលទៅជីវិតពិតដែលនឹងត្រូវប្រឈមមុខ។ គ្មានជីវិតនៃការររើរវាយ ឬក៏ជីវិតនៃប្រឌិតនោះទេ យើងត្រូវតែចាកចេញពីភាពអាប់អួរនោះ ហើយឈរយ៉ាងរឹងមាំនៅលើផែនដី។ ការទទួលខុសត្រូវតប្បីត្រូវបានបញ្ជាក់ ហើយកាតព្វកិច្ចថ្មីត្រូវតែទទួលយក។ សេរីភាពផ្ទាល់ខ្លួនមួយចំនួនត្រូវតែលះបង់ ហើយការកែតំរូវដ៏ស្មោះត្រង់ជាច្រើនត្រូវតែធ្វើឱ្យកើតមានឡើង។

មនុស្សម្នាក់នឹងដឹងមួយរំពេចក្រោយពីអាពាហ៍ពិពាហ៍ថា ស្វាមី ឬភរិយារបស់ខ្លួនមានភាពទន់ខ្សោយដែលខ្លួនមិនបានដឹង ឬមិនបានរកឃើញពីមុនមក។ គុណធម៌ដែលជានិច្ចកាលត្រូវបានលើកតំកើងនៅក្នុងការចែចង់ ឥឡូវនេះកាន់តែមានតិចទៅៗ រីឯភាពទន់ខ្សោយដែលមើលទៅហាក់ដូចជាតូច ហើយមិនសំខាន់ក្នុងការចែចង់ ឥឡូវនេះកាន់តែរីកធំទៅៗ។ ពេលវេលាសំរាប់ការយល់ចិត្ត ការវាយតម្លៃផ្ទាល់ខ្លួន និងសំរាប់អត្តន័យរួមល្អ ការសួររកហេតុផល និងការគ្រោងផែនការបានមកដល់ហើយ។ ទម្លាប់ដែលមានជាច្រើនឆ្នាំមកហើយ ឥឡូវនេះវាបានប្រាកដខ្លួនឡើងថា ស្វាមី ឬភរិយាអាចជាមនុស្សកំណាញ់ ឬខ្ជះខ្ជាយ ខ្ជិលច្រអូស ឬជាមនុស្សឧស្សាហ៍ ជាមនុស្សជឿលើសាសនា ឬមិនជឿ គាត់អាចមានចិត្តល្អ ហើយចេះជួយទុក្ខធុរះ គាត់អាចជាមនុស្សដែលឆាប់ច្រឡោត ឬក៏ចិត្តស្រាល កាចឬ ចេះធ្វើទាន អំនួត ឬខ្វះការទុកចិត្តលើខ្លួនឯង។ បញ្ហាខាងសាច់ថ្លៃបានកើតឡើងកាន់តែខិតជិតដល់ចំនុចដែលគួរឱ្យផ្តោតអារម្មណ៍ ហើយចំណងទាក់ទងរបស់ស្វាមី ឬភរិយាចំពោះបញ្ហានេះគឺត្រូវបានរីកធំឡើង។

ជាញឹកញាប់ ការគ្មានឆន្ទៈដើម្បីធ្វើឱ្យមានភាពធូរស្រាល និងដើម្បីគិតអំពីការទទួលខុសត្រូវដ៏ធ្ងន់ធ្ងរតែងតែកើតមានឡើង។ ភាពមានបានគឺពិបាកជំនួសដោយការរស់នៅខ្ចះខាត ហើយជាញឹកញាប់ យុវវ័យដូចជាស្រេកឃ្លានយ៉ាងខ្លាំង "ចំពោះចង់បានរបស់របរដូចអ្នកជិតខាងរបស់ខ្លួន"។ ជាញឹកញាប់ ការបដិសេធចំពោះការកែសំរួលខាងហិរញ្ញវត្ថុបានកើតមានឡើង។ ជាញឹកញាប់ ភរិយាវ័យក្មេងបានទាមទារឱ្យមានភាពឆើតឆាយដ៏សប្បាយរីករាយកើតមាននៅក្នុងគេហដ្ឋានរបស់ខ្លួនឱ្យដូចជាវាបានកើតឡើងនៅក្នុងគេហដ្ឋានដ៏ថ្កុំថ្កើងរបស់ឱពុកខ្លួនដូច្នោះដែរ។ ខ្លះទៀតពិតជាយល់ព្រមទទួលយកការរស់នៅខ្ចះខាតនោះ ដោយបន្តធ្វើការងារក្រោយពីការរៀបអាពាហ៍ពិពាហ៍។ ហេតុដូច្នេះហើយពួកគេបានចាកចេញពីផ្ទះ គឺជាទីន្លែងដែលត្រូវការវត្តមានរបស់ពួកគេ ដើម្បីស្វែងរកអាជីព ឬក៏ប្រកបមុខជំនួញ ដូចនេះការបង្កើតប្រព័ន្ធខាងហិរញ្ញវត្ថុក្នុងក្រុមគ្រួសារឱ្យមានស្ថេរភាព វាជាការលំបាកបំផុត ដើម្បីបានផលប្រយោជន៍ឆ្ពោះទៅកាន់ជីវិតគ្រួសារសាមញ្ញមួយ។ តាមរយៈការធ្វើការងាររបស់ស្វាមី ឬភរិយាទាំងពីររូប នោះការប្រកួតប្រជែងបានកើតមានឡើងនៅក្នុងក្រុមគ្រួសារ ហើយវាពុំមែនជាការរួបរួមគ្នាឡើយ។ និយោជិកដ៏ទៀយហត់ទាំងពីរនាក់នេះ បានត្រលប់មកគេហដ្ឋានវិញជាមួយនឹងការតឹងសរសៃករ អំនួតរៀងខ្លួន កំណើននៃភាពម្ចាស់ការ បន្ទាប់មកការយល់ច្រលំក៏កើតមានឡើង។ ការខ្វែងគំនិតគ្នាបន្តិចបន្តួចបានរីកជាបញ្ហាកាន់តែធំឡើងៗ។

ខណៈដែលអាពាហ៍ពិពាហ៍មានការលំបាក ហើយភាពមិនចុះសំរុង និងភាពស្មុគស្មាញនៅក្នុងអាពាហ៍ពិពាហ៍បានក្លាយទៅជារឿងទូទៅក៏ដោយនោះ ក៏សុភមង្គលពិត និងគ្មានទីបញ្ចប់នៅតែកើតមាន ហើយអាពាហ៍ពិពាហ៍អាចមានសេចក្តីអំណរនៅក្នុងអាពាហ៍ពិពាហ៍កាន់តែមានច្រើនឡើង ច្រើនជាងគំនិតមនុស្សអាចគិតស្មានដល់ទៅទៀត។ គូស្វាមីភរិយា និងបុគ្គលគ្រប់រូបអាចស្វែងរកសុភមង្គលនេះបាន។ "គូនិស្សីយ" គឺជាការរឿងប្រឌិត និងជារឿងភ័ន្តច្រឡំ ខណៈដែលយុវជនយុវនារីគ្រប់រូបព្យាយាមស្វែងរក ហើយខិតខំអធិស្ឋានដើម្បីស្វែងរកដៃគូដែលមាននិស្សីយ និងចិត្តគំនិតដូចគ្នានោះ ប៉ុន្តែការពិតជាក់ស្តែងគឺថាមនុស្សប្រុស និងមនុស្សស្រីដ៏ល្អគ្រប់រូបអាចទទួលបានសុភមង្គល ហើយមានអាពាហ៍ពិពាហ៍ដ៏ជោគជ័យមួយបាន ប្រសិនបើពួកគេទាំងពីរស្ម័គ្រចិត្តធ្វើការខិតខំជាមួយនឹងគ្នា។

រូបមន្តដែលពុំធ្លាប់មានការបរាជ័យគឺមាន ដើម្បីធ្វើការធានាអះអាងចំពោះគូស្វាមីភរិយាគ្រប់រូប សំរាប់ការទទួលបានអាពាហ៍ពិពាហ៍ដ៏រីករាយ និងដ៏នៅអស់កល្បជានិច្ចនោះ ប៉ុន្តែរូបមន្តនេះក៏ដូចជារូបមន្តទាំងអស់ផ្សេងទៀតផងដែរ គឺថាគ្រឿងផ្សំដ៏សំខាន់មិនត្រូវបានគេទុកចោល កាត់បន្ថយ ឬក៏កំនត់ ព្រំដែននោះទេ។ ការជ្រើសរើសពីមុនសេពគប់ ហើយក្រោយមកបន្តសេពគប់បន្ទាប់ពីដំណើរការអាពាហ៍ពិពាហ៍គឺសំខាន់ដូចគ្នា ប៉ុន្តែមិនសំខាន់ជាងអាពាហ៍ពិពាហ៍នោះទេ ជោគជ័យគឺផ្អែកទៅលើបុគ្គលទាំងពីរនាក់—គឺវាមិនស្ថិតនៅលើបុគ្គលតែម្នាក់នោះទេ ប៉ុន្តែវាស្ថិតនៅលើបុគ្គលទាំងពីររូបនេះឯង។

អាពាហ៍ពិពាហ៍មួយដែលត្រូវបានចាប់ផ្តើមឡើង ហើយបានអាស្រ័យទៅលើបទដ្ឋានសមហេតុផលដូចដែលបានបញ្ជាក់រួចមកហើយ នោះគ្មានអំណាចប្រមូលផ្ទុំណាមួយអាចបំផ្លាញអាពាហ៍ពិពាហ៍នេះបានឡើយ លើកលែងតែអំណាចដែលស្ថិតនៅក្នុងខ្លួនរបស់ពួកគេទាំងពីរនាក់តែប៉ុណ្ណោះ ឬក៏ស្វាមី ឬភរិយាទាំងពីរនាក់នេះឯង ហើយពួកគេត្រូវតែអះអាងនភាពទទួលខុសត្រូវជាទូទៅ។ មនុស្ស និងភ្នាក់ងារដទៃទៀតអាចមានឥទ្ធិពលចំពោះការល្អ ឬការអាក្រក់។ ហិរញ្ញវត្ថុ សង្គមកិច្ច នយោបាយ និងស្ថានភាពដទៃទៀតអាចមើលទៅហាក់ដូចជាបញ្ហាចោទមួយ ប៉ុន្តែជាដំបូងបង្អស់ និងជានិច្ចកាល អាពាហ៍ពិពាហ៍គឺអាស្រ័យទៅលើស្វាមី ឬភរិយាទាំងពីរនាក់ គឺជាអ្នកដែលអាចធ្វើឱ្យអាពាហ៍ពិពាហ៍របស់ពួកគេមានជោគជ័យ ហើយរីករាយជានិច្ចបាន ប្រសិនបើពួកគេមានការប្តេជ្ញាចិត្ត មានភាពមិនកំណាញ់ និងមានសេចក្តីសុចរិត។

រូបមន្តគឺសាមញ្ញ រីឯគ្រឿងផ្សំក៏មានតិចតួច ទោះជាយ៉ាងណាក៏ដោយ ក៏មានការអធិប្បាយជាច្រើនស្តីអំពីគ្រឿងផ្សំនីមួយៗផងដែរ។

ទីមួយ ត្រូវមានការចាប់ផ្តើមដ៏ត្រឹមត្រូវឆ្ពោះទៅកាន់អាពាហ៍ពិពាហ៍ វាគឺជាការចាប់ផ្តើមដែលគិតពិចារណាពីការជ្រើសយកគូស្រករ ជាអ្នកដែលអាចឈោងចាប់កំពូល នៃភាពល្អឥតខ្ចោះនៅគ្រប់កាលះទេសៈទាំងអស់ ដែលវាគឺជំណើរដ៏សំខាន់សំរាប់បុគ្គលគ្រប់រូប។ ហើយបន្ទាប់មក ភាគីទាំងពីរត្រូវតែមកកាន់ទីអាសនៈក្នុងព្រះវិហារបរិសុទ្ធដោយដឹងថា ពួកគេត្រូវខិតខំឆ្ពោះទៅរកការរួមរស់នឹងគ្នាដ៏មានជោគជ័យនេះ។

ទីពីរ មិនត្រូវគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនពេកនោះទេ ដោយបំភ្លេចខ្លួនឯង និងដោយដឹកនាំនូវរាល់ការរស់នៅជាគ្រួសារ និងរាល់ការទាក់ទងចំពោះការល្អនៃគ្រួសារដោយយកឈ្នះលើចិត្តកំណាញ់។

ទីបី ការលួងលោម និងការបង្ហាញសេចក្តីស្រឡាញ់ សេចក្តីមេត្តាករុណា ហើយនិងការគិតពិចារណាត្រូវតែមានជាបន្តបន្ទាប់ ដើម្បីរក្សាសេចក្តីស្រឡាញ់ឱ្យមានជីវិត និងរីកដុះដាលឡើង។

ទីបួន ត្រូវមានការរស់នៅដ៏ពេញលេញមួយ ស្របទៅតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ដូចដែលបានចែងនៅក្នុងដំណឹងល្អរបស់ព្រះយេស៊ូវ គ្រីស្ទ។

ដោយសារការដាក់គ្រឿងផ្សំទាំងនេះបញ្ចូលគ្នាឱ្យបានត្រឹមត្រូវ ហើយធ្វើការអនុវត្តន៍វាជាបន្តបន្ទាប់ នោះភាពអពមង្គល ការយល់ខុស ឬការបែកបាក់កំរនឹងកើតឡើងណាស់។ មេធាវីទទួលបន្ទុកផ្នែកការលះលែងគ្នានឹងត្រូវផ្លាស់ប្តូរមុខជំនាញ ហើយតុលាការទទួលបន្ទុករឿងក្តីលះលែងគ្នានឹងត្រូវបិទចោលផងដែរ។

បុគ្គលទាំងពីររូបដែលជិតនឹងរៀបអាពាហ៍ពិពាហ៍នៅចំពោះមុខអាសនៈត្រូវតែដឹងថា ដើម្បីទទួលបានអាពាហ៍ពិពាហ៍ដ៏រីករាយ ដែលខ្លួនបានរំពឹងទុកនោះ គឺពួកគេត្រូវតែយល់ថា ការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់តែម្យ៉ាងមិនបានថែរក្សា ឬក៏ឃុំគ្រងរាល់ការសំរេចចិត្តនានាដែលទាក់ទងទៅនឹងអាពាហ៍ពិពាហ៍នោះទេ ប៉ុន្តែវាចង់មានន័យទៅលើការលះបង់ ការចែករំលែក និងកាត់ការបន្ថយសេរីភាពផ្ទាល់ខ្លួនមួយចំនួនផងដែរ។ វាគឺចង់មានន័យទៅលើការសន្សំសំចៃដ៏លំបាក ហើយយូរអង្វែង។ វាចង់ផ្តោតទៅលើកូនៗដែលបង្កើនបន្ទុកផ្នែកហិរញ្ញវត្ថុ ការបំរើ ការបីបាច់ថែរក្សា និងការព្រួយបារម្ភដល់ពួកគេ ប៉ុន្តែវាក៏ជាមនោសញ្ចេតនាដ៏ជ្រាលជ្រៅ ហើយផ្អែមល្ហែមបំផុតជាងអ្វីៗទាំងអស់ផងដែរ។

មុនពេលរៀបអាពាហ៍ពិពាហ៍ បុគ្គលម្នាក់ៗគឺពិតជាមានសេរីភាពក្នុងការដើរហើរតាមចិត្តចង់ មានសេរីភាពនៅក្នុងការរៀបចំ និងដាក់ផែនការសំរាប់ជីវិតតាមតែខ្លួនគិតឃើញថាល្អ ហើយក៏មានសេរីភាពធ្វើការសំរេចចិត្តគ្រប់យ៉ាងដោយខ្លួនឯងផងដែរ។ គូស្នេហ៍គ្រប់រូបគប្បីយល់ដឹងពីមុនពេលពួកគេធ្វើការសច្ចាដែលបុគ្គលម្នាក់ៗត្រូវទទួលយល់ព្រមថា សេចក្តីល្អនៃគ្រួសារតូចថ្មីមួយនេះត្រូវមានលក្ខណៈប្រសើរជាងសេចក្តីល្អរបស់ស្វាមី ឬភរិយាជានិច្ច។ បុគ្គលម្នាក់ៗត្រូវតែលុបបំបាត់ចោលនូវពាក្យថា "ខ្ញុំ" និង "របស់ខ្ញុំ" ប៉ុន្តែត្រូវជំនួសដោយពាក្យថា

“យើង” និង “របស់យើង” វិញ។ រាល់ការសំរេចចិត្តនិមួយៗត្រូវតែមានការគិតពិចារណាថា នឹងមានមនុស្សពីរនាក់ ឬច្រើននាក់ដែលត្រូវទទួលឥទ្ធិពលដោយសារការសំរេចចិត្តនោះ។ នៅពេលដែលនារីជាភរិយារៀបនឹងធ្វើការសំរេចចិត្តធំៗក្នុងពេលនេះ នោះនាងនឹងមានការគិតគូរចំពោះឥទ្ធិពល ដែលនឹងប៉ះពាល់ដល់ឪពុកម្តាយ កូនចៅ គេហដ្ឋាន និងជីវិតខាងវិញ្ញាណរបស់ពួកគេ។ ការជ្រើសរើសអាជីពរបស់ស្វាមី ជីវិតនៅក្នុងសង្គម មិត្តភក្តិ និងរាល់ចំណង់ចំណូលចិត្តរបស់គាត់ឥឡូវនេះត្រូវតែមានការគិតពិចារណាឱ្យវែងឆ្ងាយថា គាត់ជាផ្នែក ហើយថាគាត់ត្រូវគិតពីរឿងសមូហភាពជាធំ។

ជានិច្ចកាល ការរៀបអាពាហ៍ពិពាហ៍មិនអាចប្រព្រឹត្តទៅដោយរលូន ហើយគ្មានការលំបាកនោះទេ ប៉ុន្តែវាក៏អាចជាសេចក្តីសុខសាន្តដ៏អស្ចារ្យមួយផងដែរ។ ស្វាមីឬភរិយាអាចនឹងជួបប្រទះនូវការខ្វះខាត ជម្ងឺ ការខកចិត្ត ការបរាជ័យ ព្រមទាំងមរណភាពនៅក្នុងក្រុមគ្រួសារផងដែរ ប៉ុន្តែការណ៍អស់ទាំងនេះនឹងមិនដកយកសេចក្តីសុខសាន្តចេញពីពួកគេនោះឡើយ។ អាពាហ៍ពិពាហ៍អាចទទួលជោគជ័យទៅបាន ដរាបណាភាពអាត្មានិយមពុំអាចជ្រាតចូលទៅក្នុងដួងចិត្តរបស់ស្វាមីឬភរិយាទាំងពីររូប។ ភាពវឹកវរ ហើយនិងបញ្ហានានានឹងធ្វើឪពុកម្តាយកាន់តែមានភាពស្អិតរមួត ទៅជាសាមគ្គីភាពមួយដែលមិនអាចបំបែកបាន ប្រសិនបើនៅក្នុងដួងចិត្តរបស់ពួកគេទាំងពីរគ្មានភាពអាត្មានិយម។ នៅក្នុងវិបត្តិសេដ្ឋកិច្ចនាឆ្នាំ 1930 នោះអាត្រានៃការលះលែងគ្នាបានធ្លាក់ចុះយ៉ាងខ្លាំង។ ការខ្វះខាត ការបរាជ័យ ការខកចិត្ត—បានរឹតចំណងសាមគ្គីរវាងឪពុកម្តាយ។ ទុក្ខលំបាកអាចផ្សាភ្ជាប់ទំនាក់ទំនងទាំងឡាយដែលភាពរីកចំរើនអាចបំផ្លាញចោលបាន។

អាពាហ៍ពិពាហ៍ដែលអាស្រ័យនៅលើភាពអាត្មានិយម គឺភាគច្រើនទទួលបរាជ័យយ៉ាងពិតប្រាកដ។ បុគ្គលដែលរៀបអាពាហ៍ពិពាហ៍ដើម្បីទ្រព្យសម្បត្តិ ឬក៏បុគ្គលដែលរៀបអាពាហ៍ពិពាហ៍ដើម្បីកិត្យានុភាព ឬឋានៈក្នុងសង្គម គឺនឹងមានទូវការខកចិត្តយ៉ាងពិតប្រាកដ។ បុគ្គលដែលរៀបអាពាហ៍ពិពាហ៍ដើម្បីបំពេញចិត្តភាពកោងកាច និងភាពអំនួត ឬបុគ្គលដែលរៀបអាពាហ៍ពិពាហ៍ដើម្បីសេចក្តីក្រោធ ឬបញ្ញឹមនុស្សម្នាក់ផ្សេងទៀត គឺកំពុងតែបោកប្រាស់ខ្លួនឯងប៉ុណ្ណោះ។ ប៉ុន្តែ បុគ្គលដែលរៀបអាពាពិពាហ៍ដើម្បីផ្តល់នូវសុភមង្គល ក៏ដូចជាទទួលសុភមង្គលនោះមកវិញ ឬក៏បុគ្គលដែលរៀបអាពាហ៍ពិពាហ៍ដើម្បីផ្តល់នូវការបំរើ ក៏ដូចជាទទួលការបំរើនោះមកវិញ និងបុគ្គលដែលថែរក្សាផលប្រយោជន៍សំរាប់ភាគីទាំងពីរ នោះក្រុមគ្រួសារដែលកើតមានឡើងនឹងទទួលបានឱកាសដ៏ល្អមួយ ដែលធ្វើឱ្យការរៀបអាពាហ៍ពិពាហ៍របស់ពួកគេនឹងក្លាយទៅជាអាពាហ៍ពិពាហ៍ដ៏រីករាយមួយ។

សេចក្តីស្រឡាញ់គឺប្រៀបបាននឹងបុប្ផមួយទង ហើយក៏ដូចជារូបកាយផងដែរ គឺវាត្រូវការការបំប៉នជាប្រចាំ។ រូបកាយរមែងស្លាប់នេះនឹងត្រូវស្គមរីងរៃ៉យ៉ាងឆាប់រហ័ស ហើយក៏ស្លាប់ទៅ បើគ្មានការបំប៉នឱ្យបានញឹកញាប់នោះទេ។ បុប្ផដែលនៅតូចនឹងត្រូវក្រៀមស្ងិត ដោយគ្មានជីវជាតិ និងទឹក។ ហេតុដូច្នេះ សេចក្តីស្រឡាញ់ក៏មិនអាចរំពឹងទុកថានឹងនៅជានិរន្តរ៍ដែរ លើកលែងតែសេចក្តីស្រឡាញ់ត្រូវបានបំប៉នជាបន្តបន្ទាប់ ដោយចំណែកនៃសេចក្តីស្រឡាញ់ដែលជាការបង្ហាញនៃការគោរព និងការស្ងោចសរសើរ ការបង្ហាញនូវការដឹងគុណ និងការចេះគិតពិចារណាដោយមិនអត្មានិយម។

ភាពមិនអាត្មានិយមទាំងស្រុង គឺបង្ហាញយ៉ាងច្បាស់នូវការសំរេចបានកត្តាមួយផ្សេងទៀត នៅក្នុងអាពាហ៍ពិពាហ៍ដ៏ជោគជ័យ។ ប្រសិនបើបុគ្គលម្នាក់ស្វែងរកចំណាប់អារម្មណ៍ ការលួងលោម ហើយនិងសុភមង្គលរបស់អ្នកផ្សេងទៀតជារៀងរហូត នោះសេចក្តីស្រឡាញ់នៅគ្រាដំបូង និងសេចក្តីស្នេហាដែលត្រូវបានពង្រឹងនៅក្នុងអាពាហ៍ពាហ៍ នឹងរីកដុះដាលកាន់តែធំទៅៗ។ គូស្វាមីភរិយាជាច្រើនបានបណ្តោយឱ្យអាពាហ៍ពិពាហ៍របស់ខ្លួន ប្រែក្លាយទៅជាមានភាពពុករលួយ ហើយបណ្តោយឱ្យសេចក្តីស្រឡាញ់របស់ខ្លួនកករឹងដូចជានំប៉ុងចាស់ ឬដូចជាឆាកកំប្លែងចាស់រិចរិល ឬក៏ទឹកស្រូបអាហារដ៏ត្រជាក់។ ជាការពិតណាស់ ម្ហូបអាហារដ៏សំខាន់បំផុតសំរាប់សេចក្តីស្រឡាញ់គឺ ការយកចិត្តទុកដាក់ សណ្តានចិត្ត ការចេះគិតគូរ ការខ្វាយខ្វល់ ការសំដែងចេញសេចក្តីស្រឡាញ់ ការទទួលយក អំណរគុណ ការសរសើរ មោទនភាព មិត្តភាព ភាពជឿជាក់ ភាពជាដៃគូ ភាពស្មើគ្នា និងភាពម្ចាស់ការលើខ្លួនឯង។

ដើម្បីទទួលបានសុភមង្គលដ៏ពិតប្រាកដនៅក្នុងអាពាហ៍ពិពាហ៍ នោះបុគ្គលម្នាក់ត្រូវមានការគោរពដ៏ស្មោះត្រង់ចំពោះព្រះបញ្ញត្តិនៃព្រះអម្ចាស់ជានិច្ច។ គ្មានបុគ្គលណាម្នាក់ ទោះជានៅលីវ ឬក៏រៀបអាពាហ៍ពិពាហ៍ហើយក្តី នឹងទទួលបានសុភមង្គលដ៏ប្រពៃបំផុតនោះឡើយ លុះណាតែពួកគេធ្វើខ្លួនឱ្យសុចរិត។ ភាពរីករាយ បណ្តោះអាសន្ន និងស្ថានភាពបោកបញ្ឆោតអាចកើតមានតែមួយពព្រិចភ្នែកប៉ុណ្ណោះ ប៉ុន្តែសុភមង្គលពិត ហើយយូរអង្វែងអាចកើតមានឡើងតាមរយៈភាពស្អាតស្អំ និងភាពសក្តិសមប៉ុណ្ណោះ។ បុគ្គលម្នាក់ដែលមានជំនឿលើសាសនាយ៉ាងខ្លាំងមិនអាចមានសុភមង្គលក្នុងជីវិតអសកម្មរបស់ខ្លួនបានឡើយ។ មនសិការនឹងស្តីបន្ទោសជាបន្តបន្ទាប់ នៅក្នុងដែលករណីអាពាហ៍ពិពាហ៍ស្ថិតក្នុងភាពអន្តរាយរួចជាស្រេចនោះ លើកលែងតែវាត្រូវបានគេបដិសេធទាំងស្រុង។ មនសិការឈឺចាប់អាចធ្វើឱ្យជីវិតគ្មានភាពអត់ធ្មត់។ ភាពអសកម្ម គឺជាវិនាសកម្មចំពោះអាពាហ៍ពិពាហ៍ ជាពិសេសនៅទីណាដែលគូភាគីដែលអសកម្មស្ថិតនៅក្នុងកំរិតអស្ថេរភាពនានា។

ភាពខុសប្លែកខាងសាសនា គឺជាភាពតានតឹងបំផុត ហើយវាគឺភាពខុសប្លែកមួយដែលមិនអាចដឹងបាននៅក្នុងចំណោមភាពខុសប្លែកទាំងអស់។

អាពាហ៍ពិពាហ៍ត្រូវបានតាំងឡើងដោយព្រះ។ វាមិនមែនគ្រាន់តែជាទំនៀមទំលាប់ខាងសង្គមនោះទេ។ បើគ្មានអាពាហ៍ពិពាហ៍ដ៏ត្រឹមត្រូវ ហើយប្រកបដោយជោគជ័យនោះទេ នោះបុគ្គលម្នាក់ៗនឹងមិនត្រូវបានលើកតំកើងឡើយ។ សូមអានព្រះបន្ទូលនៃព្រះអម្ចាស់របស់អ្នកថា វាគឺជាការត្រឹមត្រូវ ហើយសមស្របដើម្បីរៀបអាពាហ៍ពិពាហ៍។

វាជាការត្រឹមត្រូវណាស់ដើម្បីរៀបអាពាហ៍ពិពាហ៍ ពួកបរិសុទ្ធថ្ងៃចុងក្រោយដែលចេះគិតគូរ ហើយមានភាពឆ្លាតវៃនឹងរៀបចំផែនការជីវិតរបស់ខ្លួនដោយប្រុងប្រយ័ត្ន ដើម្បីប្រាកដថាគ្មានឧបសគ្គណាមួយមករាំងស្ទះផ្លូវនេះបានឡើយ។ ដោយសារកំហុសដ៏ធ្ងន់ធ្ងរមួយ នោះបុគ្គលម្នាក់អាចបង្កើតឧបសគ្គដែលមិនអាចដកចេញបាន ហើយដែលវាអាចរាំងស្ទះផ្លូវទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច និងភាពជាព្រះដែលជាបំណងប្រាថ្នាដ៏ធំរបស់យើង។ ប្រសិនបើមនុស្សពីរនាក់ស្រឡាញ់ព្រះអម្ចាស់ច្រើនជាងជីវិតរបស់ខ្លួនឯង ហើយបន្ទាប់មកចេះស្រឡាញ់គ្នាទៅវិញទៅមកឱ្យបានច្រើនជាងជីវិតរបស់ខ្លួនផ្ទាល់ ដោយធ្វើកិច្ចការរួមគ្នាឱ្យសមស្របទៅនឹងកម្មវិធីដំណឹងល្អ ដើម្បីធ្វើជាមូលដ្ឋានគ្រឹះរបស់ខ្លួន នោះពួកគេប្រាកដជានឹងទទួលបានសុភមង្គលដ៏អស្ចារ្យនេះ។ នៅពេលស្វាមី និងភរិយា ទៅព្រះវិហារបរិសុទ្ធរួមគ្នាជាញឹកញាប់ លត់ជង្គង់អធិស្ឋានរួមគ្នានៅក្នុងគេហដ្ឋានជាមួយនឹងគ្រួសាររបស់ខ្លួន កាន់ដៃគ្នាចូលរួមនៅក្នុងការប្រជុំសាសនា រក្សាជីវិតឱ្យបរិសុទ្ធ—ទាំងខាងចិត្តគំនិត និងខាងរូបកាយ—ដើម្បីឱ្យគំនិត និងបំណងប្រាថ្នា ព្រមទាំងសេចក្តីស្រឡាញ់របស់

ពួកគេបានវេញជាធ្លុងមួយជាមួយនឹងដៃគូរបស់ខ្លួន ហើយទាំងពីរនាក់ត្រូវធ្វើកិច្ចការរួមគ្នាក្នុងការកសាងនគរនៃព្រះ នោះសុភមង្គលនឹងកើតមានឡើងដល់កំរិតកំពូលរបស់វា។

ជួនកាល នៅក្នុងអាពាហ៍ពិពាហ៍មានការនៅដាច់ឆ្ងាយឡែត ថ្វីបើព្រះអម្ចាស់បានមានបន្ទូលថា ៖ “ត្រូវស្រឡាញ់ ប្រពន្ធខ្លួនឱ្យរស់អំពីចិត្ត ហើយត្រូវនៅជាប់នឹងនាង ហើយគ្មានឧរណាឡែតឡើយ” (ត. និង ស. 42:22) ក៏ដោយ។

នេះក៏អាចមានន័យផងដែរថាៈ “អ្នកត្រូវស្រឡាញ់ប្តីខ្លួនឱ្យរស់អំពីចិត្ត ហើយត្រូវនៅជាប់នឹងគាត់ ហើយគ្មានឧរណាឡែតឡើយ”។ ជារឿយៗ មានមនុស្សជាច្រើនបានបន្តរស់នៅជាប់នឹងឪពុកម្តាយ និងមិត្តភក្តិរបស់ខ្លួន។ ជួនកាលមាតាទាំងឡាយនឹងមិនលះបង់ការគ្រប់គ្រងដែលពួកគេធ្លាប់មាននៅលើកូនៗរបស់ខ្លួននោះឡើយ ហើយស្វាមីក៏ដូចជាភរិយាផងដែរ បានត្រឡប់ទៅរកម្តាយ និងឪពុករបស់ខ្លួន ដើម្បីសាកសួរដំបូន្មាន និងការប្រឹក្សា ព្រមទាំងរ៉ាប់រឿងរ៉ាវផ្តាល់ខ្លួនខណៈដែលភាពស្និទស្នាលនេះគួរតែធ្វើឡើងជាមួយភរិយានៅក្នុងកិច្ចការជាច្រើន ហើយខណៈដែលរាល់ទំនាក់ទំនងទាំងអស់គួរតែរក្សាទុកជាអាថ៌កំបាំង ហើយសម្ងាត់ពីអ្នកដទៃនោះ។

គូស្វាមីភរិយាជាច្រើន ធ្វើបានល្អចំពោះការស្វែងរកគេហដ្ឋានរបស់ពួកគេភ្លាមៗ ដើម្បីឃ្លាតចេញឆ្ងាយពីសាច់ញាតិទាំងសងខាង។ គេហដ្ឋានមួយនោះ អាចមិនសូវមានភាពឆើតឆាយ និងមិនធំស្តើមស្តៃ ប៉ុន្តែវានៅតែជាគេហដ្ឋានដ៏ឯករាជ្យដដែល។ ជីវិតអាពាហ៍ពិពាហ៍របស់អ្នក គួរតែមានភាពភាពម្ចាស់ដាច់ចេញពីក្រុមគ្រួសាររបស់ស្វាមី ឬភរិយារបស់អ្នក។ អ្នកស្រឡាញ់ពួកគាត់ជាដរាបតរៀងទៅ អ្នកឱ្យតំលៃយ៉ាងខ្ពស់ដល់ការប្រឹក្សារបស់ពួកគាត់ អ្នកឱ្យតំលៃនូវការចូលរួមរបស់ពួកគាត់ ប៉ុន្តែជីវិតផ្តាល់ខ្លួនរបស់អ្នកគួរតែមានការគ្រប់គ្រងដោយការសំរេចចិត្តរបស់អ្នក ដោយការសំរេចចិត្តប្រកបដោយការអធិស្ឋានរបស់អ្នក បន្ទាប់ពីអ្នកបានទទួលការប្រឹក្សាពីអ្នកដែលគប្បីផ្តល់ដំបូន្មានទោះរួចមក។ ការរស់នៅជាមួយគ្នា វាពុំមែនមានន័យត្រាន់តែជាការរស់នៅក្នុងគេហដ្ឋានតែមួយជាមួយគ្នានោះទេ ប៉ុន្តែវាមានន័យថា គឺជាការរស់នៅយ៉ាងជិតស្និទ្ធជាមួយគ្នា ៖

“ហេតុដូច្នេះហើយ គឺត្រឹមត្រូវតាមច្បាប់ថា . . . អ្នកទាំងពីរនោះនឹងត្រលប់ជាសាច់តែមួយ ហើយត្រប់អស់ទាំងនេះ ដើម្បីឱ្យផែនដីអាចបំពេញគោលបំណងនៃការបង្កបង្កើត

“ហើយដើម្បីឱ្យផែនដីអាចបានពេញទៅដោយមនុស្ស តាមការបង្កបង្កើតរបស់ខ្លួន មុនកំណើតលោកិយមកឆ្ល៉ែះ“ (ត. និង ស. 49:16–17)។

បងប្អូនប្រុសស្រីទាំងឡាយ ខ្ញុំសូមនិយាយថានេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ វាគឺជារឿងសំខាន់ខ្លាំងណាស់ ហើយមិនគួរមាននរណាម្នាក់អាចប្រកែកជាមួយព្រះអម្ចាស់បានឡើយ។ ទ្រង់បានបង្កើតផែនដីនេះ ទ្រង់បានបង្កើតមនុស្សលោក។ ទ្រង់គ្រាស់ដឹងពីស្ថានភាពនានា។ ទ្រង់បានបង្កើតកម្មវិធីនេះឡើង ហើយយើងពុំមានព្រាជ្ញា ឬការវាងវៃគ្រប់គ្រាន់ ដើម្បីនឹងឈ្លោះប្រកែកជាមួយទ្រង់ចំពោះកិច្ចការដ៏សំខាន់អស់ទាំងនេះបានឡើយ។ ទ្រង់គ្រាស់ដឹងអ្វីដែលត្រឹមត្រូវ ហើយជាការពិត។

យើងសូមឱ្យអ្នកគិតពិចារណាចំពោះកិច្ចការអស់ទាំងនេះ។ សូមគិតឱ្យច្បាស់ថាអាពាហ៍ពិពាហ៍របស់អ្នកមានភាពត្រឹមត្រូវ។ សូមគិតឱ្យច្បាស់ថាជីវិតរបស់អ្នកមានភាពត្រឹមត្រូវ។ សូមគិតឱ្យច្បាស់ថា ចំណែកនៃអាពាហ៍ពិពាហ៍របស់អ្នកត្រូវបានចំរើនទៅមុខដោយត្រឹមត្រូវ។

ដកស្រង់ចេញពី *Ensign* ខែ មិនា ឆ្នាំ 1977 ទំព័រ 3–5។

ការឆ្លើយតបទៅនឹងឧបសគ្គទាំងឡាយនៅក្នុងអាពាហ៍ពិពាហ៍ 4

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលះទេសះរបស់អ្នកផ្ទាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬច្រើន។

- នៅក្នុងកិច្ចការសំរាប់អានខាងក្រោមនេះ អែលឌើរ លីន ជី រ៉ូប៊ីនស៍ បានធ្វើការពិពិណនាមួយថាះ "រូបមន្តនៃការបង្កើតមហន្តរាយ"។ សូមអានការពិពណិនារបស់គាត់នៅទំព័រនេះ។ បន្ទាប់មក សូមបង្កើតរូបមន្តមួយសំរាប់ភាពសុដុមនៅក្នុងគេហដ្ឋាន។ សូមធ្វើការសំរេចចិត្តថាតើ "ត្រៀងផ្សំណាមួយ" ដែលអ្នកគួរដាក់បញ្ចូលនៅក្នុងរូបមន្តនេះ។
- ចូរធ្វើការតាំងចិត្តដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនៅក្នុងអាពាហ៍ពិពាហ៍ ដោយមានចិត្តអំណត់ និងដោយក្តីស្រឡាញ់ជាជាងដោយប្រើកំហឹង។ សូមធ្វើការសំរេចចិត្តអំពីអ្វីមួយដែលអ្នកអាចធ្វើ ដើម្បីរំលឹកដល់អ្នកជាញឹកញាប់អំពីការតាំងចិត្តនេះ។ ឧទាហរណ៍ អ្នកអាចដាក់កាក់មួយ ឬសម្ភារះតូចដទៃទៀតនៅក្នុងស្បែកជើងរបស់អ្នក ឬ ទុកលិខិតមួយនៅហោប៉ៅសំរាប់រំលឹកដល់ខ្លួនឯង។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

សិទ្ធិជ្រើសរើស និងកំហឹង

អែលឌើរ លីន ជី រ៉ូប៊ីនស៍
នៃក្រុមចិតសិបនាក់

សាតាំងចាក់រុកឱ្យមានកំហឹងនៅក្នុងគ្រួសារ

"ខ្ញុំមានក្រុមគ្រួសារមួយនៅលើផែនដី។ *ពួកគេធ្វើល្អនឹងខ្ញុំណាស់*"។ នេះគឺជាសេចក្តីសង្ឃឹមនៃកុមារគ្រប់រូប ដែលបានបង្ហាញចេញជាពាក្យពេចន៍នៅក្នុងទំនុកដំកើងមួយរបស់យើង ("Families Can Be Together Forever" *Hymns* ទំព័រ 300 អក្សរទ្រេតគឺជាការបន្ថែម)។

យើងបានរៀននៅក្នុងការប្រកាសស្តីអំពីក្រុមគ្រួសារថា ៖ "គ្រួសារជាផ្នែកសំខាន់មួយនៃផែនការរបស់ព្រះដ៏បង្កបង្កើត" ហើយថា "ប្តីប្រពន្ធមានភារកិច្ចដ៏ឧឡារិក ដើម្បីស្រឡាញ់ថែរក្សាគ្នាទៅវិញទៅមក "ហើយមានកាតព្វកិច្ចពិសិដ្ឋ ក្នុងការថែរក្សាអប់រំកូនចៅរបស់ខ្លួន ដោយសេចក្តីស្រឡាញ់ និងដោយសេចក្តីសុចរិត" ("ក្រុមគ្រួសារ ៖ការប្រកាសដល់ពិភពលោក" *Ensign* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 102)។

ក្រុមគ្រួសារក៏ជាគោលដៅចំបងរបស់សាតាំងផងដែរ។ វាកំពុងតែធ្វើសង្ត្រាមនឹងក្រុមគ្រួសារ។ ផែនការមួយរបស់វា គឺជាវិធីដ៏មានល្បិចកល ហើយប៊ុនប្រសប់ ដោយវាត្រូវលូនចូលទៅពីខាងក្រោយខ្សែបន្ទាត់របស់សត្រូវ រួចហើយក៏ចូលទៅក្នុងគេហដ្ឋាន និងនៅក្នុងជីវិតរបស់យើង។

ជារៀយៗ វាធ្វើឱ្យខូចខាត និងបំផ្លាញដល់ក្រុមគ្រួសារនៅក្នុងជញ្ជាំងគេហដ្ឋានផ្ទាល់របស់ពួកគេ។ យុទ្ធសាស្ត្ររបស់វា គឺចាក់រុកសមាជិកគ្រួសារឱ្យមាន *កំហឹង*រវាងគ្នានឹងគ្នា។ សាតាំងគឺជា "បិតានៃការទាស់ទែងគ្នា ហើយវាចាក់រុកចិត្តមនុស្ស ឱ្យមានកំហឹងទាស់ទែងនឹងគ្នាទៅវិញទៅមក" (នីហ្វៃទី 3 11:29 អក្សរទ្រេតជាការបន្ថែម)។ ពាក្យថា *ក្ងរច្របល់* ប្រៀបដូចជារូបមន្តនៃមហន្តរាយ ៖ គឺការធ្វើឱ្យមានកំហឹងនៅក្រោមកំដៅមធ្យម ដោយក្ងរវាជាមួយនឹងពាក្យពេចន៍ជំរើសពីរបីម៉ាត់ រួចហើយវាក៏ពុះឡើង បន្តក្ងរវារហូតដល់វាឡើងក្រាស់រួចទុកវាឱ្យត្រជាក់ ដោយទុកអារម្មណ៍ឱ្យត្រជាក់ពីរបីថ្ងៃ បំរើទាំងត្រជាក់ នោះក៏មានរបស់នៅសេសសល់ជាច្រើន។

យើងអាចជ្រើសរើសមិនខឹង

ផ្នែកដ៏មានល្បិចកលមួយនៅក្នុងយុទ្ធសាស្ត្ររបស់សាតាំង គឺដើម្បីបំបែកកំហឹងចេញពីសិទ្ធិជ្រើសរើស ដោយធ្វើឱ្យពួកយើងជឿថា យើងគឺជាជនរងគ្រោះ ហើយស្ថិតនៅក្នុងអារម្មណ៍មួយដែលយើងមិនអាចគ្រប់គ្រងបាន។ យើងបានធ្លាប់ឮពាក្យថាះ "ខ្ញុំទប់កំហឹងមិនបានទៀតឡើយ"។ ការទប់កំហឹងមិនបានរបស់មនុស្សម្នាក់គឺជាពាក្យជំរើសដែលគួរឱ្យចាប់អារម្មណ៍មួយ ដែលវាបានប្រែក្លាយជាភាសាក្រៀមដោយមានមនុស្សជាច្រើនប្រើប្រាស់យ៉ាងទូលំទូលាយ។ ពាក្យ ថា"បាត់បង់អ្វីមួយ" គឺវាទាក់ទងនឹងពាក្យ ៖ "គ្មានន័យ" "ភាពចៃដន្យ" "អចេតនា" "មិនទទួលខុសត្រូវ"—ជួនកាលធ្វេសប្រហែស ប៉ុន្តែ "មិនទទួលខុសត្រូវ។"

"គាត់ធ្វើឱ្យខ្ញុំខឹង"។ នេះគឺជាប្រយោគមួយផ្សេងទៀតដែលយើងឮ ហើយវាក៏ទាក់ទងនឹងការខ្វះការគ្រប់គ្រង ឬសិទ្ធិជ្រើសរើស។ នេះគឺជារឿងព្រេងដែលត្រូវបានគេប្រឌិតឡើង។ គ្មានទរណាធ្វើឱ្យយើងអាក់អន់ចិត្តបានឡើយ។ អ្នកដទៃទៀតមិនធ្វើឱ្យយើងខឹងទេ។ គ្មានការបង្ខិតបង្ខំចូលរួមចំណែកនោះទេ។ ការខឹងសម្បារគឺជាជំរើស ជាការសំរេចចិត្តដែលមានស្មារតី ហេតុដូច្នេះហើយ យើងអាចធ្វើការជ្រើសរើសមិនខឹងសម្បារបាន។ *យើង* ជាអ្នកជ្រើសរើស!

ចំពោះពួកអ្នកដែលនិយាយថា ៖ "ប៉ុន្តែ ខ្ញុំមិនអាចជួយខ្លួនឯងបានទេ" នោះអ្នកនិពន្ធ វិលៀម វិលបែង បានឆ្លើយតបទៅវិញថា "វាមិនសមហេតុផលនោះឡើយ"។

"ការរុករាន . . . ការទប់កំហឹង ការលើកឡើងនូវបញ្ហា ការស្រែក និងសម្រែក" ទាំងអស់នេះជាយុទ្ធសាស្ត្រដែលត្រូវបានគេរៀន នៅក្នុងការប្រឈមមុខជាមួយនឹងកំហឹង។ "យើង *បានជ្រើសរើស* យកវិធីមួយដែលមានប្រសិទ្ធភាពសំរាប់យើងកាលពីមុន។ តើយើងមានធ្លាប់កត់សំគាល់យើញថា ជារៀយៗយើងទប់កំហឹងមិនបាន នៅពេលយើងត្រូវបានធ្វើឱ្យក្តៅក្រហាយ ដោយចៅហ្វាយរបស់យើងនោះយ៉ាងដូចម្តេច ហើយតើជាញឹកញាប់ យើងធ្វើយ៉ាងដូចម្តេចនៅពេលដែលយើង ត្រូវ

បានធ្វើឱ្យមួម៉ៅដោយសារមិត្តភក្តិ ឬ ក្រុមគ្រួសារនោះ?” (“The New Obscenity,” *Reader's Digest* ខែ ធ្នូ ឆ្នាំ 1988 ទំព័រ 24 អក្សរទ្រេតជាការបន្ថែម)។

លោក វិលបែង បានព្យាយាមប្រឹងប្រែងដើម្បីចូលរួមក្នុងក្រុមកីឡាបាល់បោះវិទ្យាល័យនៅក្នុងឆ្នាំទីពីររបស់គាត់នៅវិទ្យាល័យ ហើយគាត់ក៏ទទួលបានជោគជ័យ។ នៅថ្ងៃទីមួយនៃថ្ងៃហាត់បាល់ គ្រូបង្វឹករបស់គាត់បានដាក់ឱ្យគាត់លេងតទល់នឹងអ្នកលេងម្នាក់ទៀត ខណៈដែលក្រុមរបស់គាត់បានរងចាំមើល។ នៅពេលគាត់បោះបាល់មិនចូលក្នុងចំណុចងាយស្រួលមួយ គាត់បានខឹង ហើយទន្ទ្រាំដើង ព្រមទាំងយំខ្សឹកខ្សួលទៀតផង។ គ្រូបង្វឹកបានដើរទៅរកគាត់ ហើយបាននិយាយថាះ “បើឯងលេងរប្យេបនេះម្តងទៀត ឯងនឹងមិនបានលេងសំរាប់ក្រុមរបស់ខ្ញុំទេ”។ បីឆ្នាំក្រោយមក គាត់ពុំដែលខឹងឆេវឆាវទៀតឡើយ។ ជាច្រើនឆ្នាំក្រោយមក នៅពេលគាត់សញ្ជឹងគិតដល់ហេតុការណ៍នោះឡើងវិញ គាត់បានដឹងថា នៅថ្ងៃនោះគ្រូបង្វឹករបស់គាត់បានបង្រៀនគាត់ អំពីគោលការណ៍នៃការផ្លាស់ប្តូរជីវិតថា ៖ កំហឹងគឺអាចគ្រប់គ្រងបាន (សូមមើល “The New Obscenity” ទំព័រ 24)។

ការបង្រៀនរបស់ព្រះអម្ចាស់

នៅក្នុងការបកប្រែដោយយ៉ូសែប ស្មីធ អេភេសូរ 4:26 សាវកប៉ុល បានសួរសំនួរថាះ “ចូរខឹងចុះ តែកុំឱ្យធ្វើបាបឡើយ?” ព្រះអម្ចាស់បានស្រាយបំភ្លឺយ៉ាងច្បាស់ចំពោះបញ្ហានេះថាះ

“អស់អ្នកណាដែលមានវិញ្ញាណនៃការទាស់ទែងគ្នា គឺពុំមែនជារបស់ផងយើងទេ ប៉ុន្តែជារបស់ផងអារក្សវិញ ដែលជាបិតានៃការទាស់ទែងគ្នា ហើយវាចាក់រុកចិត្តមនុស្ស ឱ្យមានកំហឹងទាស់ទែងនឹងគ្នាទៅវិញទៅមក។

“មើលចុះ នេះពុំមែនជាគោលលទ្ធិរបស់យើងទេ ដែលចាក់រុកចិត្តមនុស្សឱ្យមានកំហឹងទាស់ទែងនឹងគ្នាទៅវិញទៅមក ប៉ុន្តែ គោលលទ្ធិរបស់យើង គឺត្រូវលះបង់ការណ៍ទាំងនោះចោលវិញ” (នីហ្វៃ ទី 3 11:29–30)។

គោលលទ្ធិ ឬបញ្ជានេះចេញពីព្រះអម្ចាស់បានសន្មត់ជាមុនចំពោះសិទ្ធិជ្រើសរើសហើយវាក៏ជាការអំពាវនាវមួយចំពោះការតាស់គឿនអារម្មណ៍នៅក្នុងការធ្វើការសំរេចចិត្តមួយ។ ព្រះអម្ចាស់សង្ឃឹមលើពួកយើងដើម្បីធ្វើការជ្រើសរើស*កុំ*ឱ្យមានការខឹងច្រឡោត។

ឬការខឹងច្រឡោតអាចត្រូសមហេតុសមផល។ នៅក្នុង ម៉ាថាយ 5 ខទី 22 ព្រះអម្ចាស់មានបន្ទូលថាះ “តែខ្ញុំប្រាប់អ្នករាល់គ្នាដូច្នេះវិញ ថា សូម្បីតែអ្នកណាដែលខឹងនឹងបងប្អូន *ដោយគ្មានមូលហេតុ* នោះក្រែងត្រូវជាប់ជំនុំជំរះដែរ” (អក្សរទ្រេតជាការបន្ថែម)។ គួរឱ្យចាប់អារម្មណ៍ខ្លាំងណាស់ដែលឃ្លា “ដោយគ្មានមូលហេតុ” មិនមាននៅក្នុងការបកប្រែដោយយ៉ូសែប ស្មីធ (សូមមើល ម៉ាថាយ 5:24) ឬ នៅក្នុងនីហ្វៃ ទី 3 12:22 ។ នៅពេលព្រះអម្ចាស់លុបចោលនូវឃ្លា “ដោយគ្មានមូលហេតុ” ទ្រង់ទុកឱ្យពួកយើងដោយគ្មានការដោះសារ។ “ប៉ុន្តែ គោលលទ្ធិរបស់យើងគឺត្រូវលះបង់ការទាំងនោះចោលវិញ” (នីហ្វៃ ទី 3 11:30)។ យើងអាច “ធ្វើឱ្យឃ្លាតឆ្ងាយ” ជាមួយការខឹងច្រឡោត ត្បិតឈ្មទ្រង់បានបង្រៀន និងបញ្ជាពួកយើងយ៉ាងដូច្នេះ។

កំហឹងគឺជាការទោទន់ទៅរកឥទ្ធិពលរបស់សាតាំង

កំហឹងគឺជាការទោទន់ទៅរកឥទ្ធិពលរបស់សាតាំង ដោយលះបង់ចោលនូវការគ្រប់គ្រងលើខ្លួនឯង។ កំហឹងគឺជាអំពើបាបនៅក្នុងចិត្ត ដែលនាំទៅរកអារម្មណ៍ឬឥរិយាបទគំរាមកំហែង។ វាគឺជាវត្ថុធាតុដែលអាចធ្វើឱ្យផ្ទុះនូវកំហឹងក្រេធក្រោធ នៅពេលបើកបរលើផ្លូវជាតិ វាគឺជាស្ថានភាពយោរយៅនៅក្នុងសៃរៀនកីឡា និងជាភាពយោរយៅរបស់គ្រួសារនៅក្នុងគេហដ្ឋានទាទា។

ដោយមិនបានត្រួតពិនិត្យ កំហឹងអាចធ្វើឱ្យផ្ទុះឡើងនូវពាក្យសំដីយោរយៅមួយរំពេច និងការបំពានដល់ផ្លូវចិត្តគ្រប់សណ្ឋាន ដែលអាចធ្វើឱ្យមានស្នាកស្នាមនៅលើបេះដូងដ៏ស្រទន់មួយ។ ព្រះអង្គសង្គ្រោះបានមានបន្ទូលថា កំហឹងគឺជា “របស់ដែលធ្វើឱ្យគេស្មោគគ្រោក នោះគឺជាសេចក្តីដែលចេញពីមាត់វិញទេតើ” (ម៉ាថាយ 15:11)។

ដេវីឌ អូ មិកយេ បានមានប្រសាសន៍ថាះ “ស្វាមី និងភរិយាមិនត្រូវនិយាយ ដោយប្រើសម្លេងខ្លាំងៗដាក់គ្នាទៅវិញទៅមកនោះឡើយ លុះណាតែផ្ទះមានភ្លើងឆេះ” (*Stepping Stones to an Abundant Life* ចងក្រងដោយ Llewelyn R. McKay [ឆ្នាំ 1971], 294)។

ការបំពានលើរូបរាងកាយ គឺជាកំហឹងដែលឆ្ពួតលីលា ហើយវាគឺរឿងអយុត្តិធម៌ ហើយខ្វះភាពសុចរិត។

កំហឹងគឺជាការប៉ុនប៉ងមិនសុភាពរាបសារមួយ ដើម្បីធ្វើឱ្យមនុស្សម្នាក់ទៀតទទួលអារម្មណ៍ថាខ្លួនមានកំហុស ឬជាមធ្យោបាយដ៏យោរយៅមួយនៃការព្យាយាមកែតំរូវកំហុសអស់ទាំងនោះ។ ជារឿយៗ កំហឹងមិនត្រូវបានគេរាប់ទុកថាជាការដាក់ជាវិន័យនោះទេ ប៉ុន្តែជាទូទៅ វាគឺជាការរារាំង។ ហេតុដូច្នេះហើយ ទើបមានការព្រមាននៅក្នុងព្រះគម្ពីរថាះ “ពួកប្រុសៗអើយ ចូរស្រឡាញ់ប្រពន្ធចុះ កុំឱ្យមានចិត្តជិនឆ្អន់ឡើយ” ហើយ “ឱ ឱពុករាល់គ្នាអើយ កុំដុកដាន់កូនចៅឡើយ ក្រែងវារសាយចិត្តចេញ” (កូល៉ុស 3:19, 21)។

“ខ្ញុំនឹងមិនខឹងទៀតឡើយ”

ការជ្រើសរើស និងការទទួលខុសត្រូវ គឺជាគោលការណ៍ដែលមិនអាចបំបែកចេញពីគ្នាបានឡើយ។ ដោយសារតែកំហឹងគឺជាជំរើសមួយ នោះមានការព្រមានតឹងរឹងមួយត្រូវបានលើកឡើងនៅក្នុងការប្រកាសថាះ “បុគ្គលណា . . . ដែលធ្វើបាបភរិយា ឬកូនចៅ . . . គង់តែថ្ងៃណាមួយនឹងទទួលខុសត្រូវនៅចំពោះព្រះ”។

ការយល់អំពីទំនាក់ទំនងរវាងសិទ្ធិជ្រើសរើស និងកំហឹងគឺជាជំហានដំបូង នៅក្នុងការកំចាត់ចោលកំហឹងចេញពីជីវិតរបស់យើង។ យើងអាចជ្រើសរើសមិនខឹងច្រឡោត។ ហើយយើងអាចធ្វើការជ្រើសរើសនោះ នៅថ្ងៃនេះហើយនៅពេលនេះថាះ “ខ្ញុំនឹងមិនខឹងទៀតឡើយ”។ សូមពិចារណាចំពោះការតាំងចិត្តនេះ។

នៅក្នុងកណ្ឌទី 121 នៃគោលលទ្ធិ និង សេចក្តីសញ្ញា គឺជាប្រភពដ៏ប្រសើរមួយរបស់ពួកយើង ដើម្បីរៀនអំពីគោលការណ៍ភាពជាអ្នកដឹកនាំដ៏ត្រឹមត្រូវ។ គោលបំណងដ៏សារះសំខាន់បំផុតនៅក្នុងកណ្ឌទី 121 គឺប្រហែលជាទុកសំរាប់ស្វាមី ឬភរិយា និងឱពុកម្តាយទាំងឡាយ។ យើងត្រូវដឹកនាំគ្រួសាររបស់យើង ដោយការលួងលោម ដោយសេចក្តីអត់ធ្មត់ ដោយសុភាពរាបសា ដោយចិត្តសប្បុរស ហើយដោយសេចក្តីទន់ភ្លន់ និងភាពស្លូតបូត ដោយការស្រឡាញ់ដ៏ស្មោះត្រង់ប៉ុណ្ណោះ។ (សូមមើល គ. និង ស. 121:41–42)។

សូមឱ្យសុបិនរបស់កុមារម្នាក់ៗ ដើម្បីមានក្រុមគ្រួសារដ៏ល្អមួយនៅលើផែនដីនេះសំរាប់ពួកគេ នឹងក្លាយទៅជាការពិត។

ដកស្រង់ចេញពីសុន្ទករថាដោយ អែលឌើ រ៉ូប៊ីន នៅក្នុងសន្និសីទទូទៅរបស់សាសនាចក្រ ខែ មេសា ឆ្នាំ 1998 (សូមមើល Conference Report ខែ មេសា ឆ្នាំ 1998 ទំព័រ 105–6 ឬ *Ensign* ខែ ឧសភា ឆ្នាំ 1998 ទំព័រ 80–81)។

ការឆ្លើយតបទៅនឹងឧបសគ្គតាមរយៈទំនាក់ទំនងវិជ្ជមាន

5

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលៈទេសៈរបស់អ្នកផ្តាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- នៅក្នុងការអានកិច្ចការខាងក្រោម អែលឌើរ ចូ ដេ គ្រីស្តិនសុន សង្កេតឃើញថាៈ “លទ្ធផលនៃការគិទ្បេន ឬការនិយាយច្រំដែល បានធ្វើឱ្យមនុស្សមួយចំនួនផ្លាស់ប្តូរទៅរកអ្វីដែលប្រសើរជាងមុន។ តែប្រសិនបើយើងមិនប្រុងប្រយ័ត្នទេ នោះចេទនានៃ ការគិទ្បេន *ដើម្បីស្តាយចរិ* នឹងក្លាយទៅជាការគិះទ្បេនដែលទាំឱ្យមាន *វិនាសកម្ម* ទៅវិញ។ ជួនកាល វាជាការប្រសើរបើស្បៃមជាជាងស្រដី” (ទំព័រ 19 ។ នៅសប្តាហ៍ក្រោយ សូមត្រងត្រាប់ស្តាប់ដោយយកចិត្តទុកដាក់ ចំពោះកិច្ចការដែលយើងគិត និងនិយាយអំពីអ្នកដទៃ។ ចូរមានការប្រឹងប្រែង ដើម្បីធ្វើជាមនុស្សដែលមានសន្តានចិត្តល្អ និងដើម្បីធ្វើជាគំរូនៅគ្រប់អ៊ីៗដែលអ្នកនឹងនិយាយ។
- ចូរស្វែងរកគុណសម្បត្តិដ៏គួរឱ្យស្ងើចសរសើរដែលប្តីឬប្រពន្ធរបស់អ្នកមាន។ ចូរធ្វើតារាងបញ្ជីមួយដែលមានរាយនាមនូវគុណសម្បត្តិអស់ទាំងនេះ ហើយចូរចែកចាយវាជាមួយប្តីឬប្រពន្ធរបស់អ្នក។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

អាពាហ៍ពិពាហ៍ និងផែនការនៃសុភមង្គលដ៏មហិមា

អែលឌើរ ចូ ដេ គ្រីស្តិនសុន
នៃក្រុមចិតសិប

ពាបារ៉ា ហើយនិងខ្ញុំមានកូនចំនួនត្រាំមួយទាត់។ ជាច្រើនឆ្នាំកន្លងទៅ នៅពេលដែលខ្ញុំ និងភរិយាបានយក ពួកគេទៅលេងលោកតាលោកយាយរបស់ពួកគេ នោះឪពុករបស់ខ្ញុំបានមានប្រសាសន៍ថា “ចូ ឱពុកគិតថាកូន និងកូនស្រីពាបារ៉ា បានចាប់ផ្តើមនូវអ្វីមួយដែលកូនមិនអាចបញ្ឈប់បានឡើយ។”

នៅរដូវអ៊ីសស្ទើរនេះ យើងសូមប្រកាសដល់ពិភពលោកទាំងអស់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយថាតាមរយៈបព្វជិតភាពដ៏បរិសុទ្ធរបស់ទ្រង់ និងអំណាចផ្សាភ្ជាប់របស់បព្វជិតភាពនោះ នោះអាពាហ៍ពិពាហ៍ និងក្រុមគ្រួសារនឹងត្រូវការមិនចេះឈប់ឈរ—ហើយគ្មានទីបញ្ចប់ឡើយ។

ថ្ងៃនេះ ខ្ញុំសូមនិយាយទៅកាន់អ្នកទាំងអស់គ្នាអំពីអាពាហ៍ពិពាហ៍របស់យើង។ នេះគឺជាយោបល់ដ៏មានអត្ថប្រយោជន៍ទាំងត្រាំបី ដោយសង្ឃឹមថា វាអាចជាតម្លៃមួយនៅក្នុងការពង្រឹងអាពាហ៍ពិពាហ៍របស់យើង ទាំងបច្ចុប្បន្នកាល និងអនាគតកាល។

ចូរចងចាំពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍

1. ចូរចងចាំពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍របស់អ្នក។ សូមស្តាប់នូវពាក្យអស់ទាំងនេះមកពីអែលឌើរ ប្រូស អ ម៉ាកខនឃី ស្តីអំពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍ នៅក្នុង “ផែនការនៃសុភមង្គលដ៏មហិមា” របស់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់យើង (អាលម៉ា 42:8)ៈ

“ចាប់តាំងពីពេលប្រសូតមកភ្លាម មកទល់នឹងជីវិតរមែងស្លាប់ រហូតដល់ពេលដែលយើងបានរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ អ្វីៗគ្រប់យ៉ាងដែលយើងមាននៅក្នុងប្រពន្ធដំណឹងល្អ គឺជាការរៀបចំខ្លួន និងការធ្វើឱ្យយើងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីធ្វើឱ្យយើងមានអាពាហ៍ពិពាហ៍ដែលមានសណ្តាប់ធ្នាប់បរិសុទ្ធ ដែលនឹងធ្វើឱ្យយើងក្លាយជាស្វាមី និងភរិយានៅក្នុងជីវិតនេះ និងលោកិយខាងមុខ . . .។

“នៅក្នុងលោកនេះ ពុំមានអ្វីដែលមានសារៈសំខាន់ជាការបង្កបង្កើត និងភាពល្អឥតខ្ចោះនៃក្រុមគ្រួសារនោះទេ” (“Salvation Is a Family Affair” *Improvement Era* ខែ មិថុនា ឆ្នាំ 1970 ទំព័រ 43–44)។

អធិស្ឋានដើម្បីអាពាហ៍ពិពាហ៍របស់អ្នកមានជោគជ័យ

2. ចូរអធិស្ឋានដើម្បីឱ្យអាពាហ៍ពិពាហ៍របស់អ្នកមានជោគជ័យ។ ជាច្រើនឆ្នាំកន្លងទៅ នៅពេលដែលការទៅទស្សនកិច្ចបេសកកម្មមួយ ឬការសម្ភាសន៍ពួកអ្នកផ្សព្វផ្សាយសាសនាគឺជារឿងធម្មតា នោះអែលឌើរ ស្តែនស៊ើរ ដបុលយូ ឃីមប៊ីល ដែលជាសមាជិកក្រុមនៃពួក 12 បានជួបជាមួយអែលឌើរម្នាក់ដែលនឹងជិតបញ្ចប់បេសកកម្មរបស់គាត់។

“អែលឌើរ តើអ្នកមានផែនការអ្វីខ្លះ នៅពេលដែលបេសកកម្មរបស់អែលឌើរត្រូវបានបញ្ចប់?”

“អ៊ុំ! ខ្ញុំមានផែនការត្រឡប់ទៅចូលរៀនមហាវិទ្យាល័យវិញ”។ ហើយបន្ទាប់មកដោយស្មាមញ្ញឹម គាត់បាននិយាយបន្ថែមទ្បេតថាៈ “ក្រោយមកទ្បេត ខ្ញុំសង្ឃឹមថានឹងមានសេចក្តីស្នេហា ហើយបានរៀបការ”។

អែលឌើរ ឃីមប៊ីល បានចែកចាយនូវដំបូន្មានដែលប្រកបទៅដោយគតិបណ្ឌិតនេះថាៈ “បើដូច្នោះ ចូរកុំអធិស្ឋានដើម្បីឱ្យអ្នកបានរៀបការជាមួយអ្នកដែលអ្នកស្រឡាញ់។ *ផ្ទុយទៅវិញ សូមអធិស្ឋាន ដើម្បីស្រឡាញ់អ្នកដែលអ្នកត្រូវរៀបការជាមួយ*”។

យើងគួរតែអធិស្ឋានសុំឱ្យយើងកាន់តែមានចិត្តល្អ សុភាពរាបសារ បន្ទាបខ្លួន មានសេចក្តីអំណត់ ការអត់ទោស និង *ជាពិសេស* គាត់បន្តយភាពអត្មានិយម។

ដើម្បីទទួលស្គាល់បញ្ហាផ្តាល់ខ្លួន ឬចំណុចខ្សោយរបស់យើង ដែលជាការរាំងស្ទះយើងពីភាពធ្វើជាដៃគូអាពាហ៍ពិពាហ៍ដ៏ប្រសើរ យើងគួរតែមករកព្រះអម្ចាស់នៅ

ក្នុងការអធិស្ឋាន ហើយទទួលយកផលប្រយោជន៍នៃអំណាចព្រះគម្ពីរមរមនដែលសន្យាថាះ "ហើយបើសិនជាមនុស្សលោកមករកយើង នោះយើងនឹងបង្ហាញដល់ពួកគេនូវភាពទន់ខ្សោយរបស់ពួកគេ។ យើងឱ្យភាពទន់ខ្សោយទៅមនុស្ស ដើម្បីឱ្យពួកគេអាចបានរាបសារ ហើយគុណរបស់យើង មានគ្រប់គ្រាន់សំរាប់មនុស្សទាំងអស់ដែលបន្ទាបខ្លួនទៅចំពោះយើង ត្បិតបើសិនជាពួកគេបន្ទាបខ្លួនទៅចំពោះយើង ហើយមានសេចក្តីជំនឿជឿដល់យើង លំដាប់នោះយើងនឹងធ្វើឱ្យអ្វីដែលទន់ខ្សោយក្លាយជាខ្លាំងពូកែចំពោះពួកគេវិញ (អេធើរ 12:27)។

ហេតុដូច្នេះហើយ ការអធិស្ឋានជាការចាំបាច់។ អ្នកដឹកនាំសាសនាចក្រ និងទីប្រឹក្សាខាងអាពាហ៍ពិពាហ៍ជាច្រើន បានលើកឡើងថាពួកគេមិនដែលឃើញអាពាហ៍ពិពាហ៍មួយស្ថិតនៅក្នុងបញ្ហាធ្ងន់ធ្ងរនោះទេ នៅពេលដែលគូស្វាមីភរិយានៅតែធ្វើការអធិស្ឋានជាមួយគ្នាជារៀងរាល់ថ្ងៃ។ នៅពេលដែលមានបញ្ហាកើតឡើង ហើយអាពាហ៍ពិពាហ៍ត្រូវបានគំរាមកំហែង នោះការអធិស្ឋានជាមួយគ្នាជាដៃគូ អាចជាឱសថដ៏មានសារៈសំខាន់បំផុត។

ចូរស្តាប់ដល់ប្តីឬប្រពន្ធរបស់អ្នក

3. ស្តាប់។ ចូរចំណាយពេលដើម្បីស្តាប់ដល់ប្តីឬប្រពន្ធរបស់អ្នក ហើយត្រូវកំណត់ពេលវាឱ្យបានទៀងទាត់ថែមទៀតផង។ ទៅដើរលេងជាមួយគ្នា ហើយធ្វើការប្រមាណមើលថាតើដៃគូអាពាហ៍ពិពាហ៍របស់អ្នកមានអារម្មណ៍យ៉ាងណាដែរ។

បងប្រុស ប្រេន បាឡូ ដាក់សំនួរមួយទៅកាន់ក្រុមបព្វជិតភាពថាះ"តើក្នុងចំណោមអ្នកទាំងអស់គ្នា មានបងប្អូនប៉ុន្មាននាក់ដែលចង់ទទួលបានវិវរណៈ?" ពួកគាត់បានលើកដៃឡើងទាំងអស់គ្នា។ បន្ទាប់មក គាត់បានផ្តល់យោបល់ថា ពួកគាត់គួរតែត្រឡប់ទៅផ្ទះវិញ ហើយសួរដល់ភរិយារបស់ពួកគាត់ អំពីរបៀបដែលពួកគាត់អាចធ្វើជាស្វាមីដែលល្អប្រសើរជាងមុន។ គាត់បានបន្ថែមទៀតថាះ "ខ្ញុំបានធ្វើតាមដំបូន្មានរបស់ខ្ញុំ ហើយបានមានការពិភាក្សាដ៏សាមញ្ញមួយ [ភរិយាខ្ញុំ] ស៊ូស៊ាន ដែលអស់រយៈពេលជាងមួយម៉ោងនៅថ្ងៃត្រង់នោះ!" ("To Build a Better Marriage" *Ensign* ខែ កញ្ញា ឆ្នាំ 1992 ទំព័រ 7)។ ការសន្ទនាមួយដូចនេះអាចជាវិវរណៈមួយសំរាប់យើងម្នាក់ៗ។

តើមានបងប្អូនប្រុសម្នាក់ដែលត្រូវបានភរិយានិយាយអ្វីមួយដូចដែលខ្ញុំបានឲ្យថ្មីៗនេះថា ៖ "ចូ បងកំពុងស្តាប់អូនឬអត់?" ពុំមែនមានតែនាងទេ ដែលជាបុគ្គលកំពុងឆ្ងល់ថាតើខ្ញុំបានស្តាប់ឬអត់នោះ។ ច្រើនឆ្នាំកន្លងទៅ នៅពេលដែលខ្ញុំកំពុងតែដេកពេលថ្ងៃ នោះចៅស្រីតូច អាលីសិន របស់យើងបានមក ហើយបើកត្របកភ្នែកមួយចំហៀងរបស់ខ្ញុំ រួចបាននិយាយថា ៖ "លោកតា តើលោកតានៅក្នុងនេះឬទេ?" យើងគួរតែ "នៅក្នុងនោះ" ហើយឆ្លើយតបទៅកាន់ដៃគូរបស់យើងវិញ។

ផ្សសវាងការទិទៀនច្រំដែល

4. ផ្សសវាង "ការទិទៀនច្រំដែល។" ចូរកុំរិះគន់លើកំហុសរបស់គ្នាទៅវិញទៅមកច្រើនពេក។ សូមទទួលស្គាល់ថាគ្មានទរណាម្នាក់ល្អឥតខ្ចោះនោះទេ។ យើងទាំងអស់គ្នានៅមានផ្លូវដើរវែងឆ្ងាយណាស់ ដើម្បីក្លាយដូចព្រះគ្រីស្ទ ដូចដែលអ្នកដឹកនាំរបស់យើងបានជំរុញយើងឱ្យធ្វើដូចជាទ្រង់ដូច្នោះ។

"ការទិទៀនច្រំដែល" ដូចដែលប្រធាន ស្ពែនស៊ើរ ដបុលយូ យឹមបឹល បានហៅអាចធ្វើឱ្យប៉ះពាល់ដល់ស្ទើរតែគ្រប់អាពាហ៍ពិពាហ៍ភាគច្រើន ("Marriage and Divorce" *1976 Devotional Speeches of the Year* [ឆ្នាំ 1977] ទំព័រ 148)។ ជាទូទៅ យើងម្នាក់ៗបានដឹងខ្លួនយ៉ាងច្បាស់នូវភាពទន់ខ្សោយរបស់យើង ហើយយើងមិនត្រូវការការប្រាប់ច្រំដែលៗនោះទេ។ លទ្ធផលនៃការតិទៀនឬការនិយាយច្រំដែល បានធ្វើឱ្យមនុស្សមួយចំនួនផ្លាស់ប្តូរទៅរកអ្វីដែលប្រសើរជាងមុន។ តែប្រសិនបើយើងមិនប្រុងប្រយត្ន័ទេ នោះចេទនានៃការតិទៀន *ដើម្បីស្ថាបនា* នឹងក្លាយទៅជាការតិះទៀនដែលនាំឱ្យមាន *វិនាសកម្ម* ទៅវិញ។

ជួនកាល វាជាការប្រសើរបើស្ឈៀមជាជាងស្រដី។ នៅពេលដែលទើបបានរៀបការថ្មីថ្មោង បងស្រី ឡូឡា វលធើរ បានអានទស្សនាវដ្តីមួយដែលនិយាយថា ដើម្បីពង្រឹងនូវចំណងអាពាហ៍ពិពាហ៍មួយបាន នោះគូស្វាមីភរិយា គួរតែមានការប្រជុំចែកចាយនូវអ្វីដែលពួកគេអាចធ្វើជាតារាងចរិយាមាយាទនិយមនីមួយៗ ដែលពួកគេគិតថាជារឿងគួរឱ្យធុញទ្រាន់ជាប្រចាំ។ បងស្រីបានសរសេរដូចតទៅថា ៖

"យើងត្រូវលើកឡើងនូវរឿងប្រាំយ៉ាងដែលយើងយល់ឃើញថាជារឿងគួរឱ្យធុញទ្រាន់ ហើយខ្ញុំបានចាប់ផ្តើមមុន . . . ខ្ញុំបានប្រាប់ស្វាមីខ្ញុំថា ខ្ញុំពុំចូលចិត្តនូវរបៀបដែលគាត់ហូបក្រូចថ្លុងទេ។ គាត់បកក្រូចថ្លុង ហើយបានបរិភោគវាដូចក្រូចពោធ៏សាត់! ខ្ញុំពុំដែលស្គាល់នរណាម្នាក់ដែលហូបផ្លែក្រូចថ្លុងដូច្នេះឡើយ។ តើស្រីម្នាក់អាចត្រូវនឹករំពឹងថាខ្លួននឹងចំណាយពេលមួយជីវិត ហើយរហូតដល់ភាពអស់កល្បជានិច្ច ដោយសម្លឹងមើលស្វាមីរបស់ខ្លួនបរិភោគក្រូចថ្លុងដូចក្រូចពោធ៏សាត់ដែរឬទេ? . . .។

"បន្ទាប់ពីខ្ញុំបានបញ្ចប់ [រឿងដែលគួរឱ្យធុញទ្រាន់ទាំងប្រាំយ៉ាងរបស់ខ្ញុំ] វាត្រូវដល់វេនរបស់គាត់ដើម្បីប្រាប់ខ្ញុំនូវអ្វីដែលគាត់មិនបានចូលចិត្តអំពីខ្ញុំ [ស្វាមីខ្ញុំ] និយាយថា 'មែនហើយ និយាយដោយត្រង់ទៅ បងមិនអាចគិតឃើញនូវរឿងអ្វីមួយដែលបងមិនចូលចិត្តអំពីអូនឡើយ អូនសំឡាញ់'។

"ដកដង្ហើមធំ។

"រំពេចនោះ ខ្ញុំបែរខ្នងចេញ ដោយសារតែខ្ញុំមិនដឹងថាតើត្រូវពន្យល់យ៉ាងដូម្តេចពីទឹកភ្នែកដែលមានពេញនៅក្នុងភ្នែករបស់ខ្ញុំ និង បានហូរធ្លាក់ចុះមកលើថ្ពាល់របស់ខ្ញុំ។"

បងស្រី វលធើរ បានបញ្ចប់ថា ៖ "នៅពេលណាដែលខ្ញុំបានឲ្យថាគូស្វាមីភរិយាមានការខ្វែងគំនិតគ្នា ខ្ញុំតែងតែឆ្ងល់ថាតើពួកគេកំពុងឈឺចាប់នូវអ្វីដែលខ្ញុំហៅថាមេរោគក្រូចថ្លុងឥឡូវនេះទេ" ("The Grapefruit Syndrome" *Ensign* ខែមេសា ឆ្នាំ 1993 ទំព័រ 13)។

ត្រូវហើយ ជួនកាល វាជាការប្រសើរបើស្ឈៀមជាជាងស្រដី។

រក្សាចំណងស្នេហាររបស់អ្នកឱ្យនៅរស់រវើក

5. សូមថែរក្សាមនោសញ្ចេតនារបស់អ្នកឱ្យមានភាពរស់រវើក។ សូមចំណាយពេលដើម្បីធ្វើកិច្ចការទាំងឡាយជាមួយគ្នា—តែអ្នកទាំងពីរតែប៉ុណ្ណោះ។ ដោយសារតែវាមានសារៈសំខាន់ដូចជាការនៅជាមួយកូនចៅជាក្រុមគ្រួសារ នោះអ្នកត្រូវចំណាយពេលប្រចាំសប្តាហ៍ជាទៀងទាត់ នៅជាមួយគ្នាតែពីរនាក់។ ពេលដាក់កាលវិភាគនៅជាមួយគ្នាតែពីរនាក់ដូច្នេះ នោះវានឹងធ្វើឱ្យកូនចៅរបស់អ្នកដឹងថា អ្នកមានអារម្មណ៍គិតថាអាពាហ៍ពិពាហ៍របស់អ្នកមានសារៈសំខាន់ខ្លាំងណាស់ដែលអ្នកត្រូវតែថែរក្សាវា។ ការថែរក្សានោះត្រូវការការប្តេជ្ញាចិត្ត ការដាក់ផែនការនិងការដាក់កាលវិភាគ។

វាពុំចាំបាច់មានតំលៃខ្ពស់ទេ។ ពេលវេលានៅជាមួយគ្នា ជាធាតុដ៏សំខាន់បំផុត។

ក្រោមួយ នៅពេលដែលឪពុកក្មេករបស់ខ្ញុំបានចេញពីផ្ទះ បន្ទាប់ពីបរិភោគអាហារថ្ងៃត្រង់រួច ដើម្បីត្រឡប់ទៅចំការធ្វើចំការវិញ ម្តាយក្មេករបស់ខ្ញុំបានមានប្រសាសន៍ថា “អ័លប៊ិត បងត្រូវត្រឡប់មកវិញ ហើយត្រាប់អូនថា បងស្រឡាញ់អូន”។ ឪពុកក្មេកខ្ញុំបានញញឹម ហើយនិយាយកំប្លែងលេងថា “អែលស៊ី នៅពេលដែលយើងបានរៀបការ បងបានត្រាប់អូនថាបងស្រឡាញ់អូនរួចហើយ ហើយបើសិនជាបងផ្លាស់ប្តូរចិត្ត នោះបងនឹងត្រាប់អូន”។ វាលំបាកណាស់ក្នុងការប្រើពាក្យ “បងស្រឡាញ់អូន” ឱ្យបានច្រើនដងនោះ។ តែសូមប្រើវាឱ្យបានរាល់ថ្ងៃ។

ចូរនិយាយពាក្យថា “ខ្ញុំសូមទោស” ឱ្យបានល្បឿន

6. ចូរនិយាយពាក្យថា “ខ្ញុំសូមទោស” ឱ្យបានល្បឿន។ ការបង្កើតពាក្យនោះឡើង និងការប្តូរទៅប្រើពាក្យ “ខ្ញុំសូមអភ័យទោស និងពាក្យ សូមអត់ទោសឱ្យខ្ញុំ” វាលំបាកដូចគ្នា ទោះបីថាអ្នកពុំមែនជាជនដែលមានកំហុសទាំងស្រុងក្តី។ ស្មោហាពិតគឺត្រូវបានបង្កើតឡើងដោយអ្នកទាំងឡាយណា ដែលស្ម័គ្រចិត្តរួចជាស្រេចដើម្បីទទួលយកនូវកំហុស និងការធ្វើឱ្យអាក់អន់ចិត្តផ្ទាល់ខ្លួន។

នៅពេលដែលការខ្វែងមតិកើតឡើង បើអាចពិភាក្សា និងដោះស្រាយបានគឺជាការសំខាន់ ប៉ុន្តែបើកើតមានទោះ យកល្អគួរដើរ ចេញមួយស្របក់ជាការប្រសើរ។ ការខាំមាត់សង្កត់ចិត្តមិនតបត ហើយរាប់ពីមួយដល់ដប់ ឬរហូតដល់មួយរយ ជាប្រការសំខាន់។ ហើយនៅពេលខ្លះ សូមឱ្យកំហឹងរបស់អ្នកលិចទៅតាមថ្ងៃលិច វាអាចជួយអ្នកសំរាក ធ្វើឱ្យចិត្តស្ងប់ ហើយអាចប្រឈមមុខនឹងបញ្ហាដែលកើតមានឡើងនៅព្រឹកស្អែក និងរកឱកាសដ៏ប្រសើរមួយសំរាប់ដំណោះស្រាយ។

ជារឿយៗ យើងឮពាក្យដូចជាថា “ហេតុអ្វី យើងបានរៀបការអស់រយៈពេលហាសិបឆ្នាំកន្លងទៅហើយ ហើយយើងមិនដែលមានការខ្វែងមតិគ្នាម្តងណាសោះ”។ ប្រសិនបើនេះជាការពិត នោះបុគ្គលម្នាក់ត្រូវបានក្បៀបសង្កត់ដោយភាគីម្ខាងទៀតរបស់ខ្លួន ឬដូចអ្នកខ្លះនិយាយថា រឿងនេះគឺជាហេតុការណ៍ដ៏ចំលែកមួយ។ គូស្វាមីភរិយាវាងវៃត្រប់រូបតែងតែមានការខ្វែងមតិគ្នា។ បញ្ហាប្រឈមរបស់យើង គឺជាការបញ្ជាក់ថា យើងដឹងអំពីរបៀបដើម្បីដោះស្រាយបញ្ហាទាំងនោះ។ នោះហើយគឺជាដំណើរការចំពោះការធ្វើឱ្យមានអាពាហ៍ពិពាហ៍ដ៏ប្រសើរមួយ។

រស់នៅតាមចំណូលរបស់អ្នក

7. ចូររៀនរស់នៅតាមចំណូលរបស់អ្នក។ បញ្ហាប្រឈមមុខដ៏លំបាកបំផុតមួយចំនួន ដែលកើតឡើងនៅក្នុងអាពាហ៍ពិពាហ៍គឺដោយសារហិរញ្ញវត្ថុ។ “សមាគមមេធាវីរបស់អាមេរិកាំង . . . បានបង្ហាញច្បាប់ថា 89 ភាគរយនៃការលែងលះទាំងអស់ដែលអាចទាំទារកការឈ្លោះប្រកែក ហើយនិងការចោទប្រកាន់គឺនៅលើរឿងលុយកាក់ (Marvin J. Ashton “One for the Money” *Ensign* ខែ កក្កដា ឆ្នាំ 1975 ទំព័រ 72)។ ចូរផ្អាក ឬបោះបង់ចោលការទិញទំនិញមួយចំនួន ដើម្បីអ្នកអាចរស់នៅតាមចំណូលរបស់អ្នក។ ចូរបង់ដង្វាយមួយភាគដប់របស់អ្នកជាមុន ហើយត្រូវជ្រើសរើសពីចំណូលតាមដែលអាចធ្វើបាន។ ចូរចងចាំថាការចំណាយហាសិបដុល្លារក្នុងមួយខែ គិតជាឯចំណូលដែលអ្នករកបាន នោះគឺស្មើនឹងទទួលបានសុភមង្គល ហើយការចំណាយហាសិបដុល្លារច្រើនជាងចំណូលដែលអ្នករកបាន នោះគឺស្មើនឹងសេក្តីទុក្ខលំបាក។ ពេលវេលាមួយ អាចកើតមាននៅពេលដែលប័ណ្ណឥណទានរបស់អ្នកអស់ត្រាក់ ត្រូវកាត់ប័ណ្ណឥណទាន ហើយធ្វើដូចអ្វីដែលអែលឌើរ ជែហ្វ្រី អរ៍ ហឡិន ហៅវាថា “ការរះកាត់ប្លាស្ទិក”។ (“Things We Have Learned—Together” *Ensign* ខែ មិថុនា ឆ្នាំ 1986 ទំព័រ 30)។

រួមចំណែកក្នុងការទទួលខុសត្រូវនៅក្នុងគេហដ្ឋាន និងគ្រួសារ

8. ចូរធ្វើដាដៃគូពិត ក្នុងការទទួលខុសត្រូវរបស់គ្រួសារ និងគេហដ្ឋាន។ ចូរកុំធ្វើដូចជាស្វាមីដែលអង្គុយមួយកន្លែងចាំឱ្យមានការបំរើឆ្ងេងស្តាំ ដោយគិតថាការរកទទួលទានចិញ្ចឹមជីវិតគឺជាការងាររបស់ខ្លួន ហើយថាភរិយាគាត់តែម្នាក់ឯងគឺជាអ្នកទទួលខុសត្រូវនៅក្នុងគេហដ្ឋាន និងថែរក្សាបីបាច់កូនចៅ។ ការងារថែទាំគេហដ្ឋាន និងក្រុមគ្រួសារគឺជាការទទួលខុសត្រូវរបស់គូស្វាមីភរិយា មិនមែនតែសំរាប់ភរិយា ឬស្វាមីតែម្នាក់ឯងនោះទេ។

ចូរចងចាំថា អ្នកនៅក្នុងភាពជាដៃគូនេះរួមគ្នា។ បាបា៉រា និងខ្ញុំបានរកឃើញថា យើងអាចរៀបចំត្រៃដេករបស់យើង មិនលើសពីមួយនាទីឡើយ ហើយត្រៃនោះត្រូវបានរៀបចំយ៉ាងស្អាតសំរាប់ពេញមួយថ្ងៃ។ ទាងនិយាយថា ទាងឱ្យខ្ញុំជួយរៀបចំត្រៃដើម្បីជួយឱ្យខ្ញុំមានអារម្មណ៍ល្អចំពោះខ្លួនឯងពេញមួយថ្ងៃ ហើយខ្ញុំគិតថាប្រហែលជាមានអត្ថន័យអ្វីបង្កប់នៅក្នុងនោះ។

ចូររកពេលដើម្បីសិក្សាព្រះគម្ពីររួមគ្នា ហើយធ្វើតាមដំបូន្មានរបស់ប្រធានយឺមបឹល ៖ “នៅពេលដែលស្វាមី និងភរិយាទៅ ព្រះវិហារបរិសុទ្ធជាមួយគ្នាបានញឹកញាប់ លុតជង្គង់អធិស្ឋានជាមួយគ្នានៅក្នុងគេហដ្ឋានរបស់ពួកគេ ជាមួយក្រុមគ្រួសាររបស់ពួកគេ ដឹកដៃគ្នាទៅចូលរួមការប្រជុំរបស់សាសនាពួកគេ រក្សាជីវិតរបស់ពួកគេឱ្យបរិសុទ្ធទាំងកាយទាំងចិត្ត . . . ហើយអ្នកទាំងពីរនាក់ធ្វើការរួមគ្នាដើម្បីពង្រីកនគរព្រះ ពេលនោះពួកគេមានសុភមង្គលបំផុត។ (*Marriage and Divorce* [ឆ្នាំ 1976], 24)។

ជាសង្ខេប ៖

- ចូរចងចាំពិសារៈសំខាន់នៃអាពាហ៍ពិពាហ៍របស់អ្នក។
- អធិស្ឋានសុំឱ្យអាពាហ៍ពិពាហ៍មានជោគជ័យ។
- ស្តាប់។
- ជ្រើសរាង “ការតិះទ្បៀនច្រំដែល”
- រក្សាចំណងស្នេហារបស់អ្នកឱ្យមានជីវិតរស់រវើក
- សូមនិយាយពាក្យថា “ខ្ញុំសូមទោស” ឱ្យបានរហ័ស។
- រស់តាមចំណូលរបស់អ្នក។
- ធ្វើជាដៃគូពិតក្នុងការទទួលខុសត្រូវគេហដ្ឋាន និងក្រុមគ្រួសារ។

ខ្ញុំសូមធ្វើទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ថានៅថ្ងៃទីបី ពុំមានព្រះសពព្រះអង្គនៅក្នុងផ្នូររបស់ទ្រង់ឡើយ ហើយថា “ព្រោះដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ក្នុងលោកអ័ដាមយ៉ាងណានោះ គ្រប់គ្នាក៏នឹងបានប្រោសឱ្យរស់ ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ” (កូរិនថូសទី 1 15:22)។ ដូចនេះ ដោយសារការដឹងគុណ ចំពោះអំណាចនៃការភ្ជាប់នៅក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ នោះយើងអាចនិយាយដោយទំនុកចិត្តព្រមជាមួយនឹងកំណាព្យថា “ខ្ញុំគួរតែធ្វើ ប៉ុន្តែស្រឡាញ់ទ្រង់ច្រើនជាងនេះបន្ទាប់ពីសេចក្តីស្លាប់” (Elizabeth Barrett Browning, *Sonnets from the Portuguese* លេខ 43 បន្ទាត់ទី 14)។

ដកស្រង់ចេញពីសន្ទរកថា ដោយអែលឌើរ គ្រីស្តិនសិន នៅក្នុងសន្និសីទទូទៅរបស់សាសនាចក្រ (សូមមើល Conference Report ខែ មេសា ឆ្នាំ1995 ទំព័រ 84–87 ឬ ទស្សនាវដ្តីសាសនាចក្រ ខែ ឧសភា ឆ្នាំ 1995 ទំព័រ 64–66)។

ការពង្រឹងអាពាហ៍ពិពាហ៍តាមរយះសេចក្តីជំនឿ និង ការអធិស្ឋាន

6

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលះទេសះរបស់អ្នកផ្ទាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- សូមគិតអំពីរឿងមួយដែលអ្នកអាចធ្វើដើម្បីពង្រឹងសេចក្តីជំនឿរបស់អ្នក ទៅលើព្រះវរបិតាសួគិ និងព្រះយេស៊ូវគ្រីស្ទ។
- ជារៀងរាល់ថ្ងៃ ចូរបង្កើតពេលវេលាមួយ ដើម្បីអធិស្ឋានជាមួយប្តី ឬប្រពន្ធរបស់អ្នក។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

ស្វែងរកសេចក្តីរីករាយនៅក្នុងជីវិត

ដែលឌើរ រីឆាត ជេ ស្តត
ក្រុមនៃពួកសាវក 12 នាក់

ពិពិធភាពនៅក្នុងសេចក្តីជំនឿ

ថ្មីៗនេះ ខ្ញុំបានឈរនៅលើច្រាំងសមុទ្រប៉ែកខាងជើងដ៏ស្រស់ស្អាតមួយនៃមហាសមុទ្រប៉ាស៊ីហ្វិក ដោយសំលឹងមិនដាក់ភ្នែកទៅសមុទ្រនៅពេលអរុណោទ័យ។ ខ្ញុំបានជក់ចិត្តដិតអារម្មណ៍នឹងទឹករលកធំៗដែលបក់បោកគ្រឹមត្រូវតាមគន្លងទៅលើច្រាំងសមុទ្រ។ វាបានធ្វើឱ្យខ្ញុំនឹកចាំដល់ផែនការដ៏ខ្ជាប់ខ្ជួនរបស់ព្រះអម្ចាស់ ជាមួយនឹងស្ថេរភាពនៃផែនការនោះ ដែលជាក្រិត្យវិន័យដ៏នៅអស់កល្បជានិច្ច និងសុវត្ថិភាពនៃយុត្តិធម៌ដល់ទីបញ្ចាប់ ព្រមទាំងភាពទន់ភ្លន់នៃសេចក្តីមេត្តាករុណាដែលទទួលបានដោយសារការគោរពប្រណិបត្តិ។ ខ្ញុំបានកត់សំគាល់ឃើញថារលកនិមួយៗនឹងមាននៅកំរិតធំខុសៗគ្នា លើទិដ្ឋភាពចំពោះមាគិាតែមួយទៅកាន់ច្រាំងសមុទ្រ។ រលកខ្លះបានប៉ះផ្ទាំងថ្ម ដោយបន្សល់នូវពពុះទឹកសក្សុសហូរច្រោះ។ រលកទាំងនោះបានរអិលធ្លាក់តាមខ្សាច់សើមនៅតាមច្រាំងដែលមានពពុះទឹកដ៏គួរឱ្យចង់លេងបន្ទាប់មកពពុះ និងទឹកកួចខ្ជួលខ្មាញ់បានហូរត្រឡប់ទៅវិញ។

ខ្ញុំបានគិតដល់អ្វីដែលអាចកើតឡើងតាមវិធីផ្សេងដោយគ្មានទីបញ្ចាប់ ដែលព្រះអម្ចាស់បានប្រទានឱ្យយើង។ យើងមានសេរីភាពច្រើន មានឱកាសច្រើន ដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈ និងទេពកោសល្យដ៏ពិសេស អនុស្សាវរីយ៍ផ្ទាល់ខ្លួន និងបរិច្ចាគផ្ទាល់ខ្លួនរបស់យើង។ ដោយសារតែពុំមានឱកាសច្រើនទៀត ដើម្បីសម្លឹងមើលទៅសមុទ្រដែលប្រកបដោយសីហវិលាស នោះខ្ញុំបានព្យាយាមនឹកស្រមៃ៉ អំពីទេសភាពដ៏ធំលឿងលើយដែលព្រះអាទិត្យដ៏ត្រចះត្រចង់បានបង្កើតមក នៅពេលនោះ។ នៅពេលដែលខ្ញុំសំលឹងមើលទស្សនីយភាពដ៏ឆើតឆាយនេះដោយគោរពកោតសរសើរ នោះបានក្លាយទៅជាទ្រង់ទ្រាយនៃបង្ហូចមួយ កាំរស្មីព្រិចៗនៃព្រះអាទិត្យដែលបានរះឡើងព្រាកៗនៅក្នុងផ្ទៃមេឃដែលស្រអាប់ ដោយបានផ្លាស់ប្តូរវត្ថុគ្រប់ទៅតាមពន្លឺ ពណិ និងជីវិតរបស់វា។ វាហាក់ដូចជាព្រះអម្ចាស់មានព្រះទ័យចង់ប្រទានឱ្យនូវពរជ័យជាច្រើនទៀត ដែលជានិមិត្តរូបនៃពន្លឺអំពីការបង្រៀនរបស់ទ្រង់ ដែលផ្តល់ឱ្យនូវភាពត្រចះត្រចង់ និងសេចក្តីសង្ឃឹមដល់យើងគ្រប់គ្នាដែលស្គាល់ការបង្រៀនរបស់ទ្រង់។ ទឹកភ្នែកនៃការដឹងគុណបានហូរស្រក់មក ចំពោះពិភពលោកដ៏អស្ចារ្យដែលយើងរស់នៅនេះ ចំពោះភាពស្រស់ស្អាតខុសប្លែកពីធម្មតា ដែលព្រះវរបិតារបស់យើងប្រទានឱ្យដោយសេរីដល់អ្នកទាំងឡាយណាដែលស្រេកឃ្លាន ចង់ឃើញ ចង់ដឹង និងចង់យល់។ ជីវិតពិតជាស្រស់ស្អាតណាស់។

មានអំណរគុណចំពោះសោភ័ណភាពនៃជីវិត

តើអ្នកធ្លាប់យកពេលដើម្បីសំគាល់មើលអំពីជីវិតរបស់ខ្លួនរាល់ថ្ងៃ ថាតើជីវិតរបស់អ្នកមានភាពស្រស់ស្អាតយ៉ាងណានោះទេ? ចាប់តាំងអំពីពេលដែលអ្នកបានមើលព្រះអាទិត្យលិចចុះមក តើវាមានរយះពេលប៉ុន្មានហើយ—កាំរស្មីព្រះអាទិត្យដើមឈើ ទួលតូចៗ និងដីទំនាប ជួនកាលដោយស្ងប់ស្ងាត់ ជួលកាលលិចឡើងនូវពណិ និងទ្រង់ទ្រាយឡើងយ៉ាងច្រើនដែរឬទេ?

តើផ្ទៃមេឃស្រលះល្អយ៉ាងណាទៅ នៅពេលដែលព្រះអម្ចាស់បានបង្ហាញនូវស្ថានសួគិដ៏គួរឱ្យស្ងប់ស្ងែងរបស់ទ្រង់—ផ្កាយរះព្រាកៗ កម្មរស្មីនារាត្រីកាល—ដើម្បីបំភ្លឺគំនិតរបស់យើងដោយភាពមហស្ចារ្យ និងភាពរុងរឿងរបស់ទ្រង់នោះ?

តើវាគួរឱ្យចាប់អារម្មណ៍ប៉ុណ្ណាទៅ នៅពេលដែលឃើញគ្រាប់ពូជដែលបានដាំរួចបានលូតលាស់លើដីដែលមានជីជាតិ រីកលូតលាស់ដោយកម្លាំង និងមានត្រួយតូចលាស់ឡើង មើលទៅដូចជាពន្លកខ្ចីល្ហក់។ វាចាប់ផ្តើមដុះ និងលូតលាស់ឡើងយឺតៗតាមសភាវះរបស់វា ដែលបានដុះឡើងតាមក្រមសើនេទិកដែលព្រះអម្ចាស់បានរៀបចំឡើងដើម្បីជួយដល់ការលូតលាស់របស់វា។ ដោយមានការថែទាំ នោះវាប្រាកដជាដុះលូតលាស់ទៅជាអ្វីដែលត្រូវបានកំណត់ទុកជាះ ផ្កាលីលីប្រកបដោយភាពទាក់ទាញ និងសំរស់ស្រស់ស្អាត រុក្ខជាតិដែលមានខ្លិនក្រអូបពិដោរ ផ្លែភិចផ្លែប៊ឺ ឬផ្ការីកមានសំរស់ស្រស់ស្អាតដ៏ប្រណិត ពណិស្រាល និងគន្ធពិដោរ។

តើអ្នកធ្លាប់បានឃើញផ្កាកូឡាបក្រពុំនៅក្រពុំបានដល់ពេលណា? រាល់ថ្ងៃវាលូតលាស់តាមសភាវះថ្មី និងគួរឱ្យចាប់អារម្មណ៍យ៉ាងខ្លាំង មានសំរស់កាន់តែស្អាតរហូតដល់ក្លាយទៅជាផ្កាកុឡាបពេញលក្ខណៈ។

អ្នកគឺជាការបង្កបង្កើតដ៏អស្ចារ្យជាងគេបំផុតនៃការបង្កបង្កើតរបស់ព្រះ។ ព្រះរាជបំណងរបស់ទ្រង់ គឺថាចង់ឱ្យជីវិតរបស់អ្នកស្រស់បំព្រងល្អរុងរឿង នៅគ្រប់កាលះទេសះរបស់អ្នក។ ពេលអ្នកមានអំណរគុណ និងប្រណិបត្តិតាម នោះអ្នកនឹងប្រែក្លាយដូចជាអ្វីដែលព្រះមានព្រះរាជបំណងចង់ឱ្យអ្នកប្រែក្លាយ។

សេចក្តីអំណរក្នុងជីវិតគឺពឹងផ្អែកលើជំនឿលើព្រះ

ទុក្ខព្រួយ ការខកចិត្ត និងឧបសគ្គធ្ងន់ធ្ងរគឺជា *ព្រឹត្តិការណ៍ផ្សេងៗ* នៅក្នុងជីវិត វាមិនមែនតែជាជីវិតនោះទេ។ ខ្ញុំមិនបានកាត់បន្ថយនូវបញ្ហាលំបាកទាំងនេះឱ្យនៅខ្លីនោះទេ។ ព្រឹត្តិការណ៍ទាំងនេះអាចអូសបន្លាយរយៈពេលវែង ប៉ុន្តែបញ្ហាទាំងនេះមិនគួរបណ្តោយឱ្យក្លាយទៅជាចំនុចយុំយាំងនូវរាល់អ្វីៗ ដែលអ្នកធ្វើនោះឡើយ។ ព្រះអម្ចាស់បានបំផុសគំនិត លីហៃ ឱ្យប្រកាសអំពីមូលដ្ឋានគ្រឹះនៃសេចក្តីពិតថាះ "មនុស្សលោក ដើម្បីឱ្យគេអាចមានសេចក្តីអំណរ។"[1] ហើយនេះគឺជាសេចក្តីថ្លែងការណ៍ដែលមានលក្ខខណ្ឌៈ "ពួកគេ *អាច* មានសេចក្តីអំណរ"។ វាពុំមែនជាលក្ខខណ្ឌសំរាប់ព្រះអម្ចាស់ឡើយ។ ព្រះរាជបំណងរបស់ទ្រង់គឺថាពួកយើងម្នាក់ៗត្រូវស្វែងរកសេចក្តីរីករាយ។ វានឹងពុំមែនជាលក្ខខណ្ឌចំពោះអ្នកឡើយ នៅពេលដែលអ្នកគោរពប្រណិបត្តិព្រះបញ្ញត្តិទាំងឡាយ មានជំនឿទៅលើលោកចៅហ្វាយ ព្រមទាំងធ្វើកិច្ចការទាំងឡាយដែលចាំបាច់ ដើម្បីឱ្យមានសេចក្តីអំណរនៅផែនដីនេះ។

សេចក្តីអំណរនៅក្នុងជីវិតរបស់អ្នកពឹងផ្អែកទៅលើទំនុកចិត្តរបស់អ្នក ចំពោះព្រះវរបិតាសួគ៌ និងព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ទ្រង់ ការជឿជាក់របស់អ្នកថាផែនការនៃសុភមង្គលរបស់ទ្រង់ទាំងពីរអង្គពិតជាអាចនាំមកឱ្យអ្នកនូវសេចក្តីអំណរ។ ការគិតពិចារណា អំពីគោលលទ្ធិរបស់ទ្រង់ទាំងពីរអង្គនឹងនាំឱ្យអ្នកមានសេចក្តីអំណរចំពោះសោភ័ណ្ឌភាពនៃផែនដីនេះ និងបង្កើនទំនាក់ទំនងរបស់អ្នកជាមួយអ្នកដទៃទៀត។ វានឹងជួយអ្នកឱ្យមានជាសុកភាព ពង្រីកបទពិសោធន៍ ដែលជាលំហូរមកពីការអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ និងចម្លើយដែលទ្រង់ឆ្លើយតបមកវិញ។

ទស្សនវិស័យ និងសេចក្តីអំណត់

គ្រាប់ត្រួសតូចមួយដាក់ជិតភ្នែក នោះវាកើតឡើងជាឧបសគ្គដ៏ធំ។ កាលណាបោះចោលទៅលើដី នោះវាត្រូវបានមើលឃើញជាលក្ខណៈទស្សនវិស័យមួយ។ ទន្ទឹមនឹងនេះផងដែរ បញ្ហា ឬការសាកល្បងផ្សេងៗនៅក្នុងជីវិតរបស់អ្នក ចាំបាច់ត្រូវតែប្រមើរមើលតាមលក្ខណៈជាទស្សនវិស័យ នៃគោលលទ្ធិខាងបទព្រះគម្ពីរ។ បើមិនដូច្នោះទេ បញ្ហា និងការសាកល្បងទាំងនេះអាចនឹងគ្រប់គ្រងលើការនិមិត្តរបស់យើង ស្រូបយកថាមពលរបស់យើង ហើយដកហូតយកនូវសេចក្តីអំណរ និងភាពស្រស់ស្អាត ដែលព្រះអម្ចាស់ចង់ឱ្យយើងទទួលនៅផែនដីនេះ។ មនុស្សមួយចំនួនគឺដូចជាដុំថ្មដែលបានបោះចោលទៅក្នុងសមុទ្រនៃបញ្ហា។ ពួកគេត្រូវបានលិចទៅក្នុងទឹកដោយសារបញ្ហាទាំងនោះ។ ចូរធ្វើជាអ្នកបញ្ស្យប់។ នៅពេលជួបប្រទះនឹងបញ្ហាមួយ ត្រូវប្រយុទ្ធដើម្បីសេរីភាព ត្រូវក្រោកឡើងដើម្បីបំរើម្តងទៀតដោយរីករាយ។

អ្នកមានវត្តមាននៅលើផែនដីនេះដោយគោលបំណងដ៏ទេវភាព។ វាមិនមែនជាការកំសាន្តដោយគ្មានទីបញ្ចប់ ឬជាការស្វែងរកការសប្បាយរីករាយដែលគ្មានទីបញ្ចប់នោះទេ។ អ្នកមានវត្តមាននៅផែនដីនេះដើម្បីធ្វើការពិសោធន៍ សរបញ្ជាក់ខ្លួនឯងថា អ្នកអាចទទួលពរជ័យជាច្រើនទៀតដែលព្រះមានទុកឱ្យអ្នក។[2] ចាំបាច់ត្រូវតែមានសេចក្តីអំណត់។[3] ពរជ័យខ្លះនឹងទទួលបានឥឡូវ នេះក្នុងជីវិតនេះ ពរជ័យផ្សេងទៀតនឹងមកដល់នៅពេលជីវិតនេះ។

ព្រះអម្ចាស់មានផែនការសំរាប់ការរីកលូតលាស់ និងការអភិវឌ្ឍន៍ផ្ទាល់ខ្លួនរបស់អ្នក។ វឌ្ឍនភាពនោះ ត្រូវពន្លឿននៅពេលអ្នកមានស្មារតីចង់ឱ្យទ្រង់ដឹកនាំអ្នកនៅគ្រប់បទពិសោធន៍នៃការរីកចំរើនដែលអ្នកជួបប្រទះ មិនថាឡើយវាជាការចូលចិត្តផ្ទាល់របស់អ្នក ឬអត់នោះទេ។ នៅពេលអ្នកមានទំនុកចិត្តលើព្រះអម្ចាស់ នៅពេលអ្នកសុខចិត្តឱ្យដួងចិត្តរបស់អ្នក និងគំនិតរបស់អ្នកផ្តោតទៅលើព្រះហរទ័យរបស់ទ្រង់ នៅពេលអ្នកបង្ពុំសុំការដឹកនាំដោយព្រះវិញ្ញាណ ដើម្បីធ្វើតាមព្រះហរទ័យរបស់ទ្រង់ នោះអ្នកច្បាស់ជាទទួលបាននូវសុភមង្គលដ៏អស្ចារ្យ ព្រមទាំងបំពេញបានទូវសមិទ្ធិផលជាច្រើនពីបទពិសោធន៍ក្នុងជីវិតនេះ។ ប្រសិនបើអ្នកមានចម្ងល់ចំពោះអ្វីគ្រប់យ៉ាងដែលត្រូវបានសុំឱ្យអ្នកធ្វើ ឬត្រូវតទល់នូវរាល់បញ្ហាលំបាក នោះអ្នកត្រូវតែតស៊ូ ដើម្បីទទួលបានពរជ័យពីព្រះអម្ចាស់។[4]

សិទ្ធិនៃការជ្រើសរើសរបស់អ្នក សិទ្ធិដើម្បីធ្វើការជ្រើសរើស មិនមែនផ្តល់ឱ្យដើម្បីអ្នកអាចទទួលនូវអ្វីដែលអ្នកចង់បាននោះទេ។ អំណោយទានដ៏ទេវភាពនេះ ត្រូវបានផ្តល់ឱ្យដើម្បីអ្នកនឹងធ្វើការជ្រើសរើសនូវអ្វី ដែលព្រះវរបិតាសួគ៌របស់អ្នកមានព្រះរាជបំណងចង់ប្រទានឱ្យអ្នក។ តាមមាគ៌ានេះ ទ្រង់អាចដឹកនាំអ្នកឱ្យក្លាយជាអ្វីដែលទ្រង់ចង់ឱ្យអ្នកក្លាយជាយ៉ាងនោះ។[5] មាគ៌ានោះ នាំមកនូវសេចក្តីអំណរដ៏ និងសុភមង្គលដ៏រុងរឿង។

រស់នៅដោយមានសេចក្តីអំណរក្នុងពេលមានទុក្ខលំបាក

ចូររៀនអំពីបុគ្គលដែលពោរពេញដោយការបំផុសគំនិត ជាជនដែលបានបង្កើតនូវសេចក្តីសុខសាន្ត នៅពេលពួកគេជួបប្រទះនូវឧបសគ្គ និងរស់នៅដោយរីករាយក្នុងពេលមានទុក្ខលំបាក។ ស្ត្រីគួរជាទីស្រឡាញ់ម្នាក់ ដោយមានការឈ្លានពានជាប្រចាំពីជំងឺមិនអាចព្យាបាលបាន បានរកឃើញសេចក្តីអំណរនៅក្នុងជីវិត។ គាត់បានយល់អំពីផែនការនៃសេចក្តីសុភមង្គល បានទទួលពិធីការនៅក្នុងព្រះវិហារបរិសុទ្ធ ហើយបានប្រឹងអស់អំពីសមត្ថភាពរបស់គាត់ ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការទទួលបានពរជ័យដែលបានសន្យាទុក។ ស្សៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់គាត់សរសេរថា ៖

"វាជាថ្ងៃនៃរដូវស្លឹកឈើជ្រុះដ៏ស្រស់ស្អាត។ ខ្ញុំបានយកសំបុត្រ ហើយបានអង្គុយនៅលើទោង។ ខ្ញុំសប្បាយចិត្តណាស់ ហើយ មានអារម្មណ៍កក់ក្តៅក្រោមកំដៅព្រះអាទិត្យ ក្លិនក្រអូបពីធម្មជាតិ និងព្រៃព្រឹក្សានៅជុំវិញខ្លួនខ្ញុំ។ ខ្ញុំបានអង្គុយចុះ ហើយសរសើរខ្លួនឯង ដោយហេតុថា ខ្ញុំនៅមានជីវិតរស់នៅលើផែនដីដ៏ស្រស់ត្រកាលនេះនៅឡើយ . . .។ ព្រះអម្ចាស់ល្អចំពោះខ្ញុំណាស់។ ខ្ញុំមានអំណរគុណចំពោះទ្រង់ខ្លាំងណាស់ ដែលខ្ញុំនៅតែមានវត្តមាននៅទីនេះ និងមានអារម្មណ៍ល្អ។ ខ្ញុំសប្បាយចិត្តណាស់ ខ្ញុំចង់តែស្រែក និងរាំក្នុងគេហដ្ឋានដ៏ស្រស់ស្អាតនេះ នៅពេលដែលរស្មីព្រះអាទិត្យចាំងចូលទៅតាមបង្អួចធំ។ ខ្ញុំស្រឡាញ់ជីវិតរស់"។[6]

ម្តាយដ៏អង់អាចមួយរូបកំពុងប្រយុទ្ធយ៉ាងក្លៀវក្លាជាមួយនឹងជម្ងឺ ដែលធ្វើឱ្យល្ហិតល្ហៃដែលបានចំណាយពេលជាច្រើនម៉ោង ដើម្បីបញ្ចប់ការងារដ៏ធំមួយ ដោយខិតខំធ្វើការផ្នែកសិល្បះដេរប៉ាក់។ វាគឺជាអំណោយមួយចំពោះគូស្វាមីភរិយាទាំងពីរ ដែលជួបប្រទះការសាកល្បងជាច្រើន។ ចំពោះគូស្វាមីភរិយានេះ វាគឺជាសម្បត្តិមិនអាចកាត់ថ្លៃបាន វាបានរំឈ្មកជានិច្ចកាលចំពោះផល្លាដ៏ថ្លៃថ្លានៃការប្រឹងប្រែង ក្នុងពេលជួបប្រទះនឹងទុក្ខលំបាក សារលិខិតចុងក្រោយនៃក្តីសង្ឃឹមបានរួមបញ្ចូលនូវចំណង នៃសេចក្តីស្រឡាញ់ដ៏បរិសុទ្ធ និងការពលិកម្មខ្ពង់ខ្ពស់។

ស្វែងរកសេចក្តីអំណរ *ដែល* អ្នកមាន

កុមារបង្រៀនយើងពីរបៀបស្វែងរកសេចក្តីអំណរ បើទោះបីជាស្ថិតនៅក្រោមកាលៈទេសៈដ៏លំបាកបំផុតក្តី។ ប៉ុន្តែកុមារមិនទាន់ បានរៀននៅឡើយពីការកៀបសង្កត់ផ្លូវចិត្ត ដោយផ្តោតលើអ្វីដែលពួកគេពុំមានទេ។ ពួកគេស្វែងរកសេចក្តីអំណរក្នុងអ្វីដែលពួកគេមាន។ ខ្ញុំចងចាំពីក្មេងប្រុសម្នាក់ដែលបានរត់លេងនៅតាមដងទន្លេ។ គាត់បានចងកំប៉ុងភេសជ្ជៈនៅចុងខ្សែសន្ទូច។ គាត់បោះកំប៉ុងម្ខាងទៅ

លើមែកឈើ ហើយគាត់បានដាក់ទឹកនៅកំប៉ុងម្ខាងទៀត។ គាត់នឹងទាញកំប៉ុងម្ខាងទៀត ហើយព្រលែងកំប៉ុងនោះ។ ទម្ងន់នៃកំប៉ុងទីមួយនឹងយោងកំប៉ុងទីពីរឡើង ក្នុងពេលដែលកំប៉ុងទីមួយធ្លាក់ចុះ។ គាត់សើច ហើយរាំដោយក្តីរីករាយ។

បទពិសោធន៍សាមញ្ញ និងធ្វើយុវកម្មនៅហ៊ុំព័ទ្ធខ្លួនយើង។ បទពិសោធន៍ទាំងនេះអាចជានិយ័តករសុវត្ថិភាពមួយដើម្បីទប់ការតានតឹងចុះ និងលើកវិញ្ញាណឱ្យរឹងមាំ។ ចូរកុំយកចិត្តទុកដាក់តែទៅលើអ្វីដែលអ្នកគ្មាន ឬបានបាត់ឡើយ។ ព្រះអម្ចាស់បានសន្យាដល់អ្នកដែលប្រណិបត្តិតាមឱ្យចែករំលែកនូវអ្វីទាំងអស់ដែលទ្រង់បានប្រទានឱ្យពួកគេ។ អ្នកអាចខ្ចះខាតបណ្តោះអាសន្ននៅជីវិតនេះ ប៉ុន្តែនៅក្នុងជីវិតបន្ទាប់ អ្វីៗទាំងអស់នឹងជាពរជ័យរបស់អ្នក ប្រសិនបើអ្នកធ្វើខ្លួនសក្តិសមជាអ្នករស់នៅដោយក្លាហាន។

ចូរស្វែងរកពរជ័យដែលត្រូវសងនៅក្នុងជីវិតរបស់អ្នក នៅពេលព្រះអង្គដកហូតពីអ្នកនូវអ្វីដែលអ្នកចង់បានបំផុត តាមព្រះបញ្ញាញាណនៃព្រះអម្ចាស់។ ចំពោះជនដែលពិការភ្នែក ឬថ្លង់ នោះទ្រង់ធ្វើឱ្យវិញ្ញាណផ្សេងទៀត អាចប្រើប្រាស់ជំនួសការពិការទាំងនោះបាន។ ចំពោះអ្នកជម្ងឺ ទ្រង់បានប្រទានឱ្យការអត់ធ្មត់ ការយល់ចិត្ត និងបង្កើតសេចក្តីអំណរដល់អ្នកសប្បុរសផ្សេងទៀត។ ចំពោះជនដែលបានបាត់បង់អ្នកជាទីស្រឡាញ់ ព្រះអង្គធ្វើឱ្យចំណងនៃសេចក្តីស្រឡាញ់កាន់តែជ្រាលជ្រៅ ធ្វើឱ្យមានអនុស្សាវីយ៍ និងបង្កឱ្យមានសេចក្តីសង្ឃឹមចំពោះការជួបជុំគ្នា នាពេលអនាគត។ អ្នកនឹងរកឃើញនូវពរជ័យដែលត្រូវសង នៅពេលអ្នកព្រមទទួលយកនូវព្រះឆន្ទៈនៃព្រះអម្ចាស់ ហើយអនុវត្តសេចក្តីជំនឿទៅលើទ្រង់។ 6

ចំពោះប្រជាជនអាលម៉ាដែលមានសេចក្តីទុក្ខវេទនា ព្រះអម្ចាស់មានព្រះបន្ទូលថា ៖

“ហើយយើងនឹងសំរាលបន្ទុក . . . ហើយសូម្បីតែរូបអ្នកក៏នឹងមិនអាចចាប់អារម្មណ៍ថាមានបន្ទុកនោះនៅលើខ្នងអ្នកឡើយ . . . ហើយ យើងនឹងធ្វើការនេះ ដើម្បីអ្នករាល់គ្នាអាចដឹងពិតប្រាកដថា យើងជាព្រះអម្ចាស់ដ៏ជាព្រះ មករករាស្ត្រយើងក្នុងពេលគេមានសេចក្តីទុក្ខវេទនា។

“ហើយ . . . បន្ទុកទាំងឡាយ . . . ត្រូវបានសំរាលទៅ មែនហើយព្រះអម្ចាស់បានចំរើនកម្លាំងឱ្យគេ ដើម្បីឱ្យគេអាចទ្របន្ទុកទាំងឡាយរបស់គេបានដោយងាយ ហើយពួកគេធ្វើតាមអស់ទាំងព្រះហរទ័យនៃព្រះអម្ចាស់ ដោយការរីករាយ និងដោយការអត់ធន់។”[7]

ការធ្វើជាមនុស្សច្នៃប្រឌិតនឹងជួយឱ្យអ្នករីករាយក្នុងជីវិត

ចូរព្យាយាមមានការច្នៃប្រឌិតដើម្បីឱ្យមានសេចក្តីអំណរដែលមានមកពីការឆ្នៃប្រឌិត។ ក្រោយពី ឧត្តមស្វាមីរបស់ពួកគាត់ត្រូវបានបញ្ចាប់បេសកកម្ម ស៊ុស្ទើរ កាមេឡា យិមបឹល ស៊ុស្ទើរ អាមេលៀ មេកខនយី និងស៊ុស្ទើរ ហេឡេន រីឆាឌ បានរៀនគូរគំនូរ។ ពួកគាត់មិនត្រឹមតែបន្សល់ទុកនូវកេរដំណែលខាងសិល្បៈប៉ុណ្ណោះទេ ប៉ុន្តែ ពួកគាត់នឹងលែងឃើញព្រះអាទិត្យលិចមុខ ឬព្រៃព្រឹក្សាដូចពីមុនទៀតហើយ។ ឥឡូវនេះ ពួកគាត់ស្គាល់តែពីការលាយពណិ និងគូរគំនូរ ហើយរីករាយនឹងសំរស់ដ៏សំបូរបែបពន្ធ័ជុំវិញនៃគំនូររបស់ពួកគាត់។

ចូរជ្រើសរើសអ្វីមួយដូចជាតន្ត្រី ការរាំរែក រូបចំលាក់ ឬកំណាព្យ។ ការធ្វើជាមនុស្សដែលមានភាពច្នៃប្រឌិត នឹងជួយអ្នកឱ្យមានសេចក្តីអំណរក្នុងជីវិត។ វានាំឱ្យមានស្មារតីនៃការដឹងគុណ។ វាបង្កើតទេពកោសល្យដែលលាក់កប់ ពង្រីកសមត្ថភាពរបស់អ្នកដើម្បីពិចារណាដើម្បីធ្វើ និងស្វែងរកគោលបំណងក្នុងជីវិត។ វាបំបាត់ភាពកណ្តោចកណ្តែង និងការឈឺចិត្ត។ វាផ្តល់ការផ្លាស់ប្តូរជាថ្មីផ្តល់ឱ្យនូវសេចក្តីអំណរសាទរ ព្រមទាំងសេចក្តីសោមនស្សនៃជីវិត។

ការបំរើ ៖ គន្លឹះទៅរកសុភមង្គល

ការបំរើអ្នកដទៃដោយស្ម័ត្រចិត្តគឺជាគន្លឹះនៃសុភមង្គលស្ថិតស្ថេរ។ ប្រធានស្ពែនស៊ើរ ដបុលយូ យឹមបឹល បានមានប្រសាសន៍ថាៈ “ព្រះពិតជាសំគាល់មើលពួកយើង ហើយទ្រង់មើលថែរក្សាពួកយើង។ ប៉ុន្តែ ជាធម្មតា ការណ៍នោះធ្វើឡើងតាមរយៈមនុស្សផ្សេងទៀតដែលបុគ្គលនោះអាចបំពេញសេចក្តីត្រូវការរបស់យើងបាន។ ហេតុដូច្នេះហើយ វាចាំបាច់ណាស់ ដែលយើងត្រូវបំរើគ្នាទៅវិញទៅមក។”[8]

ខ្ញុំស្គាល់ស្ត្រីម្នាក់ដែលជាមនុស្សសប្បាយរីករាយណាស់។ រៀងរាល់ព្រឹក គាត់អធិដ្ឋានដល់ព្រះវរបិតាសួគិ ដើម្បីនាំផ្លូវគាត់ឱ្យជួបនឹងនរណាម្នាក់ដែលគាត់អាចជួយបាន។ ការអធិដ្ឋានដ៏ស្មោះត្រង់នោះ ត្រូវបានឆ្លើយតបម្តងហើយម្តងទៀត។ បន្ទុកដ៏ធ្ងន់របស់មនុស្សជាច្រើនត្រូវបានធ្វើឱ្យធូរស្រាល ហើយជីវិតរបស់ពួកគេត្រូវបានធ្វើឱ្យភ្លឺថ្លា។ ស្ត្រីម្នាក់នោះ ត្រូវបានទទួលពរជ័យជាបន្តបន្ទាប់ ក្នុងការធ្វើជាអ្នកប្រណិបត្តិតាមការដឹកនាំរបស់ព្រះអម្ចាស់។

ការលំបាកអាចក្លាយជាការរីកចំរើន

ខ្ញុំដឹងថាគ្រប់ការលំបាកដែលយើងជួបប្រទះក្នុងជីវិត សូម្បីតែការលំបាកទាំងឡាយដែលបណ្តាលមកពីសេចក្តីធ្វេសប្រហែសផ្ទាល់ខ្លួន ឬការរំលងអាចក្លាយទៅជាបទពិសោធន៍ឆ្ពោះទៅរកការរីកចំរើន ដោយសារព្រះអម្ចាស់ជាមគ្គុទេសក៏ដឹកនាំដ៏ឆ្នើមមួយអង្គ។[9] ខ្ញុំពិតជាមិនផ្តល់អនុសាសន៍ថាសេចក្តីរំលងជាមាគិានាំទៅរកការរីកចំរើននោះឡើយ។ វាឈឺចាប់ លំបាក ហើយមិនសំខាន់អ្វីទាំងអស់។ វាជាការវាងវៃជាង និងមានលក្ខណៈងាយស្រួលបំផុតក្នុងការឈានឆ្ពោះទៅរកសេចក្តីសុចរិត។ ប៉ុន្តែ តាមរយៈការប្រែចិត្ត ជំនឿសមរម្យទៅលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងការគោរពប្រណិបត្តិតាមព្រះបញ្ញត្តិរបស់ទ្រង់សូម្បីតែការខកចិត្តដែលបណ្តាលមកពីការរំលងអាចផ្លាស់ប្តូរមកជាមានសុភមង្គលវិញបាន។

ធ្វើជាតារាងមួយនូវអ្វីដែលអ្នក អាចធ្វើដើម្បីទទួលបានការសប្បាយរីករាយដូចជា ៖

- ពិចារណាពីខគម្ពី ដើម្បីយល់ពីផែនការនៃសុភមង្គល។
- អធិដ្ឋានដោយជំនឿលើព្រះយេស៊ូវគ្រីស្ទ។
- ស្រឡាញ់ និងបំរើអ្នកដទៃ។
- ទទួលពិធីការនៅក្នុងព្រះវិហារបរិសុទ្ធ។ ដើម្បីប្រសិទ្ធពរដល់អ្នកផ្សេង។
- ស្តាប់ព្យាការី និងគោរពប្រណិបត្តិតាមដំបូន្មានរបស់លោក។
- ដឹងគុណនូវអ្វីដែលអ្នកមាន។
- ញញឹមឱ្យបានច្រើន។

តារាងរបស់អ្នកនឹងផ្តល់នូវគន្លឹះ ដើម្បីទទួលបានការសប្បាយចិត្ត និងការរីករាយ។

បញ្ហាគឺជារឿងបណ្ណោះអាសន្ន ប៉ុន្តែសុភមង្គលគឺជារឿងដ៏នៅអស់កល្បជានិច្ច

ចំរៀងដ៏ល្បីរបស់ជាតិប្រេស៊ីលមួយនិយាយដដែលៗនូវពាក្យខុសឆ្គងមួយដែលមនុស្សជាច្រើនជឿថា ៖ ទុក្ខព្រួយគ្មានអវសាន្ត ប៉ុន្តែសុភមង្គលមានអវសាន្ត។ ខ្ញុំធ្វើទីបន្ទាល់ថា តាមរយះសេចក្តីជំនឿលើព្រះអង្គសង្ក្រោះ និងការប្រណិបត្តិតាមការបង្រៀនរបស់ទ្រង់ នោះសុភមង្គលគ្មានអវសាន្ត ផ្ទុយទៅវិញទុក្ខព្រួយគឺមានអវសាន្ត។

មិនថាឡើយអ្នក និងមនុស្សជាទីស្រឡាញ់របស់អ្នកជួបប្រទះនូវបញ្ហាលំបាកយ៉ាងណានោះទេ វាមិនគួរគ្របដណ្តប់លើជីវិតរបស់អ្នកឡើយ ហើយក្លាយជារឿងសំខាន់នៃអារម្មណ៍របស់អ្នកទេ។ បញ្ហាលំបាកៗគឺជាបទពិសោធន៏រីកចំរើន ជាឆាកបណ្តោះអាសន្ន ដែលត្រូវបានលេងនៅផ្ទៃខាងក្រោយនៃជីវិតដែលរីករាយប៉ុណ្ណោះ។ សូមកុំក្លាយជាអ្នកទទួលយកបញ្ហាក្នុងព្រឹត្តការណ៍ណាមួយ ដែលអ្នកមិនអាចគិតពីអ្វីទាំងអស់ ឬក៏ខ្ចល់ចំពោះខ្លួនឯង ឬចំពោះអ្នកទាំងឡាយណាដែលពឹងអាស្រ័យលើអ្នកឡើយ។ ចូរចងចាំនូវចំណូលចិត្តក្នុងការព្យាបាលរាងកាយ ការធ្វើឱ្យស្មារតី និងបញ្ហាអារម្មណ៍ជាសះស្បើយត្រូវការពេលវេលា។

ព្រះអម្ចាស់មានព្រះបន្ទូលថា ៖ "ចូរមានចិត្តអត់ធន់ក្នុងការឈឺចាប់ ត្បិតអ្នកនឹងមានដ៏ច្រើន ប៉ុន្តែចូរទ្រាំចុះ ត្បិតមើលន៏ យើងនៅ ជាមួយនឹងអ្នកគឺដរាបដល់អស់មួយជីវិតរបស់អ្នក។"[10] នៅពេលអ្នកមានអំណត់ អ្នកនឹងបានយល់នូវអត្ថន័យ នៃពាក្យដែលបានប្រាប់ថា "យើងនៅជាមួយនឹងអ្នក"។ សេចក្តីស្រឡាញ់របស់ព្រះនាំមកនូវសេចក្តីសុខសាន្ត និងសេចក្តីអំណរ។

ជំនឿរបស់អ្នកលើព្រះយេស៊ូវគ្រីស្ទ ផ្តល់នូវស្ថិតស្ថេរភាពជីវិតដ៏មានអត្ថន័យ។ សូមចងចាំថា អ្នកកំពុងធ្វើដំណើរឆ្ពោះទៅកាន់ភាពដំកើនឡើង។ ជួនកាលអ្នកជួបប្រទះនូវអ្វីដែលឱ្យផលនៃសុភមង្គលច្រើនជាងអ្នកដទៃ ប៉ុន្តែជាមួយព្រះអម្ចាស់ការណ៍នេះសុទ្ធតែមានគោលបំណងទាំងអស់។[11]

ក្នុងនាមជាសាក្សីនៃព្រះអង្គសង្ក្រោះ ខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យអត់ទោសដល់ជនណាដែលអ្នកគិតថា បានប្រមាថមើលងាយដល់អ្នក។ ប្រសិនបើមានអំពើរំលងដែលព្រះអម្ចាស់អាចធ្វើឱ្យអ្នកសះស្បើយបាន នៅពេលមានការប្រែចិត្តរបស់វា។

ចូរថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៏របស់អ្នក និងបុត្រាដ៏ជាទីស្រឡាញ់របស់ទ្រង់ ចំពោះផែនការនៃសុភមង្គល និងគោលការណ៍ដំណឹងល្អដែលពឹងផ្អែកទៅលើមូលដ្ឋានគ្រឹះរបស់វា។ ចូរមានអំណរគុណដល់ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយដែលទ្រង់ទាំងពីរអង្គបានប្រទានឱ្យ។ ខ្ញុំធ្វើជាទីបន្ទាល់ដោយស្មោះអស់ពីចិត្តថា ព្រះអង្គទាំងពីរមានអំណាចដើម្បីគ្រងជីវិតរបស់អ្នកដោយសេចក្តីសុខសាន្ត និងសេចក្តីអំណរ ដើម្បីផ្តល់នូវគោលបំណង និងអត្ថន័យរបស់វា។ អ្នកនឹងដឹងថាទុក្ខព្រួយ និងការខកចិត្តគឺជារឿងបណ្តោះអាសន្ន។ សុភមង្គលគឺជារឿងដ៏នៅអស់កល្បជានិច្ច គឺដោយសារព្រះយេស៊ូវគ្រីស្ទ។ ខ្ញុំសូមធ្វើទីបន្ទាល់ដោយឧឡារិកថា ទ្រង់មានព្រះជន្មរស់នៅ ទ្រង់សព្វព្រះទ័យអ្នក ហើយទ្រង់នឹងជួយអ្នក។

ដកស្រង់ចេញពីសុន្ទករថារបស់អែលឌើរ ស្តត ក្នុងសន្និសីទទូទៅនៃសាសនាចក្រ ខែ មេសា ឆ្នាំ 1996 (សូមមើល Conference Report ខែ មេសា ឆ្នាំ 1996 ទំព័រ 31–35 ឬ *Ensign* ខែ ឧសភា ឆ្នាំ 1996 ទំព័រ 24–26)។

កំណត់ចំណាំ

1. នីហ្ចែទី 2 2:25។
2. សូមមើល អ័ប្រាហាំ 3:25។
3. សូមមើល ម៉ូសាយ 3:19។
4. សូមមើល នីហ្ចែទី 1 3:7។
5. សូមមើល គោលលទ្ធិ និងសេចក្តីសញ្ញា 58:26–32។
6. សូមមើល Orson F. Whitney បានដកស្រង់នៅក្នុង ស្តែនស៊ើរ ដបបិលយូ ឃឺមបឹល *Faith Precedes the Miracle* (1972), 98។
7. ម៉ូសាយ 24:14–15។
8. *The Teachings of Spencer W. Kimball,* ed. Edward L. Kimball (ឆ្នាំ 1982), 252។
9. សូមមើល អេសាយ 40:31។
10. គោលលទ្ធិ និងសេចក្តីសញ្ញា 24:8។
11. សូមមើល យ៉ូសែប អែហ្ចូ ស្មីធ *គោលលទ្ធិនៃដំណឹងល្អ* ការបោះពុម្ពជាលើកទី 5 (ឆ្នាំ 1939), 177។

អំណាចញ្យាបាលនៃការអភ័យទោស

7

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលះទេសះរបស់អ្នកផ្ទាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- សិក្សាពីតំរូវនៃការអត់ទោស តាមខគម្ពីរដូចតទៅ ៖ លូកា 23:33–34 កិច្ចការ 7:58–60 នីហ្វៃទី 1 7:8–21។
- ចូរប្តេជ្ញាដើម្បីមានការអត់ទោស និងធ្វើខ្លួនសក្តិសមឱ្យបានច្រើន ចំពោះការអត់ទោសឱ្យអ្នកដទៃ។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

"អ្នកតំរូវឱ្យមានការអភ័យទោស"

ប្រធាន ហ្គរដុន ប៊ី ហ៊ុងគ្លី
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

វិញ្ញាណនៃការអភ័យទោស និងអាកប្បកិរិយានៃសេចក្តីស្រឡាញ់ ព្រមទាំងសេចក្តីមេត្តាករុណាចំពោះអ្នកទាំងឡាយណាដែលអាចធ្វើខុសចំពោះពួកយើងគឺមានសារៈសំខាន់បំផុតនៅក្នុងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ យើងម្នាក់ៗត្រូវការនូវវិញ្ញាណនេះ។ ពិភពលោកទាំងមូលត្រូវការនូវវិញ្ញាណនេះ។ ព្រះអម្ចាស់បានបង្រៀនអំពីវិញ្ញាណនេះ។ ព្រះអង្គបានបង្ហាញពីតំរូវនៃវិញ្ញាណនេះ ដែលពុំមាននរណាផ្សេងទៀតបានបង្ហាញពីតំរូវនេះឡើយ។

នៅពេលដែលទ្រង់ឈឺចាប់នៅលើឈើឆ្កាងនៅខាលវារី ជាមួយនឹងអ្នកចោទប្រកាន់ដ៏សាហាវ និងគួរឱ្យស្អប់ខ្ពើមនៅចំពោះ មុខទ្រង់ និងអ្នកទាំងឡាយណាដែលបាននាំទ្រង់មកឆ្កាងដែលគួរឱ្យរន្ធត់នេះ ទ្រង់មានបន្ទូលថា ៖ "ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ត្បិតគេមិនដឹងជាគេធ្វើអ្វីទេ" (លូកា 23:34)។

ពួកយើងពុំមានតរម្នាក់ត្រូវបានបញ្ជាឱ្យធ្វើការអភ័យទោសដោយសប្បុរសណាស់ណានោះទេ ប៉ុន្តែយើងម្នាក់ៗស្ថិតក្រោមកាតព្វកិច្ចនៃព្រះបន្ទូលដ៏ទេវភាពដើម្បីសំរេចដោយសេចក្តីមេត្តាករុណា។ ព្រះអម្ចាស់បានថ្លែងនៅក្នុងវិវរណថា ៖ "ពួកសិស្សរបស់យើងនៅសម័យបុរាណ បានស្វែងរកឱកាសទាស់ទែងគ្នាទៅវិញទៅមក ហើយមិនអត់ទោសឱ្យគ្នាទៅវិញទៅមកនៅក្នុងចិត្តរបស់ពួកគេទេ ហើយចំពោះការអាក្រក់នេះ ពួកគេត្រូវបានរងទុក្ខ និងបានវាយផ្ចាលជាខ្លាំង។

"ហេតុដូច្នេះហើយ យើងប្រាប់អ្នកថា អ្នកត្រូវអត់ទោសឱ្យគ្នាទៅវិញទៅមក ត្បិតអ្នកណាដែលមិនអត់ទោសដល់បងប្អូនរបស់ខ្លួន ចំពោះការរំលងរបស់គេទេ នោះជាប់ទោសនៅចំពោះមុខព្រះអម្ចាស់ ព្រោះនៅជាប់នឹងអ្នកនោះគឺជាបាបដ៏ធំជាង។

"យើងជាព្រះអម្ចាស់នឹងអត់ទោសដល់អ្នកណាដែលយើងនឹងអត់ទោស ប៉ុន្តែរីឯអ្នកវិញគឺតំរូវឱ្យអត់ទោសដល់មនុស្សទាំងអស់។

"ហើយអ្នករាល់គ្នាត្រូវនិយាយនៅក្នុងចិត្តថា—សូមឱ្យព្រះអង្គជំនុំជំរះរវាងអ្នក និងខ្ញុំ ហើយសងតាមអំពើដែលអ្នកធ្វើចុះ" (គ. និង ស. 64:8–11)។

តើយើងត្រូវការអនុវត្តនូវគោលការណ៍ដែលព្រះបានផ្តល់ឱ្យ និងគោលការណ៍ដែលជាដៃគូរបស់វាគឺការប្រែចិត្តនេះប៉ុណ្ណាទៅ! យើងមើលឃើញនូវសេចក្តីត្រូវការនេះនៅក្នុងគេហដ្ឋាននៃប្រជាជនទាំងពួង ដែលកំហុសតូចតាចផ្ទុំជាជម្លោះធំប៉ុនភ្នំ។ យើងឃើញវាមាននៅក្នុងចំណោមអ្នកជិតខាង ដែលការខ្វែងគំនិតមិនសំខាន់ បាននាំទៅដល់ភាពជូរចត់គ្មានទីបញ្ចប់។ យើងឃើញវានៅក្នុងធុរកិច្ចរួមគ្នាដែលមានជម្លោះ ហើយបានបដិសេធមិនព្រមទទួលការសម្រុះសម្រួល និងអត់ទោសឱ្យគ្នាជាឧទាហរណ៍ ប្រសិនបើមានឆន្ទះអង្គុយជុំគ្នា ហើយជជែកគ្នាដោយស្បៀមស្ងាត់រវាងគ្នានិងគ្នានោះ នោះរឿងរ៉ាវអាចត្រូវបានដោះស្រាយហើយទទួលបានពរជ័យទាំងអស់គ្នា។ វាប្រសើរជាងពួកគេចំណាយពេលមួយថ្ងៃៗ របស់ពួកគេចិញ្ចឹមចិត្តគុំគួន និងប៉ុនប៉ងញ្យាបាទគ្នា។

នៅក្នុងឆ្នាំទីមួយនៃការរៀបចំចាត់ចែងសាសនាចក្រ នៅពេលញ្យាការីយ៉ូសែបស្មឹធត្រូវបានចាប់ខ្លួន និងកាត់ទោសម្តង ហើយម្តងទៀត ហើយជាប់ក្នុងការចោទប្រកាន់ខុស ដោយពួកអ្នកដែលស្វែងរកការធ្វើទុក្ខទោសដល់លោកព្រះអម្ចាស់ បានមានព្រះបន្ទូលទៅកាន់លោកតាមរយៈវិវរណៈថា "ហើយអស់អ្នកណាដែលនឹងទៅរកច្បាប់ទាស់នឹងអ្នក អ្នកនោះនឹងត្រូវបណ្តាសារ ដោយសារច្បាប់" (គ. និង ស. 24:17)។ ខ្ញុំបានឃើញការណ៍នេះកើតឡើងនៅជំនាន់របស់យើង ក្នុងចំណោមអ្នកខ្លះបានចិញ្ចឹមចិត្តចងគំនុំលើគំនុំ។ ទោះក្នុងចំណោមអ្នកខ្លះដែលបានឈ្នះការប្រកួតប្រជែងរបស់គេ មើលទៅចិត្តរបស់គេហាក់ដូចជាមានសេចក្តីសុខសាន្តតិចតួច ខណៈពេលដែលពួកគេអាចរកបានលុយកាក់ ប៉ុន្តែពួកគេបានបាត់បង់អ្វីមួយដែលមានតម្លៃជាងនោះ។

ផ្សសវាងការជូរចត់

លោកហ្គាយ ឌ ម៉ៅប៉ាសេន ជាអ្នកនិពន្ធបារាំងមួយរូបបាននិទានរឿងពីកសិករម្នាក់ឈ្មោះ ហូចខំ ដែលបានមកលេងភូមិត្រូវចំនឹងថ្ងៃមានការលក់ដូរ។ ខណៈពេលដែលគាត់កំពុងដើរឆ្លងកាត់ទីធ្លាសាធារណៈ គាត់បានប្រទះភ្នែកឃើញអំបោះមួយសរសៃទុកចោលនៅលើគំនរគ្រួស។ គាត់ក៏បានរើសអំបោះនោះឡើង ហើយដាក់ចូលក្នុងហោប៉ៅរបស់គាត់។ បុរសដែលកំពុងធ្វើប្រព័ន្ធខ្សែរភ្លើងរថយន្តនៅក្នុងភូមិនោះ បានមើលឃើញពីសកម្មភាពរបស់គាត់ ហើយបុរសនោះធ្លាប់មានជម្លោះជាមួយគាត់ពីមុនមក។

ក្រោយមកនៅថ្ងៃនោះ មានគេរាយការថាបានបាត់កាបូបដៃមួយ។ បន្ទាប់មកហូចខំ ត្រូវបានចាប់ខ្លួនដោយមានការចោទប្រកាន់ពីអ្នកធ្វើប្រពន្ធ័ខ្សែភ្លើងឡាន។

គាត់ត្រូវបានគេនាំខ្លួនទៅឱ្យចៅហ្វាយស្រុក ជាអ្នកដែលគាត់ត្រូវតវ៉ាពីភាពគ្មានកំហុសរបស់គាត់ ដោយគាត់បានបង្ហាញពីអំបោះមួយសរសៃដែលគាត់រើសបាន។ ប៉ុន្តែ ពួកគេមិនជឿគាត់ឡើយ ហើយបានសើចចំអកឱ្យគាត់ថែមទៀត។

នៅថ្ងៃបន្ទាប់ កាបូបដៃនោះត្រូវបានរកឃើញ ហើយលោក ហូចខំ ត្រូវបានដោះលែងពីការចោទប្រកាន់កំហុសរបស់គាត់។ ប៉ុន្តែ ការតូចចិត្តដោយភាពអាម៉ាស់មុខដែលគាត់បានទទួល ដោយសារតែការចោទប្រកាន់ខុស គាត់បានក្លាយជាមនុស្សឈឺចាប់ ហើយនឹងមិនអាចបំភ្លេចរឿងរ៉ាវទាំងនោះបានទេ។ ការគ្មានឆន្ទះក្នុងការអត់ទោស និងបំភ្លេចរឿងរ៉ាវនោះ គាត់មិនសូវនិយាយស្តី ហើយចេះតែគិតអំពីរឿងនោះដោយមិនធ្វើអ្វីផ្សេងទៀតឡើយ។ គាត់មិនបានយកចិត្តទុកដាក់លើកសិដ្ឋានរបស់គាត់។ ត្រប់ទីកន្លែងដែលគាត់បានទៅ មនុស្សត្រប់គ្នាដែលគាត់បានជួប សុទ្ធតែនិយាយអំពីរឿងអយុត្តិធម៌ដែលបានកើតឡើងចំពោះគាត់។ រាល់ថ្ងៃ រាល់យប់ គាត់បានសញ្ជឹងគិតអំពីរឿងរ៉ាវនោះ។ គាត់បានធ្លាក់ខ្លួនឈឺដុនដាប ដោយសារការគិតមមៃពីការទទួលរងនូវការចោទប្រកាន់ដោយអយុត្តិធម៌មកលើរូបគាត់ ហើយគាត់ក៏បានទទួលអនិច្ចកម្មទៅ។ ក្នុងការវើរវាយ នាពេលជិតផុតដង្ហើមរបស់គាត់ គាត់បាននិយាយខ្សាវៗថា "អំបោះមួយសរសៃរអំបោះមួយសរសៃ" (*The Works of Guy de Maupassant* [n.d.], 34–38)។

ដោយមានបំវែបំរួលនៃចរិតលក្ខណៈ និងកាលៈទេសៈ រឿងដដែលនោះអាចកើតមានឡើងជាច្រើនទៀត នៅក្នុងយុគ្គសម័យរបស់យើងជាពុំខាន។ សំរាប់យើងត្រប់គ្នាៗ តើវាលំបាកណាស់ទៅឬ ក្នុងការអត់ទោសដល់អ្នកដែលបានធ្វើទុក្ខទោរម្នេញដល់យើងនោះ។ យើងទាំងអស់គ្នាចូលចិត្តចាំទុក ពីអំពើអាក្រក់ដែលគេបានធ្វើមកលើយើង។ ការចាំទុកនោះក្លាយជាមូលហេតុនៃកង្វល់ និងធ្វើឱ្យឈឺចុកចាប់ និងមានអន្តរាយ។ តើមានគុណធម៌ណាដែលតម្រូវឱ្យអនុវត្តក្នុងយុគសម័យយើងច្រើនជាងគុណធម៌នៃការអត់ទោស និងការបំភ្លេចចោលឬទេ? មនុស្សមួយចំនួននឹងប្រមាថចំពោះគុណធម៌នេះថាជាសញ្ញានៃភាពទន់ខ្សោយ។ មែនទេ? ខ្ញុំសន្មត់ថាវាពុំត្រូវការកម្លាំង ឬប្រាជ្ញា ដើម្បីចាំទុកពីកំហឹងជុំវិញការរងទុក្ខមិនសមហេតុផលឬឱ្យជីវិតពោរពេញដោយអារម្មណ៍គុំគួន ឬក៏បំផ្លាញសមត្ថភាពរបស់នណាម្នាក់ក្នុងតម្រោងការសងសឹកនោះ ក៏ទេដែរ។ ពុំមានសេចក្តីសុខសាន្តឡើយក្នុងការចិញ្ចឹមចិត្តឈ្នានីស។ ពុំមានសុភមង្គលឡើយក្នុងការរស់នៅសំរាប់ថ្ងៃដែលអ្នកអាច "សងសឹក" បាននោះ។

សាវក ប៉ុល មានប្រសាសន៍ពី "សមាសធាតុទន់ខ្សោយ ឬភាពទាបថោក" នៃជីវិតរបស់ពួកយើង (កាឡាទី 4:9)។ តើមានអ្វី ដែលទន់ខ្សោយ ឬទាបថោកជាងការចងចិត្តដើម្បីបំផ្លាញជីវិតរបស់មនុស្សម្នាក់ឱ្យរងទុក្ខគ្មានទីបញ្ចប់ ចំពោះអ្នកដែលអាចមានការប្រមាថយើង តាមរយៈគំនិតយង់ឃ្នង និងកាយវិការបោកបញ្ឆោតនោះ?

លោកយ៉ូសែប អេហ្វ ស្មីធ បានធ្វើជាអធិបតីលើសាសនាចក្រក្នុងជំនាន់ដែលប្រជាជនរបស់យើងជួបមហាជូរចត់។ ពួកគេចោទប្រកាន់លោកទាំងខុសឆ្គង និងបំពងសម្លេងតិទៀន ដោយពួកអ្នកនិពន្ធកាសែត ព្រមទាំងអ្នកនៅក្នុងសហគមន៍របស់លោកផងដែរ។ លោកត្រូវបានគេសរសេរដៀលត្មិះ គូរជារូបថ្លុកកំប្លែង ហើយចំអកឡកឡឺយ។ លោកបានឆ្លើយតបចំពោះពួកអ្នកដែលបានយកការបន្ទុះបង្អាប់របស់លោកធ្វើជាការលេងសើចថាះ "ចូរកុំរវល់នឹងពួកគេ ឱ្យពួកគេធ្វើអ្វីក៏ធ្វើចុះ។ ចូរផ្តល់សេរីភាពឱ្យពួកគេតាមការនិយាយដែលពួកគេចង់បាន។ ចូរឱ្យពួកគេប្រាប់រឿងរបស់ពួកគេ ហើយកាត់សេចក្តីតាមការសរសេររបស់ពួកគេចុះ (*Gospel Doctrine* ការបោះពុម្ពជាលើកទី 5 [1939], 339) ។ បន្ទាប់មក ដោយមានអារម្មណ៍នៃការលើកលែងទោស និងការបំភ្លេច លោកបានទៅមុខជាព្រមជាមួយការងារដ៏អស្ចារ្យ និងវិជ្ជមានក្នុងការការដឹកនាំសាសនាចក្រឆ្ពោះទៅរកវឌ្ឍនភាព និងសម្រេចបានទូវសមិទ្ធិផលគួរឱ្យកត់សំគាល់។ ពេលគាត់ទទួលអនិច្ចកម្ម មនុស្សជាច្រើនដែលបានចំអកឡកឡឺយឱ្យគាត់បានសរសេរគោរពសំដែងការកោតសរសើចំពោះគាត់។

ខ្ញុំរំលឹកចាំអំពីការស្តាប់ប្រសាសន៍ដ៏វែងរបស់ប្តីប្រពន្ធមួយគូដែលបានអង្គុយនៅតុទល់មុខខ្ញុំ។ មានភាពល្វីងជូរចត់កើតឡើងរវាងពួកគេ។ ខ្ញុំដឹងថាពេលមួយនោះសេចក្តីស្រឡាញ់របស់ពួកគេជ្រាលជ្រៅ ហើយពិត។ ប៉ុន្តែម្នាក់ៗបានបង្កើតទម្លាប់នៃការនិយាយពីគុណវិបត្តិពីគ្នាទៅវិញទៅមក។ ការពុំមានឆន្ទះអត់ទោសចំពោះកំហុសជាច្រើនប្រភេទដែលយើងប្រព្រឹត្ត និងពុំព្រមបំភ្លេចនូវកំហុសទាំងនោះ ហើយរស់នៅដោយអត់ធ្មត់លើកំហុសឆ្គងទាំងនោះ ពួកគេបានតិះទៀនគ្នារហូតដល់ពេលមួយដែលពួកគេដឹងថា សេចក្តីស្រឡាញ់របស់ពួកគេត្រូវបានស្លាប់រួចទៅហើយ។ វាបានក្លាយទៅជាផេះក្នុងកំរិតដែលហៅថាការលែងលះ "ដោយគ្មានកំហុស"។ ឥឡូវនេះ មានតែភាពកណ្តោចកណ្តែង និងការតិះដៀលប៉ុណ្ណោះ។ ខ្ញុំពេញចិត្តដែលថាមានវិធានការណ៍តូចមួយនៃការប្រែចិត្ត និងការអភ័យទោសពួកគេនឹងនៅតែជាប្តីប្រពន្ធនឹងគ្នា រីករាយនឹងភាពជាដៃគូដែលបានទទួលការប្រទានពរចំពោះ ពួកគេជាច្រើនអនេកក្នុងពេលកន្លងទៅ។

សេចក្តីសុខសាន្តតាមរយៈការអភ័យទោស

ប្រសិនបើនរណាម្នាក់ចិញ្ចឹមចិត្តគុំគួនចំពោះគ្នាទៅវិញទៅមក ខ្ញុំសូមអង្វរដល់អ្នកឱ្យសុំការអភ័យទោសពីព្រះអម្ចាស់ ដើម្បីប្រទានដល់អ្នកនូវភាពរឹងប៉ឹងក្នុងការអត់ទោសឱ្យគេ។ ការសំដែងនូវបំណងប្រាថ្នាបែបនេះ គឺមានសារៈសំខាន់បំផុតចំពោះការប្រែចិត្តរបស់អ្នក។ វាប្រហែលជាមិនងាយស្រួល ហើយវាក៏មិនអាចកើតឡើងភ្លាមៗនោះដែរ។ ប៉ុន្តែ ប្រសិនបើអ្នកនឹងស្វែងរកវាដោយស្មោះត្រង់ ហើយចិញ្ចឹមបីបាច់វា វា *នឹង* មកដល់។ ហើយបើទោះបីជាជនដែលអ្នកបានអត់ទោស បន្តស្វែងរក និងគំរាមកំហែងដល់អ្នក អ្នកនឹងដឹងថាអ្នកបានធ្វើ ថាអ្នកបានធ្វើនូវអ្វីដែលអ្នកអាច ដើម្បីឱ្យការផ្សះផ្សាដែលមានប្រសិទ្ធភាព។ សេចក្តីសុខសាន្តនឹងមានក្នុងចិត្តរបស់អ្នក បើពុំដូច្នេះទេ សេចក្តីសុខសាន្តនឹងពុំសំរេចបានឡើយ។ សេចក្តីសុខសាន្តនោះនឹងជាសេចក្តីសុខសាន្តរបស់ទ្រង់ ដែលបានមានបន្ទូលថាះ

"ត្បិតបើអ្នករាល់គ្នាអត់ទោសចំពោះការរំលងច្បាប់ ដែលមនុស្សលោកប្រព្រឹត្តធ្វើ នោះព្រះវរបិតានៃអ្នកដែលគង់នៅស្ថានសួគិ ទ្រង់នឹងអត់ទោសឱ្យអ្នករាល់គ្នាដែរះ

"តែបើអ្នកគ្នាមិនអត់ទោស ចំពោះការរំលងច្បាប់ឱ្យគេទេ នោះព្រះវរបិតានៃអ្នក ទ្រង់ក៏មិនអត់ទោស ចំពោះការរំលងច្បាប់ ដែលអ្នករាល់គ្នាប្រព្រឹត្តធ្វើដែរ" (ម៉ាថាយ 6:14–15)។

កូនខ្ចះខ្ចាយ

ខ្ញុំដឹងថាពុំមានប្រវត្តិរឿងណានៅក្នុងអក្សរសាស្ត្រទាំងអស់ល្អជាងរឿង ដែលយើងបានឃើញក្នុងលូកាជំពូកទីដប់ប្រាំនោះឡើយ។ វាគឺជាសាច់រឿងនៃការអត់ទោសរបស់ឱពុកចំពោះកូនប្រុសដែលបានប្រែចិត្ត។ វាគឺជាដំណើររឿងអំពីកូនប្រុសម្នាក់ដែលបានបង្ហិន ទ្រព្យរបស់គាត់ដោយសារការខិលខូច មិនស្តាប់ដំបូន្មានរបស់ឱពុកគាត់ ហើយលែងរាប់រកអ្នកទាំងឡាយដែលស្រឡាញ់គាត់។ នៅពេលដែលគាត់បានចាយវាយអស់រលីងហើយនោះ គាត់ក៏មានសេចក្តីស្រេកឃ្លាន

និងពុំមានទន្សាយណារាប់រកឡើយ ហើយ “នៅពេលគាត់ភ្ញាក់ដឹងខ្លួន” (លូកា 15:17) គាត់ក៏បានត្រឡប់ទៅរកឪពុករបស់គាត់វិញ លុះឪពុកឃើញពីចំងាយហើយ “ក៏មានចិត្តអាណិតមេត្តា ហើយរត់ទៅឱបថើបគាត់” (លូកា 15:20)។

ខ្ញុំសុំឱ្យអ្នកអានរឿងនិទាននោះ។ ឱពុកម្តាយត្រប់ៗរូបគួរតែអានរឿងនោះម្តង ហើយម្តងទៀត។ វាធំទូលាយត្រប់ត្រាន់ដើម្បីត្របដណ្តប់ក្រុមគ្រួសារ ហើយធំទូលាយជាងនេះសំរាប់ការពារមនុស្សត្រប់រូប តើយើងទាំងអស់គ្នាពុំមែនជាកូន២ប្រុស កូនស្រី ខ្ទះខ្ទាយដែលត្រូវការប្រែចិត្ត និងទទួលនូវសេចក្តីមេត្តាករុណាអត់ទោសនៃព្រះវរបិតាសួគ៌របស់យើង ហើយធ្វើតាមគំរូរបស់ទ្រង់ទេឬអី?

បុត្រាដ៏ជាទីស្រឡាញ់របស់ទ្រង់ ដែលជាអង្គប្រោសលោះរបស់យើង ផ្តល់ឱ្យពួកយើងនូវការអភ័យទោស និងសេចក្តីមេត្តាករុណា ប៉ុន្តែក្នុងការធ្វើដូច្នេះ ទ្រង់បញ្ជាឱ្យយើងប្រែចិត្ត។ អារម្មណ៍ស្មោះត្រង់ និងសប្បុរសនៃការអត់ទោសនឹងក្លាយជាការសំដែងនូវគំរូវការប្រែចិត្តនោះ។ ព្រះអម្ចាស់បានមានបន្ទូល—ហើយខ្ញុំស្រង់យកពីវិវរណៈដែលបានផ្តល់ឱ្យព្យាការីយ៉ូសែបស្ម៊ីធថា

“ហេតុដូច្នេះហើយ យើងបញ្ជាឱ្យអ្នកប្រែចិត្ត—ចូរប្រែចិត្តចុះ បើពុំនោះសោតទេ យើងនឹងវាយអ្នកដោយរំពាត់នៃព្រះឱស្ឋរបស់ យើង ហើយដោយសេចក្តីខ្ញាល់របស់យើង និងសេចក្តីពិរោធរបស់យើង នោះសេចក្តីរងទុក្ខវេទនារបស់អ្នកនឹងឈឺចាប់ណាស់—តើឈឺដល់អ្នកនោះមិនដឹងទេ ជ្រួតជ្រាបដល់អ្នកណានោះមិនដឹងទេ មែនហើយ ធ្ងន់ធ្ងរដល់ណាអ្នកណានោះ អ្នកមិនដឹងទេ។

“តួរិតមើលចុះ យើងជាព្រះបានរងទុក្ខនូវការទាំងនេះ ជំនួសមនុស្សទាំងអស់ដើម្បីកុំឱ្យគេអាចរងទុក្ខ បើសិនជាពួកគេប្រែចិត្ត

“ប៉ុន្តែ បើសិនជាពួកគេមិនព្រមប្រែចិត្តទេនោះ ពួកគេត្រូវរងទុក្ខ ដូចជាយើងដែរ

“តើជាសេចក្តីរងទុក្ខវេទនា ដែលបណ្តាលឱ្យយើងតើជាព្រះដែលមហិមាលើអ្វីៗទាំងអស់ ត្រូវញ័ររដោយសារតែការឈឺចាប់ ហើយត្រូវច្រួចលោហិតចេញពីគ្រប់រន្ធញើស ហើយត្រូវរងទុក្ខ ព្រមទាំងរូបកាយ និងវិញ្ញាណផង . . .

“ចូររៀនអំពីយើង ហើយស្តាប់តាមព្រះបន្ទូលទាំងឡាយរបស់យើងចុះ ចូរដើរក្នុងភាពស្លូតបូតនៃព្រះវិញ្ញាណរបស់យើង នោះអ្នកនឹងបានសេចក្តីសុខសាន្តក្នុងយើង” (គ. និង ស. 19:15–18, 23)។

ខរតម្ពីរទាំងនេះគឺជាបទបញ្ញត្តិ ហើយខរតម្ពីរទាំងនេះគឺជាការសន្យារបស់ទ្រង់ក្នុងការអធិស្ឋានដ៏ល្អឥតខ្ចោះរបស់ទ្រង់ ដែលបានអង្វរ “ឱ ព្រះវរបិតា . . . សូមអត់ទោស សេចក្តីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោសដល់អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ” (ម៉ាថាយ 6:9, 12)។

“រុំរបួស”

តើពាក្យសំដីរបស់អេប្រាហាំ លើងយិន មិនអស្ចារ្យទេឬដែលគាត់បាននិយាយពីសោកនាដកម្មនៃសង្គ្រាមស៊ីវិលដ៏គួរឱ្យភ័យខ្លាចមួយៈ “ដោយពុំមានការព្យាបាទចំពោះនរណាម្នាក់ ដោយសេចក្តីសប្បុរសសំរាប់ទាំងអស់គ្នា . . . ចូរយើង . . . រុំរបួស” (នៅក្នុង John Bartlett, *Familiar Quotations* [ឆ្នាំ 1968], 640)។

បងប្អូនប្រុសស្រីរបស់ខ្ញុំ ចូរយើងរុំរបួស—អ៊ុំ! របួសជារច្រើនដែលបណ្តាលមកពីសំដីចាក់រុក ដោយសារការឈឺចាប់ដែលទទួលបានពីក្តីមានះ ដោយសារគំរោងដែនការដើម្បី “សងសឹក” ជាមួយអ្នកដែលអាចធ្វើខុសចំពោះយើង។ យើងទាំងអស់គ្នាមាន អារម្មណ៍សងសឹកនេះតិចតួច នៅក្នុងខ្លួនរបស់យើង។ សំណាងល្អយើងទាំងអស់គ្នាមានអំណាចដើម្បីទៅពីលើអារម្មណ៍នេះ ប្រសិនបើយើងនឹង “បំពាក់ [ខ្លួនរបស់យើង] ដោយចំណងនៃសេចក្តីសប្បុរស ដូចជាដោយស្បៃដែលជាចំបងនៃសេចក្តីល្អឥតខ្ចោះ និងសេចក្តីសុខសាន្ត” (គ. និង ស. 88:125)។

“មនុស្សលោកប្រព្រឹត្តខុស ព្រះអម្ចាស់លើកលែងទោស” (Alexander Pope, *An Essay on Criticism,* 2:1711)។ ពុំមានសេចក្តីសុខសាន្តឡើយនៅក្នុងការសញ្ជឹងគិតលើការឈឺចាប់នៃជំពៅចាស់។ នេះគឺជាសេចក្តីសុខសាន ដ៏ផ្អែមល្ហែមនៃព្រះគ្រីស្ទដែលបានបន្ទូលថា “មានពរហើយ អស់អ្នកដែលផ្សះផ្សាគេ ត្បិតអ្នកទាំងនោះ នឹងបានហៅជាកូនរបស់ព្រះ” (ម៉ាថាយ 5:9)។

ជកស្រង់ចេញពី *Ensign* ខែ មិថុនា ឆ្នាំ 1991 ទំព័រ 2–5។

ការគ្រប់គ្រងហិរញ្ញវត្ថុក្រុមគ្រួសារ

8

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលៈទេសៈរបស់អ្នកផ្ទាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- ចូរធ្វើបញ្ជីទំនិញមួយដែលអ្នកទើបបានទិញថ្មីៗ។ ចូរសរសេរអក្សរ *ត្រូវការ* នៅជិតទំនិញនិមួយៗដែលអ្នកត្រូវការ។ សរសេរអក្សរ *ចង់បាន* នៅជិតទំនិញនិមួយៗដែលអ្នកចង់បាន ប៉ុន្តែមិនបានត្រូវការ។ ចូរប្រើប្រាស់បញ្ជីនេះដើម្បីវាយតម្លៃនូវទម្លាប់ចាយវាយរបស់អ្នក។ ប្រសិន បើអ្នកចំណាយលុយច្រើនពេកទៅលើទំនិញអ្វីដែលមិនមានសារៈសំខាន់ ចូរពិចារណាអំពីវិធីសាស្ត្រក្នុងការចាយវាយលុយរបស់អ្នកឱ្យកាន់តែមានភាពឆ្លាតវៃ។
- ចូររៀបចំថវិកាសំរាប់រដូវកាលនៅពេលអនាគតជាមួយនឹងប្តី ឬប្រពន្ធរបស់អ្នក—ប្រហែលជាសំរាប់មួយ ឬពីរសប្តាហ៍។ ចូរពិចារណាការប្រើប្រាស់ជាគំរូមួយនៅលើទំព័រ 32 ធ្វើជាការណែនាំ។ ចូរធ្វើកិច្ចការនេះរួមគ្នាដើម្បីរស់នៅតាមថវិកាដែលអ្នកបានដាក់គោលដៅ។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

ស្ថេរភាពនៅកណ្តាលភាពផ្លាស់ប្តូរ

ប្រធាន អិន អែលដន ថែនណី
ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ

អ្វីដែលខ្ញុំចង់ចែកចាយជាមួយបងប្អូននៅថ្ងៃនេះ គឺជាការអង្កេតរបស់ខ្ញុំអំពីគោលការណ៍ដែលមិនប្រែប្រួល និងជាមូលដ្ឋានគ្រឹះនៃហិរញ្ញវត្ថុដែលមានសុវត្ថិភាព និងសេចក្តីសុខសាន្តក្នុងចិត្ត បើយើងធ្វើតាម ទោះបើជាមានកាលៈទេសៈខាងសេដ្ឋកិច្ច *ណាមួយ* តើតឡើងក្តី។

“ចូរស្វែងរកនគរនៃព្រះជាមុនសិន”

ជាដំបូង ខ្ញុំចង់បង្កើតមូលដ្ឋាន និងស្តាបនាទស្សនៈវិស័យមួយដែលគោលការណ៍សេដ្ឋកិច្ចទាំងនេះត្រូវតែអនុវត្តតាម។

នាថ្ងៃមួយចៅប្រុសរបស់ខ្ញុំបាននិយាយមកកាន់ខ្ញុំថាៈ “ខ្ញុំបានសង្កេតឃើញលោកតា និងបុរសដែលមានដោគជ័យផ្សេងទៀត ហើយខ្ញុំបានធ្វើការសំរេចចិត្តថាខ្ញុំចង់ទទួលបានដោគជ័យនៅក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំចង់ធ្វើកិច្ចសម្ភាសន៍ជាមួយមនុស្សដែលទទួលបាននូវភាពដោគជ័យឱ្យបានច្រើនតាមដែលខ្ញុំអាចធ្វើទៅបាន ដើម្បីដឹងនូវអ្វីដែលធ្វើឱ្យពួកគេទទួលបានដោគជ័យ។ លោកតា ពេលគិតអំពីបទពិសោធន៍របស់លោកតាឡើងវិញ តើលោកតាជឿលើអ្វីដែលជាធាតុសំខាន់បំផុតនៃការទទួលដោគជ័យ?”

ខ្ញុំបានប្រាប់ចៅប្រុសរបស់ខ្ញុំថា ព្រះអម្ចាស់បានប្រទានឱ្យរូបមន្តដោគជ័យដ៏មហិមាដែលតាបានចេះៈ “ចូរស្វែងរកនគរនៃព្រះ និង សេចក្តីសុចរិតរបស់ទ្រង់ជាមុនសិន ទើបគ្រប់របស់ទាំងនោះនឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង” (ម៉ាថាយ 6:33)។

អ្នកខ្លះជំទាស់ថាមនុស្សដែលមានប្រាក់កាសច្រុំច្រើងខ្លះ ជាអ្នកដែល *ពុំ* បានស្វែងរកនគរព្រះមុនឡើយ។ នេះគឺជាការពិត។ ប៉ុន្តែ ព្រះអម្ចាស់ពុំសន្យាដល់យើងតែសម្ភារៈផ្នែកទ្រព្យសម្បត្តិប៉ុណ្ណោះទេ ប្រសិនបើយើងស្វែងរកនគរព្រះជាមុន។ តាមរយៈបទពិសោធន៍របស់ខ្ញុំ ខ្ញុំដឹងថានេះមិនមែនជាហេតុផលដែលត្រូវខ្វែងគំនិតគ្នាទេ។ ហិនរីក អាបសិន បានមានប្រសាសន៍ថា ៖ “ប្រាក់អាចជាសំបកនៃវត្ថុជាច្រើន ប៉ុន្តែ ពុំមែនជាគ្រាប់ឡើយ។ វានាំមកនូវម្ហូបអាហារឱ្យអ្នក ប៉ុន្តែពុំមែនជាម្ហូបអាហារដែលអ្នកចង់បរិភោគនោះឡើយ វានាំមកនូវឱសថដល់អ្នក ប៉ុន្តែពុំមែនជាសុខភាពរបស់អ្នកឡើយ វានាំឱ្យអ្នកស្គាល់គ្នា ប៉ុន្តែពុំមែនជាមិត្តភក្តិរបស់អ្នកឡើយ វានាំអ្នកបំរើឱ្យអ្នក ប៉ុន្តែពុំមែនជាអ្នកស្មោះត្រង់នឹងអ្នកឡើយ វានាំឱ្យសេចក្តីអំណរដល់អ្នក ប៉ុន្តែពុំមែនជាសេចក្តីសុខសាន្ត ឬក៏សុគមង្គលឡើយ” (នៅក្នុង *The Forbes Scrapbook of Thoughts on the Business of Life* [1968], 88)។

ពរជ័យខាងសម្ភារៈគឺជាផ្នែកមួយនៃសិក្ខាបទ ប្រសិនបើពរជ័យទាំងនោះត្រូវបានសំរេចនៅតាមផ្លូវសមរម្យ ហើយតាមគោលបំណងត្រឹមត្រូវ។ ខ្ញុំនឹកឃើញអំពីបទពិសោធន៍របស់ប្រធាន ហូច ប៊ី ព្រោន្ត។ ក្នុងនាមជាយោធាវ័យក្មេងម្នាក់ ក្នុងសង្គ្រាមលោកលើកទីមួយ គាត់បានទៅសួរសុខទុក្ខមិត្តភក្តិដែលមានវ័យចំណាស់ម្នាក់កំពុងស្នាក់នៅមន្ទីរពេទ្យ។ មិត្តភក្តិនេះគឺជាមហាសេដ្ឋី ដែលមានអាយុប៉ែតសិបឆ្នាំ កំពុងដេកស្លុកស្លឹងរកកល្យស្លាប់ជាច្រើនដង។ ទាំងភរិយាលែងលះ ឬកូនទាំងព្រាំទាក់របស់គាត់មិនបានយកចិត្តទុកដាក់មកសួរសុខទុក្ខគាត់នៅមន្ទីរពេទ្យឡើយ។ នៅពេលប្រធាន ព្រោន្ត គិតដល់ឈ្មោះរបស់មិត្តភក្តិគាត់ គាត់បានសួរទៅកាន់មិត្តរបស់គាត់ថាតើគាត់ត្រូវផ្លាស់ប្តូរខ្សែជីវិតរបស់គាត់បែបណា ប្រសិនបើគាត់មានជីវិតរស់នៅម្តងទៀតថា “បានបាត់បង់នូវអ្វីដែលប្រាក់មិនអាចទិញបាន ហើយបានកត់សំគាល់នូវស្ថានភាពសោកសៅរបស់គាត់ និងជំរៅនៃទុក្ខលំបាករបស់គាត់”។

សុភាពបុរសវ័យចំណាស់ដែលបានទទួលមរណភាពពីរបីថ្ងៃក្រោយមកបាននិយាយថា ៖ “ ‘នៅពេលដែលខ្ញុំគិតពីជីវិតក្នុងអតីតកាល ដ៏មានសារៈសំខាន់បំផុត និងទ្រព្យសម្បត្តិដ៏មានតម្លៃដែលខ្ញុំមាន ប៉ុន្តែអ្វីដែលខ្ញុំបានបាត់បង់ក្នុងដំណើរការនៃការសន្សំទឹកប្រាក់លាភរបស់ខ្ញុំនោះ គឺជា *ជំនឿដ៏សាមញ្ញដែលម្តាយរបស់ខ្ញុំមានលើព្រះអម្ចាស់ និងក្នុងដួងព្រលឹងអមតៈ*។

“ ‘. . . សំឡាញ់បានសួរខ្ញុំថាតើរបស់អ្វីទៅដែលមានសារៈសំខាន់បំផុតក្នុងជីវិត។ ខ្ញុំមិនអាចរកពាក្យណាដើម្បីឆ្លើយប្រាប់សំឡាញ់ឱ្យបានប្រសើរជាងពាក្យដែលបានប្រើក្នុងកំណាព្យនេះឡើយ’”។ គាត់បានសុំឱ្យប្រធាន ប្រោន្ត ឱ្យយកស្បៀវភៅតូចមួយក្បាលចេញពីវ៉ាលីតូចរបស់គាត់ ហើយ គាត់បានអានកំណាព្យចេញពីកូនស្បៀវភៅតូចនោះដែលមានចំណងជើងថា “ខ្ញុំជាមនុស្សចំលែក”

ខ្ញុំជាមនុស្សចំលែកចំពោះជំនឿដែលម្តាយរបស់ខ្ញុំបានបង្រៀនខ្ញុំ

ខ្ញុំជាមនុស្សចំលែកចំពោះព្រះដែលបានឲ្យម្តាយរបស់ខ្ញុំយំ

ខ្ញុំជាមនុស្សចំលែកចំពោះការលួងលោមចិត្តថា “ឥឡូវនេះខ្ញុំបានសូត្រកំណាព្យរបស់ខ្ញុំ” ហើយនាំខ្ញុំ ចំពោះហត្ថាដ៏អស់កល្បដែលបីត្រកងឱពុករបស់ខ្ញុំនៅពេលគាត់ទទួលមរណភាព

នៅពេលពិភពលោកដ៏ធំអស្ចារ្យមកដល់ ហើយហៅខ្ញុំ ខ្ញុំបានបោះបង់អ្វីទាំងអស់ដើម្បីធ្វើតាម

មិនដែលសំគាល់ឃើញនៅក្នុងភាពងងឹតងងល់របស់ខ្ញុំ ខ្ញុំបានរបូតដៃរបស់ខ្ញុំចេញពីដៃរបស់គាត់ ខ្ញុំមិនដែលសុបិនក្នុងសេចក្តីភាំងវង្វេងរបស់ខ្ញុំឡើយថា កិត្តិនាមគ្មានន័យអ្វីទាំងអស់

ថាភោគទ្រព្យមាសគឺជាត្ស្យូងស្ស ចាប់តាំងពីខ្ញុំបានរៀនសូត្រវាមក គឺដូច្នេះ

ខ្ញុំបានចំណាយពេលមួយជីវិត ដើម្បីស្វែងរកវត្ថុដែលខ្ញុំបានបោះបង់ចោល ទាំងមិនឱ្យតម្លៃនៅពេលខ្ញុំបានរកឃើញវត្ថុទាំងនោះ

ខ្ញុំបានប្រយុទ្ធ ហើយបានទទួលរង្វាន់ក្នុងបុព្វហេតុនៃជ័យជំនះជាច្រើន

ប៉ុន្តែ ខ្ញុំនឹងឱ្យ*ទាំងអស់* ទាំងកិត្តិនាម និងព្រេងសំណាង ព្រមទាំងសេចក្តីអំណរដែលពឡ័ជុំវិញរបស់ទាំងនោះ

ប្រសិនបើខ្ញុំត្រាន់តែមាន*ជំនឿ* ថាអ្វីដែលបានធ្វើឱ្យម្តាយរបស់ខ្ញុំមាន នៅតែរក្សាបានដូច្នេះ

“នោះហើយគឺជាទីបន្ទាល់នៃបុរសហៀបស្លាប់ម្នាក់ ដែលបានកើតមកក្នុងសាសនាចក្រ ប៉ុន្តែត្រូវបានរសាត់ចេញឆ្ងាយពីនេះទៅ។ នោះហើយគឺជាសំរែកយំតូចចិត្តនៃបុរសកណ្តោចកណ្តែងម្នាក់ដែលអាចមានអ្វីៗទាំងអស់ដែលប្រាក់អាចទិញបាន ប៉ុន្តែបានបាត់បង់នូវវត្ថុដែលមានសារៈសំខាន់បំផុតក្នុងជីវិត ដើម្បីសន្សំនូវទ្រព្យសម្បត្តិលោកិយយើងនេះ” (*Continuing the Quest* [1961], 32–35 អក្សរទ្រេតជាការបន្ថែម)។

នៅក្នុងព្រះគម្ពីរមរមិន ព្យាការី យ៉ាកុប បានផ្តល់ការប្រឹក្សាសំខាន់ៗអំពីបញ្ហានេះថា ៖

“បុន្តែ មុនអ្នករាល់គ្នាស្វែងរកទ្រព្យសម្បត្តិ ចូរអ្នករាល់គ្នាស្វែងរកនគរព្រះជាមុនសិន។

“ហើយបន្ទាប់ពីអ្នករាល់គ្នាបានសេចក្តីសង្ឃឹមនៅក្នុងព្រះគ្រីស្ទ នោះអ្នករាល់គ្នានឹងបានទ្រព្យសម្បត្តិ *បើសិនជាអ្នករាល់គ្នា ស្វែងរក របស់ទាំងនោះ* ហើយអ្នករាល់គ្នានឹងស្វែងរកទ្រព្យសម្បត្តិ ដោយមានបំណងចង់ធ្វើល្អ គឺដើម្បីបំពាក់ពួកអ្នកអាក្រាត ហើយចិញ្ចឹម ពួកអ្នកដែលអត់ឃ្លាន ហើយរំដោះពួកអ្នកដែលត្រូវជាប់ឃុំឃាំង ហើយជួយសង្គ្រោះដល់ពួកអ្នកឈឺ និងពួកអ្នកកំសត់ទុរគតិ។ (យ៉ាកុប 2:18–19 អក្សរទ្រេតជាការបន្ថែម)។

បន្ទាប់មកមូលដ្ឋាន និងទស្សនៈវិស័យទាំងនេះគឺៈ យើងត្រូវតែស្វែងរកនគរព្រះជាមុនសិន ធ្វើការងារ ហើយដាក់ផែនការ ព្រមទាំងចាយវាយដោយប្រុងប្រយត្ន័ ចូរដាក់ផែនការសំរាប់អនាគត ហើយប្រើប្រាស់ទ្រព្យសម្បត្តិអ្វីដែលយើងទទួលបានពីពរជ័យ ដើម្បីជួយស្ថាបនានគរនោះ។ នៅពេលដែលត្រូវបានដឹកនាំដោយទស្សនៈវិស័យដ៏អស់កល្បជានិច្ច និងដោយការស្ថាបនានៅលើគ្រឹះដ៏មាំមួននេះ យើងអាចស្វែងរកដោយមានទំនុកចិត្តចំពោះការងារប្រចាំថ្ងៃ និងការងារប្រចាំជីវិតរបស់យើង ដែលត្រូវតែដាក់ផែនការដោយប្រុងប្រយត្ន័ និងបន្តទៅមុខដោយឧស្សាហ៍ព្យាយាម។

ស្ថិតនៅក្នុងក្របខ័ណ្ឌនេះ ខ្ញុំសូមពន្យល់អំពីគោលការណ៍ទាំងប្រាំស្តីអំពីស្ថេរភាពសេដ្ឋកិច្ច។

បង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់

ស្ថេរភាព *#1: បង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់*។ ជារឿយៗ ខ្ញុំងឿងឆ្ងល់ក្នុងចិត្ត ថាតើយើងដឹងទេថាការបង់ដង្វាយមួយភាគក្នុងដប់ពុំមែនមានន័យថាយើងផ្តល់អំណោយឱ្យព្រះអម្ចាស់ និងសាសនាចក្រនោះឡើយ។ ការបង់ដង្វាយមួយភាគក្នុងដប់ គឺជាការសងបំណុលដល់ព្រះអម្ចាស់។ ព្រះអម្ចាស់គឺជាប្រភពនៃពរជ័យទាំងអស់របស់យើង រួមទាំងជីវិតរបស់យើងផងដែរ។

ការបង់ដង្វាយមួយភាគក្នុងដប់គឺជាបទបញ្ញាត្តិ ហើយជាព្រះបញ្ញត្តិដែលមានន្ទវសេចក្តីសន្យាមួយ។ ប្រសិនបើយើងគោរពប្រណិបត្តិតាមព្រះបញ្ញត្តិនេះ យើងត្រូវបានសន្យាថាយើងនឹង “បានចំរើនឡើង”។ ការរីកចំរើននេះមានច្រើនជាងទ្រព្យសម្បត្តិជាសម្ភារៈ—វាមានទាំងការមានសុខភាពល្អ និងអំណាចនៃខួរក្បាល។ វាមានទាំងសាមគ្គីភាពក្នុងក្រុមគ្រួសារ ហើយនិងការរីកចំរើនខាងវិញ្ញាណ។ ខ្ញុំសង្ឃឹមថាអ្នកទាំងឡាយណាដែលពុំបានបង់ដង្វាយពេញលេញនាពេលបច្ចុប្បន្ននេះ នឹងស្វែងរកជំនឿ និងភាពរឹងមាំដើម្បីធ្វើកិច្ចការនេះ។ នៅពេលអ្នកបំពេញកាតព្វកិច្ចនេះដល់លោកចៅហ្វាយរបស់អ្នក អ្នកនឹងជួបនូវសុភមង្គលដ៏អស្ចារ្យ ដូចជាជនដែលបានស្មោះត្រង់ចំពោះបទបញ្ញាត្តិនេះ បានដឹងរួចមកហើយ។

រស់នៅដោយសន្សំសំចៃ

ស្ថេរភាពទី #2ៈ រស់នៅដោយសន្សំសំចៃ។ ខ្ញុំបានរកឃើញថាពុំមានមធ្យោបាយណាដែលអ្នកអាចទទួលកំរៃ *ច្រើនជាង* អ្នកអាច ចំណាយនោះទេ។ ខ្ញុំមានជំនឿថាវាពុំមែនជាចំនួនប្រាក់ដែលបុគ្គលម្នាក់ៗរកបាននោះទេ ដែលនាំមកនូវសេចក្តីសុខសាន្តក្នុងចិត្ត ច្រើនដូចការចេះ *គ្រប់គ្រង* ប្រាក់របស់ពួកគាត់នោះឡើយ។ លុយអាចជាអ្នកបំរើចេះស្តាប់បង្គាប់ ប៉ុន្តែវាជាអ្នកគ្រប់គ្រងការងារដ៏យង់ឃ្នង។ អ្នកទាំងឡាយណាដែលរៀបចំរបៀបរស់នៅរបស់ខ្លួនឱ្យនៅសេសសល់បន្តិចបន្តួចលើសពីតំរូវការ នោះពួកគេគឺជាម្ចាស់លើកាលៈទេសៈរបស់ពួកគេ។ រីឯអ្នកទាំងឡាយណាដែលចំណាយលើសពីកំរៃរបស់ខ្លួនទទួលបាន នោះគឺគឺកាលៈទេសៈរបស់ពួកគេជាម្ចាស់លើខ្លួនពួកគេ។ ពួកគេរស់នៅក្នុងទាសភាព។ ប្រធាន ហ៊ីប៊ឺ ជេក្រាន្ត គ្រាមួយនិយាយថា ៖ “ប្រសិនបើមានអ្វីមួយដែលនឹងនាំមកនូវសេចក្តីសុខសាន្ត និងសេចក្តីរីករាយដល់ដួងចិត្តមនុស្ស និងដល់គ្រួសារ នោះគឺជាការរស់នៅតាមអ្វីដែលយើងមាន។ ហើយប្រសិនបើមានអ្វីមួយដែលបែកបាក់ ហើយបង្អាក់ទឹកចិត្ត ព្រមទាំងបង្ខូចទឹកចិត្ត នោះគឺជាការជំពាក់បំណុល និងកាតព្វកិច្ចរកបំណុលសងគេមិនបាន” (*Gospel Standards* ចងក្រងដោយ G. Homer Durham [ឆ្នាំ 1941], 111)។

គន្លឹះចំពោះការចំណាយតិចជាងចំណូលដែលយើងរកបាននោះគឺជារឿងសាមញ្ញ—វាហៅថាការដាក់វិន័យ។ ពុំថាក្មេង ឬចាស់នោះទេ យើងទាំងអស់គ្នាត្រូវតែរៀនដើម្បីដាក់វិន័យចំពោះខ្លួនឯង ចំពោះចំណង់របស់យើងនិងចំពោះចំណង់ចំណូលចិត្តតាមសេដ្ឋកិច្ចរបស់យើង។ តើពរជ័យប៉ុណ្ណាចំពោះអ្នកដែលរៀនចំណាយតិចជាងចំណូល ហើយចេះសន្សំសំរាប់ពេលវេលាដែលត្រូវការដែលមិនបានដឹងខ្លួនទុកជាមុននោះ។

បែងចែកសេចក្តីត្រូវការ និងចំណង់

ស្តេរភាពទី #3ៈ រៀនបែងចែករវាងសេចក្តីត្រូវការ និងចំណង់។ ការនិយមចូលចិត្តរបស់អ្នកប្រើប្រាស់គឺជាអ្វីដែលមនុស្សផលិត។ ការប្រកួតប្រជែងដោយសេរីនៃប្រពន្ធ័សហគ្រាសរបស់យើងផលិតនូវទំនិញ និងសេវាកម្មដោយគ្មានកំណត់ ដើម្បីបំពេញសេចក្តីត្រូវការរបស់យើងឱ្យមានលក្ខណៈងាយស្រួល និងប្រណិតភាពកាន់តែប្រសើរឡើង។ ខ្ញុំមិនតិទៀនពីប្រព័ន្ធ ឬភាពដែលអាចមាននៃទំនិញ ឬសេវាកម្មទាំងនេះឡើយ។ ខ្ញុំព្រួយបារម្ភតែម៉ឺងគត់អំពីសមាជិករបស់យើងដែលប្រើប្រាស់និយ័តកម្មនៅក្នុងការទិញដូររបស់ពួកគេ។ យើងត្រូវតែដឹងថាការពលិកម្មគឺជាផ្នែកដ៏សំខាន់មួយនៃវិន័យដ៏នៅអស់កល្បជានិច្ចរបស់យើង។

នៅក្នុងប្រទេសនេះ និងប្រទេសជាច្រើនទៀត ឱពុកម្តាយ និងកូនៗជាច្រើនដែលបានកើតនៅពេលសង្គ្រាមលោកលើកទី 2 បានស្គាល់តែស្ថានភាពរុងរឿងមួយប៉ុណ្ណោះ។ មនុស្សជាច្រើនត្រូវបានដាក់ឱ្យមានលក្ខ័ខណ្ឌ័ដើម្បីមានភាពពេញចិត្តមួយគ្រា។ មានកាលានុវត្តភាការងារបរិបូរណិចំពោះអ្នកទាំងឡាយដែលមានលទ្ធភាពធ្វើការ។ ប្រណិតភាពនៃថ្ងៃម្សិលមិញសំរាប់របស់ភាគច្រើន ត្រូវបានចាត់ទុកជាតំរូវការចាំបាច់នៃថ្ងៃនេះ។

ការនេះត្រូវបានធ្វើជាគំរូដោយគូស្វាមីភរិយាក្មេង ដែលជាអ្នកដែលបានរំពឹងទុកដើម្បីផ្គត់ផ្គង់គេហដ្ឋានរបស់ពួកគេ និងផ្តល់ឱ្យខ្លួនឯងនូវប្រណិតភាពផ្សេងៗ ចាប់តាំងពីពេលដែលពួកគេ *ចាប់ផ្តើម* រៀបអាពាហ៍ពិពាហ៍របស់ពួកគេ ប៉ុន្តែឱពុកម្តាយរបស់ពួកគេបានប៉ាន់ស្មានទុកថា ពួកគេនឹងទទួលបានភាពប្រណិតនោះ បន្ទាប់ពីមានការខិតខំ និងពលិកម្មជាច្រើនឆ្នាំទើបអាចទទួលបាន។ ដោយការចង់បានអ្វីៗជាច្រើនភ្លាមៗ គូស្វាមីភរិយាក្មេងខ្ចី អាចយល់ព្រមប្រើប្រាស់ផែនការឥណទានដោយងាយ ហេតុដូច្នេះហើយ ពួកគេពន្លិចខ្លួនឯងចូលទៅក្នុងបំណុល។ ធ្វើដូចនេះនឹងទុកឱ្យពួកគេនៅឆ្ងាយពីការមានបំណងប្រើប្រាស់ហិរញ្ញវត្ថុចាំបាច់ដើម្បីធ្វើ ដូចដែលសាសនាចក្រស្នើសុំឱ្យមានការស្តុកម្ហូបអាហារទុក និងកម្មវិធីសន្តិសុខផ្សេងទៀត។

ការទំរើស និងកង្វះខាតហួសពេកក្នុងការគ្រប់គ្រងលុយ នាំមកនូវទម្ងន់ដ៏ធ្ងន់ដល់ទំនាក់ទំនងអាពាហ៍ពិពាហ៍។ បញ្ហាអាពាហ៍ពិពាហ៍ជាច្រើន វាហាក់ដូចជាមានបញ្ហាមកពីឬសគល់នៃសេដ្ឋកិច្ច—ទាំងមានចំណូលមិនគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ដល់ក្រុមគ្រួសារ ឬ ការគ្រប់គ្រងមិនល្អចំពោះចំណូលដែលរកបាន។

ឱពុកវ័យក្មេងម្នាក់បានមករកបិ៊ីស្សពរបស់គាត់ ដើម្បីទទួលការប្រឹក្សាអំពីបញ្ហាហិរញ្ញវត្ថុ ហើយគាត់បានប្រាប់នូវសាច់រឿងមួយជាច្រើនដងថាៈ "បិ៊ីស្សព ខ្ញុំបានទទួលការបណ្តុះបណ្តាលយ៉ាងល្អដើម្បីធ្វើជាវិស្វករម្នាក់ ហើយខ្ញុំក៏រកចំណូលបានច្រើនដែរ។ វាហាក់ដូចជាថា នៅពេលខ្ញុំរៀននៅសាលា ខ្ញុំបានទទួលការបង្រៀនអំពីរបៀបរកលុយបានយ៉ាងល្អ ប៉ុន្តែ ពុំមានទរណាម្នាក់បានបង្រៀនខ្ញុំពីរបៀបគ្រប់គ្រងលុយឡើយ"។

ខណៈដែលយើងជឿជាក់ថានិស្សិតម្នាក់ៗ ប្រាថ្នាចង់រៀនថ្នាក់ដែលមានការអប់រំដល់អ្នកប្រើប្រាស់ ការបណ្តុះបណ្តាលជាបឋមគឺ ផ្អែកទៅលើឱពុកម្តាយ។ ឱពុកម្តាយមិនអាចទុកការបណ្តុះបណ្តាលដ៏សំខាន់នេះជាការកើតឡើងដោយចៃដន្យ ឬក៏ផ្ទេរការទទួលខុសត្រូវទាំងស្រុងទៅឱ្យសាលារៀន ឬវិទ្យាល័យរដ្ឋរបស់យើងឡើយ។

ផ្នែកសំខាន់នៃការបណ្តុះបណ្តាលនេះ គួរតែត្រូវបានពន្យល់អំពីបំណុល។ ចំពោះពួកយើងភាគច្រើន មានបំណុលហិរញ្ញវត្ថុពីរប្រភេទ —គឺបំណុលអ្នកប្រើប្រាស់ និងបំណុលវិនិយោគ ឬ បំណុលជួញដូរ។ បំណុលអ្នកប្រើប្រាស់គឺសំដៅទៅលើការទិញជឿទៅលើរបស់របរទាំងឡាយណាដែលយើងប្រើ ឬប្រើប្រាស់នៅក្នុងការរស់នៅប្រចាំថ្ងៃ។ ឧទាហរណ៍រួមមានការសងបណ្តាក់នៃការទិញសំលៀកបំពាក់ ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ សង្ហារឹម។ល។ បំណុលអ្នកប្រើប្រាស់ត្រូវបានធានាដោយការដាក់បញ្ចាំប្រាក់ចំណូលនាពេលអនាគតរបស់យើង។ ការធ្វើដូច្នេះអាចមានគ្រោះថ្នាក់ខ្លាំងណាស់។ ប្រសិនបើយើងត្រូវបញ្ឈប់ឱ្យធ្វើការជាបណ្តោះអាសន្ន ជាជនពិការ ឬ ជួបប្រទះនឹងភាពអាសន្នធ្ងន់ធ្ងរ យើងមានការលំបាកជាច្រើនក្នុងការបំពេញនូវភាតពូកិច្ចរបស់យើង។ ការទិញដោយកាត់សងជាបណ្តើរៗគឺជាវិធីថ្លៃបំផុតចំពោះការទិញដូរ។ ចំពោះតម្លៃទំនិញដែលយើងជាវ ត្រូវតែបន្ថែមការបង់ការប្រាក់ និងការប្រើប្រាស់ជាច្រើន។

ខ្ញុំដឹងថាក្រុមគ្រួសារក្មេងខ្ចីមើលយើញ វាជាការចាំបាច់នៅពេលទិញដូរជាឥណទាន។ ប៉ុន្តែ យើងសូមដាស់គ្បឿនអ្នកកុំឱ្យទិញលើសពីអ្វីដែលចាំបាច់ពិតប្រាកដ ហើយត្រូវសងបំណុលរបស់អ្នកឱ្យគ្រប់ចំនួនឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ នៅពេលដែលមានលុយបន្តិចបន្តួច នោះត្រូវជៀសវាងនូវបន្ទុកផ្សេងទៀតនៃការបង់ការប្រាក់បន្ថែមទៀត។

បំណុលវិនិយោគគួរតែត្រូវបានធានាឱ្យបានច្បាស់លាស់ ដើម្បីកុំឱ្យវាក្លាយទៅជាបន្ទុកធ្ងន់នៅក្នុងសុវត្ថិភាពគ្រួសារ។ ចូរកុំវិនិយោគដោយការប្រថុយប្រថានឡើយ។ អារម្មណ៍ដែលស្មានអាចក្លាយជាការបំពុល។ អ្នកមានធនធានជាច្រើនត្រូវបានបាត់បង់ដោយសារចំណង់ដែលមិនអាចគ្រប់គ្រងបាន ដែលបណ្តាលមកពីការចង់បានច្រើនឡើងៗ។ ចូរយើងរៀនពីទុក្ខព្រួយនៃអតីតកាល ហើយជៀសវាងធ្វើជាទាសករនៃពេលវេលា កម្លាំង និងសុខភាពទូទៅរបស់យើង ដោយសារតែចំណង់ហួសប្រមាណក្នុងការទទួលទំនិញជាសម្ភារះបន្ថែមទៀត។

ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល បានផ្តល់នូវប្រឹក្សានៃគំនិតដែលបង្ក ហេតុនេះថាៈ

"ព្រះអម្ចាស់បានប្រសិទ្ធិពរយើងឱ្យធ្វើជាមនុស្សដែលមានវិបុលភាពមិនស្មើគ្នាកន្លងមក។ ធនធានដែលត្រូវបានដាក់ នៅក្នុងអំណាចរបស់យើងគឺល្អ ហើយចាំបាច់ចំពោះការងាររបស់យើងនៅលើផែនដីនេះ។ ប៉ុន្តែ ខ្ញុំខ្លាចថាពួកយើងជាច្រើនត្រូវបានផ្តេកផ្តួលទៅតាមបក្សពួក ហើយនិងក្រុម និងហិកតា និងជង្រុកស្រូវ និងទ្រព្យសម្បត្តិ ព្រមទាំងចាប់ផ្តើមគោរពវត្ថុទាំង នោះដែលជាព្រះក្លែងក្លាយ ហើយវត្ថុទាំងនោះនឹងមានឥទ្ធិពលមកលើពួកយើង។ តើយើងមានវត្ថុល្អៗទាំងនេះច្រើនជាងជំនឿរបស់យើងអាចឈរឬ? មនុស្សជាច្រើនចំណាយពេលវេលាភាគច្រើនរបស់ខ្លួនដើម្បីបំពេញតម្រូវការខ្លួនឯង ដែលរួមមាន លុយច្រើន បណ្ណ័ភាគហ៊ុន សញ្ញាបណ្ណ័ការវិនិយោគលើផលប៉ត្រ ដីធ្លី ប័ណ្ណឥណទាន គ្រឿងសង្ហារឹម រថយន្ត ព្រម ទាំងការចង់បាន *ការរ៉ាប់រ៉ង* សុវត្ថិភាពដោយសង្ឃឹមថា អាចមានអាយុយឺនយូរ និងជីវិតរីករាយ។ យើងបានបំភ្លេចនូវហេតុការដែលកិច្ចការរបស់យើង គឺត្រូវប្រើប្រាស់ធនធានដ៏សន្ធឹកសន្ធាប់ទាំងនេះនៅក្នុងក្រុមគ្រួសារ និងក្រុមរបស់យើង ដើម្បីស្ថាបនានគរព្រះ" ("The False Gods We Worship" *Ensign* ខែ មិថុនា ឆ្នាំ 1976, 4)។

ខ្ញុំសូមធ្វើទីបន្ទាល់បន្ថែមលើប្រសាសន៍របស់ប្រធាន ឃីមចីលៅ។ ខ្ញុំដឹងថាពុំស្គាល់នូវស្ថានភាពណាផ្សេងទៀតដែលសុភមង្គល និងសេចក្តីសុខសាន្តនៃគំនិតបានកើនឡើង ដោយការប្រមូលទ្រព្យសម្បត្តិលើសពីការចង់បាន និងសេចក្តីត្រូវការសមហេតុផលមួយរបស់គ្រួសារនោះទេ។

លែលកថវិការដោយប្រយត្ន័ប្រយែង

ស្ថេរភាព #4៖ រកិវឌ្ឍ និងរស់នៅតាមថវិការដែលបានលែលក។ ខ្ញុំមានមិត្តម្នាក់មានកូនស្រីម្នាក់ដែលបានទៅរៀននៅបរទេស នៅ ប៊ី. វាយ. យូ រស់ពេលមួយឆមាស។ ជារឿយៗកូនស្រីរូបនោះបានសរសេរសំបុត្រមកផ្ទះសុំលុយបន្ថែម។ ការខ្វល់ខ្វាយរបស់ឪពុក គឺថានៅពេលដែលគាត់បានទូរស័ព្ទទៅរកកូនស្រីរបស់គាត់ពិចម្ងាយ ហើយសួរនាងអំពីមូលហេតុដែលត្រូវការប្រាក់បន្ថែមទៀតនោះ។ នៅក្នុងការសន្ទនា កូនស្រីរបស់គាត់បានពន្យល់ឪពុករបស់ខ្លួនត្រង់ថា “ប៉ុន្តែ លោកប៉ាកូនអាចប្រាប់លោកប៉ាអំពីចំនួនចំណាយមួយកាក់មួយសែននៃប្រាក់ដែលលោកប៉ាបានផ្ញើមកទៅលើអ្វីខ្លះបាន”.

គាត់បានឆ្លើយតបថា “កូនហាក់ដូចជាពុំយល់នូវអ្វីដែលប៉ាចង់និយាយសោះ។ ប៉ាចង់សំដៅទៅលើការរៀបចំថវិកា ការដាក់ផែនការចំពោះការចាយវាយ ពុំមែននៅក្នុងកំណត់ហេតុប្រចាំថ្ងៃរបស់កូន ដែលមានកត់នូវចំនួនទឹកប្រាក់ដែលត្រូវចំណាយទៅឯណានោះឡើយក”។

ជួនកាល ឪពុកម្តាយទាំងឡាយគួរតែធ្វើឱ្យដូចឪពុករបស់ក្មេងប្រុសវិទ្យាល័យម្នាក់ដែលបានផ្ញើសារតាមទូរលេខមកផ្ទះថា “កូនប្រុសគ្មានលុយ គ្មានសេចក្តីសប្បាយរីករាយ ពីកូនប្រុសរបស់លោកប៉ា”។ ឪពុករបស់ក្មេងប្រុសរូបនោះបានផ្ញើសារតាមទូរលេខត្រឡប់ទៅវិញថា “ឱ! គួរឱ្យសង្វេកណាស់កូន សូមចូលរួមសោកស្តាយផង មកពីលោកប៉ារបស់កូន។”

ខ្ញុំបានសង្កត់ធ្ងន់អំពីបញ្ហានេះនៅក្នុងកិច្ចសម្ភាសន៍របស់ខ្ញុំជាមួយមនុស្សជាច្រើនជារៀងរាល់ឆ្នាំ មានមនុស្សជាច្រើនដែលពុំមានថវិកាគ្រប់គ្រាន់ និងពុំបានដាក់វិន័យខ្លួនឯងចំពោះការចាយវាយដោយមានការបំរុងថវិកាទុកឡើយ។ មនុស្សជាច្រើនគិតថាថវិការារាំងកំប្លន់ពួកគេនូវសេរីភាពរបស់ខ្លួន។ ប៉ុន្តែ ផ្ទុយទៅវិញ មនុស្សដែលមានដោគជ័យបានដឹងថាថវិកាធ្វើឱ្យសេរីភាព សេដ្ឋកិច្ចអាចកើតមានឡើងយ៉ាងពិតប្រាកដ។

ការគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ ពុំមែនជាការស្មុកស្មាញ ឬប្រើប្រាស់ពេលវេលាច្រើនពេកនោះទេ។ មានរឿងមួយបានទិទាន ដោយឪពុកជាជនភ្សៀសខ្លួនម្នាក់ដែលបានសន្សំប្រាក់ដែលត្រូវចំណាយរបស់គាត់នៅក្នុងប្រអប់ស្បែកជើងមួយ ប្រាក់ដែលត្រូវបានទទួលទុកនៅលើប្រដាប់រវៃ ហើយសាច់ប្រាក់សុទ្ធរបស់គាត់ទុកនៅក្នុងម៉ាស៊ីនគិតលុយ។

កូនប្រុសរបស់គាត់បាននិយាយឡើងថា “កូនមិនគិតថាលោកឪពុកអាចធ្វើអាជីវកម្មរបស់លោកពុកបានតាមវិធីនេះទេ តើ លោកពុកដឹងយ៉ាងដូចម្តេចថាប្រាក់ចំណេញរបស់លោកពុកមានប៉ុន្មានទោះ?”

អ្នកជំនួញឆ្លើយតបវិញ“កូនប្រុស នៅពេលដែលឪពុកចុះពីទូក ឪពុកមានតែខោមួយចង្កេះដែលឪពុកបានស្លៀកជាប់ទីងខ្លួនប៉ុណ្ណោះ។ បច្ចុប្បន្ននេះបងស្រីរបស់កូនគឺជាគ្រូបង្រៀនសិល្បៈ បងប្រុសរបស់កូនគឺជាវេជ្ជបណ្ឌិត ហើយកូនគឺជាគណនេយ្យករមួយរូប។ ឪពុកមានឡាន មានផ្ទះ ព្រមទាំងមុខជំនួញល្អមួយ។ អ្វីៗគ្រប់យ៉ាងត្រូវបានទទួលខុសត្រូវ។ ដូច្នេះ ចូរកូនបូកបញ្ចូលវាទាំងអស់ ដកខោវែងមួយចេញ ហ្នឹងហើយជាប្រាក់ចំណេញរបស់ពុក”។

ទីប្រឹក្សាហិរញ្ញវត្ថុដែលប្រកបទៅដោយគតិបណ្ឌិតម្នាក់បានបង្រៀនថា ចំពោះថវិកាល្អនិមួយៗមានធាតុបួនយ៉ាងផ្សេងៗគ្នា។ ការបំរុងទុកគួរតែត្រូវបានធ្វើឡើង *ទីមួយ* សំរាប់ជំណើការនូវសេចក្តីត្រូវការជាមូលដ្ឋានដូចជាម្ហូបអាហារ សំលៀកបំពាក់ ។ល។ *ទីពីរ* សំរាប់តម្លៃគេហដ្ឋាន *ទីបី* សំរាប់សេចក្តីត្រូវការនៅពេលមានភាពអាសន្នដូចជាការសន្សំ ការធានារ៉ាប់រងសុខភាព និងការធានារ៉ាប់រងជីវិត និង *ទីបួន* សំរាប់វិនិយោគដោយប្រុងប្រយត្ន័ និងកម្មវិធីស្មុកទំនិញទុកសំរាប់ពេលអនាគត។

ខ្ញុំសូមផ្តល់មតិលើធាតុពីរនៃធាតុទាំងបួននេះ។ ពុំមានអ្វីដែលមើលទៅហាក់ដូចជាពិតប្រាកដច្រើនដូចទឹងការមិន ទឹកស្មានដល់មួយទៅក្នុងជីវិតរបស់យើងឡើយ។ ជាមួយនឹងការកើនឡើងនូវតម្លៃពិនិត្យសុខភាព ធានារ៉ាប់រងសុខភាព គឺជាមធ្យោបាយតែមួយគត់ ដែលគ្រួសារភាគច្រើនអាចជួបគ្រោះថ្នាក់ធ្ងន់ធ្ងរ មានជម្ងឺឬក៏ថ្លៃសំរាលកូន ជាពិសេសតម្លៃទាំងនោះ គឺសំរាប់គ្រាដែលមានការសំរាលកូនមិនគ្រប់ខែ។ ការធានារ៉ាប់រងជីវិតផ្តល់នូវប្រាក់ចំណេញជានិច្ច នៅពេលដែលអ្នកបង់ថ្លៃទទួលមរណភាពមុនកាលកំណត់។ គ្រួសារគ្រប់រូបគួរតែធ្វើការបំរុងទុកសំរាប់សុខភាពផ្ទាល់ខ្លួន និងការធានារ៉ាប់រងជីវិត។

បន្ទាប់ពីតម្រូវការតូចតាចនេះត្រូវបានរៀបចំសព្វគ្រប់ហើយ នោះយើងគួរតែចេះសន្សំសំចៃដោយគ្រប់គ្រងការសន្សំជាប្រចាំ ដើម្បីបង្កើតមូលនិធិសំរាប់ការវិនិយោគ។ ខ្ញុំសូមធ្វើការបញ្ជាក់ថា មានមនុស្សភាគតិចណាស់ ដែលមានដោគជ័យនៅក្នុងការវិនិយោគលើកដំបូង ដោយពុំបង្កើតទម្លាប់នៃការសន្សំសំចៃជាប្រចាំនោះ។ ការធ្វើវិនិយោគតំរូវឱ្យមានការដាក់វិន័យ និងសុភវិនិច្ឆ័យត្រឹមត្រូវ។ មានមធ្យោបាយច្រើនណាស់ចំពោះការធ្វើវិនិយោគ។ ខ្ញុំមានជំហ៊ួនៗតែមួយគត់គឺត្រូវជ្រើសរើសទីប្រឹក្សាវិនិយោគរបស់អ្នកដោយប្រុងប្រយត្ន័។ ត្រូវត្រាកដថា ពួកគេសមនឹងទទួលទំនុកចិត្ត អំពីអ្នកក្នុងការរក្សាទុកបញ្ជីឯកសារវិនិយោគដែលត្រឹមត្រូវ។

ត្រូវស្មោះត្រង់

ស្ថេរភាពទី #5៖ ត្រូវស្មោះត្រង់នៅគ្រប់កិច្ចការហិរញ្ញវត្ថុទាំងអស់របស់អ្នក។ គោលការណ៍នៃសេចក្តីសុចរិតនឹងមិនដែលហួសសម័យឡើយ។ វាទាក់ទងទៅនឹងអ្វីៗទាំងអស់ដែលយើងធ្វើ។ ក្នុងនាមជាអ្នកដឹកនាំ និងសមាជិកនៃសាសនាចក្រ យើងគួរតែ មានគំរូនៃសេចក្តីសុចរិតដ៏ឥតខ្ចោះ។

បងប្អូនប្រុសស្រីទាំងឡាយ តាមរយៈគោលការណ៍ទាំងត្រាំនេះ ខ្ញុំបានព្យាយាមត្រាងជាសង្ខេបនូវអ្វីដែលអាចចង្អុលបង្ហិនកលក្ខណៈ ធ្វើជាគំរូនៃការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានទានា។

ខ្ញុំសង្ឃឹមថាពួកយើងម្នាក់ៗ អាចទទួលផលប្រយោជន៍អំពីការអនុវត្តន៍តាមគោលការណ៍ទាំងនេះ។ ខ្ញុំសូមធ្វើជាទីបន្ទាល់ថាគោលការណ៍ទាំងនេះគឺជាការពិត ហើយថាសាសនាចក្រនេះ និងការងារដែលយើងកំពុងធ្វើគឺពិត។

ដកស្រង់ចេញពីសុន្ទកថារបស់ប្រធាន ឆែនណៅ ក្នុងកិច្ចប្រជុំសុខុមាលភាពទូទៅនៅខែ តុលា ឆ្នាំ 1979 នៅសន្និសិទ្ធទូទៅនៃ សាសនាចក្រ (សូមមើល របាយការណ៍ ខែកញ្ញា ឆ្នាំ 1979 ទំព័រ 117–21 ឬ *Ensign* ទំព័រ 80–82)។

ចាប់ពីថ្ងៃទី _____ **ដល់** _____
កាលបរិច្ឆេទ កាលបរិច្ឆេទ

ចំណូល	ផែនការ	ចំណូលជាក់ស្តែង
ប្រាក់ឈ្នួល ឬប្រាក់ខែបន្ទាប់ពីបង់ពន្ធរួច		
ចំណូលផ្សេងទៀត		
ចំណូលសរុប		
ចំណាយ	ផែនការ	ចំណាយពិតប្រាកដ
ដង្វាយមួយភាគក្នុងដប់		
វិភាគទានសាសនាចក្រផ្សេងទៀត		
ប្រាក់សន្សំរយៈពេលវែង		
ប្រាក់សន្សំសំរាប់ពេលមានអាសន្ន		
អ្នកបម្រើអាហារ		
ឥណទានបញ្ចាំ ឬថ្លៃជួល		
ថ្លៃទឹក ភ្លើង សាំង		
ការធ្វើដំណើរ		
ការសងបំណុល		
ការធានារ៉ាប់រង		
ចំណាយខាងវេជ្ជសាស្ត្រ		
សំលៀកបំពាក់		
ផ្សេងៗ		
ផ្សេងៗ		
ផ្សេងៗ		
ចំណាយសរុប		

ផ្នែក ខ

ការទទួលខុសត្រូវរបស់ឪពុកម្តាយដើម្បីពង្រឹងដល់ក្រុមគ្រួសារ

“កូនៗគឺជាមរតកពីព្រះអម្ចាស់”

9

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលៈទេសៈរបស់អ្នកផ្ទាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- ធ្វើការប្តេជ្ញាមួយ ដើម្បីចំណាយពេលវេលាល្អៗខ្លួនជាមួយកូនៗ របស់អ្នកនិមួយៗ ឬជាមួយកូនម្នាក់នៅក្នុងក្រុមគ្រួសារទាំងមូល របស់អ្នក។ នៅពេលអ្នកនិយាយជាមួយកូនម្នាក់ៗ ចូរស្វែងរកការរៀនសូត្រ អ្វីៗដែលថ្មីអំពីការចាប់អារម្មណ៍ សេចក្តីត្រូវការ ព្រមទាំងការប្រឈមរបស់ ពួកគេ។
- សូមចំណាយពេលជាមួយនឹងស្វាមី ឬភរិយារបស់អ្នកដើម្បីពិភាក្សាអំពីកូនៗ របស់អ្នក។ ចូរពិចារណាអំពីភាពខ្លាំង និងការប្រឈមទាំងឡាយរបស់កូន ម្នាក់ៗ។ សំរេចចិត្តនូវអ្វីដែលអ្នកអាចធ្វើដើម្បីបំពេញសេចក្តីត្រូវការរបស់កូនៗ ម្នាក់ៗ។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

កូនៗគឺជាមរតកនៃព្រះអម្ចាស់

ប្រធាន ថូម៉ាស អេស ម៉នសុន
ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ

នៅក្នុងគម្ពីរម៉ាថាយ យើងដឹងថាបន្ទាប់ពីព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់បាន ចុះមកពីលើភ្នំប្រែរូបវិញ នោះពួកទ្រង់ឈប់សំរាកនៅស្រុកកាលីឡេ រួចហើយបាន យាងមកក្រុងកាពើណិមវិញ។ ពួកសិស្សទាំងនោះបានទិយាយទៅកាន់ព្រះយេស៊ូវ ថា “តើអ្នកណាធំជាងគេនៅឯគរស្ថានសួគ៌?

“តើទ្រង់បានហៅកូនកុមារតូចមួយមកដាក់នៅកណ្តាលពួកគេ

“រួចមានបន្ទូលថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាមិនផ្លាស់គំនិត ហើយត្រឡប់ដូចជាកូនតូចនេះ នោះទីឯងចូលទៅក្នុងគរស្ថានសួគ៌ពុំបានឡើយ។

“ដូច្នេះអ្នកណាដែលបន្ទាបខ្លួនឱ្យបានដូចកូនតូចនេះ អ្នកនោះឯងឈ្មោះថា ធំជាងគេក្នុងនគរស្ថានសួគ៌ហើយ។

“អ្នកណាដែលទទួលកូនតូចណាមួយដូចកូននេះ ដោយនូវឈ្មោះខ្ញុំ នោះក៏ ឈ្មោះថា ទទួលខ្ញុំដែរ។

“ប៉ុន្តែបើអ្នកណាធ្វើឱ្យកូនតូចណាមួយនេះ ដែលជឿដល់ខ្ញុំរវាតចិត្តចេញ នោះ ស៊ូឱ្យគេយកថ្មត្បាល់កិនយ៉ាងធំចងឯកអ្នកនោះ ហើយពន្លង់ទៅក្នុងសមុទ្រទីជ្រៅ វិញ”។[1]

ខ្ញុំគិតថាវាជារឿងសំខាន់ណាស់ដែលព្រះយេស៊ូវសព្វព្រះទ័យនឹងកុមារតូចៗ ទាំងនេះ ដែលទើបតែចាកចេញពីស្ថានលើមកកាន់ផែនដីថ្មីៗនេះ។ កុមារនៅ សម័យនោះ និងកុមារនៅបច្ចុប្បន្ននេះបានឱ្យពរដ៏ឃ្លាតដល់ជីវិតរបស់ពួកយើង បង្កើត នូវសេចក្តីស្រឡាញ់ ព្រមទាំងរំលឹកអំពើល្អរបស់យើង។

តើមានអ្វីដែលសង្ឃឹមទេដែលកំណាព្យរបស់កវី វើតវ័ស និយាយអំពីកំណើត របស់ពួកយើង ៖ “តាមពីក្រោយពពកនៃ សិរីល្អយើងពិតជាមក/ពីព្រះ ដែលជា គេហដ្ឋានរបស់យើង”។[2]

កុមារតូចៗទាំងនេះភាគច្រើនមកនៅជាមួយឪពុកម្តាយដែលមានការទន្ទឹងចង់ បានយ៉ាងខ្លាំងនូវការចាប់កំណើតរបស់ពួកគេ មាតាបិតាទាំងឡាយដែលត្រេកអរជា មួយចំណែកនៃអព្ភូតហេតុនេះយើងហៅថាការចាប់កំណើត។ ពុំមាន ការលះបង់ណាធំធេងស្មើនោះទេ ក៏ពុំមានការឈឺចាប់ណាធ្ងន់ធ្ងរស្មើនោះដែរ ហើយការរង់ចាំដែលយូរពេកនោះក៏ពុំស្មើដែរ។

ពុំមានអ្វីប្លែកឡើយដែលយើងបានតក់ស្លុតនៅពេលដែលរឿងក្នុងទូរទស្សន៍មួយ មានប្រភពមកពីទីក្រុងមួយក្នុងប្រទេសអាមេរិក រាយការណ៍ថា “ទារិការដែលទើប ទឹងកើតត្រូវបានរុំនៅក្នុងក្រដាស ហើយបោះចោលទៅក្នុងធុងសំរាមមួយកំពុងស្ថិត នៅក្រោមការឃ្លាំមើលយ៉ាងយកចិត្តទុកដាក់នៅឯមន្ទីរពេទ្យ។ ទារិការនោះ សុខសប្បាយជាធម្មតា។ អ្នកនាំពាក្យនៅឯមន្ទីរពេទ្យ បាននិយាយកាលពីថ្ងៃពុធថា “ទារិការនោះពិតជាស្អាត ហើយជាទារិការដែលមានសុខភាពល្អ។ ប៉ូលីសនិយាយ ថាទារកត្រូវបានរកឃើញបន្ទាប់ពីអ្នកប្រមូលសំរាមចាក់សំរាមចេញទៅក្នុងគូទន្លាន ដឹកសំរាមរបស់ពួកគេ ហើយក៏ឃើញវត្ថុមួយរើចុះរើឡើងនៅក្នុងកាកសំណល់ សំរាម។ អាជ្ញាធរកំពុងតែតាមរកមាតារបស់ទារកនោះ។”

វាគឺជាកាតព្វកិច្ចដាច់ខាតរបស់យើង ជាឯកសិទ្ធិដ៏មានតម្លៃរបស់យើង—សូម្បី តែកាលានុវត្តភាពពិសិដ្ឋរបស់យើង—ដើម្បីស្វាគមន៍ដល់គេហដ្ឋានរបស់យើង ព្រមទាំងដល់ចិត្តរបស់យើងនូវកូនៗដែលជាព្រះគុណនៃជីវិតរបស់ពួកយើង។

កូនៗរបស់ពួកយើងមានថ្នាក់រៀនចំនួនបី ដែលមានភាពផ្សេងគ្នាច្រើនពីមួយទៅ មួយ។ ខ្ញុំនិយាយដល់ថ្នាក់រៀននៅឯសាលា ថ្នាក់រៀននៅក្នុងសាសនាចក្រ និងថ្នាក់ រៀនដែលបានហៅថាគេហដ្ឋាន។

ថ្នាក់រៀននៅឯសាលា

សាសនាចក្រតែងតែមានការយកចិត្តទុកដាក់យ៉ាងសំខាន់មួយនៅក្នុង ការអប់រំដាសាធារណៈ និងលើកទឹកចិត្តសមាជិករបស់ខ្លួនឱ្យចូលរួមនៅក្នុង សកម្មភាពឪពុកម្តាយជាគ្រូបង្រៀន និងព្រឹត្តការណ៍ផ្សេងៗទៀតដែលបានរៀបចំ ដើម្បីធ្វើឱ្យប្រសើរឡើងចំពោះការអប់រំដល់យុវជនរបស់យើង។

ពុំមានទិដ្ឋភាពនៃការអប់រំសាធារណៈណាសំខាន់ជាងគ្រូបង្រៀនដែលមានកាលានុវត្តភាពដើម្បីស្រឡាញ់ បង្រៀន និងបំផុសគំនិតកុមារា និងកុមារី យុវជន និងយុវនារីដែលស្រេកឃ្លានរកចំណេះដឹងនោះឡើយ។ ប្រធាន ដេវីដ អូ ម៉ាកខេ បានមានប្រសាសន៍ថា ៖ "ការបង្រៀនគឺជាវិជ្ជាជីវៈដ៏ថ្លៃថ្នូរបំផុតនៅក្នុងលោក។ តាមរយៈការអប់រំគ្រឹមត្រូវរបស់យុវវ័យ អាស្រ័យដោយភាពអចិន្ត្រៃយ៍ និងភាពបរិសុទ្ធនៃគេហដ្ឋាន សុវត្ថិភាព និងនិរន្តភាពនៃប្រជាជាតិ។ ឱពុកម្តាយផ្តល់ឱ្យកូនទូវកាលានុវត្តភាពសំរាប់រស់នៅ រីឯគ្រូបង្រៀនជួយឱ្យកូនរស់នៅបានគ្រឹមត្រូវ"។[3] ខ្ញុំជឿថាយើងគួរតែទទួលស្គាល់ពីសារៈសំខាន់របស់គ្រូបង្រៀន និងបេសកកម្មចាំបាច់របស់ពួកគេ ដោយផ្តល់ទូវសំភារៈឧបករណ៍ប្រើប្រាស់គ្រឹមត្រូវ ស្បៀវភៅល្អៗ ព្រមទាំងប្រាក់ខែដែលបង្ហាញនូវការដឹងគុណរបស់យើង និងការជឿទុកចិត្តរបស់យើង។

ពួកយើងម្នាក់ៗចងចាំដោយក្តីស្រឡាញ់ទូវគ្រូបង្រៀនកាលពីយុវវ័យរបស់យើង។ ខ្ញុំគិតថាវាជាការធ្វើឱ្យសប្បាយរីករាយដែលគ្រូបង្រៀនតន្ត្រីនៅសាលាបឋមសិក្សារបស់ខ្ញុំគឺជាអ្នកគ្រូ សាព។ គាត់មានសមត្ថភាពបញ្ចូលទៅក្នុងកូនសិស្សរបស់គាត់ទូវចំណង់ចំណូលចិត្តមួយចំពោះតន្ត្រី ហើយបានបង្រៀនពួកយើងឱ្យស្គាល់ឧបករណ៍ភ្លេង និងសម្លេងរបស់ឧបករណ៍ទាំងនោះ។ ខ្ញុំចាំច្បាស់ណាស់ ទូវតទ្ធិពលរបស់អ្នកគ្រូ រូថ ក្រូ ដែលបានបង្រៀនមុខវិជ្ជាសុខភាព។ ទោះបីកាលនោះស្ថិតនៅក្នុងពេលវេលាលំបាកក៏ដោយ ក៏គាត់នៅតែធ្វើឱ្យប្រាកដថាកូនសិស្សថ្នាក់ទីប្រាំមួយម្នាក់ៗមានការធ្វើផែនការសុខភាពធ្មេញ។ គាត់បានពិនិត្យដោយខ្លួនឯងផ្ទាល់ទូវកូនសិស្សម្នាក់ៗចំពោះសុខភាពធ្មេញ និងបានធ្វើយ៉ាងឡេងទាត់ទូវកិច្ចការនេះតាមរយៈធនធានសាធារណៈ និងឯកជនដោយពុំមានកូនសិស្សណាម្នាក់ចេញទៅដោយគ្មានការថែរក្សាធ្មេញឡើយ។ ដូចជាអ្នកគ្រូ បឺកហាស ដែលជាគ្រូបង្រៀនភូមិវិទ្យា បានរមូរផ្ទាំងផែនទីពិភពលោកចុះ ហើយដែលពេលខ្លះខ្ញុំពិតជាបានប្រមើល ឬសុបិនថាថ្ងៃណាមួយខ្ញុំនឹងទៅលេងទឹកដី និងប្រជាជនទាំងនេះ ជាមួយនឹងប្រដាប់ចង្អុលរបស់គាត់ គាត់បានគូសចំណាំទូវរដ្ឋធានីនៃប្រជាជាតិនានា ព្រមទាំងលក្ខណៈខុសគ្នា នៃប្រទេស ភាសា និងវប្បធម៌និមួយៗ។

អ្ហ៉ូ! សារៈសំខាន់នៅក្នុងជីវិតនៃកូនៗរបស់យើង គឺគ្រូបង្រៀនណាដែលលើកទឹកចិត្តរបស់ពួកគេ សម្រួចនូវការយល់ដឹងរបស់ពួកគេ ព្រមទាំងជំរុញជីវិតរបស់ពួកគេ!

ថ្នាក់រៀននៅឯសាសនាចក្រ

ថ្នាក់រៀននៅឯសាសនាចក្របានបន្ថែមទូវទំហំដ៏សំខាន់មួយដល់ការអប់រំនៃកូនគ្រប់ៗរូប ព្រមទាំងយុវវ័យរបស់ពួកគេ។ នៅក្នុងការរៀបចំនេះ គ្រូបង្រៀនម្នាក់ៗអាចផ្តល់ការចូលទៅដល់ខាងលើដល់អ្នកទាំងឡាយណាដែលគ្រងគ្រាប់ដល់ការបង្រៀនរបស់គាត់ និងទទួលអារម្មណ៍ពីតទ្ធិពលនៃទីបន្ទាល់របស់គាត់។ នៅក្នុងថ្នាក់បឋម សាលាថ្ងៃអាទិត្យ ការប្រជុំនៃយុវនារី ព្រមទាំងអ្នកទាំងឡាយដែលនៅក្នុងបព្វជិតភាពអើរ៉ុន គ្រូបង្រៀនដែលមានការរៀបចំល្អ ដែលបានហៅឱ្យបំរើនៅក្រោមការការបំផុសគំនិតពីព្រះអម្ចាស់ដែលអាចកែប្រែកូនយើងម្នាក់ៗ យុវវ័យម្នាក់ៗ ហើយញាុំងឱ្យទាំងអស់គ្នា "... ព្យាយាមស្វែងរក ហើយបង្រៀនគ្នាទៅវិញទៅមកនូវពាក្យសំដីនៃប្រាជ្ញាវាងវៃ"។[4] ពាក្យសំដីនៃការលើកទឹកចិត្តនៅទីនេះ និងគំនិតខាងវិញ្ញាណមួយនៅទីនោះ អាចមានតទ្ធិពលលើជីវិតដ៏មានតម្លៃ ហើយទុកស្នាមផ្តិតដែលមិនអាចរលុបបាននៅលើដួងព្រលឹងដ៏អមតៈ។

ជាច្រើនឆ្នាំកន្លងទៅនេះ នៅក្នុងពិធីជប់ល្បែងទទួលរង្វាន់ទស្សនាវដ្តី សាសនាចក្រ ពួកខ្ញុំបានអង្គុយជាមួយប្រធាន និងសុិស្ទើរ ហារូល ប៊ីលី។ ប្រធានលី បានមានប្រសាសន៍ទៅកាន់ អាន ជាកូនស្រីវ័យជំទង់របស់ពួកខ្ញុំថា ៖ "ព្រះអម្ចាស់បានផ្តល់ពរជ័យដល់ក្មួយឱ្យមានមុខ ព្រមទាំងរាងកាយដ៏ស្រស់ស្អាត។ ចូររក្សាភាពខាងក្នុងឱ្យស្រស់ស្អាតដូចជាភាពខាងក្រៅ នោះក្មួយនឹងទទួលបានពរជ័យនៃសុភមង្គលពិតប្រាកដ"។ លោកមហាគ្រូរូបនេះបន្សល់ទុកឱ្យ អាន ទូវការញាុំងសតិទៅរកនគរសេលេស្ទាល នៃនគរ ស្ថានសួគិរបស់ព្រះវរបិតាយើង។

គ្រូបង្រៀនដែលបន្ទាបខ្លួន និងមានការបំផុសគំនិតនៅក្នុងថ្នាក់រៀននៃសាសនាចក្រ អាចលើកទឹកចិត្តកូនសិស្សរបស់គាត់ទូវការចូលចិត្តមួយចំពោះព្រះគម្ពីរ។ ហេតុអ្វីគ្រូបង្រៀនអាចនាំយកដំណើររឿងរបស់ពួកសាវកជំនាន់បុរាណ និងព្រះអង្គសង្គ្រោះនៃពិភពលោក មិនគ្រាន់តែនៅក្នុងថ្នាក់រៀនប៉ុណ្ណោះទេតែថែមទាំងនៅក្នុងចិត្ត គំនិត ដួងព្រលឹងនៃកូនៗរបស់យើងថែមទៀតផង។

ថ្នាក់រៀនដែលបានហៅថាគេហដ្ឋាន

ជួនកាល សារៈសំខាន់បំផុតនៃថ្នាក់រៀនទាំងអស់គឺថ្នាក់រៀននៅគេហដ្ឋាន។ បុគ្គលិកលក្ខណៈ សេចក្តីជំនឿដ៏ជ្រាលជ្រៅរបស់យើង អាចរៀនសូត្របាននៅក្នុងគេហដ្ឋាន។ សេចក្តីសង្ឃឹមត្រូវបានចិញ្ចឹមបីបាច់ ឬត្រូវកំទេចចោល គឺនៅក្នុងគេហដ្ឋាន។ គេហដ្ឋានរបស់យើងគឺជាទីពិសោធន៍នៃជីវិតរបស់យើង។ អ្វីៗដែលយើងធ្វើនៅទីនោះ កំណត់ដំណើរនៃជីវិតរបស់យើង នៅពេលដែលយើងចាកចេញពីគេហដ្ឋាន។ បណ្ឌិត ស្តៅ អ៊ី រូសិនបឺក បានសរសេរនៅក្នុងស្បៀវភៅ "*ផ្លូវនាំទៅរកការជឿជាក់* "ថា ថ្ងៃបើមានការបង្កើតថ្មីទាំងអស់ ព្រមទាំងរចនាប្លង់ទំនើបៗ អ្វីៗដែលគេនិយមមួយគ្រា និងគ្រឿងសំណែនក៏ដោយ ក៏ពុំទាន់មានទរណាម្នាក់បានបង្កើត ឬនឹងដែលបង្កើតដើម្បីជំនួសឱ្យការបំពេញចិត្តនៃក្រុមគ្រួសាររបស់ខ្លួនឯងផ្ទាល់ឡើយ។"[5]

គេហដ្ឋានដែលរីករាយ គឺជាការចាប់ផ្តើមនៃស្ថានសួគិ។ ប្រធាន ចច អ័លប៊ើត ស្មុីធ បានសួរថា ៖ "[តើ]យើងចង់ឱ្យគេហដ្ឋានរបស់យើង មានការសប្បាយរីករាយមួយឬទេ [?] ប្រសិនបើយើងចង់បាននោះ សូមឱ្យគេហដ្ឋានរបស់យើងទាំងអស់គ្នាជាទីកន្លែងនៃការអធិស្ឋាន ថ្លែងអំណរគុណ និងការដឹងគុណដ៏ខ្ជាប់ខ្ជួន"។[6]

មានស្ថានភាពទាំងនោះដែលកូនៗ មកចាប់កំណើតនៅលើផែនដីនេះ ជាមួយនឹងរូបរាងកាយ និងគំនិត បញ្ញាពិការភាព។ ចូរព្យាយាមដូចជាយើងដឹង វាពុំមានលទ្ធភាពដើម្បីដឹងថាហេតុអ្វី ឬហេតុដូម្តេចបានជាព្រឹត្តការណ៍អស់ទាំងនេះកើតឡើងនោះ។ ខ្ញុំសូមគោរពចំពោះឱពុកម្តាយទាំងឡាយណាដែលពុំមានការតវ៉ា ទទួលយកកូនដូច្នេះនៅក្នុងដៃទាំងទ្វេររបស់ពួកគាត់ និងនៅក្នុងជីវិតរបស់ពួកគាត់ ព្រមទាំងផ្តល់វិធានការណ៍បន្ថែមចំពោះការលះបង់ទាំងនោះ និងសេចក្តីស្រឡាញ់ទៅដល់កូនម្នាក់របស់ព្រះវរបិតាសួគិ។

នារដូវក្តៅមួយ នៅឯការបោះជំរុំជាលក្ខណៈក្រុមគ្រួសារក្នុងព្រៃអាស្ពេន ខ្ញុំបានសំគាល់យើញថា មានម្តាយម្នាក់ដែលមានការអត់ធ្មត់ក្នុងការបញ្ចុកអាហារដល់កូនស្រីវ័យជំទង់ដែលមានជម្ងឺពីកំណើត ហើយត្រូវពឹងផ្អែកនៅលើម្តាយទាំងស្រុង។ ម្តាយនាងបានបញ្ចុកអាហារមួយស្លាបព្រាម្តង មួយស្លាបព្រាម្តង ឱ្យទឹកផឹកបន្តិចម្តងបន្តិចម្តង ខណៈដែលគាត់ទប់ក្បាល និងករបស់នាងឱ្យនឹង។ ខ្ញុំបានគិតតែម្នាក់ឯងយ៉ាងស្ឃៀមស្ងាត់ថា *រយៈពេល 17 ឆ្នាំមកហើយដែលម្តាយបានផ្តល់ការបំរើនេះ ព្រមទាំងអ្វីផ្សេងៗទៀតដល់កូនស្រីរបស់ខ្លួន ដោយមិនដែលគិតដល់ភាពសុខស្រួលផ្ទាល់ខ្លួន* សេចក្តីអំណរផ្ទាល់ខ្លួន ម្ហូបអាហារផ្ទាល់ខ្លួន។ សូមឱ្យព្រះប្រទានពរដល់មាតាដូច្នេះ ឱពុកដូច្នេះ កូនដូច្នេះ។ ទ្រង់នឹងប្រទានពរពិតមែន។

ភាពគ្មានកំហុសរបស់កុមារ

ឱពុកម្តាយនៅគ្រប់ទីកន្លែង យល់ដឹងថាភាពបន្សំដែលមានឥទ្ធិពលបំផុតនៃការរំជួលចិត្តក្នុងពិភពលោក ពុំមែនត្រូវបានកក្រើក ដោយព្រឹត្តការណ៍លោកធាតុដ៏ធំសម្បើមណាមួយ ឬក៏ត្រូវបានរកឃើញនៅក្នុងស្សៀវភៅប្រលោមលោក ឬស្សៀវភៅប្រវត្តិសាស្ត្រនោះឡើយ ប៉ុន្តែដោយសារឱពុកម្តាយម្នាក់ ដែលសំលឹងមិនដាក់ភ្នែកទៅលើកូនម្នាក់ដែលកំពុងដេកលក់។

នៅពេលដែលកំពុងធ្វើដូច្នេះ ខ្ញុំនឹកឃើញដល់សេចក្តីពិតនៃពាក្យសំដីរបស់ ឆាលី អិម ឌីកិនសុន ៖

ពួកគេគឺជារូបបដិមាករជាទីគោរពនៃចិត្ត និងផ្ទះសម្បែង!
ពួកគេគឺជាទេវតាលាក់កំបាំងនៃព្រះ
ពន្លឺព្រះអាទិត្យនៅតែនិទ្រាក្នុងកម្រងសក់របស់ពួកគេ
ភាពរុងរឿងរបស់ព្រះអង្គនៅតែជាពន្លឺចែងចាំងក្នុងកែវភ្នែករបស់ពួកគេ
កុមារអនាថាទាំងនេះមកពីផ្ទះ និងពីស្ថានសួគ៌
ពួកគេបានធ្វើឱ្យខ្ញុំសុភាពរាបសារ និងអោនលំទោន
ហើយឥឡូវនេះ ខ្ញុំដឹងថាហេតុអ្វីបានជាព្រះយេស៊ូវអាចប្រដូច
នគរព្រះទៅនឹងកុមារម្នាក់។[7]

នៅក្នុងបទពិសោធន៍ប្រចាំថ្ងៃរបស់យើងជាមួយកុមារ យើងដឹងថាកុមារគឺជាមនុស្សឈ្លាសវៃបំផុត ហើយជារឿយៗនិយាយតែការពិតបំផុត។ លោក ឆាលី ឌីកិនសុន ជាអ្នកនិពន្ធចំរៀងបុរាណ*បុណ្យគ្រីស្ទម៉ាស* បានឆ្លុះបញ្ចាំងនូវទិដ្ឋភាពពិតនេះ នៅពេលគាត់បានរៀបរាប់អំពីការជួបជុំគ្នាជាគ្រួសាររបស់ បប ក្រាតឆិត ដ៏រាបសារក្នុងការមានអាហារពេលល្ងាចបន្តិចបន្តួច ប៉ុន្តែឱ្យការចូលរួមមានរយៈពេលយូរនៅក្នុងបុណ្យគ្រីស្ទម៉ាស។ លោក បប ជាឱពុកបានត្រឡប់មកផ្ទះវិញដោយដាក់កូនប្រុសដ៏ទន់ខ្សោយរបស់គាត់ ឈ្មោះ ធិនី ធីម នៅលើស្មារបស់គាត់។ ធិនី ធីម "កាន់ឈើច្រត់តូចមួយ ហើយអវះយវះរបស់គាត់បានគាំទ្រដោយគ្រោងដែកមួយ" ភិរយារបស់ បប បានសួរបបថា "'តើកូនធីមធ្វើឥរិយាបទយ៉ាងណាដែរ?'"

លោក បប បានឆ្លើយតបថា "'ល្អណាស់ ហើយវាកាន់ប្រសើរឡើងៗ។ ដោយពុំបានដឹងពីមូលហេតុ កុមារាធីមបានចាប់ផ្តើមគិត ដោយអង្គុយតែម្នាក់ឯង ហើយបានគិតនូវរឿងដ៏ចម្លែកមួយដែលអ្នកមិនធ្លាប់បានឲ្យពីមុនមកនោះទេ។ នៅតាមផ្លូវត្រឡប់មកផ្ទះវិញ គាត់បានប្រាប់ខ្ញុំថា គាត់សង្ឃឹមថាមនុស្សដែលបានឃើញគាត់នៅក្នុងព្រះវិហារ ដោយហេតុថារូបគាត់ជាមនុស្សពិការ ហើយវាអាចនឹងក្លាយជាសេចក្តីអំណរចំពោះពួកគេ ដើម្បីចងចាំអំពីថ្ងៃបុណ្យគ្រីស្ទម៉ាស នូវអ្នកដែលបានធ្វើឱ្យមនុស្សខ្ងិនអាចដើរបាន ហើយមនុស្សខ្វាក់អាចមើលឃើញ'"។[8]

លោក ឆាលី អិម ឌីកិនសុន បានមានប្រសាសន៍ដោយផ្ទាល់ថា "ខ្ញុំស្រឡាញ់កុមារតូចៗទាំងនេះ ហើយវាពុំមែនជារឿងតូចតាចឡើយ នៅពេលពួកគេជាអ្នកដែលទើបមកពីវត្តមាននៃព្រះ ស្រឡាញ់យើង"។

កុមារសម្តែងចេញនូវសេចក្តីស្រឡាញ់របស់ខ្លួនតាមនិស្ស័យពីធម្មជាតិ ហើយមាននូវការច្នៃប្រឌិត។ នៅបុណ្យកំណើតរបស់ខ្ញុំកាលពីប៉ុន្មានឆ្នាំមុន មានកុមារីដ៏ស្រស់ស្អាតម្នាក់ បានបង្ហាញខ្ញុំនូវប័ណ្ណសំរាប់បុណ្យកំណើតដែលសរសេរដោយដៃរបស់នាង ហើយបានដាក់នៅក្នុងស្រោមសំបុត្រជាមួយនឹងបណ្តោងសោតូចមួយដែលនាងចូលចិត្ត ហើយនាងបានគិតថា ខ្ញុំនឹងរីករាយដើម្បីទទួលវាទុកជាអំណោយ។

"នៅរាល់ទិដ្ឋភាពដ៏ស្រស់បំប៉ងនៅក្នុងពិភពលោកនេះ គឺគ្មានអ្វីដែលមានភាពស្រស់ស្អាតជាង នៅពេលដែលមានកុមារម្នាក់ផ្តល់ឱ្យនូវអ្វីមួយនោះឡើយ។ កុមារផ្តល់នូវពិភពលោកនេះសំរាប់អ្នក។ វាបានបើកពិភពលោកនេះសំរាប់អ្នកប្រៀបបាននឹងស្សៀវភៅមួយដែលអ្នកពុំធ្លាប់បានអានពីមុនមក។ ប៉ុន្តែនៅពេលអំណោយមួយបានកើតមានឡើង នោះជានិច្ចកាលវាគឺជាវត្ថុមួយដែលមិនទំនង បានបិទភ្ជាប់ទៅនឹងអ្វីមួយដែលកោង . . . ជាទេវតាមួយអង្គដែលមើលទៅហាក់ដូចអ្នកត្លុក។ កុមារម្នាក់អាចមានរបស់បន្តិចបន្តួចប៉ុណ្ណោះដែលវាអាចផ្តល់ឱ្យបានដោយសារវាពុំបានដឹងថា វាបានផ្តល់ឱ្យយើងនូវអ្វីៗគ្រប់យ៉ាងនោះទេ"។[9]

នេះគឺជាអំណោយដូចគ្នាដែលកុមារី ជេនី បានឱ្យមកខ្ញុំ។

កុមារហាក់ដូចជាមាននូវអំណោយទានពិសិដ្ឋ ដែលឱបក្រសោបនូវសេចក្តីជំនឿចំពោះព្រះវរបិតាសួគ៌របស់ពួកគេ និងសមត្ថភាព ហើយនឹងព្រះទ័យរបស់ទ្រង់ នៅក្នុងឆ្លើយតបចំពោះការអធិស្ឋានដ៏ផ្អែមល្ហែមរបស់ពួកគេ។ ខ្ញុំមានទូវបទពិសោធន៍ផ្ទាល់ខ្លួនថា នៅពេលកុមារម្នាក់អធិស្ឋាន នោះព្រះទ្រង់សណ្តាប់នូវការអធិស្ឋាននោះ។

ខ្ញុំសូមចែកចាយជាមួយអ្នករាល់គ្នានូវបទពិសោធន៍របស់ ប៉ើរី បូណេល និង ឌែល មើហ្ស៊ ជាកីឡាករវាយកូនបាល់ដ៏ល្បីល្បាញ ដែលកាលពីមុនលេងឱ្យក្រុមអាតាឡង់តា ប្រេវស៍។ ពួកគេទាំងពីរគឺជាពួកអ្នកផ្លាស់ប្រែចិត្តជឿចូលមកក្នុងសាសនាចក្រ លោក ឌែល មើហ្ស៊ ត្រូវបានទទួលពិធិបុណ្យជ្រមុជទឹកដោយ លោក ប៉ើរី បូណេល។

"បទពិសោធន៍នេះបានកើតមានឡើងនៅក្នុងរដូវកាលឆ្នាំ 1978 គឺជាឆ្នាំដែលលោក ប៉ើរី បានរៀបរាប់ថាជា 'ការផ្លាស់ប្តូរនៃជីវិត'។ គាត់កំពុងជួបនឹងបញ្ហាស្មុគស្មាញយ៉ាងខ្លាំង។ ដោយសារការលេងរបស់គាត់មិនសូវល្អ នោះគាត់បានស្តីបន្ទោសខ្លួនឯង ហើយមានអារម្មណ៍សោកសៅ។ នៅពេល ឌែល មើ បានសុំឱ្យគាត់ទៅឯមន្ទីរពេទ្យដើម្បីបានជាគ្នា នោះគាត់ពិតជាមិនចង់ទៅឡើយ ប៉ុន្តែទោះជាយ៉ាងក៏ដោយ គាត់នៅតែទៅ។ លុះទៅដល់មន្ទីរពេទ្យ គាត់បានជួបនឹងកុមារម្នាក់ឈ្មោះ រីគី ជាអ្នកគាំទ្រម្នាក់របស់ក្រុម [អាតាឡង់តា] ប្រេវស៍ ប៉ុន្តែកុមារារូបនេះមានជម្ងឺមហារីកគ្រាប់ឈាម។ ហើយអការៈរបស់ រីគី បានបញ្ជាក់ថា សេចក្តីស្លាប់កំពុងតែខិតចូលមកជិតហើយ។ ប៉ើរី បានព្យាយាមរិះរកនូវអ្វីមួយដើម្បីធ្វើជាពាក្យលួងលោមសំរាប់ រីគី ប៉ុន្តែវាហាក់ដូចជាគ្មានពាក្យណាដែលសក្តិសមនោះឡើយ។ នៅទីបំផុត គាត់បានសួរទៅកាន់ រីគី បើសិនជាមានអ្វីមួយដែលពួកគាត់អាចជួយបាន។ កុមារាម្នាក់នេះក៏មានការស្ទាក់ស្ទើរ ហើយបន្ទាប់មកបានសុំឱ្យថាពួកគាត់ទាំងពីរអាចវាយកូនបាល់ឱ្យបានឆ្ងាយ ហើយរត់ទៅទីផ្តាច់ព្រ័ត្រនៅក្នុងការប្រកួតលើកក្រោយ។ ប៉ើរី បាននិយាយថា [ការប្រកួតលើកក្រោយមែនទេ] 'ការស្មើសុំនោះវាពុំមែនជារឿងពិបាកសំរាប់ ឌែល ដែលជាអ្នកបានវាយកូនបាល់ ហើយរត់ទៅទីផ្តាច់ព្រ័ត្រដល់ទៅពីរដងនៅយប់នោះឡើយ ប៉ុន្តែសំរាប់រូបខ្ញុំវាគឺជាបញ្ហាដ៏ធំ ពីព្រោះពេញមួយឆ្នាំនេះខ្ញុំមិនបានវាយកូនបាល់ឱ្យត្រូវ ហើយរត់ទៅកាន់ទីផ្តាច់ព្រ័ត្រនៅឡើយនោះទេ។ បន្ទាប់មក ខ្ញុំបានទទួលនូវអារម្មណ៍ដ៏កក់ក្តៅមួយ ដែលបានកើតមានចំពោះរូបខ្ញុំ ហើយបាននិយាយទៅកាន់ រីគី ឱ្យទុកចិត្ត ចុះ'"។ នៅយប់នោះ ប៉ើរី បានវាយកូនបាល់ហើយរត់ទៅទីផ្តាច់តែម្តងប៉ុណ្ណោះនៅក្នុងរដូវកាលនោះ។[10] ការអធិស្ឋានរបស់កុមារម្នាក់ត្រូវបានឆ្លើយតប បំណងប្រាថ្នារបស់កុមារម្នាក់ត្រូវបានទទួលនូវការសំរេច។

តំរូវការសំរាប់សេចក្តីសុខសាន្ត

បើសិនជាកុមារទាំងអស់មានឱពុកម្តាយជាទីស្រឡាញ់ មានគេហដ្ឋានដ៏សុខសាន្ត និងមានមិត្តដែលយល់ចិត្ត តើពិភពលោករបស់ពួកគេនឹងមានភាពអស្ចារ្យ

ប៉ុណ្ណោះទៅ។ ប៉ុន្តែជាអកុសល កុមារទាំងអស់មិនត្រូវបានគេប្រទានពរឱ្យទូរចិត្ត មេត្តាករុណាដ៏ពេញលេញនោះឡើយ។ កុមារខ្លះបានមើលឃើញឪពុកវាយធ្វើបាបម្តាយរបស់ខ្លួន ខណៈដែលមានកុមារផ្សេងទៀត បានទទួលទូវការបញ្ចប់នៃការរំលោភបំពានបែបនេះ។ វាគួរឱ្យភ័យខ្លាចខ្លាំងណាស់ នេះគឺជាអំពើគ្មានគុណធម៌ ហើយវាមានភាពអាម៉ាស់ខ្លាំងណាស់!

មន្ទីរពេទ្យក្នុងមូលដ្ឋាននៅគ្រប់ទីកន្លែងបានទទួលទូវកុមារតូចទាំងនេះ ដែលត្រូវបានគេវាយដំ ហើយមានទូវស្នាមជាំ រួមផ្សំជាមួយនឹងពាក្យកុហករបស់ពួកមនុស្សធំថា កុមារទាំងនេះ “បានរត់ទៅត្រូវនឹងទ្វារ ” ឬ “បានធ្លាក់ពីកាំជណ្តើរ”។ ពួកមនុស្សកុហក ពួកមនុស្សចូលចិត្តគំរាមកំហែងលើកុមារ នោះនៅថ្ងៃណាមួយពួកគេនឹងច្រូតកាត់ បានជាខ្យល់តូចនៃទង្វើរដ៏កខ្វក់របស់ពួកគេ។ កុមាររងគ្រោះដោយការរំលោភបំពាន ដែលមានភាពស្បៃមុខស្ងាត់ មានការឈឺចាប់ មានការធ្វើឱ្យអាក់អន់ចិត្ត និងនៅក្នុងគ្រានៃការស្មន់ នោះត្រូវតែទទួលទូវជំនួយ។

មានចៅក្រមនៅក្នុងមណ្ឌលម្នាក់បានសរសេរសំបុត្រមួយមកកាន់ខ្ញុំ ដោយមានប្រសាសន៍ថា ៖ “ការបំពានខាងផ្លូវភេទចំពោះកុមារ គឺជាឧក្រិដ្ឋកម្មដែលគ្មានគុណធម៌ ដែលធ្វើឱ្យវិទាស និងជាឧក្រិដ្ឋកម្មដែលខុសសីលធម៌ដ៏ធំមួយនៅក្នុងមជ្ឈដ្ឋានសង្គមស៊ីវិល។ ការព្រួយបារម្ភមួយអំពីកំណើននៃរបាយការណ៍ស្តីអំពីការរំលោភបំពានចំពោះកុមារខាងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទបានកើតមានឡើង។ គុណសម្បត្តិរបស់យើងកំពុងតែមមាញឹកជាមួយនឹងអាកប្បកិរិយាដ៏កខ្វក់នេះ”។

សាសនាចក្រនោះមិនបានលើកលែងទោសទូវទង្វើរដ៏សាហាវឃោរឃៅ និងថោកទាបបែបនេះឡើយ។ តែផ្ទុយទៅវិញ យើងនឹងផ្តោលទោសចំពោះការប្រព្រឹត្តបែបនេះទៅលើកូនចៅដ៏មានតម្លៃរបស់ព្រះនៅក្នុងពាក្យដ៏ឃោរឃៅបំផុត។ ចូរអនុញ្ញាតឱ្យកុមារទាំងនោះត្រូវបានទទួលទូវការជួយសង្គ្រោះ ទទួលទូវការចិញ្ចឹមបីបាច់ ទទួលបានទូវសេចក្តីស្រឡាញ់ និងត្រូវបានគេព្យាបាលឱ្យជាសះស្បើយ។ ចូរទាំក្រិដ្ឋជនទូរបនោះទៅកាន់តុលាការ ដើម្បីទទួលទោសចំពោះទង្វើររបស់ខ្លួន ហើយទទួលទូវការប្រឈមមុខស្របច្បាប់ ដើម្បីដាក់លក្ខខណ្ឌចំពោះទង្វើរដ៏ទុច្ចរិត និងដ៏អាក្រក់បែបនេះ។ នៅពេលអ្នករាល់គ្នា ហើយនិងរូបខ្ញុំដឹងអំពីទង្វើរទាំងនេះ ហើយបរាជ័យនៅក្នុងការទប់ស្កាត់ទង្វើរទាំងនេះ នោះយើងភ្ជាយទៅជាផ្នែកមួយនៃបញ្ហានេះ។ យើងចែកចាយផ្នែកនៃកំហុសនេះ។ យើងទទួលបទពិសោធន៍ទូវផ្នែកនៃការដាក់ទោសនេះ។

ខ្ញុំជ្រើរដាក់ថា ខ្ញុំមិនបាននិយាយពាក្យដែលមិនពិរោះពិសារពេកនោះទេ ប៉ុន្តែខ្ញុំស្រឡាញ់កុមារតូចៗទាំងនេះ ហើយខ្ញុំដឹងថាព្រះអម្ចាស់ស្រឡាញ់ពួកគេផងដែរ។ គ្មានជំណើររឿងណាមួយដែលល្អស្តីអំពីក្តីស្រឡាញ់ អាចត្រូវបានគេរកឃើញ ជាជាងបទពិសោធន៍របស់ព្រះយេស៊ូវ ប្រទានពរដល់កុមារ នៅក្នុងនីហ្វៃទី 3 នោះឡើយ។ ជំណើររឿងនេះរៀបរាប់អំពីព្រះយេស៊ូវព្យាបាលអ្នកឈឺ បង្រៀនប្រជាជន និងបានអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌សំរាប់ពួកគេ។ ហេតុដូច្នេះហើយ ខ្ញុំសូមដកស្រង់ព្រះបន្ទូលដ៏មានតម្លៃទាំងនេះថា ៖

“[ព្រះយេស៊ូវ] បានយកកូនកុមាររបស់គេម្តងម្នាក់ៗ ហើយប្រទានដល់ពួកវា ហើយបានអធិស្ឋានដល់ព្រះវរបិតាសំរាប់ពួកវា។

“ហើយកាលទ្រង់បានធ្វើការនេះចប់ហើយ នោះទ្រង់ក៏ព្រះកន្សែងទៀត

“ហើយទ្រង់មានបន្ទូលទៅហ្វូងមនុស្សថា ៖ មើលន៏ កូនតូចៗរបស់អ្នករាល់គ្នា។

“ហើយនៅពេលពួកគេក្រឡេកមើលទៅ នោះពួកគេបានសង្ឃឹងមើលទៅផ្ទៃមេឃ ហើយឃើញផ្ទៃមេឃបើកចំហ ហើយពួកគេឃើញពួកទេវតាហោះចុះមកពីស្ថានសួគ៌ ហាក់បីដូចជានៅក្នុងកណ្តាលភ្លើង . . . ហើយពួកទេវតាបានធ្វើការងារបំរើដល់ពួកគេ”។[11]

អ្នកអាចនឹងសួរថា *តើរឿងបែបនេះនៅតែកើតមានដល់សព្វថ្ងៃទៀតឬ?* ខ្ញុំចង់ចែកចាយជាមួយនឹងអ្នករាល់គ្នាទូវជំណើររឿងដ៏ប្រពៃមួយស្តីអំពីដូនដីតាមួយគូ ដែលបានបំរើបេសកកម្មជាយូរយារណាស់មកហើយ និងរបៀបដែលចៅប្រុសរបស់ពួកគាត់ត្រូវបានប្រទានពរឱ្យ។ ជីតាដែលជាអ្នកផ្សព្វផ្សាយសាសនាទូរបនោះ បានសរសេរថា ៖

“ឥឡូវនេះ ភរិយារបស់ខ្ញុំ ឱនណា និងរូបខ្ញុំកំពុងបំរើបេសកកម្មមួយនៅក្នុងទីក្រុង ចាកសុន រដ្ឋអូហៃអូ។ ការព្រួយបារម្ភដ៏ធំមួយរបស់យើង គឺជាគ្រួសាររបស់យើង នៅពេលយើងព្រមទទួលការហៅឱ្យបំរើបេសកកម្មនេះ។ យើងមិនអាចនៅទីនោះជាមួយនឹងពួកគេបានឡើយ នៅពេលពួកគេជួបប្រទះនឹងបញ្ហាផ្សេងនោះ។

“ពីមុនយើងបានទៅបំរើបេសកកម្មបន្តិច ចៅប្រុសរបស់យើង ឈ្មោះ អ័រ ជី ដែលទើបតែមានអាយុពីរឆ្នាំកន្លះ ត្រូវធ្វើការវះកាត់ភ្នែកស្រឡេងរបស់គាត់។ ម្តាយរបស់គាត់បានសុំឱ្យខ្ញុំទៅជាមួយនឹងពួកគេ ពីព្រោះ អ័រ ជី ហើយនិងខ្ញុំគឺជាមិត្តដ៏ល្អនឹងគ្នា។ ការវះកាត់ត្រូវបានដំណើរការទៅយ៉ាងល្អ ប៉ុន្តែ អ័រ ជី បានស្រែកយំនៅមុនពេល និងក្រោយពីការវះកាត់ ពីព្រោះគ្មានសមាជិកគ្រួសារណាម្នាក់អាចចូលទៅក្នុងបន្ទប់វះកាត់នោះបានឡើយ ហើយការណ៍នេះបានធ្វើឱ្យគាត់មានការភ័យខ្លាច។

“ប្រហែលជាត្រាំមួយខែក្រោយមក នៅពេលយើងកំពុងបំរើបេសកកម្ម អ័រ ជី ត្រូវទៅព្យាបាលភ្នែកម្ខាងទៀតរបស់គាត់។ ម្តាយរបស់គាត់បានទូរស័ព្ទមក ហើយបានសម្តែងចេញទូវសេចក្តីព្រាថ្នាទៅក្នុងការសុំឱ្យខ្ញុំទៅជាមួយនឹងពួកគេ សំរាប់ការវះកាត់លើទីពីរនេះ។ ជាការពិតណាស់ ដោយសារតែចម្ងាយផ្លូវ និងបេសកកម្មបានរារាំងរូបខ្ញុំ ចំពោះការមានវត្តមានជាមួយនឹងគាត់។ ឱនណា ហើយនិងខ្ញុំបានតមអាហារ ព្រមទាំងបានធ្វើការអធិស្ឋានដល់ព្រះអម្ចាស់ ដើម្បីឱ្យទ្រង់ជួយលួងលោមចិត្តដល់ចៅប្រុសរបស់យើង អំឡុងពេលនៃការវះកាត់របស់គាត់។

“មិនយូរប៉ុន្មានបន្ទាប់ពីការវះកាត់ត្រូវបានបញ្ចប់ យើងបានទូរស័ព្ទទៅកាន់ពួកគេ ហើយបានដឹងថា អ័រ ជីបានទឹកឃើញអំពីបទពិសោធន៍កាលពីលើកមុន នោះជាហេតុធ្វើគាត់មិនចង់ឃ្លាតចេញពីឪពុកម្តាយរបស់គាត់ឡើយ។ ប៉ុន្តែរំពេចដែលគាត់បានចូលទៅក្នុងបន្ទប់វះកាត់ នោះគាត់ស្បៃមុខស្ងាត់។ គាត់បានដោះវ៉ែនតាចេញ ហើយដេកនៅលើតុវះកាត់ ព្រមទាំងសុខចិត្តទទួលយកទូរការវះកាត់ដោយវិញ្ញាណដ៏រាបសា។ យើងមានអំណរគុណខ្លាំងណាស់ ដែលការអធិស្ឋានរបស់យើងត្រូវបានឆ្លើយតប។

“ពីរបីថ្ងៃក្រោយមកទៀត យើងបានទូរស័ព្ទទៅកាន់កូនស្រីរបស់យើង ហើយបានសាកសួរសុខទុក្ខរបស់ អ័រ ជី។ គាត់មានសុខភាពល្អដូចធម្មតា ហើយកូនស្រីរបស់យើងបានរៀបរាប់ច្រាប់យើងទូរឿងរ៉ាវដែលបានកើតមានឡើងថា ៖ នាពេលរស្យៅលបន្ទាប់ពីការវះកាត់នោះមក អ័រ ជី បានភ្ញាក់ឡើង ហើយច្រាប់ម្តាយរបស់គាត់ថា លោកតាបាននៅទីនោះអំឡុងពេលនៃការវះកាត់របស់គាត់។ គាត់បាននិយាយថា ‘លោកតាបាននៅទីនោះ ហើយបានធ្វើឱ្យអ្វីៗមានសភាពធម្មតា’ ។ អ្នករាល់គ្នាឃើញទេថា ព្រះអម្ចាស់បានធ្វើទូរការលេចចេញមកទៅកាន់កុមារាតូចម្នាក់នោះ ដើម្បីគាត់អាចបានឃើញលោកតារបស់ខ្លួន ដោយស្ថិតនៅក្រោមឥទ្ធិពលនៃថ្នាំស្ពឹក ប៉ុន្តែតាមពិតទៅ ជីដូនជីតារស់គាត់កំពុងស្ថិតនៅក្នុងបេសកកម្មមួយដែលមានចម្ងាយ 2,897 គីឡូម៉ែត្រពីគាត់ឯណោះ”។

ក្មួយប្រុស អ័រ ជី លោកតាប្រហែលជាមិនបានក្បែរក្មួយនៅពេលនោះឡើយ ប៉ុន្តែក្មួយបានស្ថិតនៅក្នុងការអធិស្ឋានរបស់គាត់ ហើយត្រូវបានប្រទានឱ្យដោយព្រះវរបិតានៃយើងទាំងអស់គ្នា។

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ សូមឱ្យសំណើចរបស់កុមារទាំងឡាយបានធ្វើឱ្យផ្លូវចិត្តរបស់យើងរីករាយ។ សូមឱ្យសេចក្តីជំនឿរបស់កុមារទាំងឡាយបានល្អឯណោមដល់ព្រលឹងយើង។ សូមឱ្យសេចក្តីស្រឡាញ់របស់កុមារទាំងឡាយ បានបំផុសគំនិតដល់ទង្ហើររបស់យើង។ "កូនចៅជាមរតកមកពីព្រះយេហូវ៉ា"។[12] សូមឱ្យព្រះវរបិតាសួគ៌របស់យើងប្រទានពរដល់ព្រលឹងដ៏ផ្អែមល្ហែម និងជាមិត្តដ៏ពិសេសរបស់លោកចៅហ្វាយទាំងនេះ។

ដកស្រង់ចេញមកពី *Ensign* ខែ មិថុនា ឆ្នាំ 2000 ទំព័រ 2–5។

កំណត់ចំណាំ

1. ម៉ាថាយ 18:1–6។
2. "Ode: Intimations of Immortality from Recollections of Early Childhood"។
3. *Gospel Ideals* (1954) ទំព័រ 436។
4. គោលលទ្ធិ និង សេចក្តីសញ្ញា 88:118។
5. *The Road to Confidence* (ឆ្នាំ 1959) ទំព័រ 121។
6. នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1944 ទំព័រ 32។
7. ដកស្រង់ចេញពី *The Children* និពន្ធដោយ Jack M. Lyon និងអ្នកនិពន្ធដទៃទៀត នៅក្នុង *Best-Loved Poems of the LDS People* (ឆ្នាំ 1996) ទំព័រ 21។
8. *A Christmas Carol and Cricket on the Hearth* (គ្មានការបកប្រែជាភាសាខ្មែរ) ទំព័រ 50–51។
9. Margaret Lee Runbeck, *Bits & Pieces* ថ្ងៃទី 20 ខែ កញ្ញា ឆ្នាំ 1990។
10. James L. Ison, *Mormons in the Major Leagues* (ឆ្នាំ 1991) ទំព័រ 21។
11. និហ្វៃទី 3 17:21–24។
12. ទំនុកដំកើង 127:3។

តួនាទីពិសិដ្ឋរបស់ឪពុក និងម្តាយ

ផ្នែកទី 1៖ តួនាទីរបស់ឪពុក

10

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលៈទេសៈរបស់អ្នកផ្តាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- សូមមើលឡើងវិញអំពីតួនាទីរបស់ឪពុក និងម្តាយដូចដែលបានបង្ហាញនៅក្នុងប្រយោគទីប្រាំពីរនៃ “ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក” (សូមមើលទំព័រ iv)។ សូមធ្វើការកំណត់អំពីរបៀបដែលសេចក្តីទូន្មាននេះអនុវត្តនៅក្នុងគេហដ្ឋានរបស់អ្នក និងអ្វីដែលអ្នកនឹងធ្វើតាមសេចក្តីណែនាំនេះប្រកបដោយការអធិស្ឋាន។
- សូមសរសេរសំបុត្រមួយទៅកាន់ឪពុក ឬក៏ទៅកាន់ជីតារបស់អ្នក។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

ជូនចំពោះពួកឪពុកទាំងឡាយនៃអ៊ីស្រាអែល

ប្រធាន អែសរ៉ា ថាហ្វ បិនសឺន
ប្រធានសាសនាចក្រទី 13

បងប្អូនប្រុសជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំមានអំណរគុណដោយមានវត្តមាននៅទីនេះជាមួយនឹងអ្នករាល់គ្នា នៅក្នុងការប្រមូលផ្តុំដ៏រុងរឿងនៃពួកអ្នកកាន់បព្វជិតភាពនៃព្រះ។ ខ្ញុំសូមអធិស្ឋានដើម្បីឱ្យព្រះវិញ្ញាណ នៃព្រះអម្ចាស់នឹងគង់នៅទីនេះជាមួយខ្ញុំ និងជាមួយអ្នករាល់គ្នាផងដែរ នៅពេលខ្ញុំថ្លែងសុន្ទរកថាទៅកាន់អ្នករាល់គ្នាស្តីអំពីប្រធានបទមួយដ៏សំខាន់បំផុត។ នារាត្រីនេះ ខ្ញុំសូមនិយាយទៅកាន់ពួកឪពុកទាំងឡាយដែលបានប្រមូលផ្តុំគ្នានៅទីនេះ និងនៅទូទាំងសាសនាចក្រអំពីការហៅដ៏ពិសិដ្ឋរបស់ពួកគេ។

ខ្ញុំសង្ឃឹមថាអ្នករាល់គ្នា ដែលជាយុវជននឹងខិតខំត្រងត្រាប់ស្តាប់ផងដែរ ខណៈដែលអ្នកកំពុងរៀបចំខ្លួនធ្វើជាឪពុកនៃសាសនាចក្រនេះនាពេលអនាគត។

ការហៅដ៏នៅអស់កល្បជានិច្ច

លោកឪពុកទាំងឡាយអើយ តួនាទីរបស់អ្នករាល់គ្នា គឺជាការហៅដ៏នៅអស់កល្បជានិច្ច វាគឺជាការហៅដែលអ្នកនឹងមិនទទួលបានការដោះលែងនោះឡើយ។ ការហៅទាំងឡាយនៅក្នុងសាសនាចក្រ គឺមានសារៈសំខាន់ខ្លាំងណាស់ រឹងធាតុពិតរបស់វាទិញគឺជាការហៅសំរាប់តែរយៈពេលមួយប៉ុណ្ណោះ ហើយក្រោយមកក៏មានការដោះលែងដ៏សមរម្យមួយនឹងត្រូវបានធ្វើឡើង។ ប៉ុន្តែការហៅក្នុងនាមឪពុកម្នាក់ គឺនៅអស់កល្បជានិច្ច ហើយសារៈសំខាន់របស់វាគឺហួសពីពេលវេលានៃជីវិតនេះទៅទៀត។ វាគឺជាការហៅមួយសំរាប់ពេលនេះ និងពេលដ៏អស់កល្បជានិច្ច។

ប្រធាន ហារ៉ូល ប៊ី លី បានធ្វើសេចក្តីថ្លែងការណ៍ដ៏ជាក់លាក់មួយថា “កិច្ចការដ៏សំខាន់បំផុតរបស់ព្រះអម្ចាស់ ដែលអ្នករាល់គ្នា [ជាឪពុក] ហើយនឹងរូបខ្ញុំមិនឆ្ងាយធ្វើពីមុនមក នឹងក្លាយទៅជាការងារដែលយើងនឹងធ្វើនៅក្នុងគេហដ្ឋានរបស់យើងផ្តាល់។ ការបង្រៀនតាមផ្ទះ កិច្ចការរបស់គណៈប៊ីស្សព និងកិច្ចការសាសនាចក្រផ្សេងទៀត គឺមានសារៈសំខាន់ទាំងអស់ ប៉ុន្តែកិច្ចការដ៏សំខាន់បំផុតនោះគឺជាកិច្ចការនៅក្នុងគេហដ្ឋានរបស់អ្នក” (*Strengthening the Home* [ភូនស្បៃវគៅ ឆ្នាំ 1973] ទំព័រ 7)។

ដូច្នេះតើការទទួលខុសត្រូវដ៏ជាក់លាក់មួយរបស់ឪពុកនៅក្នុងជញ្ជាំងដ៏ពិសិដ្ឋនៃគេហដ្ឋានរបស់គាត់គឺជាអ្វី? ខ្ញុំសូមណែនាំអំពីការទទួលខុសត្រូវចំនួនពីរ ដែលវាទាក់ទងនឹងឪពុកនៃអ៊ីស្រាអែលគ្រប់រូប។

ផ្តល់សេចក្តីត្រូវការផ្នែកសម្ភារ

ទីមួយ អ្នករាល់គ្នាមានការទទួលខុសត្រូវដ៏ពិសិដ្ឋមួយ នៅក្នុងការផ្តល់សេចក្តីត្រូវការផ្នែកសម្ភារៈដល់គ្រួសាររបស់អ្នក។

ព្រះអម្ចាស់បានបញ្ជាក់យ៉ាងច្បាស់លាស់ចំពោះតួនាទីស្តីអំពីការផ្តល់ និងការចិញ្ចឹមបីបាច់កូនចៅដ៏សុចរិត។ ចាប់តាំងពីដើមដំបូងមក លោកអ័ដាមត្រូវបានណែនាំឱ្យខិតខំធ្វើការចិញ្ចឹមជីវិតដោយសារការបែកញើស ប៉ុន្តែ មិនមែនជានាងអេវ៉ាទេ។

សាវកប៉ុលបានណែនាំដល់ស្វាមី និងឪពុកទាំងឡាយថា “បើមានអ្នកណាដែលមិនផ្គត់ផ្គង់សណ្តានខ្លួន គឺឱ្យពួកអ្នកផ្ទះខ្លួនជាដើម អ្នកនោះឈ្មោះថាបានបោះបង់ចោលសេចក្តីជំនឿហើយ ក៏អាក្រក់ជាងមនុស្សដែលមិនបានជឿទៅទៀត” (ធីម៉ូថេទី 1 5:8)។

នៅដើមប្រវត្តិសាស្ត្រនៃសាសនាចក្រដែលបានស្តារឡើងវិញនេះ ព្រះអម្ចាស់បានផ្តល់ការទទួលខុសត្រូវយ៉ាងច្បាស់លាស់ ដល់បុរសទាំងឡាយ ជាមួយនឹងកាតព្វកិច្ចដើម្បីផ្គត់ផ្គង់ដល់ភរិយា និងគ្រួសាររបស់ខ្លួន។ នៅខែ មករា ឆ្នាំ 1832 ទ្រង់បានមានព្រះបន្ទូលថា “យើងត្រាប់អ្នកជាព្រាកដ៏ថា រីឯមនុស្សគ្រប់រូបណាដែលត្រូវផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្លួន នោះចូរឱ្យអ្នកនោះផ្គត់ផ្គង់ចុះ ហើយអ្នកនោះនឹងពុំត្រូវបាត់បង់មកុដរបស់ខ្លួនឡើយ” (គ. និង ស. 75:28)។ បីខែក្រោយមក ព្រះអម្ចាស់បានមានព្រះបន្ទូលម្តងទៀតថា “ពួកស្ត្រីមានសិទ្ធិពឹងពាក់ទៅលើស្វាមីរបស់ខ្លួន សំរាប់ការចិញ្ចឹមជីវិតរហូតដល់ស្វាមីរបស់ខ្លួនត្រូវបានយកទៅ” (គ. និង ស. 83:2)។ នេះគឺជាសិទ្ធិដ៏ទេវភាពរបស់ភរិយា និងម្តាយមួយរូប។ ខណៈដែលនាងមើលថែ និងចិញ្ចឹមបីបាច់កូនចៅរបស់ខ្លួននៅក្នុងគេហដ្ឋាន នោះស្វាមីរបស់នាងជាអ្នករកត្រាក់ចំណូលសំរាប់ផ្គត់ផ្គង់ការរស់នៅក្នុងគ្រួសារ ដើម្បីធ្វើឱ្យការចិញ្ចឹមបីបាច់នេះអាចប្រព្រឹត្តទៅបាន។

នៅក្នុងគេហដ្ឋានមួយដែលមាន ស្វាមីមានកាយសម្បទារឹងមាំ គឺត្រូវបានគេរំពឹងទុកឱ្យធ្វើជាអ្នកផ្គត់ផ្គង់ដល់គ្រួសារ។ នៅពេលខ្លះ យើងបានឮអំពីពួកស្វាមីដែលបានបាត់បង់ការងាររបស់ខ្លួន ដោយសារតែស្ថានភាពផ្នែកសេដ្ឋកិច្ច បានរំពឹងឱ្យភរិយាចេញទៅធ្វើការក្រៅផ្ទះ សូម្បីតែស្វាមីរូបនោះនៅមានសមត្ថភាពគ្រប់គ្រាន់ នៅក្នុងការផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្លួនក៏ដោយ។ នៅក្នុងករណីទាំងនេះ យើងសូមលើកទឹកចិត្តដល់ស្វាមីទាំងឡាយ ឱ្យធ្វើអ្វីៗគ្រប់យ៉ាងនៅក្នុងអំណាចរបស់ខ្លួន ដើម្បីបង្កភាពងាយស្រួលដល់ភរិយារបស់ខ្លួនអាចមើលថែកូនចៅនៅក្នុងគេហដ្ឋាន ខណៈដែលស្វាមីបន្តផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្លួនដោយអស់ពីសមត្ថភាពរបស់គាត់នោះ ទោះបីជាការងារដែលគាត់ធ្វើមានលក្ខណៈមិនធំដុំ ហើយការចាត់ចែងថវិកាក្នុងគ្រួសារមានលក្ខណៈតិចតួចក៏ដោយ។

ជាងនេះទៅទៀត សេចក្តីត្រូវការផ្នែករមប់រំ ឬផ្នែកសម្ភារៈពុំមែនជាហេតុផលដ៏សមរម្យមួយ ដើម្បីឱ្យភរិយាចេញទៅធ្វើការក្នុងនាមជាអ្នកផ្គត់ផ្គង់ដល់គ្រួសារដោយពន្យាពេលមានកូនចៅនោះឡើយ។

ពាក្យទូន្មានរបស់ប្រធានឃឹមបឹល

ខ្ញុំចងចាំអំពីពាក្យទូន្មានរបស់ព្យាការីជាទីស្រឡាញ់របស់យើងគឺ លោក ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល ខណៈដែលលោកមានប្រសាសន៍ទៅកាន់និស្សិតដែលបានរៀបអាពាហ៍ពិពាហ៍ទាំងឡាយ។ លោកបានមានប្រសាសន៍ថា ៖ “ខ្ញុំបានប្រាប់ពួកយុវវ័យចំនួនមួយម៉ឺនទាក់ថា នៅពេលពួកគេរៀបអាពាហ៍ពិពាហ៍ នោះពួកគេមិនគួររង់ចាំរហូតដល់ពួកគេបញ្ចប់ការសិក្សា និងមានប្រាក់សមតាមបំណងទើបមានកូននោះទេ . . .។ ពួកគេគប្បីរស់នៅជាមួយគ្នា ហើយអនុញ្ញាតឱ្យមានកូនចៅជាធម្មតា . . .។

ប្រធាន ឃឹមបឹល បានបន្តទៀតថា “តាមខ្ញុំដឹងគឺគ្មានខគម្ពីរណាមួយ ដែលអនុញ្ញាតឱ្យភរិយាវ័យក្មេងទុកចោលក្រុមគ្រួសាររបស់ខ្លួន ហើយចេញទៅធ្វើការដើម្បីជួយស្វាមីរបស់ខ្លួនឱ្យបញ្ចប់ការសិក្សានោះឡើយ។ មានស្វាមីរាប់ពាន់ទាក់ដែលបានធ្វើការនេះដោយខ្លួនឯង ហើយបានចិញ្ចឹមបីបាច់គ្រួសារនៅពេលតែមួយខណៈដែលពួកគេកំពុងទៅរៀន” (“Marriage Is Honorable” នៅក្នុង *Speeches of the Year, 1973* [ឆ្នាំ 1974] ទំព័រ 263)។

តួនាទីរបស់ម្តាយនៅក្នុងគេហដ្ឋាន

បងប្អូនប្រុសនៃបព្វជិតភាព ខ្ញុំសូមបន្តធ្វើការគូសបញ្ជាក់ចំពោះសារៈសំខាន់អំពីម្តាយដែលស្នាក់នៅឯគេហដ្ឋាន ដើម្បីចិញ្ចឹមបីបាច់ មើលថែ និងបង្រៀនកូនចៅរបស់ខ្លួននៅក្នុងគោលការណ៍ទាំងឡាយនៃសេចក្តីសុចរិត។

ខ្ញុំបានទទួលអារម្មណ៍ថា ចំនួនដ៏ធំនៃម្តាយជាពួកបរិសុទ្ធថ្ងៃចុងក្រោយចង់ធ្វើតាមពាក្យទូន្មាននេះដោយស្មោះស្ម័ត្រ ខណៈដែលខ្ញុំបានធ្វើដំណើរទៅជុំវិញសាសនាចក្រ។ ប៉ុន្តែយើងដឹងថា ពេលខ្លះម្តាយជាច្រើនត្រូវចេញទៅធ្វើការនៅក្រៅផ្ទះ ដោយមានការលើកទឹកចិត្ត ឬការពោលពាក្យអះអាងពីសំណាក់ស្វាមីរបស់ខ្លួន។ ស្វាមីរូបនេះគឺជាស្វាមីដែលចង់បាននូវសម្ភារៈថ្លៃៗ ដែលចាំបាច់ត្រូវមានប្រាក់ចំណូលបន្ថែមទៀតទើបអាចទិញបាន។ បងប្អូនប្រុស នៅក្នុងករណីបែបនេះ គ្រួសារពុំមែនជាផ្នែកតែមួយដែលនឹងទទួលរងទុក្ខប៉ុណ្ណោះទេ ប៉ុន្តែការរីកចំរើនខាងវិញ្ញាណរបស់អ្នករាល់គ្នាផ្តាល់នឹងត្រូវចុះទន់ខ្សោយផងដែរ។ ខ្ញុំសូមនិយាយទៅកាន់អ្នករាល់គ្នាថា ព្រះអម្ចាស់បានប្រទានឱ្យបុរសគ្រប់រូបនូវការទទួលខុសត្រូវ ដើម្បីផ្គត់ផ្គង់ដល់ក្រុមគ្រួសាររបស់ខ្លួន នៅក្នុងរបៀបមួយដែលអនុញ្ញាតឱ្យភរិយាបំពេញតួនាទីរបស់នាងជាម្តាយនៅក្នុងគេហដ្ឋាន។

ការរៀបចំទុកដាក់ក្នុងក្រុមគ្រួសារមានសារៈសំខាន់ណាស់នាបច្ចុប្បន្ននេះ

ឪពុកទាំងឡាយ កត្តាដ៏សំខាន់មួយផ្សេងទៀតនៅក្នុងការផ្គត់ផ្គង់ចំពោះតំរូវការផ្នែកសម្ភារៈដល់គ្រួសាររបស់អ្នក នោះគឺជាស្បៀងអាហារដែលអ្នកត្រូវតែមានសំរាប់គ្រួសាររបស់អ្នក នៅក្នុងករណីដែលមានគ្រោះអាសន្នណាមួយ។ ការរៀបចំទុកដាក់ក្នុងក្រុមគ្រួសារ គឺជាគោលការណ៍ផ្នែកសុខុមាលភាពសំរាប់រយៈពេលវែង។ វាកាន់តែមានសារៈសំខាន់នាបច្ចុប្បន្ននេះ។

ខ្ញុំសូមសួរអ្នករាល់គ្នាដោយស្មោះថា តើអ្នករាល់គ្នាមានស្បៀងផ្គត់ផ្គង់ដល់គ្រួសាររបស់អ្នក មានដូចជាម្ហូបអាហារ សំលៀកបំពាក់ និងប្រេងសាំង ប្រសិនបើអ្នកទុកបានសំរាប់រយៈពេលមួយឆ្នាំដែរឬទេ? វិវរណៈនៅក្នុងការបង្កើត និងការស្តុកទុកម្ហូបអាហារអាចមានសារៈសំខាន់ចំពោះសុខុមាលភាពផ្នែករូបកាយរបស់យើងនាបច្ចុប្បន្ននេះ គឺវាដូចគ្នាទៅនឹងការប្រមូលផ្តុំប្រជាជនចូលទៅក្នុងទូកធំនៅក្នុងសម័យកាលណូអាដូច្នោះដែរ។

ជាងនេះទៅទៀត តើអ្នករាល់គ្នាកំពុងរស់នៅស្របទៅតាមប្រាក់ចំណូលរបស់អ្នក ហើយមានការសន្សំទុកបន្តិចបន្តួចដែរឬទេ?

តើអ្នករាល់គ្នាមានភាពស្មោះត្រង់ចំពោះព្រះអម្ចាស់នៅក្នុងការបង់ដង្វាយមួយភាគក្នុងដប់របស់អ្នកដែរឬទេ? ការរស់នៅស្របតាមច្បាប់ដ៏ទេវភាពនេះនឹងនាំមកនូវពរជ័យទាំងខាងផ្នែកវិញ្ញាណ និងផ្នែកសម្ភារៈ។

ប្រាកដណាស់ បងប្អូនប្រុសទាំងឡាយ ក្នុងនាមជាឪពុកនៃអ៊ីស្រាអែល អ្នករាល់គ្នាមានការទទួលខុសត្រូវដ៏ធំមួយ នៅក្នុងការផ្គត់ផ្គង់ដល់គ្រួសាររបស់អ្នកចំពោះសេចក្តីត្រូវការផ្នែកសម្ភារៈ និងដើម្បីមានស្បៀងអាហារចាំបាច់សំរាប់ករណីគ្រោះអាសន្នណាមួយ។

រៀបចំការដឹកនាំខាងវិញ្ញាណ

ទីពីរ អ្នករាល់គ្នាមានការទទួលខុសត្រូវដ៏ពិសិដ្ឋមួយ ដើម្បីការផ្តល់ការដឹកនាំខាងវិញ្ញាណនៅក្នុងគ្រួសាររបស់អ្នក។

នៅក្នុងកូនស្បៃវែងមួយដែលបានបោះពុម្ព ដោយក្រុមប្រឹក្សានៃពួក 12 នាក់កាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ យើងសូមលើកឡើងដូចខាងក្រោមនេះថា ៖ “ភាពជាឪពុកគឺជាអ្នកដឹកនាំ ហើយវាគឺជាការដឹកនាំមួយប្រភេទដែលមានសារៈសំខាន់បំផុត។ ភាពជាឪពុកកើតមានតាំងតែពីដំបូងមកម្ល៉េះ ហើយវានឹងនៅតែដូច្នេះដដែល។ ឪពុក ដោយមានជំនួយ និងដោយទទួលបានពាក្យប្រឹក្សា ព្រមទាំងការលើកទឹកចិត្តពីសំណាក់ដៃគូដ៏នៅអស់កល្បជានិច្ចរបស់ខ្លួន នោះអ្នករាល់គ្នាទីងដើរតួជាអ្នកដឹកនាំនៅក្នុងគេហដ្ឋាន” (*Father, Consider Your Ways* [កូនស្បៃវែង ឆ្នាំ 1973] ទំព័រ 4–5)។

ទោះយ៉ាងណាក្តី ព្រមគ្នាជាមួយនឹងតួនាទីជាអ្នកដឹកនាំក៏មាននូវភាគពូកិច្ចដ៏សំខាន់ផងដែរ។ ពេលខ្លះយើងឮដំណើររឿងស្តីអំពីបុរសជាច្រើន រួមមានទាំងបុរសនៅក្នុងសាសនាចក្រផង គឺជាអ្នកដែលបានគិតថា ការធ្វើជាមេគ្រួសារបានផ្តល់ឱ្យពួកគេនូវតួនាទីដ៏ធំមួយ ហើយបានធ្វើឱ្យពួកគេមានអំណាចក្នុងការនិយាយស្តី និងបង្កើតតំរូវការទៅលើក្រុមគ្រួសាររបស់ខ្លួន។

សាវកប៉ុលបានចង្អុលបង្ហាញថា “ត្បិតប្តីជាក្បាលនៃប្រពន្ធ *ដូចជា* ព្រះគ្រីស្ទទ្រង់ជាសិរសានៃពួកជំនុំដែរ” (អេភេសូរ 5:23 អក្សរទ្រេតត្រូវបានបន្ថែម)។ ការណ៍

នោះគឺជាគំរូដែលយើងត្រូវធ្វើតាមនៅក្នុងតួនាទីរបស់យើងជាអ្នកដឹកនាំនៅក្នុងគេហដ្ឋាន។ យើងពុំធ្លាប់ឃើញព្រះអង្គសង្គ្រោះដឹកនាំសាសនាចក្រនេះ ដោយព្រហស្តដែលមានភាពត្រេតត្រាត ឬក៏គ្មានមេត្តាករុណានោះដែរ។ យើងពុំធ្លាប់ឃើញព្រះអង្គសង្គ្រោះប្រព្រឹត្តចំពោះសាសនាចក្រនេះ ដោយការមិនគោរព ឬការរើងរូសនោះឡើយ។ យើងពុំធ្លាប់ឃើញព្រះអង្គសង្គ្រោះប្រើកម្លាំង ឬប្រើការបង្ខិតបង្ខំដើម្បីឱ្យសមស្របទៅនឹងព្រះទ័យរបស់ទ្រង់នោះឡើយ។ គ្មានទីកន្លែងណាមួយដែលយើងរកឃើញព្រះអង្គសង្គ្រោះបានប្រព្រឹត្តអំពើទាំងអស់នេះឡើយ ប៉ុន្តែផ្ទុយទៅវិញទ្រង់បានធ្វើទ្រង្វើដែលមានការអប់រំ ការលើកទឹកចិត្ត ការលួងលោម និងការលើកតំកើងចំពោះសាសនាចក្រ។ បងប្អូនប្រុស ខ្ញុំសូមនិយាយទៅកាន់អ្នករាល់គ្នាជាមួយនឹងភាពម៉ឺងម៉ាត់ថា ទ្រង់គឺជាគំរូដែលយើងត្រូវតែធ្វើតាម នៅពេលយើងធ្វើការដឹកនាំខាងវិញ្ញាណនៅក្នុងក្រុមគ្រួសាររបស់យើង។

អ្វីដែលសំខាន់ជាងគេបំផុតគឺថា កិច្ចការនេះកើតមានឡើងយ៉ាងពិតប្រាកដនៅក្នុងទំនាក់ទំនងរវាងអ្នករាល់គ្នា និងភរិយារបស់អ្នក។

ស្រឡាញ់ភរិយារបស់អ្នក

នេះគឺជាពាក្យទូន្មានមួយទៀតមកពីសាវកប៉ុល គឺជាពាក្យទូន្មានដ៏មានអត្ថន័យបំផុត ហើយចំនឹងចំណុចនេះ។ គាត់បាននិយាយដោយសាមញ្ញថា “បុរសរាល់គ្នាអើយ ចូរស្រឡាញ់ប្រពន្ធខ្លួនដូចជាព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ” (អេភេសូរ 5:25)។

នៅក្នុងវិវរណៈថ្ងៃចុងក្រោយព្រះអម្ចាស់បានមានព្រះបន្ទូលជាថ្មីម្តងទៀតស្តីអំពីកាតព្វកិច្ចនេះ។ ទ្រង់មានបន្ទូលថា “ត្រូវស្រឡាញ់ប្រពន្ធខ្លួនឱ្យរស់ពិចិត្ត ហើយត្រូវនៅជាប់នឹងនាង ហើយគ្មានន្ទរណាទៀតឡើយ” (គ. និង ស. 42:22)។ ចំពោះចំណេះដឹងរបស់ខ្ញុំមានតែរឿងមួយផ្សេងទៀតប៉ុណ្ណោះនៅក្នុងខគម្ពីរទាំងអស់ ដែលយើងត្រូវបានដាក់បញ្ញត្តិឱ្យស្រឡាញ់ឱ្យរស់ពីដួងចិត្តរបស់ នោះគឺជាការស្រឡាញ់ដល់ព្រះ។ សូមពិចារណាអំពីអត្ថន័យនេះ!

សេចក្តីស្រឡាញ់ប្រភេទនេះ គួរតែត្រូវបានបង្ហាញចំពោះភរិយារបស់អ្នករាល់គ្នាតាមរបៀបជាច្រើនយ៉ាង។ ចំណុចទីមួយ ហើយដែលជាចំណុចសំខាន់ជាងគេបំផុត គឺថានៅក្នុងជីវិតរបស់អ្នករាល់គ្នា គ្មានអ្វីមួយដែលមានសារៈសំខាន់ជាងភរិយារបស់អ្នកនោះឡើយ លើកលែងតែព្រះមួយអង្គមួយអង្គប៉ុណ្ណោះ—វាពុំមែនជាការងារ ហើយវាក៏ពុំមែនជាសកម្មភាពកំសាន្ត និងពុំមែនជាការសំរាកលំហែកាយនោះដែរ។ ភរិយារបស់អ្នករាល់គ្នា គឺជាមួកការពារដ៏មានតម្លៃ និងដ៏នៅអស់កល្បជានិច្ចរបស់អ្នក—ពួកគេគឺជាដៃគូរបស់អ្នករាល់គ្នា។

តើពាក្យថាស្រឡាញ់មនុស្សម្នាក់ឱ្យរស់ពីចិត្តមានអត្ថន័យយ៉ាងដូចម្តេច? ពាក្យនេះមានន័យថា ជាសេចក្តីស្រឡាញ់ឱ្យរស់ពីវិញ្ញាណ និងឱ្យរស់ពីការលះបង់របស់អ្នក។ ពិតប្រាកដណាស់ នៅពេលអ្នករាល់គ្នាស្រឡាញ់ភរិយារបស់អ្នកឱ្យរស់ពីចិត្តរបស់អ្នក នោះអ្នករាល់គ្នាមិនអាចមើលស្រាលចំពោះនាង រិះគន់នាង ស្វែងរកកំហុសចោទក្រាន់នាង ឬរំលោភបំពានទៅលើនាងតាមរយៈពាក្យសម្តី និងតាមរយៈអាកប្បកិរិយា ឬទង្វើរនៃការខឹងសម្បារណាមួយនោះឡើយ។

តើពាក្យថា “នៅជាប់នឹងនាង”មានអត្ថន័យយ៉ាងដូចម្តេច? ពាក្យនេះមានន័យថា អ្នកត្រូវរស់នៅក្បែរនាង ត្រូវមានភាពសក្តិសម និងសេចក្តីស្មោះត្រង់ចំពោះនាង ហើយអ្នកត្រូវមានការសន្ទនាជាមួយនាង និងត្រូវសម្តែងចេញនូវសេចក្តីស្រឡាញ់របស់អ្នកចំពោះនាង។

សេចក្តីស្រឡាញ់មានន័យថា ការចេះសម្របខ្លួនទៅនឹងអារម្មណ៍ និងសេចក្តីត្រូវការរបស់នាង។ នាងចង់បាននូវការយល់ចិត្ត និងការឱ្យតម្លៃ។ នាងចង់ស្តាប់ឮពាក្យថា អ្នករាល់គ្នាមើលមកនាង ជាមនុស្សម្នាក់ដែលគួរឱ្យស្រឡាញ់ មានភាពទាក់ទាញ និងមានសារៈសំខាន់ចំពោះអ្នក។ សេចក្តីស្រឡាញ់មានន័យថា ការដាក់ផ្នែកសុខុមាលភាព និងការគោរពរបស់នាងឱ្យស្ថិតនៅក្នុងកំរិតដ៏ខ្ពស់បំផុតមួយក្នុងជីវិតរបស់អ្នក។

អ្នករាល់គ្នាគួរតែមានអំណរគុណដែលនាងបានធ្វើជាម្តាយរបស់កូនចៅអ្នក និងធ្វើជាម្ចាស់ក្សត្រីនៅក្នុងគេហដ្ឋានរបស់អ្នក អ្នករាល់គ្នាគួរមានអំណរគុណដែលនាងត្រូវបានជ្រើសរើសឱ្យធ្វើកិច្ចការផ្ទះ និងធ្វើជាម្តាយ—ដូចជានាងត្រូវការពោះ ត្រូវចិញ្ចឹមបីបាច់ ស្រឡាញ់ និងបង្ហាត់បង្រៀនដល់កូនចៅរបស់អ្នក—ដែលនេះគឺជាការហោដ៏ថ្លៃថ្នូរជាងគេបំផុត។

ស្វាមីទាំងឡាយ សូមទទួលស្គាល់ចំពោះភាពវៃឆ្លាតរបស់ភរិយាអ្នក និងសមត្ថភាពរបស់នាងនៅក្នុងការប្រឹក្សាជាមួយនឹងអ្នករាល់គ្នា ក្នុងនាមជាដៃគូដ៏ពិតប្រាកដមួយស្តីអំពីផែនការសំរាប់គ្រួសារ សកម្មភាពជាគ្រួសារ និងការរៀបចំថវិកាសំរាប់គ្រួសារ។ សូមកុំមានភាពតានតឹងជាមួយនឹងពេលវេលា ឬធនធានរបស់អ្នកឡើយ។

សូមផ្តល់ឱកាសដល់នាងដើម្បីទទួលការរីកចំរើនខាងផ្នែកចំណេះដឹង ខាងអារម្មណ៍ ខាងសង្គម ក៏ដូចជាផ្នែកខាងវិញ្ញាណផងដែរ។

បងប្អូនប្រុស ចូរចងចាំថា សេចក្តីស្រឡាញ់អាចត្រូវបានបណ្តុះ និងចិញ្ចឹមបីបាច់តាមរយៈកត្តាតូចៗជាច្រើន។ ផ្កាយទាំងឡាយមានភាពស្រស់ស្អាតនៅក្នុងឱកាសដ៏ពិសេសជាច្រើន ប៉ុន្តែហេតុការណ៍នេះអាចកើតឡើងបាន អាស្រ័យទៅលើឆន្ទៈចង់ជួយលាងចាន ការផ្លាស់កន្ទុប ការក្រោកពីដំណេកនៅពេលកូនយំនៅពេលយប់ និងការទុកទូរទស្សន៍ និងសារព័ត៌មានមួយអន្លើ ដើម្បីជួយនៅក្នុងការចំអិនអាហារពេលល្ងាចរបស់អ្នករាល់គ្នា។ យើងអាចនិយាយពាក្យថា “បងស្រឡាញ់អូន” ចេញពីទង្វើររបស់យើងដោយស្បៀមស្ងាត់។ ការណ៍ទាំងនេះទាំមកនូវប្រយោជន៍ដ៏ធំធេងបន្ថែមទៀត សំរាប់កិច្ចខិតខំដ៏តូចតាចបែបនេះ។

ការដឹកនាំបព្វជិតភាពដែលមានសេចក្តីស្រឡាញ់បែបនេះ អាចយកទៅអនុវត្តចំពោះកូនចៅ ក៏ដូចជាចំពោះភរិយារបស់អ្នករាល់គ្នាផងដែរ។

តួនាទីរបស់ឪពុកនៅក្នុងគេហដ្ឋាន

ម្តាយទាំងឡាយដើរតួនាទីដ៏សំខាន់មួយ ប្រៀបបាននៅនឹងបេះដូងនៃគេហដ្ឋាន ប៉ុន្តែតួនាទីនេះពុំមែនជារបៀបដែលកាត់បន្ថយតួនាទីដ៏សំខាន់ដូចគ្នានេះ ដែលឪពុកត្រូវធ្វើក្នុងនាមជាមេគ្រួសារ ដូចជាការចិញ្ចឹមបីបាច់ ការបង្ហាត់បង្រៀន និងការផ្តល់សេចក្តីស្រឡាញ់ដល់កូនចៅរបស់ខ្លួននោះឡើយ។

នៅក្នុងនាមជាលោកអយ្យកោនៅក្នុងគេហដ្ឋានរបស់អ្នក អ្នករាល់គ្នាមានការទទួលខុសត្រូវដ៏ធំមួយ ដើម្បីគិតអំពីការដឹកនាំនៅក្នុងការមានទំនាក់ទំនងល្អជាមួយនឹងកូនចៅរបស់អ្នក។ អ្នករាល់គ្នាត្រូវជួយបង្កើតគេហដ្ឋានមួយដែលព្រះវិញ្ញាណនៃព្រះអម្ចាស់អាចគង់នៅបាន។ តួនាទីរបស់អ្នករាល់គ្នាគឺដើម្បីផ្តល់ការដឹកនាំចំពោះសមាជិកគ្រួសារទាំងអស់។ អ្នករាល់គ្នាគប្បីរៀបចំបង្កើតច្បាប់ និងវិន័យសំរាប់គ្រួសារ។

គេហដ្ឋានរបស់អ្នករាល់គ្នាគួរជាស្ថានសួគ៌នៃសេចក្តីសុខសាន្ត និងសេចក្តីអំណរសំរាប់គ្រួសាររបស់អ្នក។ ពិតប្រាកដណាស់ មិនគួរមានកូនណាម្នាក់ភ័យខ្លាចចំពោះ

ឱពុករបស់ខ្លួននោះទេ—ជាពិសេសចំពោះឱពុកដែលកាន់បព្វជិតភាព។ កាតព្វកិច្ច មួយរបស់ឱពុកគឺត្រូវធ្វើឱ្យគេហដ្ឋានរបស់ខ្លួនក្លាយទៅជាទីកន្លែងមួយ ដែលមានសុភមង្គល និងមានសេចក្តីអំណរ។ គាត់មិនអាចធ្វើកិច្ចការនេះបានឡើយ ខណៈដែលទីកន្លែងនោះមានទូវអាកប្បកិរយានៃការឈ្លោះទាស់ទែងគ្នា ឬភាពមិនសុចរិតនោះ។ លទ្ធផលដ៏ធំធេងរបស់ឱពុកដ៏សុចរិតទាំងឡាយនៅក្នុងការធ្វើជាគំរូ ដូចជាការធ្វើឱ្យមានវិន័យ និងការបង្ហាត់បង្រៀន ការចិញ្ចឹមបីបាច់ និងការផ្តល់ទូវសេចក្តីស្រឡាញ់ គឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះសុខុមាលភាពខាងវិញ្ញាណរបស់កូនចៅខ្លួន។

ផ្តល់ការដឹកនាំខាងវិញ្ញាណ

ដោយសេចក្តីស្រឡាញ់នៅក្នុងដួងចិត្តរបស់ខ្ញុំចំពោះឱពុកទាំងឡាយក្នុងអឺស្រាអែល សូមឱ្យខ្ញុំណែនាំទូវវិធីដ៏ជាក់លាក់ ចំនួនដប់យ៉ាងដែលឱពុកទាំងឡាយអាចផ្តល់ទូវការដឹកនាំខាងវិញ្ញាណចំពោះកូនៗរបស់ខ្លួន ៖

1. សូមផ្តល់ទូវការប្រសិទ្ធពររបស់ឱពុកទៅដល់កូនៗរបស់អ្នក។ ធ្វើពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ដល់កូនៗរបស់អ្នក។ តែងតាំងបព្វជិតភាពដល់កូនប្រុសៗរបស់អ្នក។ ការណ៍ទាំងនេះនឹងក្លាយជាផ្នែកដ៏សំខាន់ខាងវិញ្ញាណនៅក្នុងជីវិតកូនចៅរបស់អ្នក។

2. សូមដឹកនាំដោយផ្ទាល់ខ្លួនការអធិស្ឋានជាគ្រួសារ ការអានព្រះគម្ពីរប្រចាំថ្ងៃ និងរាត្រីជួបជុំក្រុមគ្រួសារប្រចាំសប្តាហ៍។ ការចូលរួមដោយផ្ទាល់របស់អ្នកនឹងបង្ហាញដល់កូនៗរបស់អ្នកថាសកម្មភាពទាំងនេះមានសារៈសំខាន់យ៉ាងណា។

3. នៅពេលដែលអាចធ្វើបាន សូមចូលរួមក្នុងការប្រជុំសាសនាចក្ររួមគ្នាជាគ្រួសារ។ ការថ្វាយបង្គំជាគ្រួសារ ដោយស្ថិតនៅក្រោមការដឹកនាំរបស់អ្នក គឺសំខាន់បំផុតចំពោះសុខុមាលភាពខាងវិញ្ញាណរបស់កូនៗអ្នក។

4. សូមទៅដើរលេងជាលក្ខណៈ ឱពុក និងកូនស្រី ព្រមទាំងមានការចេញដើរលេងជាលក្ខណៈឱពុក និងកូនប្រុស ជាមួយនឹងកូនៗរបស់អ្នក។ សូមទៅបោះជំរំ និងធ្វើពិចនិច ចូលរួមការប្រកួតកីឡា និងការសម្តែងសិល្បៈ ចូលរួមកម្មវិធីសាលាជាលក្ខណៈគ្រួសារ ។ល។ ការមានឱពុកនៅទីនោះនឹងធ្វើឱ្យអ្វីៗទាំងអស់មានការផ្លាស់ប្តូរ។

5. បង្កើតជាទំនៀមទំលាប់ធ្វើវិស្សមកាល និងការដើរកំសាន្តជាលក្ខណៈគ្រួសារ។ អនុស្សាវរីយ៍ទាំងនេះនឹងមិនធ្វើឱ្យកូនៗរបស់អ្នកអាចបំភ្លេចបានឡើយ។

6. សូមមានការជួបផ្ទាល់នឹងកូនម្នាក់ៗរបស់អ្នកជាទៀងទាត់។ អនុញ្ញាតឱ្យពួកគេនិយាយអំពីអ្វីដែលពួកគេ ចង់និយាយ។ បង្រៀនពួកគេនូវគោលការណ៍នៃដំណឹងល្អ។ បង្រៀនពួកគេនូវគុណតម្លៃពិតទាំងឡាយ។ ប្រាប់ពួកគេថាអ្នកស្រឡាញ់ពួកគេ។ សូមចំណាយពេលផ្ទាល់ខ្លួននៅជាមួយនឹងកូនៗរបស់អ្នក ដើម្បីប្រាប់ពួកគេថា នេះជាកន្លែងដែលឱពុកដាក់នូវអាទិភាពជាងគេ។

7. បង្រៀនកូនៗរបស់អ្នកឱ្យចេះធ្វើការ ហើយបង្ហាញពួកគេនូវតម្លៃនៃការធ្វើការឆ្ពោះទៅរកគោលដៅដ៏សក្តិសមមួយ។ បង្កើតមូលនិធិបេសកកម្ម និងមូលនិធិអប់រំសំរាប់កូនៗរបស់អ្នក ដើម្បីបង្ហាញពួកគេនូវអ្វីដែលឱពុកចាត់ទុកថាជាការសំខាន់។

8. លើកទឹកចិត្តឱ្យស្តាប់តន្ត្រីល្អ និងរូបភាពល្អៗ ព្រមទាំងអក្សរសាស្ត្រល្អក្នុងគេហដ្ឋានរបស់អ្នក។ គេហដ្ឋានដែលមាន ព្រះវិញ្ញាណនៃការលាងសំអាត និងភាពស្រស់បំព្រង នឹងប្រទានពរដល់ជីវិតនៃកូនៗរបស់អ្នកជារៀងរហូត។

9. ប្រសិនបើចម្ងាយផ្លូវអំណោយផល សូមចូលរួមក្នុងព្រះវិហារបរិសុទ្ធជាមួយនឹងភរិយារបស់អ្នកឱ្យបានទៀងទាត់។ នោះកូនៗរបស់អ្នកនឹងកាន់តែយល់ អំពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ និងពាក្យសម្បថក្នុងព្រះវិហារបរិសុទ្ធ ហើយនិងក្រុមគ្រួសារដ៏អស់កល្បជានិច្ច។

10. សូមឱ្យកូនៗរបស់អ្នកមើលឃើញនូវសេចក្តីអំណរ និងសេចក្តីពេញចិត្តរបស់អ្នកក្នុងការបំរើសាសនាចក្រ។ ការណ៍នេះអាចឆ្លងដល់ពួកគេ ដើម្បីឱ្យពួកគេនឹងមានបំណងចង់បំរើក្នុងសាសនាចក្រ ហើយនឹងស្រឡាញ់នគរនោះផងដែរ។

ការហៅដ៏សំខាន់បំផុតរបស់អ្នករាល់គ្នា

ឱ! ស្វាមី និងឱពុកទាំងឡាយនៃអឺស្រាអែលអើយ អ្នករាល់គ្នាអាចធ្វើកិច្ចការដ៏ច្រើនសន្ធឹកសន្ធាប់សំរាប់សេចក្តីសង្គ្រោះ និងការលើកតំកើងដល់ក្រុមគ្រួសាររបស់អ្នកបាន! ការទទួលខុសត្រូវរបស់អ្នករាល់គ្នាគឺមានសារៈសំខាន់ខ្លាំងណាស់។

សូមចងចាំថាការហៅដ៏ពិសិដ្ឋរបស់អ្នករាល់គ្នាក្នុងនាមជាឱពុកមួយរូបនៃអឺស្រាអែល—គឺជាការហៅដ៏សំខាន់បំផុតរបស់អ្នករាល់គ្នាសំរាប់ពេលនេះ និងពេលដ៏អស់កល្បជានិច្ច—វាគឺជាការហៅមួយដែលអ្នករាល់គ្នានឹងមិនអាចត្រូវបានគេដោះលែងឡើយ។

សូមឱ្យអ្នករាល់គ្នាធ្វើការផ្តត់ផ្តង់ចំពោះសេចក្តីត្រូវការផ្នែកសម្ភារៈដល់គ្រួសាររបស់អ្នក ដោយមានដៃគូដ៏នៅអស់កល្បជានិច្ចរបស់អ្នកនៅក្បែរខ្លួនរបស់អ្នករាល់គ្នាជានិច្ច សូមឱ្យអ្នករាល់គ្នាបំពេញការទទួលខុសត្រូវដ៏ពិសិដ្ឋរបស់ខ្លួន នៅក្នុងការរៀបចំការដឹកនាំខាងវិញ្ញាណនៅក្នុងគេហដ្ឋានរបស់អ្នក។

ដកស្រង់ចេញពីសុន្ទរកថាដោយប្រធាន ប៊ែនសឹន នៅក្នុងសម័យប្រជុំបព្វជិតភាពនៃសន្និសីទទូទៅរបស់សាសនាចក្រ ខែ តុលា ឆ្នាំ 1987 (សូមមើល Conference Report ខែ តុលា ឆ្នាំ 1987 ទំព័រ 59–63 ឬ *Ensign* ខែ វិច្ឆិកា ឆ្នាំ 1987 ទំព័រ 48–51)។

តួនាទីពិសិដ្ឋរបស់ឱពុក និងម្តាយ

11

ផ្នែកទី 2ៈ តួនាទីរបស់ម្តាយ

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលៈទេសៈរបស់អ្នកផ្ទាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- នៅក្នុងការប្រកាសអំពីក្រុមគ្រួសារ យើងត្រូវបានទូន្មានថា "ឱពុកម្តាយមានភារៈកិច្ចឱ្យចេះជួយគ្នាទៅវិញទៅមកជាគូស្មើគ្នា" (សូមមើលទំព័រ iv ស្យេវភៅណែនាំការសិក្សានេះ)។ សូមមើលឡើងវិញនូវការណែនាំទាំង 10 របស់ប្រធាន អើសរ៉ា ថាហ្ វ ប៊ែនសឹន សំរាប់ឱពុកនៅទំព័រ 40–41 នៅក្នុងស្យេវភៅណែនាំការសិក្សានេះ និងការណែនាំចំនួន 10 ផ្សេងទៀតសំរាប់ម្តាយនៅទំព័រ 40–41 ជាមួយនឹងស្វាមី ឬភរិយារបស់អ្នក។ សូមពិភាក្សានូវរប្យេបមួយចំនួនដែលអ្នកអាចធ្វើការរួមគ្នា ហើយជួយគ្នាទៅវិញទៅមកនៅក្នុងការទទួលខុសត្រូវទាំងនេះ។
- សូមសរសរសំបុត្រមួយទៅកាន់ម្តាយ ឬជីដូនរបស់អ្នក។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

"ដោយសារតែនាងគឺជាម្តាយមួយរូប"

អែលឌើរ ជែហ្វ្រី អរ៍ ហឡិន
នៃក្រុមនៃពួកសាវក 12 នាក់

វិភាគទានចំពោះម្តាយទាំងឡាយ

នៅក្នុងប្រលោមលោករបស់កវី វីកទើរ ហុហ្គោ មានដំណើររឿងប៉ុន្មានឃ្លាបានលើកឡើងថាះ

មានពលបាលត្រីម្នាក់បានត្អូញត្អែរថា "នាងបានហែកនំប៉ុងជាពីរចំណែក ហើយឱ្យទៅកូនៗរបស់នាងដែលស្រេកឃ្លាន។ 'នាងគ្មានទុកអ្វីសំរាប់ខ្លួនឯងសោះឡើយ'។

មានពលទាហានម្នាក់ទៀតបាននិយាយថា "'ដោយសារតែនាងមិនឃ្លាន'។

ពលបាលត្រីរូបនោះបានតបថា "'មិនមែនទេ ដោយសារតែនាងគឺជាម្តាយមួយរូប'"។

នៅក្នុងឆ្នាំដែលយើងបានធ្វើការអបអរសាទរចំពោះសេចក្តីជំនឿ និងសេចក្តីក្លាហានរបស់ពួកអ្នក ដែលបានធ្វើដំណើរដោយថ្មើរជើងឆ្លងកាត់រដ្ឋអាយអូវ៉ា រដ្ឋណេប្រាស្កា និងរដ្ឋវ៉ាយអូមីង ខ្ញុំបានជូនកិត្តិយសនេះទៅដល់អ្នកម្តាយសម័យទំនើប នៃពួកអ្នកត្រួសត្រាយផ្លូវទាំងនោះ ដែលបានមើលថែ បានអធិស្ឋាន ហើយជាងនេះទៅទៀត គឺពួកគាត់បានកប់សាកសពកូនរបស់ខ្លួននៅតាមផ្លូវដ៏វែងឆ្ងាយនោះផង។ ចំពោះស្ត្រីទាំងឡាយដែលមានបំណង់ចង់ធ្វើជាម្តាយយ៉ាងខ្លាំង ប៉ុន្តែឱកាសមិនបានផ្តល់ឱ្យ ខ្ញុំសូមនិយាយដោយយល់ពីភាពក្តុកក្តួលរបស់អ្នក និងយើងស្តីអំពីប្រធានបទនេះថា នាពេលខាងមុខ ព្រះនឹងនាំមកនូវ "សេចក្តីសង្ឃឹមដល់ដួងចិត្តដែលស្រពោន [នោះ]"។[1] ដូចអ្វីដែលពួកពួកការីបានបង្រៀនម្តងហើយម្តងទៀតនៅលើវេទិកានេះថា នៅពេលចុងក្រោយបង្អស់ "គ្មានពរដ៏យណាមួយនឹងត្រូវបានដកយក" ពីពួកស្មោះត្រង់ឡើយ ទោះបីជាពរដ៏យទាំងនោះមិនកើតឡើងភ្លាមៗក៏ដោយ។[2] នៅក្នុងពេលនេះយើងមានសេចក្តីអំណរ ដែលការហៅឱ្យចិញ្ចឹមបីបាច់មិនត្រូវបានកំណត់ចំពោះតែការបីបាច់ដល់កូនចៅផ្ទាល់របស់យើងនោះឡើយ។

ដោយបានលើកឡើងអំពីម្តាយគ្រប់រូប នោះខ្ញុំមិនបានបំភ្លេចចោលចំពោះតួនាទីដ៏មានសារៈសំខាន់ ហើយចាំបាច់របស់ឱពុកនោះឡើយ ជាពិសេសការកំព្រាឱពុកនៅក្នុងគេហដ្ឋានទាពេលបច្ចុប្បន្ននេះ គឺត្រូវបានវាស់វែងដោយមនុស្សមួយចំនួនថាជា "បញ្ហាខាងសង្គមដ៏សំខាន់មួយនៅក្នុងសម័យកាលរបស់យើង"។[3] ពិតប្រាកណាស់ ការកំព្រាឱពុកអាចក្លាយជាបញ្ហាមួយដ៏ធំ សូម្បីតែនៅក្នុងគេហដ្ឋានមួយដែលមានវត្តមានរបស់ឱពុកក្តី—គឺទាំងនៅពេលបរិភោគអាហារ និងពេលសំរាក ដូចជាគេនិយាយថា គ្មានឱពុក"ធ្វើអន្តរាគមន៍ឡើយ"។ ប៉ុន្តែនោះគឺជាសារលិខិតបញ្ចជិតភាពមួយ សំរាប់ថ្ងៃក្រោយទៀត។ នៅថ្ងៃនេះខ្ញុំសូមកោតសរសើរដល់ដៃទាំងទ្វេររបស់ម្តាយទាំងនោះ ដែលបានយោលអង្រឹងដល់ទារកតូច ហើយបានបង្រៀនដល់កូនចៅរបស់ខ្លួនដោយសេចក្តីសុចរិត នោះគឺជាគោលបំណងដ៏សំខាន់របស់ព្រះអម្ចាស់នៅក្នុងជីវិតរមែងស្លាប់នេះ។

ដោយនិយាយអំពីប្រធានបទនេះ ខ្ញុំសូមនិយាយឡើងវិញនូវពាក្យរបស់ប៉ុលដែលបានសរសេរកោតសរសើរចំពោះ "សេចក្តីជំនឿស្មោះត្រង់ . . . មុនដំបូង" របស់ធីម៉ូថេ ដោយគាត់បាននិយាយថា "សេចក្តីជំនឿនោះបាននៅក្នុងយាយឡូអ៊ីសជាជីដូនអ្នកជាមុនដំបូង រូចក៏ [នៅក្នុង]អ៊ើនីសជាម្តាយអ្នកដែរ"។[4] ប៉ុលបាននិយាយទៀតថា "តាំងពី [ថ្ងៃដែលអ្នកនៅជា]កុមារតូចមកអ្នកបានស្គាល់បទគម្ពីរទាំងប៉ុន្មាន"។[5] យើងសូមថ្លែងអំណរគុណចំពោះអ្នកម្តាយ និងជីដូនគ្រប់រូបដែលបានបង្រៀនសេចក្តីពិតដល់កូនចៅរបស់ខ្លួនតាំងពីកុមារមក។

ការលះបង់ដែលបានធ្វើឡើងដោយពួកអ្នកម្តាយវ័យក្មេង

ក្នុងការនិយាយអំពីពួកអ្នកម្តាយជាទូទៅ ជាពិសេសខ្ញុំចង់ធ្វើការកោតសរសើរហើយក៏ធ្វើលើកទឹកចិត្តដល់ពួកអ្នកម្តាយ*វ័យក្មេង* ផងដែរ។ កិច្ចការជាម្តាយមានការលំបាកណាស់ ជានិច្ចកាលវាគឺជាកិច្ចការដែលគ្មានមនុស្សណាម្នាក់កត់សំគាល់យើញឡើយ។ ជាញឹកញាប់ គ្រាដ៏លំបាកបំផុត គឺជាពេលដែលស្វាមី ឬភរិយា—ឬពួកគេទាំងពីរនាក់—នៅរៀន ឬស្ថិតនៅក្នុងជំហានចាប់ផ្តើមទាំងនោះ និងនៅពេលសមត្ថភាពក្នុងការរកប្រាក់ចំណូលផ្គត់ផ្គង់ជីវិតរបស់ស្វាមីមានភាពស្តួចស្តើង។ ផ្នែកហិរញ្ញវត្ថុរបស់គ្រួសារមានភាពស្តួចស្តើង គឺចាប់ពីមានអ្វីបន្តិចបន្តួចរហូតដល់គ្មានអ្វីទាំងអស់។ ជាធម្មតាផ្ទះល្វែងត្រូវបានលំអរទៅដោយគ្រឿងតុទូ ដែលទិញមក

ពីហាងលក់របស់របរចាស់ ឬក៏គ្មានរបស់របរទាំងអស់នោះសោះឡើយ។ ប្រសិនបើមានឡាន ក៏ឡានទោះមានសំបកកង់ដែលអស់ក្រឡា និងធុងសាំងគ្មានប្រេងដែរ។ ប៉ុន្តែការលំបាកដ៏ធំជាងគេបំផុតសំរាប់អ្នកម្តាយវ័យក្មេង គឺជាការឡើយហត់ ដោយត្រូវបំបៅកូនតូចនៅពេលយប់។ នៅគ្រប់ពេលវេលាក្នុងជីវិតរបស់ខ្ញុំ ខ្ញុំដឹងថាក្នុងរយៈពេលប៉ុន្មានឆ្នាំនោះ អ្នកម្តាយទាំងឡាយត្រូវបន្តការអត់ងងុយដ៏យូរ ដោយទុកឱកាសដល់អ្នកដទៃផ្សេងទៀតបានសំរាកដាជាងខ្លួនឯង។ វាពុំមែនជាការភ្ញាក់ផ្អើលឡើយ ខណៈដែលផ្នែកខាងក្រោមរង្វង់ផ្នែករបស់ពួកគេមានស្រមោលកាន់តែធំទៅៗ។

ពិតត្រាកដណាស់ ជាញឹកញាប់នេះគឺជាសុិស្ទើរដែលយើងចង់ហៅ—ឬត្រូវហៅ—ឱ្យបំរើនៅក្នុងអង្គការជំនួយរបស់រួម និងស្តេក។ នោះគឺជារឿងសមហេតុផលណាស់។ តើមានមនុស្សណាខ្លះ ដែលមិនចង់បានឥទ្ធិពលដ៏ល្អឥតខ្ចោះរបស់យុវនារីទាំងឡាយ ដែលបានប្រែក្លាយខ្លួនដូចជា ឡូរីស និងអើរីសនោះ? មនុស្សគ្រប់គ្នាអើយ ចូរមានភាពឈ្លាសវៃឡើង។ សូមចងចាំថា ក្រុមគ្រួសារគឺជាអទិភាពដ៏ខ្ពស់បំផុតជាងអ្វីៗទាំងអស់ ជាពិសេសនៅក្នុងគ្រាចាប់ផ្តើមទាំងនោះ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកម្តាយវ័យក្មេងនៅតែរកឃើញនូវរបៀបដ៏វិសេសវិសាល ដើម្បីបំរើយ៉ាងស្មោះត្រង់នៅក្នុងសាសនាចក្រ ដូចដែលមនុស្សដទៃទៀតបានបំរើ និងពង្រឹងដល់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេផងដែរ។

សូមធ្វើឱ្យអស់ពីសមត្ថភាពរបស់អ្នកដើម្បីឆ្លងកាត់ពេលវេលាទាំងនេះ ប៉ុន្តែចំពោះរឿងអ្វីៗផ្សេងទៀតដែលអ្នកធ្វើ សូមរីករាយចំពោះតួនាទីនោះ ដែលជាតួនាទីដ៏សំខាន់បំផុតរបស់អ្នក និងជាអ្វីដែលស្ថានសួគ៌បានបញ្ជូនពួកទេវតាឱ្យមើលថែអ្នក និងកូនតូចរបស់អ្នក។ ស្វាមីទាំងឡាយ—ក៏ដូចជាពួកអ្នកដឹកនាំសាសនាចក្រ និងមិត្តភក្តិទាំងឡាយនៅគ្រប់ទិសទី សូមផ្តល់នូវការជួយជ្រោមជ្រែង និងការចេះយោគយល់ ហើយត្រូវមានភាពឈ្លាសវៃ។ សូមចងចាំថា “មានពេលសំរាប់គ្រប់ទាំងអស់ គឺមានពេលសំរាប់គ្រប់ការដែលចង់ធ្វើនៅក្រោមមេឃ”។[6]

អ្នកម្តាយទាំងឡាយ យើងសូមទទួលស្គាល់ និងគោរពដល់សេចក្តីជំនឿរបស់អ្នករាល់គ្នានៅគ្រប់ជំហាន។ សូមដឹងថា ការណ៍នេះមានតម្លៃខ្លាំងណាស់សំរាប់ពេលនោះ បច្ចុប្បន្នកាល និងជារឿងរហូត។ ចំពោះហេតុផលណាមួយក៏ដោយ ប្រសិនបើអ្នករាល់គ្នាកំពុងធ្វើកិច្ចខិតខំដ៏ក្លាហាននេះតែម្នាក់ឯង ដោយគ្មានស្វាមីរបស់អ្នកនៅក្បែរខ្លួន នោះយើងនឹងធ្វើការអធិស្ឋាន កាន់តែច្រើនថែមទៀតសំរាប់ចំពោះអ្នករាល់គ្នា ហើយការប្តេជ្ញាចិត្តរបស់យើងនៅក្នុងការផ្តល់ជំនួយ ដល់អ្នករាល់គ្នានឹងកាន់តែមានច្រើនឡើងផងដែរ។

ម្តាយចូលរួមចំណែកក្នុងកិច្ចការរបស់ព្រះ

មានម្តាយវ័យក្មេងម្នាក់បានសរសេរមកកាន់ខ្ញុំកាលពីពេលថ្មីៗនេះថា ការព្រួយបារម្ភរបស់នាងបានកើត មានឡើងដោយបញ្ហាបិយ៉ាងនៅចំពោះមុខ។ ទីមួយ គឺថានៅពេលណាដែលនាងឮការនិយាយអំពីភាពជាម្តាយរបស់ អិល.ឌី.អេស នាងព្រួយបារម្ភដោយសារ នាងមានអារម្មណ៍ថា នាងពេញខ្នាត ឬនិយាយម្យ៉ាងទៀតថានាងមិនសក្តិសមចំពោះកិច្ចនេះទេ។ ទីពីរ នាងមានអារម្មណ៍ដូចជាពិភពលោកនេះ បានរំពឹងទុកឱ្យនាងបង្រៀនកូនៗរបស់នាងឱ្យចេះអាន ចេះសរសេរ រៀបចំគេហដ្ឋាន រៀនភាសាឡាតាំង រៀនពិជគណិត និងអ៊ិនធើរណែត—ទាំងអស់មុនពេលកូនចេះនិយាយអ្វីមួយដែលអាក្រក់ ដូចជាពាក្យ “គួរឱ្យខ្ពើមណាស់”។ ទីបី ជាញឹកញាប់នាងមាន អារម្មណ៍ថា ពេលខ្លះមនុស្សកំពុងតែភ្លក្លែងនឹងខ្លួនឯង ដែលភាគច្រើនគឺគ្មានចេទនាទេ ពីព្រោះពាក្យណែនាំ ដែលនាងបានទទួល ឬសូម្បីតែការគោតសរសើរដែលនាងបានទទួល ហាក់ដូចជាគ្មានឆ្អុះបញ្ចាំងឱ្យដាក់ទុនខាងគំនិត សកម្មភាពខាងវិញ្ញាណ និងខាងអារម្មណ៍ ទាំងយប់ទាំងថ្ងៃ ដើម្បីចាប់យកនូវគំរូវការដែលមានកំណត់ ដែលពេលខ្លះ ត្រូវបានគំរូវឱ្យមានការព្យាយាមដើម្បីប្រែក្លាយ និងការចង់ក្លាយជាម្តាយដែលព្រះបានសង្ឃឹមទុកចំពោះនាង។

នាងបាននិយាយថា ប៉ុន្តែមានចំណុចមួយដែលបានធ្វើនាងនៅតែបន្ត ៖ “តាមរយៈរឿងទាំងតូចទាំងធំនេះ និងទឹកភ្នែកដែលស្រក់ចុះមកជាញឹកញាប់ ដោយសារកិច្ចការនេះ *ខ្ញុំបានដឹងនៅក្នុងក្រអៅបេះដូងរបស់ខ្ញុំថា ខ្ញុំកំពុងតែធ្វើកិច្ចការរបស់ព្រះ* ។ ខ្ញុំដឹងថាក្នុងភាពជាម្តាយរបស់ខ្ញុំ ខ្ញុំស្ថិតនៅក្នុងភាពជាដៃគូដ៏អស់កល្បជានិច្ចជាមួយនឹងទ្រង់។ ខ្ញុំមានទំនុកចិត្តយ៉ាងខ្លាំងថា ព្រះរកឃើញគោលបំណង និងអត្ថន័យនៅក្នុងការធ្វើជាឪពុកម្តាយ ទោះបីជាកូនចៅរបស់ទ្រង់មួយចំនួនបានធ្វើឱ្យទ្រង់ព្រះកន្សែងក៏ដោយ”។

នាងបាននិយាយថា “ដោយសារការយល់ដឹងនេះ ដែលខ្ញុំបានព្យាយាមរំឭកឡើងវិញ អំពីថ្ងៃដ៏លំបាកទាំងឡាយដែលបានកើតឡើងដោយផ្សេងទៀត ពេលដែលកិច្ចការទាំងអស់នេះហាក់ដូចជាលើសលុបបន្តិចក្តី។ វាប្រហែលជាការអសមត្ថភាព និងការខ្វល់ខ្វាយរបស់យើងយ៉ាងពិតដែលជំរុញឱ្យយើងទៅរកទ្រង់ ហើយអនុញ្ញាតឱ្យទ្រង់ដែលមានលទ្ធភាពឈោងមករកយើងវិញ”។ នាងបានបន្ថែមទៀតថា “ប្រហែលជាទ្រង់សង្ឃឹមដោយសម្ងាត់ថា យើង *នឹង* ខ្វល់ខ្វាយ ហើយ *នឹង* ទូលអង្វរសុំជំនួយរបស់ទ្រង់។ បន្ទាប់មក ខ្ញុំជឿថា ទ្រង់អាចបង្រៀនកូនៗទាំងនេះដោយផ្ទាល់តាមរយៈយើង ប៉ុន្តែដោយគ្មានការរីងទទឹងធ្វើឡើង”។ នាងបានបញ្ចប់ថា “ខ្ញុំស្រឡាញ់គំនិតនោះ។ វាផ្តល់សេចក្តីសង្ឃឹមឱ្យខ្ញុំ។ ប្រសិនបើខ្ញុំដ៏ត្រឹមត្រូវនៅចំពោះព្រះវរបិតាសួគ៌របស់ខ្ញុំ នោះប្រហែលជាការដឹកនាំរបស់ទ្រង់ចំពោះកូនៗរបស់យើង មិនអាចត្រូវបានរារាំងឡើយ។ ប្រហែលជាពេលនោះវាអាចជាកិច្ចការ *របស់ទ្រង់* និងសេរីល្អ*របស់ទ្រង់* នៅក្នុងការយល់ដឹងដ៏ពិតបំផុត”។[7]

កូនចៅរបស់អ្នកនឹងរាប់អ្នកថាជាពរជ័យ

នៅក្នុងពន្លឺនៃការសម្តែងចេញអារម្មណ៍បែបនោះ វាបានសបញ្ជាក់យ៉ាងច្បាស់ថា ស្រមោលដ៏ធំនៅក្រោមរង្វង់ផ្នែកមួយចំនួននោះ គឺវាកើតមានឡើងពុំមែនដោយសារតែការផ្លាស់កន្ទុបឱ្យកូន ការជូនកូនទៅសាលារៀន ឬក៏សកម្មភាពផ្សេងទៀតប៉ុណ្ណោះទេ ប៉ុន្តែយ៉ាងហោចណាស់វាកើតឡើងដោយសារការអត់ងងុយប៉ុន្មានយប់ ដើម្បីចំណាយពេលមើលថែទាំដល់ព្រលឹង និងដោយសារការស្វែងរកដ៏ស្មោះត្រង់នូវសមត្ថភាព ដើម្បីចិញ្ចឹមកូនចៅទាំងនេះឱ្យស្របតាមអ្វី ដែលព្រះសព្វព្រះទ័យឱ្យពួកគេធ្វើ។ ដោយមានក្តីរំភើបចំពោះការលះបង់ និងការប្តេជ្ញាចិត្តទាំងនេះ ខ្ញុំសូមនិយាយទៅកាន់អ្នកម្តាយទាំងឡាយដោយចំៗថា នៅក្នុងព្រះនាមនៃព្រះអម្ចាស់ អ្នករាល់គ្នាមានសារៈសំខាន់ខ្លាំងណាស់។ អ្នករាល់គ្នាកំពុងធ្វើកិច្ចការនេះបានយ៉ាងល្អបំផុត។ ជាការពិតណាស់ កាលដែលអ្នករាល់គ្នាត្រូវបានប្រទានឱ្យនូវការទទួលខុសត្រូវមួយបែបនេះ គឺជាភស្តុតាងដ៏អស់កល្បជានិច្ចថាព្រះវរបិតា គង់នៅស្ថានសួគ៌របស់អ្នកមានទំនុកចិត្តចំពោះអ្នករាល់គ្នា។ ទ្រង់ត្រាស់ដឹងថា ការបង្កើតកូនរបស់អ្នកមិនបានធ្វើឱ្យអ្នករាល់គ្នាមានប្រជាប្រិយភាពគ្លាមៗនោះទេ។ អ្នករាល់គ្នានឹងបានធ្វើនូវរាល់កិច្ចការទាំងអស់ ដែលមនុស្សម្នាក់អាចធ្វើ និងរាល់កិច្ចការដែលព្រះសព្វព្រះទ័យឱ្យអ្នករាល់គ្នាធ្វើបាន ប្រសិនបើជាអ្នករាល់គ្នា និងស្វាមីរបស់អ្នកព្យាយាមស្រឡាញ់ព្រះ ហើយរស់នៅតាមដំណឹងល្អដោយខ្លួនឯង ប្រសិនបើអ្នករាល់គ្នាទូលសុំការដឹកនាំ និងការលួងលោមពីព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យាចំពោះពួកស្មោះត្រង់ ប្រសិនបើអ្នករាល់គ្នាទៅកាន់ព្រះវិហារបរិសុទ្ធ

ដើម្បីធ្វើ និងប្រកាសនូវសេចក្តីសន្យាស្តីអំពីសេចក្តីសញ្ញាដ៏ពិសិដ្ឋបំផុត ដែលស្ត្រី ឬបុរសម្នាក់អាចធ្វើនៅក្នុងពិភពលោកនេះ ប្រសិនបើអ្នករាល់គ្នានឹងបង្ហាញដល់មនុស្សដទៃ រួមទាំងកូនចៅរបស់អ្នកផងដែរ អំពីការខ្វាយខ្វាយ សណ្តានចិត្ត ដួងចិត្ត ដែលចេះអភ័យទោសដូចគ្នានេះ ដែលអ្នករាល់គ្នាចង់ឱ្យស្ថានសួគិបង្ហាញដល់អ្នក ប្រសិនបើអ្នករាល់គ្នាព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីធ្វើជាឱពុកម្តាយដ៏ល្អបំផុត តាមដែលអ្នកអាចធ្វើបាននោះ។

នៅពេលខ្លះ ការសំរេចចិត្តរបស់កូន ឬក៏ចៅម្នាក់នឹងធ្វើឱ្យអ្នករាល់គ្នាខូចចិត្ត។ ជួនកាល ការរំពឹងទុកទាំងឡាយនឹងមិនកើតឡើងភ្លាមៗនោះឡើយ។ ឱពុកម្តាយគ្រប់រូបមានការព្រួយបារម្ភចំពោះបញ្ហានោះ។ សូម្បីតែ ប្រធាន យ៉ូសែប អែហ្ស ស្មីធ ដែលជាឱពុកម្នាក់គួរឱ្យស្រឡាញ់ ហើយមានជោគជ័យយ៉ាងអស្ចារ្យ ក៏បានទូលសុំផងដែរថា "ឱ!ព្រះអម្ចាស់អើយ សូមកុំឱ្យទូលបង្គំបាត់បង់កូនចៅរបស់ផងទូលបង្គំឡើយ"។[8] នោះគឺជាការទូលសុំរបស់ឱពុកម្តាយគ្រប់រូប ហើយនៅក្នុងនោះវាគឺជាអ្វីមួយដែលឱពុកម្តាយគ្រប់រូបមានការភ័យខ្លាច។ ប៉ុន្តែពួកអ្នកដែលខិតខំព្យាយាម ហើយខិតខំអធិស្ឋាន នោះនឹងមិនទទួលបរាជ័យឡើយ។ អ្នករាល់គ្នាមានសិទ្ធិគ្រប់យ៉ាងដើម្បីទទួលការលើកទឹកចិត្ត និងដើម្បីដឹងថា នៅគ្រាចុងក្រោយបង្អស់ កូនរបស់អ្នករាល់គ្នានឹងរាប់ថាអ្នកជាពរជ័យ ដូចគ្នានឹងជំនាន់នៃបុព្វស្ត្រីពីមុនអ្នករាល់គ្នា ដែលមានសេចក្តីសង្ឃឹម និងមានសេចក្តីភ័យខ្លាចដូចគ្នានឹងអ្នករាល់គ្នាផងដែរ។

ការទទួលខុសត្រូវរបស់អ្នក គឺជាទំនៀមទំលាប់ដ៏ឆ្នើមរបស់នាងអេវ៉ា ដែលជាម្តាយនៃគ្រួសារមនុស្សលោកទាំងអស់ ជាស្ត្រីម្នាក់ដែលយល់ថា នាង និងលោកអ័ដាម *ត្រូវ* ធ្លាក់ខ្លួន "ដើម្បីឱ្យមាន បុរស [និងស្ត្រីទាំងឡាយ]"[9] ហើយដើម្បឱ្យមាននូវសេចក្តីអំណរ។ ត្ងនាទីរបស់អ្នក គឺជាទំនៀមទំលាប់ដ៏ឆ្នើមរបស់នាងសាវ៉ា នាងរ៉ិបេកា និងនាងរ៉ាជែល បើគ្មានអ្នកទាំងអស់នេះនោះទេ នោះនឹងពុំអាចមាននូវការសន្យារបស់លោកអយ្យកោដ៏សំខាន់កើតមានដល់លោក អ័ប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប ដែលបានប្រទានពរដល់យើងទាំងអស់គ្នានោះ។ ការទទួលខុសត្រូវរបស់អ្នក គឺជាទំនៀមទំលាប់ដ៏ឆ្នើមរបស់នាងឡូអ៊ីស និងនាងអ៊ីនីស និងម្តាយនៃកងទ័ពកំលោះ 2,000 នាក់។ ត្ងនាទីរបស់អ្នក គឺជាទំនៀមទំលាប់ដ៏ឆ្នើមរបស់នាងម៉ារ៉ា ដែលបានជ្រើស និងបានតែងតាំងពីមុនកើតមានពិភពលោកនេះ ដើម្បីឱ្យមានគកិ ពរពោះ និងប្រសូត្រព្រះរាជបុត្រានៃព្រះផ្ទាល់។ យើងសូមអរគុណដល់អ្នកទាំងអស់គ្នា រួមទាំងម្តាយរបស់យើងផ្ទាល់ផងដែរ ហើយសូមប្រាប់ទៅអ្នកថា គ្មានកិច្ចការណាមួយនៅក្នុង ពិភពលោកនេះដែលសំខាន់ជាងការចូលរួមដោយផ្ទាល់បំផុតក្នុងកិច្ចការ និងសេរីល្អនៃព្រះឡើយ ក្នុងការនាំមកនូវជីវិតមតះ និងជីវិតនៅលើផែនដីនៃបុត្រាបុត្រីរបស់ទ្រង់ ដើម្បីឱ្យកើតមានជីវិតអមតះ និងជីវិតដ៏អស់កល្បជានិច្ច ក្នុងនគរសេឡេស្ទាលដ៏ខ្ពស់នោះឡើយ

សូមពឹងផ្អែកចំពោះព្រះអង្គសង្គ្រោះជារៀងរហូត

មានអ្នកម្តាយមួយរូបបានមានប្រសាសន៍ថា នៅពេលអ្នករាល់គ្នាមកឯព្រះអម្ចាស់ដោយភាពស្លូតបូត និងចិត្តសុភាពរាបសា ហើយ "គោះទ្វារស្ថានសួគិ ទូលសុំ ហើយទូលអង្វរដើម្បីទទួលបានការដឹកនាំ និងប្រាជ្ញា ព្រមទាំងជំនួយសំរាប់កិច្ចការដ៏អស្ចារ្យនេះ" នោះទ្វារនឹងបើកឡើងដើម្បីផ្តល់ដល់អ្នករាល់គ្នានូវសិទ្ធិអំណាច និងជំនួយដ៏នៅអស់កល្បជានិច្ច។ សូមស្វែងរកសេចក្តីសន្យារបស់ព្រះអង្គសង្គ្រោះនៃពិភពលោក។ សូមទូលសុំការព្យាបាលដែលលួងលោមចិត្តចេញពីដង្វាយធួន សំរាប់រាល់បញ្ហាដែលកើតមានចំពោះអ្នករាល់គ្នា និងកូនចៅរបស់អ្នក។ សូមដឹងថា ដោយសារតែសេចក្តីជំនឿ នោះរឿងគ្រប់យ៉ាងនឹងប្រែមកជាល្អវិញចំពោះអ្នករាល់គ្នា ឬកាន់តែមានភាពល្អប្រសើរថែមទៀត ដោយសារតែអ្នករាល់គ្នា។

អ្នករាល់គ្នាមិនអាចធ្វើកិច្ចការនេះតែម្នាក់ឯងបានឡើយ ប៉ុន្តែអ្នករាល់គ្នា*ពិត* ជាមាននូវជំនួយ។ លោកចៅហ្វាយនៃស្ថានសួគិ និងផែនដីនេះនឹងគង់នៅទីនោះដើម្បីប្រសិទ្ធពរដល់អ្នករាល់គ្នា—ទ្រង់គឺជាអង្គដែលនឹងយាងទៅតាមកូនចៀមដែលបាត់ ហើយទ្រង់គឺជាអង្គដែលបានបោសរកប្រាក់ដែលបាត់ ហើយក៏ជាអង្គដែលរង់ចាំជានិច្ចចំពោះការវិលត្រឡប់វិញរបស់កូនប្រុសខ្ជះខ្ជាយ។ ត្ងនាទីរបស់អ្នករាល់គ្នា គឺជាកិច្ចការនៃសេចក្តីសង្គ្រោះ ហេតុដូច្នេះហើយ អ្នករាល់គ្នានឹងត្រូវបានលើកដំកើង និងប្រទានរង្វាន់ឱ្យ ដោយធ្វើឱ្យអ្នករាល់គ្នាកាន់តែមានសមត្ថភាព ហើយមានលក្ខណៈកាន់តែល្អប្រសើរជាងមុន ដរាបណាអ្នករាល់គ្នាព្យាយាមធ្វើកិច្ចការដែលស្មោះត្រង់ ទោះជាយ៉ាងណាក៏ដោយ នៅពេលខ្លះអ្នករាល់គ្នាក៏អាចទទួលអារម្មណ៍ទន់ខ្សោយផងដែរ។

សូមចងចាំម្តងហើយម្តងទៀតអំពីរយះពេលនៃភាពជាម្តាយរបស់អ្នករាល់គ្នាថា ៖ "អ្នករាល់គ្នាមិនបានមកដល់នេះ លើកលែងតែដោយព្រះបន្ទូលនៃព្រះគ្រីស្ទ ដោយមានសេចក្តីជំនឿដ៏រឹងប៉ឹងដល់ព្រះអង្គ ដោយពឹងផ្អែកទាំងស្រុង ទៅលើបុណ្យគុណរបស់ទ្រង់ដែលមានឥទ្ធិឬទ្ធិដើម្បីសង្គ្រោះ"។[10]

សូមពឹងផ្អែកលើទ្រង់។ សូមពឹងផ្អែកទាំងស្រុងលើទ្រង់។ សូមពឹងផ្អែកទៅលើទ្រង់ជារៀងរហូត។ ហើយ "ឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ ដោយមានការភ្លឺថ្លានៃសេចក្តីសង្ឃឹមដ៏ឥតខ្ចោះ"។[11] អ្នករាល់គ្នាកំពុងធ្វើកិច្ចការរបស់ព្រះ។ អ្នករាល់គ្នាកំពុងធ្វើកិច្ចការនេះបានយ៉ាងល្អ។ ទ្រង់កំពុងប្រសិទ្ធពរដល់អ្នករាល់គ្នា ហើយទ្រង់នឹងនៅតែប្រសិទ្ធពរដល់អ្នករាល់គ្នាជារៀងរហូត—*ជាពិសេស*—នៅពេលអ្នករាល់គ្នាជួបបញ្ហាដ៏លំបាកបំផុត។ ប្រៀបដូចនឹងស្ត្រីមិនស្គាល់ឈ្មោះ ហើយរាបសាដែលបានស្វែងរកផ្លូវរបស់នាងនៅក្នុងចំណោមក្រុមមនុស្សកុះករ ដើម្បីនឹងបានប៉ះព្រះពស្ត្ររបស់លោកចៅហ្វាយ ទោះបីជានាងមិនប្រាកដ ហើយមានការអាម៉ាស់ខ្លះៗក្តីផងដែរ នោះព្រះគ្រីស្ទនឹងមានព្រះបន្ទូលទៅកាន់ស្ត្រីដែលមានការព្រួយបារម្ភ ហើយខ្ចល់ខ្ចយ ហើយពេលខ្លះនាងបានទួញយំ ដោយសារតែការទទួលខុសត្រូវរបស់ខ្លួនក្នុងនាមជាម្តាយថា "ចូរសង្ឃឹមឡើងកូនអើយ សេចក្តីជំនឿរបស់នាងបានជួយសង្គ្រោះនាងហើយ"។[12] ហើយសេចក្តីជំនឿនោះ នឹងជួយសង្គ្រោះដល់កូនចៅរបស់អ្នករាល់គ្នាផងដែរ។

ដកស្រង់ចេញមកពីសុន្ទរកថាដោយអែលឌើរ ហឡិន នៅក្នុងសន្និសីទទូទៅនៃសាសនាចក្រ ខែ មេសា ឆ្នាំ 1997 (សូមមើល Conference Report ខែ មេសា ឆ្នាំ 1997 ទំព័រ 46–49 ឬ *Ensign* ខែ ឧសភា ឆ្នាំ 1997 ទំព័រ 35–37)។

កំណត់ចំណាំ

1. "ព្រះអង្គប្រោសលោះនៃអ៊ីស្រាអែល" *ទំនុកដំកើងព្រះ* ទំព័រ 5 សូមមើលផងដែរ នីហ្វៃទី 3 22:1។
2. សូមមើល Joseph Fielding Smith, *Doctrines of Salvation* រៀបរៀងដោយ Bruce R. McConkie រ៉ុលទី 3 (1954–56) 2:76 Harold B. Lee, *Ye Are the Light of the World: Selected Sermons and Writings of President Harold B. Lee* (ឆ្នាំ 1974) ទំព័រ 292 និង ហ្គរដុន ប៊ី ហ៊ុងគ្លី នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1991 ទំព័រ 94។
3. Tom Lowe "Fatherlessness: The Central Social Problem of Our Time" Claremont Institute Home Page Editorial ខែ មករា ឆ្នាំ 1996។
4. ធីម៉ូថេទី 2 1:5។
5. ធីម៉ូថេទី 2 3:15។
6. សេស្តា 3:1។
7. សារលិខិតផ្ទាល់ខ្លួន។
8. យ៉ូសែប អែហ្ស ស្មីធ *Gospel Doctrine* ការបោះពុម្ពលើទី 5 (ឆ្នាំ 1939) ទំព័រ 462។

9. នីហ្វៃទី 2 2:25។
10. នីហ្វៃទី 2 31:19។
11. នីហ្វៃទី 2 31:20។
12. ម៉ាថាយ 9:22។

ជូនចំពោះអ្នកម្តាយទាំងឡាយនៅក្នុងសិ៊ីយ៉ូន

ប្រធាន អែសរ៉ា ថាហ្ទ បែនសឹន
ប្រធានសាសនាចក្រទី 13

អ្នកម្តាយទាំងឡាយនៅក្នុងសិ៊ីយ៉ូនអើយ ត្ថនាទីដែលព្រះបានប្រទានឱ្យអ្នករាល់គ្នាមានសារះសំខាន់ខ្លាំងណាស់ ចំពោះការលើកដំកើងផ្ទាល់ខ្លួនរបស់អ្នក និងចំពោះសេចក្តីសង្ត្រោះ និងការលើកដំកើងដល់ក្រុមគ្រួសាររបស់អ្នក។ កុមារគឺត្រូវការម្តាយជាជាងអ្វីៗទាំងអស់ដែលប្រាក់អាចទិញបាន។ ការចំណាយពេលវេលានៅជាមួយនឹងកូនរបស់អ្នក គឺជាអំណោយទានដ៏មហិមាជាងគេបំផុត។

ដោយសេចក្តីស្រឡាញ់អស់ពីដួងចិត្តចំពោះអ្នកម្តាយនៅក្នុងសិ៊ីយ៉ូន នាពេលនេះខ្ញុំសូមណែនាំអំពីរបៀបដ៏ជាក់លាក់ចំនួនដប់ ដែលអ្នកម្តាយទាំងឡាយរបស់យើងអាចចំណាយពេលវេលារបស់ខ្លួននៅជាមួយនឹងកូនៗបាន។

ចូរផ្តល់ពេលវេលាដល់កូនចៅពេញមួយជីវិតរបស់គេ។ ទីមួយ សូមរកពេលវេលាសំរាប់កូនចៅជានិច្ច— គឺនៅពេលកូនចៅរបស់អ្នករាល់គ្នាទៅសាលារៀន ឬត្រលប់មកវិញ នៅពេលពួកគេចេញទៅដើរលេងជាគូ ហើយត្រលប់មកវិញ និងនៅពេលពួកគេនាំមិត្តភក្តិមកលេងផ្ទះ។ សូមញែកពេលវេលាសំរាប់កូនចៅរបស់អ្នកមិនថាកូនចៅរបស់អ្នកមានអាយុប្រាំមួយឆ្នាំ ឬដប់ប្រាំមួយឆ្នាំនោះទេ។ នៅក្នុងសុភាសិតយើងអានថា "កូនណាដែលបណ្តោយឱ្យប្រព្រឹត្តតាមអំពើចិត្ត នោះតែងធ្វើឱ្យម្តាយមានសេចក្តីខ្មាស់វិញ" (សុភាសិត 29:15)។ នៅក្នុងចំណោមបញ្ហាដ៏ធំជាងគេបំផុតរបស់សង្គមយើង គឺថាកុមាររាប់លាននាក់មានឱពុកម្តាយដែលធ្វើការហើយចំណាយពេលជាប្រចាំរបស់ខ្លួននៅក្នុងគេហដ្ឋានដែលគ្មានការគ្រប់គ្រង។

ចូរធ្វើជាមិត្តដ៏ពិតប្រាកដម្នាក់។ ទីពីរ អ្នកម្តាយទាំងឡាយ សូមចំណាយពេលដើម្បីធ្វើជាមិត្តពិតប្រាកដចំពោះកូនចៅរបស់អ្នក។ សូមត្រង់ត្រាប់ស្តាប់កូនចៅរបស់អ្នក។ សូមនិយាយលេងជាមួយនឹងពួកគេ សូមសើចសប្បាយ ហើយនិយាយរឿងកំប្លែងជាមួយនឹងពួកគេ សូមច្រៀងជាមួយនឹងពួកគេ សូមលេងសប្បាយនឹងពួកគេ សូមទួញយំជាមួយនឹងពួកគេ សូមឱបក្រសោបពួកគេ សូមកោតសរសើរពួកគេ ដោយស្មោះអស់ពីចិត្ត។ ពិតណាស់ សូមចំណាយពេលនៅជាមួយនឹងតែពីរនាក់តទល់ឱ្យបានញឹកញាប់ ដោយពុំមានការប្រញ៉ាប់ប្រញ៉ាល់។ ចូរធ្វើជាមិត្តដ៏ពិតប្រាកដម្នាក់សំរាប់កូនចៅរបស់អ្នករាល់គ្នា។

ចូរអានរឿងឱ្យកូនអ្នកស្តាប់។ ទីបី អ្នកម្តាយទាំងឡាយ សូមញែកពេលដើម្បីអានរឿងឱ្យកូនអ្នកស្តាប់។ សូមអានរឿងឱ្យកូនប្រុសស្រីអ្នកស្តាប់ចាប់តាំងពីពួកគេគេងនៅក្នុងអង្រឹងនៅឡើយ។ សូមចងចាំនូវអ្វីដែលកវីនិពន្ធបាននិយាយថា ៖

> អ្នកប្រហែលជាមានទ្រព្យសម្បត្តិដ៏ច្រើនឥតគណនា
> មានទាំងហិបដាក់គ្រឿងអលង្ការ និងហិបមាស។
> ប៉ុន្តែខ្ញុំមាននូវអ្វីដែលអ្នកមិនកាត់ថ្លៃបាន—
> គឺខ្ញុំមានអ្នកម្តាយដែលតែងតែអានរឿងឱ្យខ្ញុំស្តាប់។
> (Strickland Gillilan "The Reading Mother")។

អ្នករាល់គ្នានឹងបណ្តុះសេចក្តីស្រឡាញ់មួយសំរាប់អត្ថបទដ៏ល្អ និងសេចក្តីស្រឡាញ់ដ៏ពិតមួយចំពោះខគម្ពីរទាំងឡាយ ប្រសិនបើអ្នករាល់គ្នាអានរឿងទាំងនេះដល់កូនចៅរបស់អ្នកឱ្យបានទៀងទាត់នោះ។

ចូរអធិស្ឋានជាមួយនឹងកូនចៅរបស់អ្នក។ ទីបួន សូមញែកពេលដើម្បីអធិស្ឋានជាមួយនឹងកូនចៅរបស់អ្នក។ ដោយស្ថិតនៅក្រោមការដឹកនាំរបស់ឱពុក ការអធិស្ឋានជាគ្រួសារគប្បីធ្វើឡើងនៅពេលព្រឹក និងនៅពេលយប់។ សូមធ្វើឱ្យកូនចៅរបស់អ្នកទទួលអារម្មណ៍នៃសេចក្តីជំនឿរបស់អ្នក នៅពេលអ្នករាល់គ្នាបួងសួងសុំពរជ័យពីស្ថានសួគិសំរាប់ពួកគេ។ សូមលើកឡើងនូវពាក្យសម្តីរបស់យ៉ាកុបជាថ្មីម្តងទៀតដែលថា ". . . សេចក្តីទូលអង្វរដ៏អស់ពីចិត្តរបស់ [ម្តាយ] សុចរិតនោះពូកែណាស់" (យ៉ាកុប 5:16)។ សូមធ្វើឱ្យកូនចៅរបស់អ្នកចូលរួមនៅក្នុងការអធិស្ឋានផ្ទាល់ខ្លួន និងការអធិស្ឋានជាគ្រួសារ ហើយរីករាយនៅក្នុងពាក្យសម្តីដ៏ផ្អែមល្ហែមរបស់ពួកគេទៅកាន់ព្រះវរបិតាគង់នៅស្ថានសួគិ។

ចូរធ្វើរាត្រីជួបជុំក្រុមគ្រួសារប្រចាំសប្តាហ៍។ ទីប្រាំ សូមញែកពេលដើម្បីធ្វើរាត្រីជួបជុំក្រុមគ្រួសារប្រចាំសប្តាហ៍។ ដោយមានអធិបតីភាពពីស្វាមីរបស់អ្នករាល់គ្នា សូមចូលរួមនៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ដែលមានការលើកដំកើងខាងវិញ្ញាណជារៀងរាល់សប្តាហ៍។ សូមធ្វើឱ្យកូនចៅរបស់អ្នក មានការចូលរួមយ៉ាងសកម្មនៅក្នុងកម្មវិធីនេះ។ សូមបង្រៀនពួកគេអំពីគោលការណ៍ដ៏ត្រឹមត្រូវ។ សូមធ្វើឱ្យកម្មវិធីនេះក្លាយទៅជាប្រពៃណីដ៏មហិមាមួយប្រចាំគ្រួសាររបស់អ្នក។ សូមចងចាំចំពោះការសន្យាដ៏អស្ចារ្យ ដែលបានធ្វើឡើងដោយប្រធាន យ៉ូសែប អែហ្ទ ស្មីធ នៅពេលរាត្រីជួបជុំក្រុមគ្រួសារ ត្រូវបានគេណែនាំជាលើកដំបូងទៅកាន់សាសនាចក្រថា ៖ "បើសិនជាពួកបរិសុទ្ធគោរពប្រណិបត្តិតាមពាក្យទូន្មាននេះ យើងសូមសន្យាថាពរជ័យដ៏មហិមានឹងកើតមានឡើង។ សេចក្តីស្រឡាញ់នៅក្នុងផ្ទះ និងការគោរពប្រណិបត្តិចំពោះឱពុកម្តាយនឹងមានការកើនឡើង។ សេចក្តីជំនឿ នឹងត្រូវបានបណ្តុះកាន់តែខ្លាំងឡើងនៅក្នុងដួងចិត្តរបស់យុវវ័យនៃអ៊ីស្រាអែល ហើយពួកគេនឹងទទួលបានទូវអំណាច ដើម្បីប្រយុទ្ធប្រឆាំងនឹងឥទ្ធិពលអាក្រក់ និងការល្បួងទាំងឡាយដែលចោមវាយប្រហារពួកគេ" (នៅក្នុងការរៀបរៀងរបស់ James R. Clark *Messages of the First Presidency of The Church of Jesus Christ of Latter-day Saints* រ៉ុលទី 6 [ឆ្នាំ 1965–75], 4:339)។ ការសន្យាដ៏អស្ចារ្យនេះនៅតែមានឥទ្ធិពលរហូតដល់សព្វថ្ងៃនេះ។

ចូរបរិភោគអាហារជុំគ្នា។ ទីប្រាំមួយ សូមញែកពេលដើម្បីមានការបរិភោគអាហារជុំគ្នាឱ្យបានញឹកញាប់។ នេះគឺជាការលំបាកមួយនៅពេលកូនចៅធំដឹងក្តីហើយនិងនៅពេលជីវិតមានភាពមមាញឹកនោះ។ ប៉ុន្តែការសន្ទនាដ៏រីករាយ ការចែកចាយផែនការ និងសកម្មភាពប្រចាំថ្ងៃ ព្រមទាំងឱកាសបង្រៀនដ៏ពិសេសអាចកើតឡើងនៅពេលបរិភោគអាហារ ដោយសារឱពុកម្តាយព្រមទាំងកូនៗសហការគ្នា។

ចូរអានព្រះគម្ពីរជារៀងរាល់ថ្ងៃ។ ទីប្រាំពីរ សូមញែកពេលដើម្បីអានព្រះគម្ពីររួមគ្នាជាគ្រួសារ។ ការអានព្រះគម្ពីរផ្ទាល់ខ្លួនគឺមានសារះសំខាន់ខ្លាំងណាស់ ប៉ុន្តែការអានព្រះគម្ពីរជាគ្រួសារគឺរឹតតែសំខាន់ជាងនេះទៅទៀត។ ការអានព្រះគម្ពីរមរមនរួមគ្នាជាគ្រួសារនឹងនាំមកនូវការកើនឡើងខាងវិញ្ញាណនៅក្នុងគេហដ្ឋានរបស់អ្នក ហើយវានឹងផ្តល់ឱ្យទាំងឱពុកម្តាយ និងកូនទូវអំណាចការពារប្រឆាំងនឹងការល្បួងទាំងឡាយ ហើយនឹងមានព្រះវិញ្ញាណបរិសុទ្ធធ្វើជាដៃគូរបស់ពួកគេជាប់ជានិច្ច។ ខ្ញុំសូមសន្យានឹងអ្នករាល់គ្នាថា ព្រះគម្ពីរមរមនឹងផ្លាស់ប្តូរជីវិតក្រុមគ្រួសាររបស់អ្នក។

ចូរធ្វើកិច្ចការជាគ្រួសារ។ ទីក្រុងបី សូមញែកពេលដើម្បីធ្វើកិច្ចការរួមគ្នាជាគ្រួសារ។ សូមបង្កើតការដើរលេងជាគ្រួសារ និងពិធីអបអរខួបកំណើត ព្រមទាំងការធ្វើដំណើរកំសាន្តសំរាប់ឱកាសពិសេស និងដើម្បីបង្កើតនូវអនុស្សាវរីយ៍។ នៅពេលណាមួយដែលអាចធ្វើបាន សូមចូលរួមជាគ្រួសារក្នុងព្រឹត្តិការណ៍សំខាន់ៗ ដែលមានសមាជិកគ្រួសារម្នាក់កំពុងចូលរួមនៅក្នុងកម្មវិធីនោះ ដូចជា ការសម្តែងប្រចាំសាលា ការប្រកួតកីឡា ការឡើងនិយាយ ការសម្តែងសិល្បៈ ជាដើម។ សូមចូលរួមនៅក្នុងការប្រជុំរបស់ព្រះវិហារ ហើយអង្គុយរួមគ្នាជាគ្រួសារ នៅពេលអ្នករាល់គ្នាអាចធ្វើបាន។ អ្នកម្តាយទាំងឡាយដែលជួយក្រុមគ្រួសារឱ្យរឹងមាំស្ថាន ហើយធ្វើការរួមគ្នានឹងរួមរស់ជាមួយគ្នា ហើយវានឹងប្រទានពរដល់ជីវិតកូនចៅជារៀងរហូត។

ចូរបង្រៀនដល់កូនចៅរបស់អ្នក។ ទីក្រុងបួន អ្នកម្តាយទាំងឡាយ សូមញែកពេលបង្រៀនដល់កូនចៅរបស់អ្នក។ សូមក្តាប់យកឱកាសនៃការបង្រៀន។ កិច្ចការនេះអាចធ្វើទៅបាននៅគ្រប់ពេលទាំងអស់—ដូចជា នៅពេលបរិភោគអាហារ នៅក្នុងមជ្ឈដ្ឋានសាមញ្ញមួយ ឬនៅពេលអង្គុយជុំគ្នាដ៏ពិសេស នៅពេលចូលសំរាក ឬនៅពេលដើរលំហែជាមួយគ្នានៅពេលព្រឹក។ អ្នកម្តាយទាំងឡាយអើយ អ្នករាល់គ្នាគឺជាគ្រូបង្រៀនដ៏ល្អបំផុតរបស់កូនអ្នក។ សូមកុំផ្លាស់ប្តូរការទទួលខុសត្រូវដ៏មានតម្លៃចំពោះការមើលថែ និងបង្ហាត់បង្រៀនដល់កូនចៅនេះឡើយ។ សេចក្តីស្រឡាញ់ និងកង្វល់ដែលពោរពេញដោយការអធិស្ឋានរបស់ម្តាយមួយរូប សំរាប់កូនរបស់ខ្លួនគឺជាគ្រឿងយ៉ាំដ៏សំខាន់បំផុតរបស់ទាង នៅក្នុងការបង្រៀនកូនចៅ។

សូមបង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អដល់កូនចៅ។ សូមបង្រៀនពួកគេថា គោលការណ៍ទាំងនេះនឹងតបស្នងមកវិញនូវសេចក្តីល្អ។ សូមបង្រៀនពួកគេថា អំពើបាបនឹងពុំទាំមកនូវសេចក្តីសុខនោះឡើយ។ សូមបង្រៀនពួកគេអំពីសេចក្តីស្រឡាញ់ចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និងអំពីទីបន្ទាល់នៃទេវភាពរបស់ដំណឹងល្អ។

សូមបង្រៀនដល់បុត្រាបុត្រីរបស់អ្នកអំពីភាពរមទម្ង ហើយបង្រៀនពួកគេឱ្យគោរពសិទ្ធិបុរស និងសិទ្ធិស្ត្រី។ សូមបង្រៀនកូនចៅរបស់អ្នកអំពីភាពបរិសុទ្ធខាងផ្លូវភេទ បទដ្ឋាននៃការដើរលេងជាគូដ៏ត្រឹមត្រូវ អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ ការបំរើជាអ្នកផ្សព្វផ្សាយសាសនា និងសារៈសំខាន់នៃការទទួលយក និងការលើកដំកើងការហៅរបស់សាសនាចក្រ។

សូមបង្រៀនពួកគេអំពីសេចក្តីស្រឡាញ់ចំពោះការងារ និងតម្លៃនៃការអប់រំដ៏ល្អ។

សូមបង្រៀនពួកគេអំពីសារៈសំខាន់នៃប្រភេទការកំសាន្តដ៏ត្រឹមត្រូវ រួមមានខ្សែភាពយន្ត តន្ត្រី ស្បែរភេរ៉ា និងទស្សនាវដ្តីសមរម្យ។ សូមពិភាក្សាអំពីរឿងអាក្រក់នៃរូបអាសគ្រាម និងថ្នាំញៀន ហើយបង្រៀនដល់ពួកគេអំពីតម្លៃនៃការរស់នៅក្នុងជីវិតដែលស្រស់ស្អាត។

ពិតប្រាកដណាស់ អ្នកម្តាយទាំងឡាយ សូមបង្រៀនកូនចៅរបស់អ្នកអំពីដំណឹងល្អនៅក្នុងគេហដ្ឋានរបស់អ្នកផ្ទាល់ នៅឯការប្រជុំពិសេសរបស់អ្នក។ នេះគឺជាការបង្រៀនដ៏មានប្រសិទ្ធភាពបំផុតមួយ ដែលកូនចៅរបស់អ្នកនឹងមិនធ្លាប់មានពីមុនមកទេ។ នេះគឺជារបៀបនៃការបង្រៀនរបស់ព្រះអម្ចាស់។ សាសនាចក្រមិនអាចបង្រៀនដល់ពួកគេ ដូចជាអ្នករាល់គ្នាបានឡើយ។ សាលារៀនក៏មិនអាចបង្រៀនពួកគេឱ្យដូចគ្នានេះបានដែរ។ មជ្ឈមណ្ឌលមើលថែកុមារក៏មិនអាចធ្វើកិច្ចការនេះបានដែរ។ ប៉ុន្តែអ្នករាល់គ្នាអាចធ្វើបាន ហើយព្រះអម្ចាស់នឹងគាំទ្រដល់អ្នករាល់គ្នា។ កូនចៅរបស់អ្នកនឹងចងចាំការបង្រៀនរបស់អ្នកជារៀងរហូត ហើយនៅពេលពួកគេចំរើនវ័យឡើង នោះការបង្រៀនទាំងនេះនឹងមិនចាកឆ្ងាយពីពួកគេឡើយ។ ពួកគេនឹងរាប់អ្នកថាជាពរជ័យ—ថាអ្នករាល់គ្នាពិតជាទេពអប្សររបស់ពួកគេពិតមែន។

អ្នកម្តាយទាំងឡាយអើយ ការបង្រៀនមកពីស្ថានសួគ៌ និងការបង្រៀនដោយម្តាយនេះគឺត្រូវការពេលវេលា—គឺជាពេលវេលាដ៏យូរអង្វែង។ ការបង្រៀននេះមិនអាចសំរេចទៅបានដោយមានប្រសិទ្ធភាព ដោយគ្រាន់តែប្រើពេលវេលាតែបន្តិចបន្តួចប៉ុណ្ណោះនោះឡើយ។ កិច្ចការនេះត្រូវធ្វើឡើងគ្រប់ពេលវេលាទាំងអស់ ដើម្បីទទួលបានសេចក្តីសង្គ្រោះ និងលើកដំកើងកូនចៅរបស់អ្នកនោះ។ កិច្ចការនេះគឺជាតួនាទីដ៏ទេវភាពរបស់អ្នករាល់គ្នា។

ចូរស្រាលាញ់កូនចៅរបស់អ្នកដោយសុទ្ធចិត្ត។ ចំណុចទីដប់ ហើយក៏ជាចំណុចចុងក្រោយផងដែរ គឺថាអ្នកម្តាយទាំងឡាយ សូមញែកពេលដើម្បីស្រឡាញ់កូនចៅរបស់អ្នកដោយសុទ្ធចិត្ត។ សេចក្តីស្រឡាញ់ដែលពុំមានការបង្ហាត់បង្រៀនរបស់ម្តាយមួយរូប អាចទាំទៅរកសេចក្តីស្រឡាញ់ដែលមានលក្ខណៈដូចជាព្រះគ្រីស្ទ។

នេះគឺជាការគោតសរសើរដ៏ប្រពៃមួយរបស់កូនប្រុសម្នាក់ចំពោះម្តាយរបស់ខ្លួនថា ៖ “ខ្ញុំមិនបានចងចាំអ្វីច្រើនអំពីទស្សនៈនៃការជ្រើសរើសរបស់គាត់ ឬក៏ស្ថានភាពសង្គមរបស់គាត់ និងគំនិតរបស់គាត់អំពីការបង្ហាត់បង្រៀនកូន របបអាហារ និងវិធីសាស្ត្រចិញ្ចឹមកូនរបស់គាត់នោះទេ ខ្ញុំមិនអាចចងចាំបានឡើយ។ នៅពេលនេះរឿងដ៏សំខាន់ដែលធ្វើឱ្យខ្ញុំនឹកឃើញកាលពីនៅតូចនោះគឺថា គាត់ស្រឡាញ់ខ្ញុំ។ គាត់ចូលចិត្តសំរាកនៅលើស្មៅជាមួយខ្ញុំ ហើយនិទានរឿង ឬលេងល្បែងចិទ្ធពួនជាមួយនឹងពួកយើង។ គាត់តែងតែឱបក្រសោបខ្ញុំ។ ហើយខ្ញុំចូលចិត្តទង្ហើររបស់គាត់បែបនោះខ្លាំងណាស់។ ផ្ទៃមុខរបស់គាត់បង្កប់ទៅដោយស្នាមញញឹម។ ចំពោះខ្ញុំទង្ហើរនេះប្រៀបបានដូចព្រះ ហើយនឹងពួកបរិសុទ្ធនៅឯស្ថានសួគ៌ដែលនិទានរឿងអំពីទ្រង់។ ហើយច្រៀង! រាល់អារម្មណ៍រីករាយដែលមាននៅក្នុងជីវិតរបស់ខ្ញុំ គ្មានអារម្មណ៍ណាមួយអាចប្រៀបផ្ទឹមនឹងសេចក្តីអំណរ នៃការរារាគោងឡើងទៅលើភ្លៅរបស់គាត់ ហើយក៏គេងលក់ទៅនោះឡើយ ខណៈដែលគាត់ច្រៀងនៅក្នុងកោអ៊ីរយោលរបស់គាត់ ហើយយោលវាទៅវិញទៅមក។ ដោយគិតអំពីរឿងនេះ ខ្ញុំចង់ដឹងថា នៅក្នុងការបង្ហាត់បង្រៀនកូនចៅរបស់ខ្លួននៅពេលមានទុក្ខ តើស្ត្រីនៅបច្ចុប្បន្ននេះ ជាមួយនឹងគំនិត និងផែនការដ៏ប្រពៃរបស់ខ្លួន បានយល់អំពីអ្វីដែលជាកត្តាដ៏មិហាមាមួយដែលពួកគាត់មានដែរឬទេ។ ខ្ញុំចង់ដឹងថាតើគាត់បានដឹងអំពីទំហំនៃសេចក្តីស្រឡាញ់ និងការយល់ចិត្តដែលដក់ជាប់នៅក្នុងជីវិតរបស់កូនម្នាក់ដែរឬទេ”។

អ្នកម្តាយទាំងឡាយអើយ កូនវ័យដំទង់របស់អ្នកត្រូវការនូវសេចក្តីស្រឡាញ់ និងការយល់ចិត្តដូចគ្នានោះផងដែរ។ វាហាក់ដូចជាមានភាពងាយស្រួលជាងចំពោះឪពុកម្តាយជាច្រើនក្នុងការសម្តែងចេញនូវអារម្មណ៍ និងសេចក្តីស្រឡាញ់របស់ខ្លួនទៅកាន់កូន នៅពេលពួកគេនៅជាកុមារភាព ប៉ុន្តែវាមានការលំបាកយ៉ាងខ្លាំង នៅពេលពួកគេមានវ័យធំឡើង។ សូមធ្វើកិច្ចការនេះប្រកបដោយការអធិស្ឋាន។ សូមកុំឱ្យមានការប្រៀបធៀប អំពីភាពខុសគ្នារវាងជំនាន់របស់មនុស្សចាស់ និងមនុស្សវ័យក្មេងនោះឡើយ។ ហើយអ្វីដែលចំណុចដ៏សំខាន់នោះ គឺជាសេចក្តីស្រឡាញ់។ យុវវ័យរបស់យើងត្រូវការសេចក្តីស្រឡាញ់ និងការយល់ចិត្ត ពុំមែនជាការបង្ខិតបង្ខំនោះឡើយ។ ពួកគេត្រូវការភាពយោគយល់ និងការយល់ដឹង ពុំមែនជាការខ្វះការយកចិត្តទុកដាក់ពីសំណាក់ឪពុកម្តាយនោះឡើយ។ ពួកគេត្រូវការពេលវេលារបស់ឪពុកម្តាយ។ ការបង្រៀនដែលមានសណ្ឋានចិត្តរបស់ម្តាយមួយរូប ព្រមជាមួយនឹងសេចក្តីស្រឡាញ់ និងទំនុកចិត្តរបស់ទាងចំពោះកូនប្រុសស្រីវ័យដំទង់ អាចជួយសង្គ្រោះពួកគេចេញពីពិភពលោកដ៏ទុច្ចរិតយ៉ាងពិតប្រាកដ។

ដកស្រង់ចេញមកពីសុន្ទរកថារបស់ប្រធាន ប៊ែនសឺន នៅឯការប្រជុំពិសេសមួយសំរាប់ឪពុកម្តាយ នាថ្ងៃទី 22 ខែ កុម្ភៈ ឆ្នាំ 1987។

ការបង្រៀនកូនចៅតាមរយៈគំរូ និងការណែនាំ

12

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលៈទេសៈរបស់អ្នកផ្ទាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- សូមពិចារណាអំពីសេចក្តីត្រូវការរបស់កូនអ្នក ឬសេចក្តីត្រូវការនៃចៅ ក្មួយ ប្រុសស្រីរបស់អ្នក ឬកុមារដទៃទៀតដែលអ្នកស្គាល់។ សូមធ្វើផែនការ ដើម្បីស្វែងរកឱកាសបង្រៀនកុមារទាំងនេះ តាមរយៈសកម្មភាព និងពាក្យសម្តីរបស់អ្នក។
- សូមមើលឡើងវិញនូវសម្ភារៈស្តីអំពីការបង្រៀននៅក្នុងគ្រួសារដែលមាននៅក្នុង *Teaching, No Greater Call* (36123) ទំព័រ 127–43 និង *ស្ត្រីរៀបណែនាំក្នុងគ្រួសារ* (31180) ទំព័រ 5–12 ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាសម្ភារៈនេះជាមួយនឹងស្វាមី ឬភរិយារបស់អ្នក។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

ឧបសគ្គដ៏ធំជាងគេបំផុតនៅក្នុងពិភពលោកនេះ—គឺការធ្វើជាឪពុកម្តាយដ៏ល្អ

រ៉ែលឌើរ ជែមស៍ អ៊ី ហ្វោស្ត
នៃក្រុមនៃពួកសាវក 12 ទាក់

ការធ្វើជាឪពុកម្តាយគឺជាការហៅដ៏ទេវភាព

ខ្ញុំមានអារម្មណ៍រំភើបខ្លាំងណាស់ចំពោះការពិភាក្សាអំពីប្រធានបទមួយ ដែលខ្ញុំបានជ្រើសរើសដើម្បីរៀបរាប់ អំពីឧបសគ្គដ៏ធំជាងគេបំផុតនៅក្នុងពិភពលោកនេះ។ ការធ្វើជាឪពុកម្តាយដ៏ល្អតែងតែមានមកជាមួយនូវឱកាស និងការទទួលខុសត្រូវ។ ចំពោះប្រធានបទនេះ មានទស្សនៈជាច្រើនកើតមានឡើងមកពីសំណាក់ឪពុកម្តាយ ប៉ុន្តែមានតែមនុស្សមួយចំនួនប៉ុណ្ណោះដែលប្រកាសថា ពួកគេមានទូវរាល់ចម្លើយទាំងអស់។ ខ្ញុំដឹងខ្លួនឯងច្បាស់ថា ខ្ញុំពុំមែនជាមនុស្សម្នាក់ក្នុងចំណោមនោះឡើយ។

ខ្ញុំបានទទួលអារម្មណ៍ថា មានយុវជនយុវនារីដ៏ឆ្មើមជាច្រើន នៅក្នុងចំណោមសមាជិករបស់យើងនាពេលបច្ចុប្បន្ននេះ ជាងពេលណាៗទាំងអស់នៅក្នុងឆាកជីវិតរបស់ខ្ញុំ។ ព្រឹត្តិការណ៍នេះបានសបញ្ជាក់ឱ្យឃើញថា យុវវ័យដ៏ឆ្មើមទាំងនេះ ត្រូវបានគេបណ្តុះបណ្តាលចេញមកពីគេហដ្ឋានដ៏ល្អ ហើយមានឪពុកម្តាយដែលមានការប្តេជ្ញាចិត្ត និងនៅមើលថែទាំ។ ទោះជាយ៉ាងក៏ដោយ ក៏ឪពុកម្តាយដែលមានការយកចិត្តទុកដាក់ភាគច្រើនមានអារម្មណ៍ថា ពួកគាត់នៅតែមានកំហុសមួយចំនួន។ នៅគ្រាមួយ ខ្ញុំបានធ្វើរឿងមួយដោយមិនបានគិតគូរវែងឆ្ងាយ ពេលនោះម្តាយរបស់ខ្ញុំបានស្រែកឡើងថា “តើម៉ាក់បានធ្វើអ្វីខុសខ្លះទៅ?”

ព្រះអម្ចាស់បានណែនាំថា “ចិញ្ចឹមកូនចៅរបស់ខ្លួននៅក្នុងពន្លឺ និងសេចក្តីពិត” (ត. និង ស. 93:40)។ ចំពោះរូបខ្ញុំ គ្មានកិច្ចការរបស់មនុស្សលោកណាមួយដែលមានសារៈសំខាន់ជាងកិច្ចការនេះទៀតឡើយ។

ការធ្វើជាឪពុក ឬម្តាយមួយរូបពុំមែនគ្រាន់តែជាឧបសគ្គមួយប៉ុណ្ណោះនោះទេ ប៉ុន្តែវាក៏ជាការហៅដ៏ទេវភាពផងដែរ។ វាគឺជាកិច្ចការមួយដែលតំរូវឱ្យមានការលះបង់។ ប្រធាន ដាវីឌ អូ មិកឃៃ បានលើកឡើងថា ការធ្វើជាឪពុកម្តាយគឺជា “ទំនុកចិត្តដ៏ធំជាងគេបង្អស់ដែលត្រូវបានប្រទានឱ្យដល់មនុស្សលោកគ្រប់រូប” (*The Responsibility of Parents to Their Children* [កូនស្ត្រីរៀវភៅ n.d.] ទំព័រ 1)។

ការបង្កើតគេហដ្ឋានដែលពោរពេញដោយសុភមង្គល

ខណៈដែលឧបសគ្គរបស់មនុស្សមួយចំនួន មានលក្ខណៈធំធេងជាងការធ្វើជាឪពុកម្តាយដ៏ល្អ នោះក៏មានឱកាសមួយចំនួន ទឹងត្រូវបានប្រទានឱ្យសំរាប់សេចក្តីអំណរដ៏ធំធេងផងដែរ។ ពិតប្រាកដណាស់ គ្មានកិច្ចការណាមួយនៅក្នុងពិភពលោកនេះ ដែលសំខាន់ជាងការរៀបចំកូនចៅរបស់យើងឱ្យចេះកោតខ្លាចដល់ព្រះ ឱ្យមានភាពរីករាយ ការគោរព និងមានសមត្ថភាពនោះឡើយ។ ឪពុកម្តាយគ្រប់រូបទឹងរកឃើញថា គ្មានកិច្ចការណាមួយដែលពោរពេញទៅដោយសុភមង្គលជាងការធ្វើឱ្យកូនចៅរបស់ខ្លួនមានការគោរពដល់ពួកគេ និងការបង្រៀនរបស់ពួកគេនោះឡើយ។ វាគឺជាសិរីល្អនៃភាពជាឪពុកម្តាយ។ យ៉ូហានបានធ្វើទីបន្ទាល់ថា “គ្មានសេចក្តីណាដែលទាំឱ្យខ្ញុំអរសប្បាយ លើសជាងសេចក្តីនេះទេ គឺដែលឮនិយាយថា ពួកកូនខ្ញុំកំពុងតែប្រព្រឹត្តតាមសេចក្តីពិតនោះឯង” (យ៉ូហានទី 3 1:4)។ នៅក្នុងទស្សនៈរបស់ខ្ញុំ ការបង្រៀន ការចិញ្ចឹមបីបាច់ និងការបង្ហាត់បង្រៀនដល់កូនចៅតំរូវឱ្យមានភាពឈ្លាសវៃ ការយល់ចិត្ត សេចក្តីបន្ទាបខ្លួន កម្លាំងពលំ ព្រាជ្ញា ជីវភាពខាងផ្លូវវិញ្ញាណ និងការខិតខំ ដែលវាមានតំរូវការច្រើនជាងឧបសគ្គដទៃផ្សេងទៀត ដែលយើងអាចជួបប្រទះនៅក្នុងជីវិតនេះ។ ជាពិសេសកិច្ចការនេះកាន់តែលំបាកថែមទៀត នៅពេលគ្រិះសីលធម៌ស្តីអំពីការគោរព និងសុភវធម៌នៅជុំវិញខ្លួនយើងកំពុងត្រូវបានបំផ្លិចបំផ្លាញ។ ដើម្បីមានគេហដ្ឋានដែលពោរពេញដោយសុភមង្គល នោះតម្លៃផ្សេងៗត្រូវតែបានគេបង្រៀន ហើយនៅទីនោះឯងត្រូវមានច្បាប់ទម្លាប់ ត្រូវមានបទដ្ឋាន និងត្រូវមានភាពពេញលេញ។ សង្គមជាច្រើនបានផ្តល់ដល់ឪពុកម្តាយនូវការគាំទ្រតិចតួចបំផុត នៅក្នុងការបង្រៀន និងការគោរពតម្លៃខាងសីលធម៌។ ប្រពៃណីមួយចំនួនកំពុងប្រែក្លាយទៅជាគ្មានតម្លៃ ហើយយុវវ័យជាច្រើននៅក្នុងសង្គមទាំងនោះ កំពុងប្រែក្លាយខ្លួនទៅជាអ្នកសើចចំអកដល់តម្លៃខាងសីលធម៌។

ដរាបណាសង្គមទាំងមូលបានបាត់បង់នូវអត្តសញ្ញាណខាងសីលធម៌របស់ខ្លួន នោះក្រុមគ្រួសារជាច្រើនទឹងមានការបែកបាក់គ្នា ដូច្នេះសេចក្តីសង្ឃឹមដ៏ល្អបំផុត

គឺត្រូវងាកទៅរកការយកចិត្តទុកដាក់ និងកិច្ចខិតខំដ៏ធំធេងនៅក្នុងការបង្រៀនកូនចៅយើង—ដែលជាមនុស្សជំនាន់ក្រោយ។ ដើម្បីធ្វើកិច្ចការទាំងនេះបាន ជាដំបូងយើងត្រូវពង្រឹងឡើងវិញ ចំពោះពួកត្រូបង្រៀនក្នុងថ្នាក់កុមារ។ អ្នកដឹកនាំនៅក្នុងចំណោមពួកត្រូបង្រៀនទាំងនេះ គឺជាឱពុកម្តាយ និងសមាជិកត្រួសារដទៃទៀត ព្រមទាំងការមានបរិយាកាសដ៏ល្អបំផុតមួយនៅក្នុងគេហដ្ឋាន។ ជាងនេះទៅទៀត យើងត្រូវតែព្យាយាមឱ្យបានខ្លាំងឡើងថែមទៀត នៅក្នុងការធ្វើឱ្យគេហដ្ឋានរបស់យើងមានភាពរឹងមាំ ដើម្បីឱ្យគេហដ្ឋានរបស់យើងអាចឈរជាទីជំរកប្រឆាំងនឹងរឿងអាក្រក់ និងឥទ្ធិពលដែលបំផ្លិចបំផ្លាញសីលធម៌សង្គមនៅជុំវិញយើង។ ភាពសុខដុមសុភមង្គល សេចក្តីសុខសាន្ត និងសេចក្តីស្រឡាញ់នៅក្នុងគេហដ្ឋានអាចជួយផ្តល់ដល់កូនៗទាំងនោះ នូវកម្លាំងនៅខាងក្នុងដែលតំរូវឱ្យមាន ដើម្បីការពារនឹងឧបសគ្គនៃឆាកជីវិត។ លោកស្រី បាបារ៉ា ប៊ុស ជាភរិយានៃប្រធានាធិបតី [សហរដ្ឋអាមេរិក] លោក ចច ប៊ុស កាលពីប៉ុន្មានខែកន្លងទៅនេះ បានមានប្រសាសន៍ទៅកាន់ពួកនិស្សិត ដែលបញ្ចប់សិក្សានៅឯសាកលវិទ្យា រ៉ៃឡេស្លី ថា ៖

“ទោះបីជាស្ថិតនៅក្នុងវ័យ ឬពេលវេលាណាមួយក៏ដោយ វានឹងមានទូវរឿងមួយដែលអាចផ្លាស់ប្តូរ នោះគឺ ៖ ឱពុកម្តាយទាំងឡាយ ប្រសិនបើអ្នករាល់គ្នាមានកូន នោះពួកគេគឺជាមនុស្សដ៏សំខាន់បំផុតរបស់អ្នក។ អ្នករាល់គ្នាត្រូវអានស្យេវភៅឱ្យកូនរបស់អ្នកស្តាប់ ហើយអ្នករាល់គ្នាត្រូវឱបក្រសោបកូនរបស់អ្នក ព្រមទាំងផ្តល់សេចក្តីស្រឡាញ់ដល់ពួកគេផងដែរ។ ជោគជ័យរបស់អ្នករាល់គ្នានៅក្នុងគ្រួសារ និងជោគជ័យរបស់យើងនៅក្នុងសង្គម គឺពុំមែនពឹងផ្អែកទៅលើអ្វីដែលកើតឡើងនៅក្នុងសេតវិមាននោះទេ ប៉ុន្តែវាអាស្រ័យទៅលើអ្វីដែលកើតឡើងនៅក្នុងគេហដ្ឋានរបស់អ្នករាល់គ្នា” (*Washington Post* ថ្ងៃទី 2 ខែ មិថុនា ឆ្នាំ 1990 ទំព័រ 2)។

ដើម្បីធ្វើជាឱពុកម្តាយដ៏ល្អមួយរូប គឺវាតំរូវឱ្យឱពុកម្តាយលះបង់នូវសេចក្តីត្រូវការ និងបំណងប្រាថ្នាផ្ទាល់ខ្លួន នៅក្នុងការបំពេញនូវសេចក្តីត្រូវការរបស់កូនចៅខ្លួន។ ជាលទ្ធផលនៃការលះបង់នេះ ឱពុកម្តាយដែលមានការព្យាយាមនឹងអភិវឌ្ឍនូវអាកប្បកិរិយាដ៏ថ្លៃថ្នូរ ហើយរៀនអនុវត្តនូវសេចក្តីពិតស្តីអំពីភាពមិនអត្មានិយម ដែលបានបង្រៀនដោយព្រះអង្គសង្គ្រោះ។

ខ្ញុំមានសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតចំពោះឱពុក ឬម្តាយទោល ដែលបានជួបនឹងឧបសគ្គផ្សេងៗ ហើយបានលះបង់ដោយព្យាយមសំរាប់ឱកាសដ៏វិសេសវិសាល ដើម្បីធ្វើឱ្យក្រុមគ្រួសារបានរួមរស់ជាមួយគ្នា។ ពួកគាត់គប្បីទទួលនូវការគោរព និងជំនួយនៅក្នុងកិច្ចខិតខំដ៏អស្ចារ្យរបស់ពួកគាត់។ ប៉ុន្តែរាល់កិច្ចការរបស់ឱពុកម្តាយកាន់តែមានភាពងាយស្រួល នៅពេលមានវត្តមានរបស់ឱពុកម្តាយនៅក្នុងគេហដ្ឋាន។ ជាញឹកញាប់ កូនៗបង្កនូវផលវិបាក ហើយដកយកនូវកម្លាំង និងប្រាជ្ញារបស់ឱពុកម្តាយ។

ជាញឹកញាប់ តើអ្នកធ្វើការអធិស្ឋានជាគ្រួសារប៉ុន្មានដង?

កាលពីប៉ុន្មានឆ្នាំមុន ប៊ីស្សព ស្តេនលី ស្មូត ត្រូវបានជួបសម្ភាសន៍ជាមួយនឹងប្រធាន ស្តែនស៊ើរ ដបុលយូ ឃឹមបឹល។ ប្រធាន ស្តែនស៊ើរ ដបុលយូ ឃឹមបឹល បានសួរដល់លោកថា “តើជាញឹកញាប់អ្នកធ្វើការអធិស្ឋានជាគ្រួសារប៉ុន្មានដង?”

ប៊ីស្សព ស្មូត បានឆ្លើយតបថា “យើងបានព្យាយាមធ្វើការអធិស្ឋានជាគ្រួសារពីរដងក្នុងមួយថ្ងៃ ប៉ុន្តែជាមធ្យមយើងធ្វើវាតែម្តងប៉ុណ្ណោះក្នុងមួយថ្ងៃ”។

ប្រធាន ឃឹមបឹល បានមានប្រសាសន៍ថា “កាលពីមុន ការធ្វើការអធិស្ឋានជាគ្រួសារម្តងក្នុងមួយថ្ងៃគឺរឿងដែលអាចទទួលយកបាន។ ប៉ុន្តែនាពេលអនាគតកាណ៍នេះ គឺពុំល្មមគប់គ្រន់ឡើយ បើយើងចង់សង្គ្រោះដល់ក្រុមគ្រួសាររបស់យើងនោះ”។

ខ្ញុំចង់ដឹងថា តើការមានរាត្រីជួបជុំក្រុមគ្រួសារដ៏សាមញ្ញ ហើយមិនសូវបានធ្វើជាញឹកញាប់នោះ វានឹងល្មមគ្រប់គ្រាន់សំរាប់នាពេលអនាគត ដើម្បពង្រឹងដល់កូនចៅរបស់យើងជាមួយនឹងកម្លាំងខាងសីលធម៌ដែរឬទេ។ នាពេលអានាគត ការសិក្សាព្រះគម្ពីរជាគ្រួសារដែលបានធ្វើឡើងយូរៗម្តងនោះ គឺវាមិនល្មមគ្រប់គ្រាន់ ដើម្បីការពារកូនចៅរបស់យើងជាមួយនឹងភាពចាំបាច់ខាងគុណធម៌ នៅក្នុងការតស៊ូនឹងការបំផ្លិចបំផ្លាញខាងសីលធម៌ក្នុងមុជ្ឈដ្ឋាន ដែលពួកគេនឹងរស់នៅនោះទេ។ នៅក្នុងពិភពលោកនេះ តើកុមារទាំងឡាយអាចរៀនសូត្រអំពីព្រហ្មចារីយភាព សេចក្តីទៀងត្រង់ សេចក្តីស្មោះត្រង់ និងសុភាវធម៌របស់មនុស្សនៅទីកន្លែងណាក្រៅពីនៅក្នុងគេហដ្ឋាននោះ? ពិតប្រាកដណាស់ រឿងសំខាន់ទាំងនេះ នឹងត្រូវបានពង្រឹងឡើងវិញនៅក្នុងព្រះវិហារ ប៉ុន្តែការបង្រៀនរបស់ឱពុកម្តាយគឺមានសារះសំខាន់បំផុត។

ឱពុកម្តាយត្រូវធ្វើជាគំរូ

នៅពេលឱពុកម្តាយព្យាយាមបង្រៀនកូនចៅរបស់ខ្លួនឱ្យជៀសវាងនូវរឿងអាក្រក់ នោះវានឹងពុំបាច់ឱ្យឱពុកម្តាយត្រូវនិយាយទៅកាន់កូនចៅរបស់ខ្លួននូវពាក្យទាំងនេះថា “ប៉ាម៉ាក់ឆ្លងកាត់ពិភពលោកនេះច្រើនជាងកូន ហើយប៉ាម៉ាក់ក៏ដឹងអំពីរឿងរ៉ាវនៅក្នុងពិភពលោកនេះច្រើនជាងកូនផងដែរ”។ ការលាក់ពុតរបស់ឱពុកម្តាយអាចធ្វើឱ្យកូនៗសើចចំអក ហើយមិនជឿនូវអ្វីដែលពួកគេបានបង្រៀននៅក្នុងគេហដ្ឋានឡើយ។ ឧទាហរណ៍ នៅពេលឱពុកម្តាយមើលខ្សែភាពយន្ត ពួកគេបានហាមយាត់មិនឱ្យកូនចៅរបស់ពួកគេមើល នោះសេចក្តីជឿជាក់ចំពោះឱពុកម្តាយត្រូវបានកាត់បន្ថយ។ បើសិនជាកូនចៅរំពឹងទុកឱ្យមានទូវសេចក្តីស្មោះត្រង់ នោះឱពុកម្តាយត្រូវតែមានទូវសេចក្តីស្មោះត្រង់ជាមុន។ បើសិនជាកូនរំពឹងទុកឱ្យមានគុណធម៌ នោះឱពុកម្តាយត្រូវតែមានទូវគុណធម៌ជាមុន។ បើសិនជាអ្នករាល់គ្នាចង់ឱ្យកូនចៅរបស់អ្នកមានទូវការគោរព នោះអ្នករាល់គ្នាក៏ត្រូវតែមានទូវការគោរពផងដែរ”។

នៅក្នុងចំណោមរឿងសំខាន់ៗដទៃទៀតដែលកុមារទាំងឡាយ គប្បីត្រូវបានគេបង្រៀននោះគឺ ការគោរពចំពោះអ្នកដទៃ ដោយចាប់ផ្តើមពីឱពុកម្តាយ និងគ្រួសាររបស់កុមាររូបនោះផ្ទាល់ ដែលវាគឺជាការគោរពចំពោះនិមិត្តរូបនៃសេចក្តីជំនឿ និងជំនឿដ៏ស្មោះត្រង់របស់មនុស្សដទៃ ជាការគោរពចំពោះច្បាប់ និងបទបញ្ជា ជាការគោរពចំពោះទ្រព្យសម្បត្តិរបស់អ្នកដទៃ និងជាការគោរពចំពោះអ្នកមានសិទ្ធិអំណាច។ ប៉ុលបានរំពួកដល់យើងថា កុមារទាំងឡាយគប្បី “រៀនឱ្យចេះគោរពប្រណិបត្តិដល់ពួកអ្នកផ្ទះខ្លួន” (ធីម៉ូថេទី 1 5:4)។

ការដាក់វិន័យដល់កូនចៅ

ឧបសគ្គដ៏លំបាកបំផុតមួយនៃការដាក់វិន័យ គឺជាការដាក់វិន័យដល់កូនចៅឱ្យមានលក្ខណៈសមរម្យ។ ការចិញ្ចឹមបីបាច់កូនគឺជារឿងបុគ្គល។ កុមារគ្រប់រូបមានលក្ខណៈពិសេសខុសៗពីគ្នា។ អ្វីមួយដែលធ្លាប់ធ្វើចំពោះកុមារម្នាក់ មិនមានន័យថាវាអាចប្រើការបានជាមួយនឹងកុមារម្នាក់ទៀតនោះឡើយ។ ខ្ញុំពុំធ្លាប់ស្គាល់មនុស្សណាម្នាក់ ដែលមានប្រាជ្ញាគ្រប់គ្រាន់ នៅក្នុងរៀបរាប់ថាតើការដាក់វិន័យប្រភេទណាមួយមានលក្ខណៈធ្ងន់ ឬស្រាលនោះទេ គឺមានតែឱពុកម្តាយរបស់កុមារទាំងនោះ ជាអ្នកស្រឡាញ់ពួកគេបំផុតប៉ុណ្ណោះ ទើបអាចដឹងបានអំពីបញ្ហានេះ។ វាគឺជាបញ្ហាមួយនៃការកាត់សេចក្តីដែលពោរពេញដោយការអធិស្ឋានរបស់ឱពុកម្តាយ។ ពិតប្រាកដណាស់ គោលការណ៍នៃការប្រើអំណាច និងការគាំទ្រគឺថា

ការដាក់វិន័យដល់កូនចៅត្រូវតែមានការលើកទឹកចិត្តឱ្យបានច្រើន តាមរយៈសេចក្តីស្រឡាញ់ជាជាងតាមរយៈការដាក់វិន័យ។ ព្រិកហាំ យ៉ង់ បានទូន្មានថា “ប្រសិនបើអ្នករាល់គ្នាពុំធ្លាប់ស្តីបន្ទោសដល់បុគ្គលណាម្នាក់នោះ សូមកុំស្តីបន្ទោសឱ្យហួសពីសេចក្តីល្អឯណោម ដែលមាននៅក្នុងខ្លួនអ្នក ដើម្បីផ្សះផ្សានោះឡើយ” (*Discourses of Brigham Young* ចងក្រងដោយ John A. Widtsoe [ឆ្នាំ 1954] ទំព័រ 278)។ ទោះជាយ៉ាងណា ការណែនាំ និងការដាក់វិន័យ គឺជាផ្នែកដ៏សំខាន់យ៉ាងពិតប្រាកដមួយនៃការចិញ្ចឹមបីបាច់កូនចៅ។ ប្រសិនបើឪពុកម្តាយមិនបង្ហាត់បង្រៀនកូនរបស់ខ្លួន នោះមូលដ្ឋានខាងក្រោមនឹងបង្ហាត់បង្រៀនពួកគេតាមរបៀបមួយដែលឪពុកម្តាយទាំងឡាយមិនចូលចិត្តសោះឡើយ។ ដោយគ្មានការបង្ហាត់បង្រៀន នោះកុមារទាំងឡាយនឹងពុំមានការគោរព មិនថាឡើយជាច្បាប់ទម្លាប់នៅក្នុងគេហដ្ឋាន ឬជាច្បាប់នៅក្នុងសង្គមនោះទេ។

គោលបំណងដ៏សំខាន់មួយចំពោះការដាក់វិន័យ គឺជាការបង្រៀនអំពីការគោរពប្រណិបត្តិ។ ប្រធាន ដាវីឌ អូ មិកឃៃ បានលើកឡើងថា ៖ “ឪពុកម្តាយដែលបរាជ័យនៅក្នុងការបង្រៀនកូនចៅរបស់ខ្លួនអំពីការគោរពប្រណិបត្តិ ដោយកិច្ចការនេះមិនបានអនុវត្តនៅក្នុងគេហដ្ឋាន[របស់ខ្លួន] នោះសង្គមនឹងទាមទារឱ្យមានការគោរពប្រណិបត្តិពីសំណាក់កុមារទាំងនោះ។ ដូច្នេះ វាគឺជាការប្រសើរបំផុតសំរាប់ឪពុកម្តាយឱ្យចេះមានសណ្តានចិត្ត ការយោគយល់ និងការយល់ដឹងនៅក្នុងការបង្ហាត់បង្រៀនដល់កូនចៅឱ្យចេះគោរពប្រណិបត្តិជាជាងការទុកពួកគេចោលនៅក្នុងការបង្ហាត់បង្រៀនដែលគ្មានការយោគយល់ និងពោរពេញដោយភាពយោរយៅដែលសង្គមនឹងធ្វើឡើង ប្រសិនបើឪពុកម្តាយមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យបានរួចរាល់នោះ” (*The Responsibility of Parents to Their Children* ទំព័រ 3)។

ការបង្រៀនកូនចៅឱ្យចេះធ្វើការងារ

ផ្នែកដ៏សំខាន់មួយនៃការបង្រៀនកូនចៅឱ្យមានវិន័យគឺត្រូវឱ្យពួកគេរៀនធ្វើការងារ។ នៅពេលយើងធំវ័យឡើង យើងទាំងអស់គ្នាភាគច្រើនមានលក្ខណៈដូចគ្នាទៅនឹងមនុស្សម្នាក់ដែលនិយាយថា “ខ្ញុំចូលចិត្តធ្វើការងារ វាបានសណ្តំដួងចិត្តរបស់ខ្ញុំ។ ខ្ញុំអាចអង្គុយ ហើយមើលទៅកិច្ចការទាំងនោះអស់ពេលយ៉ាងយូរ” (Jerome Klapka Jerome នៅក្នុង *The International Dictionary of Thoughts* រៀបរៀងដោយ John P. Bradley, Leo F. Daniels និង Thomas C. Jones [ឆ្នាំ 1969] ទំព័រ 782)។ ជាថ្មីម្តងទៀត ពួកគ្រូបង្រៀនដ៏ប្រពៃបំផុតចំពោះគោលការណ៍ការងារនេះ គឺជាឪពុកម្តាយនេះឯង។ ចំពោះខ្ញុំ ការងារបានក្លាយទៅជាសេចក្តីអំណរមួយ នៅពេលខ្ញុំបានធ្វើការជាលើកដំបូង នៅក្បែរឪពុករបស់ខ្ញុំ ជីតាខ្ញុំ ពូ និងបងប្អូនប្រុសរបស់ខ្ញុំ។ ខ្ញុំជឿជាក់ថា ជាញឹកញាប់ខ្ញុំបានបង្កបញ្ហាជាជាងការជួយដល់ពួកគាត់ ប៉ុន្តែអនុស្សាវរីយ៍នោះមានភាពផ្អែមល្ហែមណាស់ ហើយមេរៀនដែលបានរៀនក៏មានតម្លៃដងដែរ។ កុមារទាំងឡាយត្រូវការរៀនទទួលខុសត្រូវ និងភាពឯករាជ្យ។ តើឪពុកម្តាយញែកពេលវេលាដើម្បីបង្ហាញ និងចង្អុលបង្ហាញ ហើយពន្យល់ដើម្បីកូនចៅអាចប្រែក្លាយដូចដែលលីហៃបានបង្រៀនថា “ធ្វើសកម្មភាពដោយខ្លួនឯង . . . ពុំមែនទទួលសកម្មភាព” ដែរឬទេ? (នីហ្វៃទី 2 2:26)។

ល្អធើរ ប៊ីប៊ែង ជាសាវកប្បាករដ៏អស្ចារ្យបំផុតមួយរូបនៅក្នុងពិភពលោកបាននិយាយថា “ប្រសិនបើយើងមិនបានយកចិត្តទុកដាក់ ចំពោះរុក្ខជាតិរបស់យើងឱ្យបានច្រើនជាងការយកចិត្តទុកដាក់ដែលយើងមានចំពោះកូនចៅរបស់យើង នោះប្រហែលជាឥឡូវនេះយើងរស់នៅក្នុងព្រៃ ដែលមានស្មៅពាសពេញទៅហើយ” (នៅក្នុង *Elbert Hubbard's Scrap Book* [ឆ្នាំ 1923] ទំព័រ 227)។

ឧបសគ្គដ៏ធំចំពោះឪពុកម្តាយទាំងឡាយ

កុមារទាំងឡាយគឺជាអ្នកទទួលបាននូវសិទ្ធិជ្រើសរើសខាងសីលធម៌ផងដែរ តាមរយៈអ្វីដែលយើងបានផ្តល់ទៅឱ្យពួកគេនូវឱកាសដើម្បីរីកចំរើន លូតលាស់ និងអភិវឌ្ឍ។ សិទ្ធិជ្រើសរើសនោះបានអនុញ្ញាតឱ្យកុមារទាំងឡាយ ស្វែងរកការជ្រើសរើសដែលផ្តាស់ប្តូរគ្នាស្តីអំពីភាពអត្ថានិយម ភាពខ្ជះខ្ជាយ ការមិនប្រកាន់ទោសចំពោះខ្លួនឯង និងការមិនបំផ្លិចបំផ្លាញខ្លួនឯង។ ជាញឹកញាប់ កុមារទាំងឡាយសម្តែងចេញនូវសិទ្ធិជ្រើសរើសនេះនៅពេលពួកគេមានវ័យកុមារ។

ចូរឱ្យឪពុកម្តាយទាំងឡាយដែលមានមនះសិកា សេចក្តីស្រឡាញ់ ហើយខ្វាយខ្វល់ ព្រមទាំងឪពុកម្តាយទាំងឡាយណា ដែលបានរស់នៅស្របតាមគោលការណ៍ទាំងឡាយ នៃសេចក្តីសុចរិតយ៉ាងល្អប្រសើរតាមដែលពួកគេអាចធ្វើទៅបាននោះ អាចត្រូវបានទទួលនូវការលួងលោមចិត្តដោយការដឹងថា ពួកគេគឺជាឪពុកម្តាយដ៏ល្អ ថ្វីបើមានទង្វើរខុសឆ្គងកើតមានចំពោះកូនចៅមួយចំនួនរបស់ពួកគេក៏ដោយ។ កុមារទាំងនេះមានការទទួលខុសត្រូវមួយដោយខ្លួនឯងនៅក្នុងការស្តាប់ការគោរព ហើយនឹងត្រូវបានបង្រៀនឱ្យចេះរៀនសូត្រ។ ជានិច្চកាល ឪពុកម្តាយទាំងឡាយមិនអាចឆ្លើយតបនូវរាល់ភាពគ្មានសណ្តាប់ធ្នាប់របស់កូនខ្លួនបានឡើយ ពីព្រោះពួកគេ មិនអាចអះអាងចំពោះតំរិយាបទដ៏ល្អរបស់កុមារទាំងនោះបាន។ ការគ្រប់គ្រងចំពោះកុមារមួយចំនួន អាចអនុវត្តតាមច្រាច្បាស់របស់សាឡូម៉ូន និងការអត់ធ្មត់របស់យ៉ូប។

ជាញឹកញាប់ ឧបសគ្គដ៏ធំមួយបានកើតមានឡើងចំពោះឪពុកម្តាយដែលមានទ្រព្យសម្បត្តិសុភសួម ឬជាអ្នកដែលមានភាពតឹងតែងខ្លាំងពេក។ តាមការសង្កេតឃើញមួយចំនួន នៅក្នុងកាលៈទេសៈបែបនោះ កុមារមួយចំនួនបានធ្វើឱ្យឪពុកម្តាយរបស់ខ្លួនក្លាយទៅជាពិរុទ្ធិកជន តាមរយៈការដកយកការគាំទ្រ នៃច្បាប់ជាឪពុកម្តាយរបស់ពួកគេ លើកលែងតែឪពុកម្តាយទាំងឡាយនោះ យល់ស្របទៅនឹងតំរូវការរបស់កូនខ្លួន។ អែលឌើរ ឡេល អេ ម៉ាកស្វែល បានមានប្រសាសន៍ថា “ពួកអ្នកដែលធ្វើអ្វីសព្វបែបយ៉ាង *ឱ្យ* កូនរបស់ខ្លួន មិនយូរប៉ុន្មានពួកគេនឹងដឹងខ្លួនថាពួកគេមិនអាចធ្វើអ្វីមួយ*ជាមួយនឹង* កូនចៅរបស់ពួកគេបានទៀតឡើយ។ មានកុមារជាច្រើនត្រូវបានគេ*ធ្វើ* នូវអ្វីៗគ្រប់យ៉ាងសំរាប់ពួកគេ ប៉ុន្តែវត្ថុទាំងអស់នោះស្ទើរតែ*បំផ្លាញ* ពួកគេទៅវិញ” (នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1975 ទំព័រ 150 ឬ *Ensign* ខែ ឧសភា ឆ្នាំ 1975 ទំព័រ 101)។ យើងហាក់ដូចជាពុំមានអំណរគុណទាំងស្រុងចំពោះសម្ភារៈ ដែលយើងមិនបានរកវាដោយខ្លួនឯងនោះឡើយ នេះគឺជាធម្មជាតិរបស់មនុស្ស។

ជាការពិតណាស់ មានការសើចចំអកឡើងថា ឪពុកម្តាយមួយចំនួនមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះកូនចៅរបស់ខ្លួននៅក្នុងទទួលយក និងការមានប្រជាប្រិយភាពជាមួយនឹងក្រុមមនុស្សដែលមានវ័យដំណាលគ្នា ប៉ុន្តែឪពុកម្តាយទាំងនេះមានការភ័យខ្លាចថា កូនចៅរបស់ពួកគេអាចធ្វើនូវអ្វីដែលក្រុមមនុស្សមានវ័យដំណាលគ្នានឹងកូនខ្លួនកំពុងធ្វើ។

ការជួយកូនចៅឱ្យមានបទដ្ឋានសីលធម៌នៅក្នុងខ្លួនរបស់ពួកគេ

ជាទូទៅ កុមារទាំងឡាយណាដែលធ្វើតាមការសំរេចចិត្តបែបនោះ ហើយមានដំណោះស្រាយដើម្បីដកខ្លួនចេញពីថ្នាំញៀន គ្រឿងស្រវឹង និងរឿងផ្លូវភេទដែលខុស

ច្បាប់ គឺជាពួកអ្នកដែលបានទទួលយក ហើយទុកតម្លៃដ៏រឹងមាំនៃគេហដ្ឋានទៅក្នុងខ្លួនរបស់ពួកគេ ទៅពេលពួកគេរស់នៅតាមឪពុកម្តាយរបស់ពួកគេ។ ទៅក្នុងគ្រានៃការធ្វើការសំរេចចិត្តដ៏លំបាក ភាគច្រើនពួកគេធ្វើតាមការបង្រៀនរបស់ឪពុកម្តាយខ្លួនជាជាងគំរូនៃក្រុមមនុស្សដែលមានវ័យដំណាលគ្នាទីងពួកគេ ឬការលោកបញ្ឆោតពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយ ដែលធ្វើឱ្យការសេពគ្រឿងស្រវឹង ការប្រព្រឹត្តខាងផ្លូវភេទខុសច្បាប់ ការត្បត់ចិត្ត ការគ្មានភាពស្មោះត្រង់ និងកត្តាពាក់ព័ន្ធផ្សេងទៀតមើលតួរឱ្យមានចំណាប់អារម្មណ៍នោះ។ ពួកគេរាល់គ្នាប្រែប្រួបដូចជាយុវជនពីរពាន់ទាក់របស់ហេលេមិនដែល “បានបង្រៀនដោយម្តាយគេថា បើសិនជាពួកគេពុំសង្ស័យទេ នោះព្រះទ្រង់នឹងដោះលែងពួកគេឱ្យរួច” ពីសេចក្តីស្លាប់ (អាលម៉ា 56:47)។ “ហើយពួកគេបានរៀបរាប់ . . . ពាក្យពេចន៍របស់ម្តាយគេថា ៖ យើងខ្ញុំមិនសង្ស័យសោះថា ម្តាយយើងជឿងការណ៍នេះ” (អាលម៉ា 56:48)។

អ្វីមួយដែលអាចជួយពង្រឹងការបង្រៀនរបស់ឪពុកម្តាយ និងតម្លៃសីលធម៌ទៅក្នុងជីវិតរបស់កូនចៅពួកគេបាន គឺជាជំនឿដ៏រឹងមាំមួយលើអាទិទេព។ ទៅពេលជំនឿនេះប្រែក្លាយទៅជាផ្នែកនៃព្រលឹងរបស់ពួកគេ នោះពួកគេនឹងមានកម្លាំងទៅក្នុងខ្លួន។ ដូច្នេះ ទៅក្នុងចំណោមរឿងសំខាន់ៗទាំងអស់ដែលយើងត្រូវបង្រៀន តើឪពុកម្តាយគប្បីបង្រៀនអ្វីខ្លះ? ព្រះគម្ពីរបានច្រាប់យើងថា ឪពុកម្តាយត្រូវបង្រៀនកូនចៅរបស់ខ្លួនអំពី “សេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅ និងអំពីបុណ្យជ្រមុជទឹក ហើយនិងអំពីអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ” និង “គោលលទ្ធិអំពីការប្រែចិត្ត” (គ. និង ស. 68:25)។ សេចក្តីពិតទាំងនេះត្រូវតែបង្រៀនទៅក្នុងគេហដ្ឋាន។ វាមិនអាចត្រូវបានបង្រៀនទៅឯសាលារដ្ឋ ឬក៏ទីងត្រូវបានទទួលការលើកទឹកចិត្តពីសំណាក់រដ្ឋាភិបាល ឬសង្គមនោះឡើយ។ ជាការពិតណាស់ កម្មវិធីសាសនាចក្រទាំងឡាយអាចជួយបង្រៀនដល់ពួកគេ ប៉ុន្តែការបង្រៀនដ៏មានប្រសិទ្ធភាពបំផុតកើតមានឡើងទៅក្នុងគេហដ្ឋាន។

សរសៃអំបោះរាប់ពាន់នៃសេចក្តីស្រឡាញ់

ឱកាសបង្រៀនរបស់ឪពុកម្តាយពុំបាច់មានលក្ខណៈធំ ឬក៏ធ្វើឱ្យមានការរំភើបនិងមានភាពអស្ចារ្យនោះទេ។ យើងរៀនកិច្ចការទាំងនេះមកពីគ្រូបង្រៀនដ៏ចំណាន។ លោក ឆាលី ហេនរី ផាកហឺត បានទិយាយថា ៖

“ភាពស្រស់ស្អាតដ៏ពេញលេញនៃឆាកជីវិតរបស់ព្រះគ្រីស្ទ គឺជាភាពស្រស់ស្អាតដែលបានបន្ថែមទៅលើទង្ហើរដ៏សាមញ្ញបំផុតនៃភាពស្រស់ស្អាត—ដោយការមានបន្ទូលជាមួយនឹងស្ត្រីទៅឯអណ្តូងទឹក . . . ដោយការបង្ហាញដល់អ្នកដឹកនាំវ័យក្មេងថា ការលោភលន់ដែលលាក់បាំងនៅក្នុងជួងចិត្តរបស់គាត់ បានធ្វើឱ្យគាត់ឃ្លាតឆ្ងាយពីនគរស្ថានសួគ៌ . . . ដោយការបង្រៀនក្រុមមនុស្សមួយចំនួនតូចអំពីរបៀបអធិស្ឋាន . . . ដោយការបង្កាត់ភ្លើង និងការអាំងត្រីសំរាប់សិស្សរបស់ទ្រង់ ដើម្បីពួកគេអាចបរិភោគសំរាប់អាហារពេលព្រឹក នៅពេលពួកគេត្រឡប់មកកាន់ឆ្នេរសមុទ្រវិញដោយអស់កម្លាំង ហើយអស់សង្ឃឹមក្រោយពីការរកត្រីនៅក្នុងពេលយប់ដ៏ត្រជាក់នោះ។ កិច្ចការទាំងអស់នេះ ដែលអ្នករាល់គ្នាបានឃើញ ចូរយើងធ្វើឱ្យមានភាពងាយស្រួលនៅក្នុងគុណសម្បត្តិ និងអាកប្បកិរិយាពិតនៃចំណាប់អារម្មណ៍របស់[ព្រះគ្រីស្ទ] ចូរឱ្យយើងមានភាពជាក់លាក់ ល្អិតល្អន់ ហើយចូលរួម និងធ្វើកិច្ចការតូចតាចទាំងនេះ” (“Kindness and Love” នៅក្នុង *Leaves of Gold* [1938] ទំព័រ 177)។

ការធ្វើជាឪពុកម្តាយគឺបែបនេះឯង។ រឿងតូចតាចគឺជារឿងដ៏ធំដែលបានដេរភ្ជាប់ទៅនឹងកម្រាលពាក់ ដោយសរសៃអំបោះរាប់ពាន់នៃសេចក្តីស្រឡាញ់ សេចក្តីជំនឿ ការដាក់វិន័យ ការលះបង់ ការអត់ធ្មត់ និងការងារ។

កូនចៅនៃសេចក្តីសញ្ញា

មានសេចក្តីសន្យាខាងវិញ្ញាណដ៏អស្ចារ្យមួយចំនួន ដែលអាចជួយឪពុកម្តាយដ៏ស្មោះត្រង់នៅក្នុងសាសនាចក្រនេះបាន។ កូនចៅនៃការផ្សារភ្ជាប់ដ៏នៅអស់កល្បជានិច្ចអាចកើតមានចំពោះពួកគេនូវសេចក្តីសន្យាដ៏ទេវភាព ដែលបានធ្វើឡើងចំពោះបុព្វបុរសដ៏ឆ្លាហានរបស់ពួកគេ ជាអ្នកដែលបានរក្សាសេចក្តីសញ្ញារបស់ខ្លួនយ៉ាងថ្លៃថ្នូរ។ សេចក្តីសញ្ញាទាំងឡាយ ដែលត្រូវបានចងចាំដោយពួកឪពុកម្តាយ នោះព្រះនឹងចងចាំនូវសេចក្តីសញ្ញាទាំងនោះផងដែរ។ ដូច្នេះ កុមារទាំងឡាយអាចក្លាយទៅជាអ្នកទទួលផលប្រយោជន៍ និងអ្នកត្រងមរតកនៃសេចក្តីសញ្ញា និងសេចក្តីសន្យាដ៏មហិមាទាំងនេះ។ ការណ៍នេះកើតមានឡើង ដោយសារតែពួកគេគឺជាកូនចៅនៃសេចក្តីសញ្ញា (សូមមើល Orson F. Whitney នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1929 ទំព័រ 110–11)។

ព្រះប្រទានពរដល់ឪពុកម្តាយដែលមានការលំបាក ការលះបង់ និងជាឪពុកម្តាយដែលគួរឱ្យគោតសរសើរនៅក្នុងពិភពលោកនេះ។ ជាពិសេស សូមឱ្យទ្រង់ប្រទានកិត្តិយលដល់សេចក្តីសញ្ញាទាំងឡាយ ដែលបានរក្សាដោយឪពុកម្តាយដ៏ស្មោះត្រង់នៅក្នុងចំណោមសមាជិកយើង ហើយសូមឱ្យទ្រង់ថែរក្សាដល់កូនចៅនៃសេចក្តីសញ្ញាទាំងនេះផងដែរ។

ដកស្រង់មកពីសុន្ទរកថាមួយដោយអែលឌើរ ហ្វោស្ត នៅក្នុងសន្និសីទទូទៅនៃសាសនាចក្រ ខែ គុលា ឆ្នាំ 1990 (សូមមើល Conference Report ខែ គុលា ឆ្នាំ 1990 ទំព័រ 39–43 ឬ *Ensign* ខែ វិច្ឆិកា ឆ្នាំ 1990 ទំព័រ 32–35)។

តុម្លួយដែលហុំព័ទ្ធទៅដោយសេចក្តីស្រឡាញ់

អែលឌើរ ឡឺហ្គ្រង់ អ័រ ខឺតទីស
នៃពួក 70 នាក់

មានរឿងជាច្រើនដែលត្រូវបានគេនិពន្ធឡើងស្តីអំពីសារៈសំខាន់នៃគេហដ្ឋាន។ អែលឌើរ ម៉ារ៉ុន ជេ រ៉ូមនី បានច្រាប់យើងថា “ជម្ងឺដ៏កាចសាហាវនៃសង្គម គឺជាអស្ថេរភាពនៃគ្រួសារ”។[1] យើងទទួលស្គាល់ថា គេហដ្ឋានមួយចំនួនមានលក្ខណៈធំ ហើយលំអរទៅដោយគ្រឿងបរិក្ខារដ៏មានតម្លៃជាច្រើន។ គេហដ្ឋានផ្សេងទៀតមានលក្ខណៈតូច ហើយខ្វះខាត ដោយមានជាក់តាំងគ្រឿងបរិក្ខារតែបន្តិចបន្តួចនៅក្នុងនោះ។ ប៉ុន្តែផ្ទះនីមួយៗ “អាចប្រែក្លាយដូចជាស្ថានសួគ៌នៅលើផែនដីនេះ នៅពេលយើងពោរពេញទៅដោយសេចក្តីស្រឡាញ់ . . . ជាទីកន្លែងដែលយើងចង់រស់នៅ” ដូចជាចំរៀងទំនុកដំកើងព្រះជាទីស្រឡាញ់របស់យើងមួយបទ បានរំឭកដល់យើងយ៉ាងដូច្នោះ។[2]

តុបាយគឺជា គ្រឿងបរិក្ខាដ៏សំខាន់មួយ ដែលភាគច្រើនយើញមាននៅគ្រប់គេហដ្ឋានទាំងអស់។ វាអាចមានសណ្ឋានជាតុធំ តុតូច ឬវាក៏អាចមានសណ្ឋានជាតុតូចមួយដែលអាចដាក់ម្ហូបអាហារ ឬប្រដាប់ប្រដារផ្ទះបានបន្តិចបន្តួច។ ប៉ុន្តែតួនាទីសំខាន់របស់វា គឺដើម្បីធ្វើជាទីកន្លែងមួយដែលសមាជិកគ្រួសារម្នាក់ៗអាចបរិភោគអាហារបាន។

ទៅក្នុងឱកាសដ៏ពិសេសនេះ បំណងប្រាថ្នារបស់ខ្ញុំគឺដើម្បីទាញចំណាប់អារម្មណ៍របស់អ្នករាល់គ្នាឱ្យយល់កាន់តែស៊ីជំរៅថែមទៀត អំពីតួនាទីដ៏សំខាន់របស់តុបាយ

ថាវាគឺជាទីកន្លែងដែលយើងអាចទទួលនូវអ្វីៗជាច្រើនទៀត ក្រៅពីម្ហូបអាហារដើម្បីចិញ្ចឹមរូបកាយរបស់យើង។

ការពិភាក្សាអំពីជំណឹងល្អនៅជុំវិញតុបាយ

ជាទូទៅ គ្រួសារមួយមានសមាជិកចាប់ពីពីរនាក់ឡើងទៅដែលមានអាយុខុសគ្នា ប៉ុន្តែគ្រួសារនោះត្រូវមានការជួបជុំគ្នា—វាពុំមែនគ្រាន់តែជាការបរិភោគអាហារជុំគ្នាប៉ុណ្ណោះនោះទេ ប៉ុន្តែជាការជួបជុំគ្នាដើម្បីអធិស្ឋាន សន្ទនា ស្តាប់និទានរឿង និងដើម្បីរីកចំរើនទាំងអស់គ្នា។ ប្រធាន ហ្គរដុន ប៊ី ហ៊ុងគ្លី បានលើកឡើងនូវបញ្ហានេះបានយ៉ាងល្អ ដោយលោកបានមានប្រសាសន៍ថា ៖

“ការស្នើសុំរបស់ខ្ញុំ—គឺជាការអង្វរកមួយដើម្បីជួយសង្រ្គោះកុមារទាំងឡាយ—ហើយខ្ញុំសង្ឃឹមថា ខ្ញុំនឹងមានឥទ្ធិពលគ្រប់គ្រាន់នៅក្នុងការលើកឡើងអំពីបញ្ហានេះ។ ពួកកុមារទាំងនេះជាច្រើនកំពុងដើរដោយការឈឺចាប់ និងការភ័យខ្លាច នៅក្នុងភាពឯកកោរ ហើយអស់សង្ឃឹម។ កុមារទាំងឡាយត្រូវការនូវពន្លឺនៃព្រះអាទិត្យ។ ពួកគេត្រូវការនូវសុភមង្គល។ ពួកគេត្រូវការនូវសេចក្តីស្រឡាញ់ និងការចិញ្ចឹមបីបាច់។ ពួកគេត្រូវការសេចក្តីមេត្តាករុណា ភាពស្រស់បំព្រង និងភាពកក់ក្តៅ។ គ្រប់គេហដ្ឋាន ដោយមិនគិតអំពីតម្លៃនៃគេហដ្ឋាននោះ វាអាចផ្តល់នូវបរិស្ថាននៃសេចក្តីស្រឡាញ់មួយ ដែលនឹងក្លាយទៅជាបរិស្ថាននៃសេចក្តីសង្រ្គោះ”។[3]

សមាជិកគ្រួសារភាគច្រើនស្ថិតនៅក្រោមកម្លាំងជាច្រើននៃពិភពលោកខាងក្រៅ ក៏ដូចជាឥទ្ធិពលដ៏ខ្លាំងក្លានៃវិទ្យុ ទូរទស្សន៍ កាសែតវីដេអូ និងរឿងដទៃជាច្រើនទៀតដែលយើងបានទាំចូលក្នុងផ្ទះរបស់យើង។

សូមនឹកស្រមៃអំពីការជួបជុំគ្នាជាក្រុមគ្រួសារមួយ នៅជុំវិញតុមួយដែលជាតុបាយ មានការពិភាក្សាអំពីជំណឹងល្អ អំពីការប្រជុំសាក្រាម៉ង់ អំពីសារលិខិតនានា អំពី *លីអាហូណា ឬសារលិខិតគណៈប្រធានទីមួយថ្មី* អំពីមេរៀនទៅថ្នាក់សាលាថ្ងៃអាទិត្យ ការស្តាប់តន្ត្រីល្អ ការពិភាក្សាអំពីព្រះយេស៊ូវគ្រីស្ទ និងការបង្រៀនរបស់ទ្រង់។ តារាងនេះមានច្រើនជាងនេះទៅទៀត។ ពុំមែនមានតែឱពុកម្តាយ ដែលមានភាពឈ្លាសវៃក្នុងរៀបចំសកម្មភាពណាមួយ ដើម្បីធ្វើឱ្យបុគ្គលនៅទីនោះមានឱកាសមួយនៅក្នុងការនិយាយ និងមានឱកាសពេញលេញនៅក្នុងការចូលរួមនោះទេ ប៉ុន្តែសមាជិកគ្រួសារផ្សេងទៀតក៏អាចធ្វើកិច្ចការនេះបានផងដែរ។

ការអធិស្ឋានជាក្រុមគ្រួសារនៅជុំវិញតុបាយ

សូមពិចារណាអំពីសក្តានុពលនៃការលុតជង្គង់ចុះជាក្រុមគ្រួសារនៅជុំវិញតុមួយ (ដោយគ្មានទូរទស្សន៍) ដោយអធិស្ឋាន និងដោយទូលសុំសំរាប់ជំនួយ ព្រមទាំងធ្វើការថ្លែងអំណរគុណដល់ព្រះវរបិតារបស់យើងចំពោះពរជ័យទាំងឡាយ—វាគឺជាការបង្រៀនដល់មនុស្សគ្រប់វ័យអំពីសារៈសំខាន់នៃព្រះវរបិតាដែលគង់នៅស្ថានសួគ៌ជាទីស្រឡាញ់។ ការអធិស្ឋានជាគ្រួសារជាមួយនឹងកូនតូចៗអាចជាការល្អដល់ពេលពួកគេធំពេញវ័យ វាគឺជាពេលដែលពួកនឹងចាប់ផ្តើមអធិស្ឋានជាមួយនឹងក្រុមគ្រួសាររបស់ខ្លួន។

រ៉ែលឌើរ ថូម៉ាស អេស ម៉នសុន បានលើកឡើងអំពីបញ្ហានេះបានយ៉ាងល្អ ដោយលោកបានមានប្រសាសន៍ថា ៖

“ព្រះអម្ចាស់បានណែនាំថា យើងត្រូវមានការអធិស្ឋានជាគ្រួសារ ខណៈដែលទ្រង់មានបន្ទូលថា ៖ ‘ចូរអធិស្ឋាននៅក្នុងក្រុមគ្រួសារអ្នក ដល់ព្រះវរបិតាដោយនូវនាមយើងជានិច្ច ដើម្បីឱ្យប្រពន្ធរបស់អ្នក និងកូនចៅរបស់អ្នកអាចបានពរ’។ (នីហ្ចៃទី 3 18:21)។

“តើអ្នកនឹងចូលរួមជាមួយនឹងខ្ញុំ នៅពេលយើងផ្តោតយកចិត្តទុកដាក់ទៅលើគ្រួសារពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏សាមញ្ញមួយ នៅក្នុងការធ្វើការអធិស្ឋានទៅកាន់ព្រះអម្ចាស់ដែរឬទេ? ឱពុក ម្តាយ និងកូនម្នាក់ៗបានលុតជង្គង់ ឱនក្បាលចុះ ហើយបិទផ្នែករបស់ពួកគេ។ វិញ្ញាណដ៏ផ្អែមល្ហែមមួយនៃសេចក្តីស្រឡាញ់សាមគ្គីភាព និងសេចក្តីសុខសាន្តបានកើតមានពាសពេញនៅក្នុងគេហដ្ឋាននោះ។ នៅពេលឱពុកម្តាយបានឲកូនប្រុសតូចរបស់ខ្លួន អធិស្ឋានទៅកាន់ព្រះថា សូមឱ្យឱពុករបស់គាត់នឹងធ្វើអ្វីដែលត្រឹមត្រូវ ហើយគោរពប្រណិបត្តិចំពោះព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ តើអ្នកគិតថាឱពុករូបនោះគិតថា វាជាការពិបាកក្នុងការគោរពដល់ការអធិស្ឋាន នៃកូនប្រុសដ៏គួរឱ្យស្រឡាញ់របស់ខ្លួនដែរឬទេ? នៅពេលកូនស្រីវ័យជំទង់មួយរូបបានឲម្តាយជាទីស្រឡាញ់របស់នាងទូលសុំដល់ព្រះអម្ចាស់ថា សូមឱ្យកូនស្រីរបស់គាត់នឹងទទួលបានការបំផុសគំនិតនៅក្នុងជ្រើសរើសដៃគូរបស់ខ្លួន ថានាងនឹងរៀបចំខ្លួនសំរាប់អាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ តើអ្នកមិនជឿថា កូនស្រីរូបនោះនឹងស្វែងរកកិត្តិយសទាំងនោះ ដោយការបន្ទាបខ្លួន ការទូលអង្វរចំពោះសំណើរនៃម្តាយរបស់នាង ជាអ្នកដែលនាងស្រឡាញ់ជាទីបំផុតនោះដែរឬទេ? នៅពេលឱពុកម្តាយ និងកូនម្នាក់ៗអធិស្ឋានដោយស្មោះត្រង់ថា សូមឱ្យកូនប្រុសដ៏ល្អទាំងនេះ នៅក្នុងគ្រួសារនឹងរស់នៅដោយមានភាពសក្តិសម ដើម្បីពួកគេអាចទទួលការហៅឱ្យបំរើមួយ ជាអ្នកតំណាងរបស់ព្រះអម្ចាស់នៅក្នុងតំបន់បេសកកម្មនៃសាសនា តើយើងមិនបានចាប់ផ្តើមមើលយើញនូវរបៀប ដែលកូនប្រុសទាំងនោះមានវ័យធំឡើងជាមួយនឹងបំណងប្រាថ្នា ដើម្បីបំរើជាអ្នកផ្សព្វផ្សាយសាសនាទេឬ?”[4]

ដូចដែលមនុស្សជាច្រើនបាននិយាយថា “តើអ្នកអាចបញ្ជូនឱពុកម្តាយ និងកូនចៅរបស់អ្នកចេញទៅពិភពលោកខាងក្រៅជារៀងរាល់ថ្ងៃដោយគ្មានការប្រមូលផ្តុំគ្នា ហើយនិយាយទៅកាន់ព្រះអម្ចាស់ដោយរបៀបណា?” ឱពុកម្តាយដ៏ឈ្លាសវៃនឹងសិក្សាអំពីកាលវិភាគ ហើយដាក់ផែនការរបស់ខ្លួន យ៉ាងហោចណាស់ឱ្យបានម្តងក្នុងមួយថ្ងៃ ដើម្បីប្រមូលគ្រួសារនៅក្នុងទទួលពរជ័យនៃការអធិស្ឋាន។ មិនយូរប៉ុន្មាន សមាជិកគ្រួសារវ័យក្មេងនឹងរៀនអំពីរបៀប ដើម្បីផ្លាស់ប្តូរវេណរបស់ខ្លួនក្នុងការអធិស្ឋានជាគ្រួសារ ហើយរៀនអំពីតម្លៃដ៏វិសេសវិសាលបំផុតដែលកើតមាននៅក្នុងការអធិស្ឋានជាគ្រួសារ។

ចូរធ្វើឱ្យគេហដ្ឋានក្លាយទៅជាទីកន្លែងដ៏មានសុភមង្គលមួយ

ខ្ញុំបានលើកឡើងកាលពីមុនមកថា “គេហដ្ឋានគួរតែជាទីកន្លែងដែលមានសុភមង្គល ពីព្រោះមានកិច្ចការជាច្រើនដែលរក្សាវាឱ្យនៅតែមានសភាពបែបនោះ។ មានពាក្យលើកឡើងថា សុភមង្គលគឺជាគ្រួសារ ហើយយើងគប្បីព្យាយាមដើម្បីធ្វើឱ្យគេហដ្ឋានរបស់យើង មានការសប្បាយរីករាយសំរាប់យើង និងកូនចៅរបស់យើង។ គេហដ្ឋានដែលមានសុភមង្គលមួយ គឺជាគេហដ្ឋានមួយដែលស្ថាបនានៅលើការបង្រៀននៃដំណឹងល្អ។ កិច្ចការនេះគំរូវឱ្យមានកិច្ចខិតខំគ្រប់បែបយ៉ាងដោយប្រុងប្រយ័ត្ន និងជានិរន្តរ៍តទៅ”។[5]

មានក្មេងជំទង់ដ៏រវល់ម្នាក់នៅក្នុងគ្រួសារដ៏ធំមួយ បានត្អូញត្អែរចំពោះរយៈពេលនៅក្នុងការធ្វើការអធិស្ឋានជាគ្រួសារ។ នៅពេលអ្នកម្តាយដ៏ឈ្លាសវៃកំពុងអធិស្ឋាននៅថ្ងៃបន្ទាប់ គឺគាត់មានចេតនាធ្វើការអធិស្ឋាននេះដោយគ្មានក្មេងជំទង់រូបនោះ។ នៅពេលការអធិស្ឋានត្រូវបានបញ្ចប់ ក្មេងរូបនោះបាននិយាយថា “ម៉ាក់ ម៉ាក់បានអធិស្ឋានដោយគ្មានរូបកូនហើយ!” អ្នកម្តាយជាទីស្រឡាញ់រូបនោះបានពន្យល់ថា គាត់គ្រាន់តែឆ្លើយតបទៅនឹងការត្អូញត្អែររបស់ក្មេងជំទង់រូបនោះប៉ុណ្ណោះ។ ក្មេងរូបនោះបានត្អូញត្អែរម្តងទៀតថា “សូមកុំទុកកូនចោលអី”។

ការសិក្សាព្រះគម្ពីរនៅជុំវិញតុបាយ

សូមនឹកគិតថាមានគ្រួសារមួយកំពុងអង្គុយនៅជុំវិញតុមួយ ដោយបានបើកព្រះគម្ពីរ ហើយពិភាក្សាអំពីសេចក្តីពិត និងមេរៀនជាច្រើនដើម្បីទទួលបានចំណេះដឹង។ ពិតប្រាកដណាស់ សកម្មភាពនេះ គឺជាតុបាយមួយដែលហ៊ុំព័ទ្ធទៅដោយសេចក្តីស្រឡាញ់!

ជនជាតិអេក្វាដ័រទាំងឡាយយល់ស្របថា កុមារទាំងឡាយត្រូវអានឱ្យបានច្រើនក្រៅពីការអាននៅក្នុងសាលារៀន។ យើងអាចប្រសិទ្ធពរដល់កូនចៅរបស់យើងដោយការអានព្រះគម្ពីរជាមួយពួកគេជារៀងរាល់ថ្ងៃ—នៅឯតុបាយ។

ដើម្បីមានពេលវេលាមួយដែលគ្រួសារអាចជួបជុំគ្នានៅឯតុបាយ គឺត្រូវមានការកែសំរួល និងការរៀបចំផែនការដោយប្រុងប្រយ័ត្នដូច្នេះ តើកិច្ចការដែលសំខាន់បំផុតចំពោះសាមគ្គីភាពនៃគ្រួសារ ការរីកលូតលាស់ខាងវិញ្ញាណរបស់គ្រួសារ និងស្ពានដែលសាងរវាងសមាជិកគ្រួសារ នៅពេលពួកនិយាយ ស្តាប់ ឆ្លើយតប ហើយព័ទ្ធជុំវិញដោយសេចក្តីស្រឡាញ់អាចមានអ្វីខ្លះ? ជោគជ័យដ៏ធំធេងរបស់យើងគឺជាការខិតខំព្យាយាម—ម្តងហើយម្តងទៀត។

ពង្រឹងចំណងក្រុមគ្រួសារ

នៅក្នុងពិភពលោកសព្វថ្ងៃនេះ មានកម្លាំងជាច្រើនដែលកំពុងស្វែងរកបំផ្លិចបំផ្លាញដល់ក្រុមគ្រួសារ និងគេហដ្ឋាន។ ឱពុកម្តាយដ៏ឈ្លាសវៃនឹងព្យាយាមពង្រឹងចំណងក្រុមគ្រួសារ ហើយបង្កើនកិច្ចការខាងវិញ្ញាណនៅក្នុងគេហដ្ឋាន និងផ្តោតសំខាន់ទៅលើព្រះយេស៊ូវគ្រីស្ទ និងសកម្មភាពព្រះវិហារបរិសុទ្ធ។ ប្រធាន ហារើដ ដបុលយូ ហឹនធើរ បានប្រាប់យើងថា ៖

“ខ្ញុំអធិស្ឋានថា យើងអាចប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកជាមួយនឹងសេចក្តីមេត្តាករុណា ភាពឱនលំទោន ការបន្ទាបខ្លួន និងការអត់ធ្មត់ ព្រមទាំងការអភ័យទោសផងដែរ . . .។

“ចំណុចទីពីរ ហើយដោយស្ថិតនៅក្នុងវិញ្ញាណដូចគ្នានោះ ខ្ញុំសូមអញ្ជើញដល់សមាជិកនៃសាសនាចក្រនេះផងដែរ ឱ្យស្តាបនាព្រះវិហារបរិសុទ្ធនៃព្រះអម្ចាស់ ធ្វើជានិមិត្តរូបដ៏មហិមានៃសមាជិកភាពរបស់ពួកគេ និងមជ្ឈដ្ឋានសេឡេស្ទាលសំរាប់សេចក្តីសញ្ញាដ៏ពិសិដ្ឋបំផុតរបស់ពួកគេ។ វាគួរតែជាបំណងប្រាថ្នាដ៏ជ្រាលជ្រៅបំផុតនៅក្នុងដួងចិត្តរបស់ខ្ញុំ ដើម្បីឱ្យសមាជិកនៃសាសនាចក្រគ្រប់រូប មានភាពសក្តិសមនៅក្នុងការទៅកាន់ព្រះវិហារបរិសុទ្ធ”។[6]

សេចក្តីណែនាំដែលធ្វើឡើងដោយប្រធាន ហឹនធើរ អាចមានលក្ខណៈកាន់តែប្រសើរឡើង តាមរយៈអ្វីដែលកើតមាននៅជុំវិញតុបាយ។

នៅក្នុងគេហដ្ឋានរបស់យើង យើងគប្បីអនុវត្តនូវរបៀបក្នុងការប្រព្រឹត្តចំពោះអ្នកដទៃ។ លោក ហ្គូធេ បានលើកឡើងនូវពាក្យដ៏ប្រពៃថា “ប្រសិនបើអ្នកប្រព្រឹត្តចំពោះ [បុគ្គលម្នាក់] ស្របទៅតាមចរិកលក្ខណៈរបស់បុគ្គលនោះ នោះគាត់នឹងស្ថិតនៅក្នុងស្ថានភាពដដែលរបស់គាត់ ប៉ុន្តែប្រសិនបើអ្នកប្រព្រឹត្តចំពោះគាត់ ដោយផ្តោតទៅលើរឿងពីអតីត . . . ឬទៅលើរឿងដែល[អាចនឹងកើតមាន]ចំពោះគាត់ . . . នោះគាត់នឹង [អាចប្រែក្លាយស្របទៅតាមអ្វីដែលអ្នកគិត ឬប្រព្រឹត្តចំពោះគាត់] ”។[7]

ការធ្វើឱ្យគេហដ្ឋានក្លាយជាទីកន្លែងនៃការឧទ្ទិស

អែលឌើរ ប៊ីយដ៍ យេ ជាកកឺ បានលើកឡើងថា ៖ “ដើម្បីនាំយកវត្ថុមួយចំនួនមកពីស្ថានសួគិចូលទៅក្នុងគេហដ្ឋាន នោះគឺត្រូវប្រាកដថាសមាជិកគ្រួសារនឹងសំរបខ្លួនចំពោះការចូលរួមក្នុងព្រះវិហារ។ ពិតប្រាកដណាស់ រាត្រីជួបជុំក្រុមគ្រួសារ គឺមានលក្ខណៈល្អបំផុតចំពោះបញ្ហានេះ—វាគឺជាការប្រជុំមួយនៅក្នុងគេហដ្ឋាន ដែលអាចត្រូវបានរៀបចំឡើងឱ្យសមស្របទៅតាមតំរូវការរបស់មនុស្សគ្រប់រូប ហើយវាក៏ដូចជាការប្រជុំនៅក្នុងព្រះវិហារ ឬការប្រជុំទាំងឡាយណាដែលធ្វើឡើងនៅក្នុងរោងថ្វាយបង្គំផងដែរ”។[8]

ពាក្យទូន្មាននេះក៏សមស្របទៅនឹងអ្វីដែលអែលឌើរ ឌីន អិល ឡ័រសុន បានប្រាប់ដល់យើងថា ៖ “អគារព្រះវិហារទាំងឡាយរបស់យើងពុំមែនជាទីកន្លែងតែមួយគត់ដែលយើងអាចថ្វាយបង្គំប៉ុណ្ណោះនោះទេ។ គេហដ្ឋានរបស់យើងក៏គប្បីជាទីកន្លែងនៃការឧទ្ទិសផងដែរ។ វាគឺជាការប្រសើរខ្លាំងណាស់ ប្រសិនបើយើងអាច ‘ចេញពីផ្ទះទៅកាន់ព្រះវិហារ’ជារៀងរាល់ថ្ងៃនោះ។ ត្មានទីកន្លែងណាផ្សេងទៀតដែលព្រះវិញ្ញាណ នៃព្រះអម្ចាស់មានការទទួលស្វាគមន៍ ហើយមានវត្តមានយ៉ាងងាយស្រួលបំផុតដូចនៅក្នុងគេហដ្ឋានរបស់យើងនោះឡើយ”។[9]

នៅពេលយើងខិតខំដើម្បីសំរេចបាននូវកិច្ចការទាំងអស់នេះនៅក្នុងគេហដ្ឋានរបស់យើង នោះយើងនឹងមានការចងចាំជានិច្ច ចំពោះសេចក្តីថ្លែងការណ៍ដ៏មានសារៈសំខាន់ ដែលប្រធាន ហារូ ប៊ីលី បានមានប្រសាសន៍ថា ៖ “សូមចងចាំថាកិច្ចការដ៏មានសារៈសំខាន់បំផុតរបស់ព្រះអម្ចាស់ ដែលអ្នក [និងរូបខ្ញុំ] ពុំធ្លាប់ធ្វើពីមុនមកនោះ . . . គឺនៅក្នុងរង្វង់នៃគេហដ្ឋាន [របស់យើង] ”។[10]

ពាក្យអង្វររបស់ខ្ញុំនាថ្ងៃនេះគឺថា យើងម្នាក់ៗនឹងថែទាំកិច្ចការនៅក្នុងគេហដ្ឋាន និងនៅឯតុបាយរបស់យើងដោយប្រុងប្រយ័ត្ន ហើយបន្តព្យាយាមនាំយកស្ថានសួគិចូលទៅក្នុងគេហដ្ឋានរបស់យើង ហើយនិងមករកព្រះយេស៊ូវគ្រីស្ទ។

ដកស្រង់ចេញមកពីសុន្ទរកថាដោយអែលឌើរ ខីតទីស នៅក្នុងសន្និសីទទូទៅនៃសាសនាចក្រ ខែ មេសា ឆ្នាំ 1995 (សូមមើល Conference Report ខែ មេសា ឆ្នាំ 1995 ទំព័រ 109–11 ឬ *Ensign* ខែ ឧសភា ឆ្នាំ 1995 ទំព័រ 82–83)។

កំណត់ចំណាំ

1. “Scriptures As They Relate to Family Stability” *Ensign* ខែ កុម្ភះ ឆ្នាំ 1972 ទំព័រ 57។
2. “Home Can Be a Heaven on Earth” *Hymns* ទំព័រ 298។
3. នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1994 ទំព័រ 74–75 ឬ *Ensign* ខែ វិច្ឆិកា ឆ្នាំ 1994 ទំព័រ 54។
4. *Pathways to Perfection* (ឆ្នាំ 1973) ទំព័រ 26–27។
5. នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1990 ទំព័រ 13 ឬ *Ensign* ខែ វិច្ឆិកា ឆ្នាំ 1990 ទំព័រ 12។
6. នៅក្នុង “President Howard W. Hunter: Fourteenth President of the Church” *Ensign* ខែ កក្កដា ឆ្នាំ 1994 ទំព័រ 4–5។
7. នៅក្នុង Emerson Roy West *Vital Quotations* (ឆ្នាំ 1968) ទំព័រ 171។
8. “Begin Where You Are—At Home” *Ensign* ខែ កុម្ភះ ឆ្នាំ 1972 ទំព័រ 71។
9. នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1989 ទំព័រ 78 ឬ *Ensign* ខែ វិច្ឆិកា ឆ្នាំ 1989 ទំព័រ 63។
10. *Strengthening the Home* (កូនស្សៀវភៅ ឆ្នាំ 1973) ទំព័រ 7។

ការបង្រៀនគោលការណ៍ដំណឹងល្អចំពោះកូនៗ

13

ភាគទី 1

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលះទេសះរបស់អ្នកផ្ទាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា 68:25–28។ នៅពេលអ្នកអានខគម្ពីរទាំងនេះ សូមកំណត់ឱ្យបានច្បាស់អំពីគោលការណ៍ និងពិធីបរិសុទ្ធទាំងឡាយដែលព្រះអម្ចាស់បានដាក់បញ្ញត្តិដល់ឱពុកម្តាយនៅក្នុងការបង្រៀនដល់កូនចៅរបស់ខ្លួន។ សូមធ្វើផែនការចំពោះកិច្ចការមួយចំនួនដែលអ្នកអាចធ្វើបាន នៅក្នុងការបង្រៀនគោលការណ៍ និងពិធីបរិសុទ្ធទាំងនេះដល់កូន ឬចៅរបស់អ្នក ព្រមទាំងទៅកាន់ក្មួយប្រុសស្រី ឬកុមារដទៃទៀតដែលអ្នកស្គាល់។
- នៅពេលអ្នកអានអត្ថបទដូចខាងក្រោមនេះ សូមផ្តោតការយកចិត្តទុកដាក់ទៅលើការណែនាំមួយ ឬពីរ ដែលផ្តល់ឱ្យដោយអែលឌើរ រ៉ូបឺត ឌី ហែល ។ ប្រសិនបើឱកាសផ្សេងគ្នាកើតមានឡើង សូមផ្តោតយកចិត្តទុកដាក់ទៅលើការណែនាំផ្សេងទៀតនៅក្នុងអត្ថបទទាំងនោះ។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

ការពង្រឹងក្រុមគ្រួសារ ៖ ករណីយកិច្ចដ៏ពិសិដ្ឋរបស់យើង

អែលឌើរ រ៉ូបឺត ឌី ហែល
នៃក្រុមនៃពួកសាវក 12 នាក់

ព្រះវិញ្ញាណពង្រឹងដល់ក្រុមគ្រួសារ

ការពង្រឹងដល់ក្រុមគ្រួសារគឺជាករណីយកិច្ចដ៏ពិសិដ្ឋរបស់យើង ក្នុងនាមជាឱពុកម្តាយ កូនចៅ សមាជិកគ្រួសារដទៃទៀត ពួកអ្នកដឹកនាំ និងសមាជិកនៃសាសនាចក្រម្នាក់ៗ។

សារះសំខាន់នៃការពង្រឹងខាងវិញ្ញាណដល់ក្រុមគ្រួសារ គឺត្រូវបានបង្រៀនយ៉ាងច្បាស់លាស់នៅក្នុងព្រះគម្ពីរ។ លោកអ័ដាម និងនាងអេវ៉ាបានបង្រៀនដំណឹងល្អដល់កូនប្រុសស្រីរបស់ខ្លួន។ គ្រៀងបូជារបស់អេបិលត្រូវបានទទួលយកដោយព្រះអម្ចាស់ជាព្រះដែលគាត់ស្រឡាញ់។ ផ្ទុយទៅវិញ កាអ៊ីន "បានស្រឡាញ់អារក្សសាតាំងជាងព្រះ" ហើយបានប្រព្រឹត្តអំពើបាបដ៏ធំ។ លោកអ័ដាម និងនាងអេវ៉ា "បានមានទុក្ខនៅចំពោះព្រះអម្ចាស់ពីព្រោះតែកាអ៊ីន និងបងប្អូនគាត់" ប៉ុន្តែពួកគេពុំដែលបោះបង់ចោលនូវការបង្រៀនដំណឹងល្អដល់កូនចៅរបស់ពួកគេឡើយ (សូមមើល ម៉ូសេ 5:12, 18, 20, 27; 6:1, 58)។

យើងត្រូវយល់ដឹងថា កូនចៅរបស់យើងម្នាក់ៗកើតមកជាមួយនឹងអំណោយទាន និងទេពកោសល្យផ្សេងៗគ្នា។ កុមារខ្លះ ដូចជា អេបិល ត្រូវបានប្រទានឱ្យនូវអំណោយទាននៃសេចក្តីជំនឿតាំងពីកំណើត។ កុមារផ្សេងទៀតមានការលំបាកចំពោះរាល់ការសំរេចចិត្តដែលពួកគេធ្វើ។ ក្នុងនាមជាឱពុកម្តាយ យើងពុំគួរបណ្តោយឱ្យការស្រាវជ្រាវ និងដំណើរការដ៏ស្មុគស្មាញរបស់កូនចៅយើង ធ្វើឱ្យយើងវៀចវេរ ឬបាត់បង់សេចក្តីជំនឿនៅលើព្រះអម្ចាស់នោះឡើយ។

អាលម៉ាជាកូន នៅពេល "ត្រូវបានញាំញីដោយការទុក្ខវេទនា . . . [ហើយ] កើតទុក្ខដោយការនឹកឃើញដល់អំពើបាបដ៏ច្រើន [របស់ខ្លួន]" បាននឹកឃើញថា ឱពុករបស់ខ្លួនធ្លាប់បានបង្រៀនអំពី "ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ដើម្បីមកធ្វើឱ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សលោក" (អាលម៉ា 36:17)។ ពាក្យសំដីរបស់ឱពុកគាត់បានដឹកនាំគាត់ឱ្យឈានទៅរកការផ្លាស់ប្រែចិត្តជឿ។ នៅក្នុងលក្ខណះដូចគ្នានេះដែរ ការបង្រៀន និងទីបន្ទាល់របស់យើងនឹងធ្វើឱ្យកូនចៅរបស់យើងមានការចងចាំ។

កងទ័ពកម្លោះ 2,000 នាក់នៅក្នុងពលទ័ពរបស់ហេលេមិនបានធ្វើទីបន្ទាល់ថា អ្នកម្តាយដ៏សុចរិតរបស់ពួកគេបានបង្រៀនគោលការណ៍ទាំងឡាយ នៃដំណឹងល្អពោរពេញដោយឥទ្ធិពលយ៉ាងខ្លាំងដល់ពួកគេ (សូមមើល អាលម៉ា 56:47–48)។

នៅគ្រានៃការស្វែងរកខាងវិញ្ញាណដ៏ធំ អេណុស បាននិយាយថា "ពាក្យទាំងឡាយដែលខ្ញុំតែងបានឲ្យឱពុកខ្ញុំនិយាយជាញឹកញាប់ អំពីជីវិតដ៏នៅអស់កល្បជានិច្ច . . . ជ្រួតជ្រាបទៅក្នុងដួងចិត្តរបស់ខ្ញុំ" (អេណុស 1:3)។

នៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា ព្រះអម្ចាស់បានមានព្រះបន្ទូលថា ឱពុកម្តាយទាំងឡាយត្រូវបង្រៀនកូនចៅរបស់ខ្លួន "ឱ្យយល់នូវគោលលទ្ធិអំពីការប្រែចិត្ត សេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ ជាព្រះព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅ និងអំពីបុណ្យជ្រមុជទឹក ហើយនិងអំពីអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដោយសារការដាក់ដៃលើ កាលមានអាយុប្រាំបីឆ្នាំ . . .។

"ហើយពួកគេក៏ត្រូវបង្រៀនកូនចៅរបស់ខ្លួនឱ្យអធិស្ឋាន និងឱ្យដើរដោយទៀងត្រង់នៅចំពោះព្រះអម្ចាស់" (គ. និង ស. 68:25, 28)។

ការបង្រៀនដំណឹងល្អពង្រឹងដល់ក្រុមគ្រួសារ

នៅពេលយើងបង្រៀនដំណឹងល្អដល់កូនចៅរបស់យើងតាមរយះពាក្យសំដី និងគំរូ នោះក្រុមគ្រួសាររបស់យើងនឹងត្រូវបានពង្រឹង ហើយក៏មានការការពារខាងផ្នែកវិញ្ញាណផងដែរ។

ពាក្យសំដីទាំងឡាយនៃពួកព្យាការីដែលនៅរស់បានបញ្ជាក់យ៉ាងច្បាស់ ទាក់ទងនឹងករណីយកិច្ចដ៏ពិសិដ្ឋរបស់យើង នៅក្នុងការពង្រឹងខាងផ្នែកវិញ្ញាណដល់ក្រុមគ្រួសាររបស់យើង។ នៅក្នុងឆ្នាំ 1995 គណះប្រធានទីមួយ និងក្រុមប្រឹក្សានៃពួកសាវក 12 នាក់ បានចេញនូវការប្រកាសមួយដល់ពិភពលោក ដោយបានប្រកាសថា "គ្រួសារ គឺជាផ្នែកសំខាន់មួយនៃផែនការរបស់ព្រះដ៏បង្កបង្កើតសំរាប់គោលដៅ

ដ៏អស់កល្បជានិច្ចនៃកូនចៅរបស់ព្រះអង្គ . . .។ គូស្វាមីភរិយាមានការទទួលខុសត្រូវខ្ពស់ ដើម្បីស្រឡាញ់ថែរក្សាគ្នាទៅវិញទៅមក ព្រមទាំងស្រឡាញ់ថែរក្សាកូនចៅរបស់ខ្លួនផង . . .។ ឪពុកម្តាយមានកាតព្វកិច្ចដ៏ពិសិដ្ឋ ក្នុងការថែរក្សាកូនចៅរបស់ខ្លួន ដោយសេចក្តីស្រឡាញ់ និងដោយសេចក្តីសុចរិត ដើម្បីកូនចៅខាងផ្លូវសាច់ឈាម និងផ្លូវវិញ្ញាណ តាមសេចក្តីត្រូវការរបស់ពួកគេ ដើម្បីបង្រៀនកូនចៅឱ្យចេះស្រឡាញ់គ្នា ហើយបំរើគ្នាទៅវិញទៅមក ចេះគោរពតាម ព្រះបញ្ញាត្តិទាំងឡាយនៃព្រះ” (“ក្រុមគួសារ៖ ការប្រកាសដល់ពិភពលោក” *Ensign* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 102)។

នៅក្នុងកុម្ភៈឆ្នាំនេះ គណៈប្រធានទីមួយបានចេញផ្សាយការអំពាវនាវមួយដល់ឪពុកម្តាយគ្រប់រូប “ឱ្យពលិកម្មនូវកិច្ចខិតខំដោយអស់ពីសមត្ថភាពរបស់ខ្លួន ចំពោះការបង្រៀន និងការបីបាច់ដល់កូនចៅរបស់ពួកគេ នៅក្នុងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ដែលនឹងរក្សាពួកគេឱ្យខិតជិតនឹងសាសនាចក្រ។ គេហដ្ឋានគឺជាគ្រឹះនៃជីវិតសុចរិត ហើយគ្មានទីកន្លែងណាមួយផ្សេងទៀតអាចជួយ ឬមកបំពេញតួនាទីដ៏សំខាន់នៅក្នុងការអនុវត្តន៍ការទទួលខុសត្រូវនេះ ដែលព្រះទ្រង់បានប្រទានឱ្យនោះឡើយ”។

នៅក្នុងសារលិខិតខែកុម្ភៈ គណៈប្រធានទីមួយបានបង្រៀនថា តាមរយៈការបង្រៀន និងការបីបាច់កូនចៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ នោះឪពុកម្តាយអាចការពារក្រុមគ្រួសាររបស់ខ្លួនឱ្យរួចផុតពីសារធាតុកាចសាហាវទាំងឡាយ។ ពួកលោកបានទូន្មានដល់ឪពុកម្តាយ និងកូនចៅទាំងឡាយបន្ថែមទៀតថា “ឱ្យផ្តល់អាទិភាពជ័ន្លស់បំផុតដល់ការអធិស្ឋានជាគ្រួសារ រាត្រីជួបជុំក្រុមគ្រួសារ ការសិក្សា និងការបង្រៀនអំពីដំណឹងល្អ និងសកម្មភាពជាគ្រួសារល្អៗផ្សេងទៀត។ ទោះបីជាតំរូវការ ឬសកម្មភាពផ្សេងទៀតមានភាពសក្តិសម ឬមានភាពសមរម្យយ៉ាងណាក៏ដោយ ក៏សកម្មភាពទាំងនេះមិនត្រូវបានអនុញ្ញាតឱ្យជំនួសដល់ករណីយកិច្ចដ៏ទេវភាពដែលបានទទួលការតែងតាំងនេះបានឡើយ វាគឺជាកិច្ចការដែលមានតែឪពុកម្តាយ និងគ្រួសារប៉ុណ្ណោះទើបអាចធ្វើកិច្ចការនេះបាន” (First Presidency letter, 11 Feb. 1999 ចុះផ្សាយនៅក្នុង *Church News* ថ្ងៃទី 27 ខែ កុម្ភៈ ឆ្នាំ 1999 ទំព័រ 3)។

ដោយមានជំនួយពីព្រះអម្ចាស់ និងគោលលទ្ធិរបស់ទ្រង់ នោះរាល់កិច្ចខិតខំដែលពោរពេញទៅដោយការឈឺចាប់មកពីឧបសគ្គទាំងឡាយ ដែលគ្រួសារមួយអាចនឹងជួបប្រទះនឹងត្រូវបានយល់ដឹង ហើយមានជ័យជំនះ។ ទោះបីជាសមាជិកគ្រួសារមានតំរូវការណាមួយក៏ដោយ ក៏យើងអាចពង្រឹងដល់ក្រុមគ្រួសាររបស់យើង នៅពេលយើងធ្វើតាមពាក្យទូន្មានដែលបានផ្តល់ឱ្យដោយពួកព្យាការី។

គន្លឹះនៅក្នុងការពង្រឹងដល់ក្រុមគ្រួសាររបស់យើងគឺជាការមានព្រះវិញ្ញាណនៃព្រះអម្ចាស់គង់នៅក្នុងគេហដ្ឋានរបស់យើង។ គោលដៅនៃក្រុមគ្រួសាររបស់យើងគឺត្រូវស្ថិតនៅលើផ្លូវត្រង់ និងចង្អៀត។

យោបល់សំរាប់ការពង្រឹងដល់ក្រុមគ្រួសារ

មានរឿងជាច្រើនដែលមិនអាចរៀបរាប់អស់ អាចសំរេចទៅបាននៅក្នុងរង្វង់នៃគេហដ្ឋានរបស់យើង ដើម្បីពង្រឹងដល់ក្រុមគ្រួសារ។ ខ្ញុំសូមចែកចាយយោបល់មួយចំនួនដែលអាចជួយជ្រោមជ្រែងដល់ការពង្រឹងក្រុមគ្រួសាររបស់យើង។ ខ្ញុំសូមផ្តល់យោបល់ទាំងនេះនៅក្នុងវិញ្ញាណនៃការលើកទឹកចិត្ត ដោយដឹងថាគ្រួសារនិមួយៗ—និងការសមាជិកគ្រួសារគ្រប់រូប—គឺមានតម្លៃវិសេសវិសាលខ្លាំងណាស់។

គេហដ្ឋានគឺជាកន្លែងនៃសេចក្តីសុខសាន្ត

- សូមធ្វើឱ្យគេហដ្ឋានរបស់យើងក្លាយទៅជាទីកន្លែងនៃសេចក្តីសុខសាន្តមួយដែលសមាជិកគ្រួសារគ្រប់រូបអាចទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់ និងអារម្មណ៍នៃភាពជាសមាជិក។ សូមជឿជាថា កូនម្នាក់ៗមានអំណោយទាន និងទេពកោសល្យផ្សេងគ្នា ពួកគេម្នាក់ៗគឺជាបុគ្គលដែលត្រូវការសេចក្តីស្រឡាញ់ និងការយល់ចិត្តជាពិសេស។
- សូមចងចាំថា “ពាក្យតបឆ្លើយដោយស្រទន់ នោះរមែងរំងាប់សេចក្តីក្រោធទៅ” (សុភាសិត 15:1)។ នៅពេលភរិយាជាទីស្រឡាញ់របស់ខ្ញុំ ហើយនិងខ្ញុំបានផ្សាភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធសលត៍ លេក អែលឌើរ ហារ៉ូល ប៊ី លីបានផ្តល់ពាក្យទូន្មានដ៏ល្អសំរាប់ពួកយើងថា ៖ “នៅពេលអ្នកបន្លឺសំលេងរបស់អ្នកនៅក្នុងសេចក្តីក្រោធ នោះព្រះវិញ្ញាណនឹងចាកចេញពីគេហដ្ឋានរបស់អ្នក”។ យើងមិនត្រូវមានសេចក្តីក្រោធឡើយ សូមចាក់សោទ្វារនៃគេហដ្ឋានរបស់យើង ឬដួងចិត្តរបស់យើងចំពោះកូនចៅរបស់យើង។ បើប្រប្រួបធ្យូបនឹងកូនប្រុសដ៏ខ្ជះខ្ជាយ កូនចៅរបស់យើងក៏ត្រូវការដឹងផងដែរថា នៅពេលការណ៍ទាំងនោះកើតមានឡើងចំពោះពួកគេ នោះពួកគេអាចបែរមករកយើងដើម្បីអាចទទួលបានសេចក្តីស្រឡាញ់ និងពាក្យទូន្មានផងដែរ។
- សូមចំណាយពេលផ្ទាល់ខ្លួនជាមួយនឹងកូនម្នាក់ៗរបស់យើង ដោយអនុញ្ញាតឱ្យពួកគេជ្រើសរើសសកម្មភាព និងប្រធានបទសំរាប់ការសន្ទនា។ សូមធ្វើកុំឱ្យមានការរំខាន។

បង្រៀនកូនចៅឱ្យអធិស្ឋាន អានព្រះគម្ពីរ និងស្តាប់តន្ត្រីសក្តិសម

- សូមលើកទឹកចិត្តកូនចៅយើងឱ្យមានគរិយាបទខាងសាសនាផ្ទាល់ខ្លួន ដូចជាការអធិស្ឋានផ្ទាល់ខ្លួន ការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន និងការតមអាហារសំរាប់សេចក្តីត្រូវការដ៏ជាក់លាក់។ សូមវាស់វែងនូវការលូតលាស់ខាងវិញ្ញាណរបស់ពួកគេ ដោយអង្កេតមើលចំពោះគរិយាបទ ពាក្យសំដី និងការប្រព្រឹត្តរបស់ពួកគេចំពោះអ្នកដទៃ។
- សូមអធិស្ឋានជារ្យៀងរាល់ថ្ងៃជាមួយនឹងកូនចៅរបស់យើង។
- សូមអានព្រះគម្ពីររួមគ្នា។ ខ្ញុំចងចាំថា ឪពុកម្តាយរបស់ខ្ញុំបានអានព្រះគម្ពីរជាមួយពួកយើង ខណៈដែលយើងអង្គុយនៅលើគ័ដ្ឋ ហើយត្រងត្រាប់ស្តាប់។ ជួនកាលពួកគាត់បានសួរថា “តើខគម្ពីរនោះមានអត្ថន័យយ៉ាងណាចំពោះកូនគ្រប់គ្នា?” ឬថា “តើខគម្ពីរនោះបានធ្វើឱ្យកូនរាល់គ្នាមានអារម្មណ៍យ៉ាងណាដែរ?” បន្ទាប់មកពួកគាត់នឹងស្តាប់យើង នៅពេលយើងឆ្លើយតបនៅក្នុងពាក្យពេចន៍របស់យើងផ្ទាល់។
- សូមអានពាក្យសំដីនៃពួកព្យាការីដែលនៅរស់ និងអត្ថបទដែលបំផុសគំនិតផ្សេងទៀតសំរាប់កុមារ យុវវ័យ និងក្មេងដំទង់នៅក្នុងទស្សនាវដ្តីសាសនាចក្រ។
- យើងអាចបំពេញគេហដ្ឋានរបស់យើងជាមួយនឹងសំលេងនៃតន្ត្រីសក្តិសមនៅពេលយើងច្រៀងរួមគ្នាចេញពីស្បៃវត៌ទំនុកដំកើងព្រះ និង *ចំរៀងកុមារា កុមារី*។

ការធ្វើរាត្រីជួបជុំក្រុមគ្រួសារ និងក្រុមប្រឹក្សាគ្រួសារ

- សូមធ្វើរាត្រីជួបជុំក្រុមគ្រួសារជារ្យៀងរាល់សប្តាហ៍។ ក្នុងទាមជាឪពុកម្តាយជួនកាលយើងក៏មានការសម្លុតដើម្បីបង្រៀន ឬធ្វើទីបន្ទាល់ដល់កូនចៅរបស់យើងផងដែរ។ ខ្ញុំក៏មានការរអ៊ូសខ្លួនផងដែរចំពោះបញ្ហានេះនៅក្នុងឆាកជីវិត

របស់ខ្ញុំ។ កូនចៅរបស់យើងចង់ឱ្យយើងចែកចាយអំពីអារម្មណ៍ខាងវិញ្ញាណជាមួយនឹងពួកគេ ដោយបង្រៀនដល់ពួកគេ និងដោយធ្វើទីបន្ទាល់ទៅកាន់ពួកគេ។

- សូមធ្វើការប្រឹក្សាគ្រួសារដើម្បីពិភាក្សាអំពីផែនការ និងកង្វល់ប្រចាំគ្រួសារ។ ការប្រឹក្សាគ្រួសារដ៏មានប្រសិទ្ធភាពបំផុតមួយចំនួន គឺជាការជួបនិយាយដោយផ្ទាល់ជាមួយនឹងសមាជិកគ្រួសារម្នាក់ៗ។ សូមជួយកូនចៅរបស់យើងឱ្យដឹងថា យោបល់របស់ពួកគេមានសារៈសំខាន់ណាស់។ សូមស្តាប់ពួកគេ ហើយរៀនពីពួកគេ។

ចែកចាយដំណឹងល្អ គាំទ្រដល់ពួកអ្នកដឹកនាំសាសនាចក្រ និងចូលរួមជាគ្រួសារ

- សូមអញ្ជើញពួកអ្នកផ្សព្វផ្សាយសាសនាឱ្យបង្រៀនសមាជិកអសកម្ម ឬមិត្តភក្តិដែលពុំជាសមាជិកនៅក្នុងគេដឋានរបស់អ្នក។
- សូមបង្ហាញថា យើងគាំទ្រ និងជួយជ្រោមជ្រែងដល់ពួកអ្នកដឹកនាំសាសនាចក្រ។
- សូមបរិភោគអាហាររួមគ្នា ប្រសិនបើអាចធ្វើទៅបាន ហើយសូមធ្វើការពិភាក្សាដ៏មានអត្ថន័យនៅឯតុអាហារ។
- សូមធ្វើការរួមគ្នាជាគ្រួសារ ទោះបីជាកិច្ចការនោះអាចនឹងធ្វើឱ្យរួចរាល់នៅក្នុងរយៈពេលយ៉ាងឆាប់រហ័សមួយ ឬក៏មានលក្ខណៈងាយស្រួលនៅក្នុងការធ្វើវាដោយខ្លួនឯងក៏ដោយ។ សូមនិយាយជាមួយនឹងកូនប្រុសស្រីរបស់យើង នៅពេលយើងធ្វើការរួមគ្នា។ ខ្ញុំមានឱកាសបែបនោះនៅរៀងរាល់ថ្ងៃសៅរ៍ជាមួយនឹងឪពុករបស់ខ្ញុំ។

ការបង្រៀនកូនចៅឱ្យក្លាយជាមិត្តល្អ ហើយរៀបចំខ្លួនសំរាប់ពេលអនាគត

- សូមជួយកូនចៅរបស់យើងឱ្យរៀនស្វែងរកអំពីរបៀបបង្កើតមិត្តភាពល្អ និងធ្វើឱ្យមិត្តភក្តិរបស់ពួកគេទទួលអារម្មណ៍ស្វាគមន៍នៅក្នុងគេហដ្ឋានរបស់យើង។ សូមព្យាយាមស្គាល់ឪពុកម្តាយនៃមិត្តភក្តិរបស់កូនចៅយើង។
- សូមបង្រៀនកូនចៅរបស់យើង តាមរយៈការធ្វើជាគំរូនៅក្នុងការគ្រប់គ្រងពេលវេលា និងធនធានទានា។ សូមជួយពួកគេឱ្យរៀនអំពីភាពខ្លួនទីពឹងខ្លួន និងអំពីសារៈសំខាន់នៃការរៀបចំខ្លួនសំរាប់ពេលអនាគត។

ការចែកចាយកេរដំណែល និងប្រពៃណីរបស់គ្រួសារ

- សូមបង្រៀនកូនចៅរបស់យើងអំពីប្រវត្តិនៃបុព្វការីជន និងអំពីពង្សប្រវត្តិរបស់យើង។
- សូមបង្កើតប្រពៃណីរបស់គ្រួសារ។ សូមធ្វើផែនការ និងការដើរកំសាន្តដ៏រីករាយជាមួយគ្នា ដោយពិចារណាអំពីសេចក្តីត្រូវការ ទេពកោសល្យ និងសមត្ថភាពរបស់ពួកគេ។ សូមជួយពួកគេបង្កើតនូវអនុស្សាវរីយ៍ដ៏រីករាយ អភិវឌ្ឍទេពកោសល្យរបស់ពួកគេ និងបង្កើតអារម្មណ៍នៃទំនុកចិត្តចំពោះខ្លួនឯង។

ការបង្រៀនអំពីសារៈសំខាន់នៃការគោរពប្រណិបត្តិព្រះបញ្ញត្តិ និងការទទួលពិធីបរិសុទ្ធ

- តាមរយៈពាក្យសំដី និងគំរូ សូមបង្រៀនអំពីតម្លៃខាងសីលធម៌ និងការតាំងចិត្តមួយនៅក្នុងការគោរពតាមព្រះបញ្ញត្តិ។
- បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក និងការបញ្ជាក់របស់ខ្ញុំមក ម្តាយរបស់ខ្ញុំបានទាំខ្ញុំទៅជ្រុងម្ខាង ហើយសួរថា “តើកូនមានអារម្មណ៍យ៉ាងដូចម្តេចដែរ?” ខ្ញុំបានរៀបរាប់ដោយអស់ពីសមត្ថភាពរបស់ខ្ញុំ នូវអារម្មណ៍ដ៏កក់ក្តៅនៃសេចក្តីសុខសាន្ត ការលួងលួង និងសុភមង្គលដែលខ្ញុំមាន។ ម្តាយរបស់ខ្ញុំបានពន្យល់ថា អារម្មណ៍ដែលខ្ញុំកំពុងតែមានគឺជាអំណោយទាន ដែលខ្ញុំទើបតែបានទទួល ជាអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។ គាត់បានត្រាប់ដល់ខ្ញុំថា បើសិនជាខ្ញុំរស់នៅឱ្យមានភាពសក្តិសមចំពោះអំណោយទាននេះ នោះខ្ញុំនឹងមានអំណោយទាននោះជារៀងរហូត។ នោះគឺជាខណៈពេលនៃការបង្រៀនមួយដែលបានដក់ជាប់នៅក្នុងចិត្តរបស់ខ្ញុំជានិច្ច។

សូមបង្រៀនកូនចៅរបស់យើងអំពីសារៈសំខាន់នៃពិធីបុណ្យជ្រមុជទឹក និងការបញ្ជាក់ ដោយការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ការទទួលទានសាក្រាម៉ង់ ការគោរពដល់បព្វជិតភាព ព្រមទាំងការធ្វើ និងការរក្សាសេចក្តីសញ្ញានៅក្នុងព្រះវិហារបរិសុទ្ធ។ ពួកគេត្រូវដឹងអំពីសារៈសំខាន់នៃការរស់នៅដ៏សក្តិសមចំពោះប័ណ្ណចូលព្រះវិហារបរិសុទ្ធ និងការរៀបចំខ្លួនសំរាប់អាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ។

- ប្រសិនបើអ្នកពុំទាន់បានផ្សាភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធជាមួយនឹងស្វាមី ឬភរិយា ព្រមទាំងកូនចៅរបស់អ្នកនោះ សូមធ្វើកិច្ចខិតខំជាគ្រួសារដើម្បីទទួលពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធ។ សូមរៀបចំគោលដៅជាគ្រួសារ។
- បងប្អូនប្រុស សូមមានភាពសក្តិសមចំពោះបព្វជិតភាពដែលអ្នកកាន់ ហើយប្រើបព្វជិតភាពនេះដើម្បីប្រទានពរដល់ជីវិតនៃគ្រួសាររបស់អ្នក . . .។

ចូរមានឆន្ទៈចូលរួមនៅក្នុងសកម្មភាពរបស់សមាគមសាលារៀន និងសាសនាចក្រ

នៅខាងក្រៅគេហដ្ឋានគឺមានធនធានជាច្រើន។ ការប្រើប្រាស់ធនធានទាំងនោះដោយឈ្លាសវៃ នឹងពង្រឹងដល់ក្រុមគ្រួសាររបស់យើង។

- សូមលើកទឹកចិត្តកូនចៅរបស់យើងឱ្យបំរើនៅក្នុងសាសនាចក្រ និងនៅក្នុងសមាគម។
- សូមនិយាយទៅកាន់ពួកគ្រូបង្រៀន គ្រូបង្ហាត់ អ្នកប្រឹក្សា អ្នកណែនាំ និងអ្នកដឹកនាំសាសនាចក្ររបស់កូនចៅយើង អំពីបញ្ហា និងសេចក្តីត្រូវការទាំងឡាយរបស់កូនចៅយើង។
- សូមជឹងអំពីអ្វីដែលកូនចៅរបស់យើងចូលចិត្តធ្វើនៅក្នុងពេលទំនេរ។ សូមត្រួតពិនិត្យចំពោះការជ្រើសរើសរបស់ពួកគេ ដែលទាក់ទងនឹងខ្សែភាពយន្ត កម្មវិធីទូរទស្សន៍ និងខ្សែវីដេអូ។ ប្រសិនបើពួកគេកំពុងប្រើប្រាស់អ៊ិនធើរណែត សូមជឹងអំពីអ្វីដែលពួកគេកំពុងធ្វើ។ សូមជួយពួកគេឱ្យមើលឃើញអំពីសារៈសំខាន់នៃការកំសាន្តដ៏សមរម្យ។
- សូមលើកទឹកចិត្តឱ្យមានសកម្មភាពល្អៗនៅក្នុងសាលារៀន។ សូមជឹងអំពីអ្វីដែលកូនចៅរបស់យើងកំពុងសិក្សា។ សូមជួយពួកគេនៅក្នុងការធ្វើកិច្ចការសាលា។ សូមជួយពួកគេយល់ដឹងអំពីសារៈសំខាន់នៃការអប់រំ និងអំពីការរៀបចំខ្លួនសំរាប់ការងារ ហើយនិងភាពខ្លួនទីពឹងខ្លួន។
- យុវនារី ៖ សូមចូលរួមនៅក្នុងសមាគមសង្គ្រោះ នៅពេលអ្នកមានអាយុ 18 ឆ្នាំ។ អ្នករាល់គ្នាមួយចំនួនអាចនឹងមានការទើសទាល់នៅក្នុងការផ្លាស់ប្តូរនេះ។ អ្នករាល់គ្នាអាចនឹងមានការភ័យខ្លាចថា អ្នកនឹងមិនអាចសំរបខ្លួនបានឡើយ។

បងប្អូនស្រីវ័យក្មេងទាំងឡាយរបស់ខ្ញុំអើយ ការណ៍នេះពុំមែនជាបញ្ហានោះឡើយ។ នៅក្នុងសមាគមសង្ក្រោះមានទូវអ្វីៗជាច្រើនដែលអ្នកត្រូវរៀន។ វាអាចក្លាយទៅជាពរជ័យមួយសំរាប់ជីវិតរបស់អ្នក។

- យុវជន ៖ សូមគោរពដល់បព្ចជិតភាពអើរ៉ុន។ បព្ចជិតភាពនេះគឺជាបព្ចជិតភាពរៀបចំខ្លួន ដែលនឹងរៀបចំអ្នកសំរាប់បព្ចជិតភាពមិលគីស្សាដែក។ សូមចូលរួមយ៉ាងសកម្មនៅក្នុងក្រុមអែលឌើរ នៅពេលអ្នកត្រូវបានតែងតាំងនៅក្នុងបព្ចជិតភាពមិលគីស្សាដែក។ ភាពជាបងប្អូនប្រុស ការបង្រៀនជាក្រុម និងឱកាសនៅក្នុងការបំរើអ្នកដទៃនឹងប្រសិទ្ធពរដល់អ្នករាល់គ្នា និងគ្រួសាររបស់អ្នកពេញមួយជីវិតរបស់អ្នក។

ធ្វើតាមគំរូនៃសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់

គ្រប់ក្រុមគ្រួសារអាចត្រូវបានពង្រឹងនៅក្នុងរបៀបផ្សេងៗពីគ្នា ប្រសិនបើព្រះវិញ្ញាណនៃព្រះអម្ចាស់ ត្រូវបានដឹកនាំឱ្យចូលទៅក្នុងគេហដ្ឋានរបស់យើង ហើយយើងបង្រៀនតាមគំរូរបស់ទ្រង់។

- សូមប្រព្រឹត្តដោយសេចក្តីជំនឿ ៖ សូមកុំមានប្រតិកម្មចំពោះសេចក្តីភ័យខ្លាច។ នៅពេលកូនចៅវ័យជំទង់របស់យើងចាប់ផ្តើមសាកល្បងចំពោះតម្លៃគ្រួសារនោះឱពុកម្តាយទាំងឡាយ ត្រូវទៅរកព្រះអម្ចាស់សំរាប់ការណែនាំ ស្តីអំពីសេចក្តីត្រូវការដ៏ជាក់លាក់នៃសមាជិកគ្រួសារម្នាក់ៗ។ នេះគឺជាពេលវេលាសំរាប់ការបន្ថែមសេចក្តីស្រឡាញ់ និងការជួយជ្រោមជ្រែង ហើយនិងដើម្បីពង្រឹងជាថ្មីចំពោះការបង្រៀនរបស់អ្នកអំពីរបៀបនៅក្នុងការធ្វើការសំរេចចិត្ត។ វាគឺជាការគួរឱ្យភ័យខ្លាចដែលបណ្តោយឱ្យកូនចៅរបស់យើង រៀនចេញពីកំហុសដែលពួកគេបានធ្វើ ប៉ុន្តែឆន្ទះរបស់ពួកគេដើម្បីជ្រើសរើសរបៀបរបស់ព្រះអម្ចាស់ និងតម្លៃនៃគ្រួសារគឺមានភាពអស្ចារ្យ នៅពេលការជ្រើសរើសនោះកើតឡើងចេញពីដួងចិត្ត ជាជាងនៅពេលយើងព្យាយាមបង្ខិតបង្ខំឱ្យពួកគេស្វែងរកតម្លៃទាំងនោះ។ របៀបរបស់ព្រះអម្ចាស់ស្តីអំពីសេចក្តីស្រឡាញ់ និងការទទួលយក គឺមានភាពប្រសើរជាងរបៀបរបស់សាតាំងស្តីអំពីការបង្តាប់ និងការបង្ខិតបង្ខំ ជាពិសេសនៅក្នុងចិញ្ចឹមបីបាច់កូនចៅវ័យជំទង់។

- សូមចងចាំប្រសាសន៍របស់ព្យាការីយ៉ូសែប ស្មីធ ថា ៖ "គ្មានអ្វីមួយដែលសំខាន់ជាងការដឹកនាំមនុស្សឱ្យលះបង់អំពើបាប ដោយដឹកដៃរបស់ពួកគេ ហើយមើលថែពួកគេដោយភាពទន់ភ្លន់នោះឡើយ។ នៅពេលបុគ្គលទាំងឡាយបង្ហាញសេចក្តីមេត្តាកុរណា និងសេចក្តីស្រឡាញ់តែបន្តិចបន្តួចចំពោះខ្ញុំ សេចក្តីស្រឡាញ់នោះបានមានអំណាចខ្លាំងណាស់មកលើគំនិតរបស់ខ្ញុំ ខណៈដែលរឿងផ្ទុយគ្នាមានទូវនិន្នាការមួយ ដើម្បីរៀបចំអារម្មណ៍អាក្រក់ និងភាពក្រៀមក្រំនៅក្នុងគំនិតរបស់មនុស្សលោក" (*Teachings of the Prophet Joseph Smith* រៀបរៀងដោយ Joseph Fielding Smith [1976] ទំព័រ 240)។

កូនចៅដែលដើរខុសផ្លូវនឹងវិលត្រឡប់មកវិញ

- បន្ទាប់ពីយើងបានធ្វើអ្វីៗគ្រប់យ៉ាងហើយក៏ដោយ ក៏យើងអាចនឹងទទួលបានទូវសេចក្តីអស់សង្ឃឹមផងដែរ នៅពេលកូនចៅរបស់យើងមួយចំនួនបានចាកចេញពីផ្លូវនៃសេចក្តីសុចរិតនោះ ប៉ុន្តែពាក្យសំដីរបស់ អូសុន អែហ្ស រីតនី អាចលួងលោមយើងបាន ដោយគាត់បាននិយាយថា ៖ "ទោះបីជាកូនចៀមមួយចំនួនអាចនឹងវង្វេងផ្លូវក៏ដោយ ប៉ុន្តែព្រះនេត្រនៃអ្នកគង្វាលគឺនៅតែសម្លឹងមើលមកលើពួកគេដដែល ហើយមិនយូរប៉ុន្មានពួកគេនឹងទទួលអារម្មណ៍នូវព្រះហត្ថ នៃទិព្ចញ្ញាណដ៏ទេវភាពដែលឈោងទៅចាប់ពួកគេ ហើយនាំពួកគេត្រឡប់មកឯក្រោលវិញ។ ទោះបីជានៅក្នុងជីវិតនេះ ឬនៅជីវិតក្រោយក៏ដោយ នោះពួកគេនឹងវិលត្រឡប់មកវិញ។ ពួកគេនឹងត្រូវបង់ថ្លៃសំណងរបស់ពួកគេចំពោះយុត្តិធមិ ពួកគេនឹងរងទុក្ខចំពោះអំពើបាបរបស់ខ្លួន ហើយពួកគេអាចនឹងដើរនៅលើផ្លូវបន្លាមួយ ប៉ុន្តែប្រសិនបើ នៅទីបំផុតការណ៍នេះនឹងដឹកនាំពួកគេទៅកាន់ដួងចិត្តរបស់ឱពុក [និងម្តាយ] ជាទីស្រឡាញ់ និងមានការអភ័យទោស ដូចជាកូនប្រុសខ្ជះខ្ជាយដែលមានការនឹកស្តាយ នោះបទពិសោធន៍ដ៏ឈឺចាប់ទាំងនេះនឹងមិនឥតប្រយោជន៍ឡើយ។ សូមអធិស្ឋានសំរាប់កូនចៅដែលធ្វេសប្រហែស និងមិនស្តាប់បង្តាប់ [របស់យើង] សូមឱបក្រសោបពួកគេជាមួយនឹងសេចក្តីជំនឿ[របស់យើង]។ សូមមានសេចក្តីសង្ឃឹម សេចក្តីទុកចិត្ត រហូតដល់អ្នកបានឃើញនូវសេចក្តីសង្ក្រោះនៃព្រះ" (ការដកស្រង់ពាក្យសំដី យ៉ូសែប ស្មីធ នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1929 ទំព័រ 110)។

ពួកមជ្ឈឹមវ័យនៅលីវ និងសមាជិកគ្រួសារដទៃទៀតអាចផ្តល់ជាកម្លាំង

- ចុះប្រសិនបើអ្នករាល់គ្នានៅលីវ ឬមិនត្រូវបានប្រទានពរឱ្យមានកូនចៅវិញ? តើអ្នកត្រូវមានការខ្វាយខ្វល់អំពីពាក្យទូន្មាននោះ ស្តីអំពីក្រុមគ្រួសារដែរឬទេ? ពិតប្រាកដណាស់។ នេះគឺជាអ្វីមួយដែលយើងទាំងអស់គ្នាត្រូវរៀនសូត្រនៅក្នុងជីវិតលើផែនដីនេះ។ ជាញឹកញាប់ សមាជិកមជ្ឈឹមវ័យទាំងឡាយដែលនៅលីវ អាចផ្តល់ជាកម្លាំងដ៏ពិសេសមួយប្រភេទដល់គ្រួសារ ដោយប្រែក្លាយទៅជាប្រភពនៃការគាំទ្រ ការទទួលយក និងសេចក្តីស្រឡាញ់ដ៏ធំមួយចំពោះគ្រួសាររបស់ខ្លួន និងក្រុមគ្រួសារនៃពួកអ្នកដែលរស់នៅជុំវិញពួកគេ។

- មានសមាជិកគ្រួសារដទៃទៀតជាច្រើន ដែលស្ថិតនៅក្នុងមជ្ឈឹមវ័យបានដើរតួជាឱពុកម្តាយនៅក្នុងកិច្ចការជាច្រើន ដោយសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ។ ជីដូនជីតាពូមីង បងប្អូនប្រុសស្រី ក្មួយប្រុសក្មួយស្រី បងប្អូនជីដូនមួយ និងសមាជិកគ្រួសារដទៃទៀតអាចមានឥទ្ធិពលដ៏ធំចំពោះគ្រួសារ។ ខ្ញុំចង់សម្តែងចេញនូវអំណរគុណរបស់ខ្ញុំ ចំពោះសមាជិកគ្រួសារផ្សេងទៀតរបស់ខ្ញុំ ដែលបានណែនាំខ្ញុំតាមរយះគំរូ និងទីបន្ទាល់របស់ពួកគេ។ ពេលខ្លះ សមាជិកគ្រួសារផ្សេងទៀតអាចនិយាយនូវអ្វីដែលឱពុកម្តាយមិនអាចនិយាយបាន ដោយគ្មានការចាប់ផ្តើមទាស់គំនិតគ្នាឡើយ។ មានយុវនារីម្នាក់ បន្ទាប់ពីមានការពិភាក្សាដែលផុសចេញពីដួងចិត្តដ៏យូរមួយជាមួយម្តាយរបស់នាងមក នាងបាននិយាយថា ៖ "វាគឺរឿងដែលគួរឱ្យព្រួយបារម្ភ ដោយប្រាប់ម៉ាក់ ហើយនិងប៉ាថា ខ្ញុំបានធ្វើនូវរឿងដែលខុសឆ្គងមួយនោះ។ ប៉ុន្តែ រឿងនោះកាន់តែអាក្រក់ទៅទៀត បើខ្ញុំប្រាប់អ្នកមីងស៊ូសិន។ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនអាចធ្វើឱ្យគាត់អាប់មុខបានឡើយ"។

គ្មានក្រុមគ្រួសារណាមួយដែលល្អឥតខ្ចោះនោះទេ

ការដឹងថា យើងស្ថិតនៅក្នុងជីវិតរមែងស្លាប់នេះដើម្បីរៀនសូត្រ និងដើម្បីអភិវឌ្ឍសេចក្តីជំនឿរបស់យើង នោះយើងគប្បីយល់ដឹងថា មានការផ្ទុយចំពោះរឿងសព្វសារពើផងដែរ។ អំឡុងពេលនៃការប្រឹក្សាគ្រួសារមួយនៅក្នុងគេហដ្ឋានរបស់ខ្ញុំ ភរិយារបស់ខ្ញុំបាននិយាយថា "នៅពេលអ្នកគិតថា មនុស្សម្នាក់មានគ្រួសារដ៏ល្អឥតខ្ចោះមួយនោះ នោះមានន័យថាអ្នកមិនទាន់យល់អំពីបញ្ហានេះឱ្យបានដិតដល់នៅឡើយនោះទេ"។

រៀបចំគេហដ្ឋាន និងគ្រួសារឱ្យមានរបៀបរៀបរយ

បងប្អូនប្រុសស្រីទាំងឡាយ ក្នុងនាមយើងជាឪពុកម្តាយ ចូរយើងស្តាប់ពាក្យដាស់តឿន ទាំងជាពាក្យស្តីបន្ទោស ដែលព្រះអម្ចាស់បានប្រទានដល់យ៉ូសែប ស៊្មីធ និងពួកអ្នកដឹកនាំនៃសាសនាចក្រនៅក្នុងឆ្នាំ 1833 ដោយទ្រង់មានបន្ទូលថា ឱ្យ “តាំងគេហដ្ឋាន [របស់យើង] ឱ្យមានរបៀបរៀបរយ” (គ. និង ស. 93:43)។ “យើងបានបញ្ជាដល់អ្នកឱ្យចិញ្ចឹមកូនចៅរបស់ខ្លួននៅក្នុងពន្លឺ និងសេចក្តីពិត” (គ. និង ស. 93:40)។ “ត្រូវរៀបចំគ្រួសារ [របស់យើង] ឱ្យមានរបៀបរៀបរយ ហើយត្រូវមើលឱ្យឃើញថា ពួកគេមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង ហើយត្រូវអធិស្ឋានជានិច្ច បើពុំនោះសោតទេ ពួកគេនឹងត្រូវដកចេញពីកន្លែងរបស់ពួកគេ” (គ. និង ស. 93:50)។

ពួកព្យាការីនាសម័យរបស់យើងបានផ្តល់ឱ្យនូវពាក្យដាស់តឿនដូចគ្នានេះដែរដល់ឪពុកម្តាយឱ្យរៀបចំក្រុមគ្រួសាររបស់យើង ឱ្យមានរបៀបរៀបរយ។ សូមឱ្យយើងត្រូវបានប្រទានពរឱ្យជាមួយនឹងការបំផុសគំនិត និងសេចក្តីស្រឡាញ់ ដើម្បីប្រឈមមុខដោយសេចក្តីទៅនឹងរឿងផ្ទុយគ្នានៅក្នុងគ្រួសាររបស់យើង។ បន្ទាប់មកយើងនឹងដឹងថា ការសាកល្បងរបស់យើងនឹងនាំយើងខិតទៅជិតព្រះអម្ចាស់ ហើយធ្វើឱ្យយើងមានភាពជិតស្និទចំពោះគ្នាទៅវិញទៅមក។ សូមឱ្យយើងស្តាប់សំលេងរបស់ព្យាការី ហើយរៀបចំគេហដ្ឋានរបស់យើងឱ្យមានរបៀបរៀបរយ (សូមមើល គ. និង ស. 93:41–49)។ គ្រួសារនឹងមានភាពរឹងមាំ នៅពេលយើងខិតទៅជិតព្រះអម្ចាស់ ហើយសមាជិកគ្រួសារម្នាក់ៗនឹងត្រូវបានពង្រឹង នៅពេលយើងលើកកំពស់ និងពង្រឹង ហើយស្រឡាញ់ ព្រមទាំងចេះថែរក្សាចំពោះគ្នាទៅវិញទៅមក។ “អ្នកលើកខ្ញុំឡើង ហើយខ្ញុំនឹងលើកអ្នកឡើងដូចគ្នា បន្ទាប់មកយើងនឹងឡើងទៅស្ថានសួគ៌ទាំងអស់គ្នា” (សុភាសិតរបស់ខ្វាកគ័រ)។

សូមឱ្យយើងមានសមត្ថភាពដើម្បីស្វាគមន៍ និងរក្សាព្រះវិញ្ញាណនៃព្រះអម្ចាស់នៅក្នុងគេហដ្ឋានរបស់យើង ដើម្បីពង្រឹងដល់គ្រួសារយើង។ ដើម្បីធ្វើឱ្យសមាជិកម្នាក់ៗនៅក្នុងគ្រួសាររបស់យើងអាចស្ថិតនៅលើ “ផ្លូវតូច ហើយចង្អៀតដែលនាំទៅឯជីវិតដ៏នៅអស់កល្បជានិច្ច” (នីហ្វៃទី 2 31:18) ខ្ញុំសូមធ្វើការអធិស្ឋានចំពោះកិច្ចការទាំងនេះ។

ការដកស្រង់ចេញមកពីសុន្ទរកថា ដោយអែលឌើរ ហ៊ែល នៅក្នុងសន្និសីទទូទៅនៃសាសនាចក្រ ខែ មេសា ឆ្នាំ 1999 (សូមមើល Conference Report ខែ មេសា ឆ្នាំ 1999 ទំព័រ 39–44 ឬ *Ensign* ខែ ឧសភា ឆ្នាំ 1999 ទំព័រ 32–34)។

ការបង្រៀនគោលការណ៍ដ៏ណឹងល្អចំពោះកូនៗ

14

ភាគទី 2

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលៈទេសៈរបស់អ្នកផ្តាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬច្រើន។

- សូមរៀបចំផែនការដើម្បីធ្វើសកម្មភាពបំរើរួមគ្នាជាគ្រួសារមួយ។
- សូមធ្វើកិច្ចការជាគ្រួសារជាមួយនឹងកូន ឬជាមួយនឹងចៅ ក្មួយប្រុសស្រី ឬក្មេងណាម្នាក់ដែលរស់នៅក្នុងគ្រួសាររបស់អ្នក។ ចូរនិយាយជជែកលេងជាមួយនឹងក្មេងទាំងនោះ ខណៈដែលអ្នកកំពុងធ្វើកិច្ចការរួមគ្នា។ សូមក្តាប់យកឱកាសនៃការបង្រៀនដោយពុំនិយាយរិះគន់ចំពោះការព្យាយាមជួយរបស់ក្មេងរូបនោះឡើយ។
- សូមអានទៅជំពូកដូចមានខាងក្រោម ទៅក្នុងកូនស្បៃវែក៖ *ដើម្បីកំលាំងនៃយុវជន* (34285) ៖ “ប្រព័ន្ធផ្សព្វផ្សាយ ៖ ខ្សែភាពយន្ត ទូរទស្សន៍ វិទ្យុ កាសែតវីដេអូ ស្បៃវែក៖ និងទស្សនាវដ្តី” (ទំព័រ 17–19) “តន្ត្រី និងការរាំ” (ទំព័រ 20–20) និង “ភាពបរិសុទ្ធខាងផ្លូវភេទ” (ទំព័រ 26–28)។ បន្ទាប់ពីអ្នកបានមើលឡើងវិញនូវឯកសារនេះ សូមកត់ត្រាថាតើកូនរបស់ណាមួយ ដែលគប្បីទទួលនូវអត្ថប្រយោជន៍មកពីការអាន និងការពិភាក្សាឯកសារនេះជាមួយនឹងអ្នក។

កិច្ចការសំរាប់អាន

សូមសិក្សាតាមអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ សូមអាន ហើយពិភាក្សាអត្ថបទនេះជាមួយស្វាមី ឬភរិយារបស់អ្នក។

បង្រៀនកូនចៅ

ប្រធាន ចិយដ៍ ឃេ ផាកគី
ប្រធានស្តីទីនៃក្រុមនៃពួកសាវក 12 នាក់

មនុស្សជាច្រើនដែលបានប្រមូលផ្តុំគ្នានៅទីនេះ និងនៅឯទីកន្លែងផ្សេងទៀតបានបង្ហាញនូវការស្រេកឃ្លានយ៉ាងខ្លាំង ចំពោះសេចក្តីពិតដែលកើតមានមកជាមួយនឹងសមាជិកភាព នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។

នៅពេលខ្ញុំបានអធិស្ឋានដើម្បីស្វែងយល់នូវអ្វីមួយ ដែលផ្តល់អត្ថប្រយោជន៍បំផុតចំពោះអ្នករាល់គ្នា នោះបានទឹកឃើញថា នៅក្នុងរយៈពេលបីសប្តាហ៍ទៀតខ្ញុំនឹងឈានចូលវ័យ 75 ឆ្នាំ ហើយឈានចូលទៅកាន់វ័យមួយដែលខ្ញុំចង់ហៅថា *វ័យចំណាស់* ។

ខ្ញុំបានធ្វើជាគ្រូបង្រៀនអស់រយៈពេលជាង 50 ឆ្នាំ។ ពិតប្រាកដណាស់ អ្វីមួយដែលខ្ញុំបានរៀនសូត្រនឹងមានអត្ថប្រយោជន៍ចំពោះអ្នករាល់គ្នា។

ខ្ញុំបានរៀនរឿងនេះតាមរយៈបទពិសោធន៍ថា ៖ ជីវិតនឹងបង្រៀនយើងនូវអ្វីមួយដែលយើងមិនចង់ដឹង។ មេរៀនដ៏លំបាកទាំងនេះអាចក្លាយទៅជាមេរៀនមួយដ៏មានតម្លៃបំផុត។

ខ្ញុំបានរៀនអ្វីមួយផ្សេងទៀតអំពីការរៀនតាមរបៀបរបស់ខ្ញុំចំពោះ *វ័យចំណាស់*។ សូមពិចារណាការសន្ទនានេះរវាងវេជ្ជបណ្ឌិត និងអ្នកជម្ងឺ ៖

វេជ្ជបណ្ឌិត ៖ “តើខ្ញុំអាចជួយអ្នកដោយរបៀបណា? តើអ្នកចេះតែមានអការៈយ៉ាងណាដែរ?”

អ្នកជម្ងឺ ៖ “លោកវេជ្ជបណ្ឌិត ខ្ញុំមានបញ្ហាជាមួយនឹងការចងចាំរបស់ខ្ញុំ។ ខ្ញុំអានអ្វីមួយរួចហើយ ខ្ញុំមិនអាចចង់ចាំវាបានឡើយ។ ពេលខ្ញុំចូលទៅក្នុងបន្ទប់មួយ ខ្ញុំមិនអាចចង់ចាំអំពីហេតុផលដែលខ្ញុំត្រូវទៅទីនោះឡើយ។ ខ្ញុំអាចចងចាំអំពីទីកន្លែងដែលដាក់របស់របរនានាឡើយ”។

វេជ្ជបណ្ឌិត ៖ “អញ្ចឹង សូមប្រាប់មកមើលថាតើអ្នកមានអការៈបែបនេះយូរប៉ុណ្ណាហើយ?”

អ្នកជម្ងឺ ៖ “តើខ្ញុំមានអការៈអ្វីយូរប៉ុណ្ណា?”

ឥឡូវនេះ បើសិនជារឿងនោះធ្វើឱ្យអ្នករាល់គ្នាអស់សំណើច នោះមានន័យថាអ្នករាល់គ្នាមានអាយុសំបាលៗ 60 ឆ្នាំ ឬថាអ្នករាល់គ្នាកំពុងសើចចំអកឱ្យខ្លួនឯងហើយ។

ការបង្រៀនកូនចៅទាន់ពួកគេនៅក្មេង

នៅពេលអ្នករាល់គ្នាកាន់តែមានវ័យចំណាស់ នោះអ្នកមិនអាចរៀន ឬចងចាំឬសិក្សាដូចកាលពីអ្នករាល់គ្នានៅក្មេងបានឡើយ។ តើវាអាចជាហេតុផលដែលព្យាការីអាលម៉ាបានទូន្មានថា “ឱ្យចេះមានព្រាជ្ញានៅក្នុងយុវវ័យរបស់កូនចុះ មែនហើយ ចូររៀននៅក្នុងយុវវ័យរបស់កូនឱ្យចេះកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ” នោះដែរឬទេ?[1]

ខ្ញុំកាន់តែមានការពិបាកនៅក្នុងទន្លេញាព្រះគម្ពីរ និងប្រយោគកំណាព្យ។ កាលពីខ្ញុំនៅជាយុវវ័យ ខ្ញុំអាចទន្លេញអ្វីមួយតែម្តងទៅពីរដងប៉ុណ្ណោះ រួចហើយខ្ញុំក៏អាចចងចាំវាបាន។ បើសិនជាខ្ញុំស្តាត្រាវាច្រើនដង ជាពិសេសជាងនេះទៅទៀត បើសិនជាខ្ញុំសរសេរវា នោះវានឹងត្រូវបានកត់ត្រានៅក្នុងគំនិតរបស់ខ្ញុំជារៀងរហូត។

ភាពជាយុវវ័យគឺជាពេលវេលាដែលមានភាពងាយស្រួលនៅក្នុងការរៀនសូត្រ។ នោះគឺជាហេតុផលដែលពួកគ្រូបង្រៀនរបស់ក្មេង និងយុវវ័យទាំងឡាយ មានន័យកង្វល់ដូចគ្នានេះសំរាប់ពួកអ្នកដឹកនាំសាសនាចក្រតាំងតែពីដំបូងមកម្ល៉េះ។

វាគឺជាការណ៍សំខាន់យ៉ាងល្អឥតខ្ចោះដើម្បីបង្រៀនដំណឹងល្អ និងមេរៀនរបស់ជីវិតដល់ក្មេង និងយុវវ័យទាំងឡាយ។

ព្រះអម្ចាស់បានដាក់ការទទួលខុសត្រូវទីមួយមកលើឪពុកម្តាយ ហើយបានដាស់តឿនពួកគេថា ៖

“ដរាបណាឱពុកម្តាយមានកូនចៅនៅក្នុងក្រុងស៊ីយ៉ូន . . . បង្រៀនកូនចៅឱ្យយល់នៅគោលលទ្ធិអំពីការប្រែចិត្ត សេចក្តីជំនឿដល់ព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅ និងអំពីបុណ្យជ្រមុជទឹក ហើយនិងអំពីអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដោយសារការដាក់ដៃលើ កាលមានអាយុត្រាំបីឆ្នាំ នោះអំពើបាបនឹងធ្លាក់មកលើក្បាលរបស់ឱពុកម្តាយវិញ”។[2]

វាគឺជាគោលចំណងដ៏សំខាន់នៃសាសនាចក្រនេះនៅក្នុងការបង្រៀនយុវវ័យ ៖ ដំបូងគឺនៅក្នុងគេហដ្ឋាន ហើយបន្ទាប់មកនៅក្នុងព្រះវិហារ។

ការស្តុកទុកចំណេះដឹង

រឿងមួយទៀតដែលខ្ញុំបានរៀនគឺទាក់ទងនឹងការចងចាំ អំពីអ្វីដែលយើងបានរៀនកាលពីយើងនៅក្មេង។ ចំណេះដឹងបានស្តុកទុកនៅក្នុងគំនិតដ៏ក្មេងខ្ចីអាចរង់ចាំរយៈពេលជាច្រើនឆ្នាំ សំរាប់ឱកាសដែលចំណេះដឹងនេះត្រូវបានយកទៅប្រើប្រាស់។

សូមឱ្យខ្ញុំបង្ហាញចំណុចនេះដល់អ្នករាល់គ្នា។ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះទំនោរនៃសមាជិកទាំងឡាយ ដែលបានធ្វេសប្រហែសដល់ពាក្យទូន្មានរបស់ប៊ីស្សព ជាងនេះទៅទៀតគឺដាក់បន្ទុកបន្ថែមទៀតទៅលើគាត់។

ខ្ញុំបានសំរេចចិត្តដើម្បីនិយាយនៅក្នុងសន្និសីទទូទៅអំពីប៊ីស្សព។

ខ្ញុំបានរៀបចំអត្ថបទនេះប្រកបដោយការអធិស្ឋាន ហើយការសន្ទនាមួយកាលពី 50 ឆ្នាំមុនបានកើតមាននៅក្នុងគំនិតរបស់ខ្ញុំ។ វាបានជួយខ្ញុំនៅក្នុងទាមជាគ្រូបង្រៀនម្នាក់—ជាជំនួយយ៉ាងល្អតែខ្លោះ។ ឥឡូវនេះ ខ្ញុំសូមដកស្រង់ការសន្ទនានោះនៅក្នុងសន្និសីទទូទៅដែលមានដូចខាងក្រោមនេះ ៖

“អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ ខ្ញុំបានបំរើនៅក្នុងក្រុមប្រឹក្សាជាន់ខ្ពស់ស្តេកជាមួយនឹង អេមើរី វ៉ាយ។ អេមើរី បានបំរើជាប៊ីស្សពនៃវួដហាពើរ អស់រយៈពេល 10 ឆ្នាំ។ ភរិយារបស់គាត់អ្នកស្រី លូស៊ី បានក្លាយជាប្រធានសមាគមសង្គ្រោះស្តេករបស់យើង។

“លោកស្រី លូស៊ី បានប្រាប់ខ្ញុំថា នាព្រឹកនៅទិទាយរដូវមួយ មានអ្នកជិតខាងម្នាក់បានគោះទ្វាររបស់នាង ហើយបានសួរអេមើរី។ នាងបានប្រាប់គាត់ថា អេមើរី បានចេញទៅភ្នែរហើយ។ បន្ទាប់មកអ្នកជិតខាងរូបនោះបាននិយាយដោយមានកង្វល់យ៉ាងខ្លាំង។ កាលពីព្រឹកព្រលឹម គាត់បានឆ្លងកាត់កសិដ្ឋាន ហើយបានឃើញថាហ្វូងសេះរបស់អេមើរី កំពុងឈរនៅក្នុងគន្លងដែលរាស់បានពាក់កណ្តាល ដោយមានបង្គៀរដាក់នៅលើនង្គ័លទៀតផង។ ប៉ុន្តែគាត់មើលមិនឃើញអេមើរទេ។ អ្នកជិតខាងរូបនោះមិនបានគិតអំពីអ្វីឡើយ រហូតដល់ក្រោយមកនៅពេលគាត់បានឆ្លងកាត់ទីវាលនោះម្តងទៀត ហើយហ្វូងសេះនោះមិនកំរើកទៅទីណាសោះ។ គាត់បានផ្លោះរំលងរបង រួចហើយបានដើរឆ្លងកាត់ទីវាលនោះសំដៅទៅរកហ្វូងសេះ។ ប៉ុន្តែគាត់មិនឃើញអេមើរ ទេ។ គាត់បានរួសរាន់ត្រឡប់មកកាន់គេហដ្ឋានដើម្បីសាកសួរដល់លោកស្រី លូស៊ី។

“លូស៊ីបានឆ្លើយតមដោយស្បើមស្ងាត់ថា ‘អ៊ុំ! កុំមានការបារម្ភធ្ងន់អ៊ុំ។ ខ្ញុំគិតថាប្រហែលជានរណាម្នាក់មានបញ្ហាហើយ រួចក៏មកទាំប៊ីស្សពទៅ’។

“ទិដ្ឋភាពនៃហ្វូងសេះដែលឈរអស់រយៈពេលយ៉ាងយូរនៅក្នុងទីវាលនោះជានិមិត្តរូបនៃការលះបង់របស់ប៊ីស្សពនៅក្នុង សាសនាចក្រ និងទីប្រឹក្សាដែលឈរនៅក្បែរគាត់។ បើនិយាយជាការប្រៀបធ្យេប ប៊ីស្សព និងទីប្រឹក្សាគ្រប់រូប បានទុកចោលក្រុមរបស់គាត់ ដែលកំពុងឈរនៅក្នុងគន្លងដែលភ្ជួរមិនទាន់ហើយ នៅពេលមាននរណាម្នាក់ត្រូវការជំនួយ”។[3]

ពីមុនមកខ្ញុំពុំធ្លាប់ប្រើបទពិសោធន៍នោះក្នុងការឡើងនិយាយ—គឺពុំធ្លាប់គិតអំពីរឿងនោះឡើយ។

ខ្ញុំចង់កែសំរួលទូវរឿងនេះនៅក្នុងគំនិតរបស់ខ្ញុំ ពីមុននិយាយអំពីរឿងនេះនៅក្នុងសន្និសីទ ដូច្នេះខ្ញុំបានស្វែងរកកូនស្រីរបស់អេមើរី វ៉ាយ។ នាងបានយល់ព្រមជួបនឹងខ្ញុំនៅឯគេហដ្ឋានចាស់របស់ពួកគេ ហើយបង្ហាញខ្ញុំនូវទីវាលនោះ ដែលឪពុករបស់នាងភ្ជួរកាលពីថ្ងៃនោះ។

នៅព្រឹកថ្ងៃអាទិត្យមួយ កូនប្រុសរបស់ខ្ញុំម្នាក់ បានទាំខ្ញុំទៅកាន់ទីនោះតាំងពីព្រឹកព្រលឹម។ គាត់បានថតរូបយ៉ាងច្រើន។

នៅព្រឹកនោះគឺជាព្រឹកនាទិទាយរដូវមួយដ៏ស្រស់បំព្រង។ ទីវាលនោះទើបតែត្រូវបានគេភ្ជួរថ្មីៗ ដូចដែលមានកាលពីប៉ុន្មានឆ្នាំមុន។ មានសត្វរំពេជាច្រើនកំពុងរកចំណីនៅក្នុងដីដែលទើបភ្ជួរហើយថ្មីៗ។

ដោយការចងចាំអំពីការសន្ទនានោះ អនុស្សាវរីយ៍តែមួយរំពេចនោះពុំមែនលក្ខណៈចម្លែកចំពោះខ្ញុំឡើយ។ វាបានបញ្ជាក់ថែមទៀតអំពីសេចក្តីពិតនៃខគម្ពីរ—ជាខគម្ពីរមួយ ដែលខ្ញុំបានទន្ទេញនៅក្នុងយុវវ័យរបស់ខ្ញុំដោយចៃដន្យ—

“ចូរអ្នករាល់គ្នាកុំចប់ព្រួយទុកជាមុន ពីអ្វីដែលអ្នករាល់គ្នាត្រូវថានោះឡើយ ប៉ុន្តែចូររក្សាទុកក្នុងគំនិតរបស់អ្នករាល់គ្នា ជាបន្ទន្ទូវព្រះបន្ទូលទាំងឡាយខាងជីវិតវិញ ហើយសេចក្តីដែលត្រូវនិយាយនឹងបានប្រទានដល់អ្នករាល់គ្នានៅចំម៉ោងនោះឯង នូវចំណែកដែលនឹងវាល់ដល់មនុស្សគ្រប់រូប”។[4]

ចំពោះពួកអ្នកដែលស្វែងរកចំណេះដឹងបានប្រទានឱ្យនូវសេចក្តីសន្យាមួយដូចខាងក្រោមនេះ ៖

“អស់អ្នកណាដែលទទួលអ្នក នោះយើងក៏នៅទីនោះដែរ គ្បិតយើងនឹងទៅពីមុខអ្នក។ យើងនឹងនៅខាងស្តាំដៃអ្នក ហើយខាងឆ្វេងដៃអ្នក ហើយព្រះវិញ្ញាណរបស់យើងនឹងសណ្ឋិតនៅក្នុងដួងចិត្តរបស់អ្នក ហើយពួកទេវតារបស់យើងជុំវិញអ្នក ដើម្បីទ្រអ្នកឡើង”។[5]

វាគឺជាមេរៀនដ៏ល្អមួយចំពោះខ្ញុំ ប៉ុន្តែមេរៀនរបស់ខ្ញុំមិនបញ្ចប់ត្រឹមនោះទេ។

ខ្ញុំបានរៀនគូរគំនូរ និងឆ្លាក់ឈើកាលពីនៅក្មេង។ ភាគច្រើន ខ្ញុំបានរៀនធ្វើកិច្ចការនេះដោយខ្លួនឯង។ ខណៈដែលកូនចៅរបស់ខ្ញុំចាប់ផ្តើមធំឡើងតាមវ័យរបស់ពួកគេ នោះពេលវេលារបស់ខ្ញុំត្រូវបានលះបង់ ដើម្បីបង្រៀនពួកគេអំពីចំណេះដឹងទាំងឡាយដែលខ្ញុំបានរៀនសូត្រអំពីជីវិត និងអំពីការឆ្លាក់ឈើ និងការគូរគំនូរ កាលពីខ្ញុំនៅក្មេង។

បន្ទាប់ពីពួកគេធំពេញវ័យ នោះខ្ញុំបានជ្រើសរើសយកការឆ្លាក់ឈើជាវិធីសាស្ត្រមួយសំរាប់ការលំហែកាយ។ ខ្ញុំបានឆ្លាក់រូបបក្សី ហើយបានចំណាយពេលជាច្រើនម៉ោងដើម្បីធ្វើការឆ្លាក់នោះ។ នៅពេលមានគេសួរខ្ញុំថា “តើអ្នកបានចំណាយពេលប៉ុន្មានម៉ោងដើម្បីឆ្លាក់រូបនេះ?” ខ្ញុំតែងតែឆ្លើយថា “ខ្ញុំមិនបានដឹងនោះទេ។ បើសិនជាខ្ញុំដឹងនោះ ខ្ញុំនឹងបញ្ឈប់វា”។

នៅក្នុងអំឡុងពេលប៉ុន្មានម៉ោងនៃការធ្វើការទាំងនោះ ដោយដៃរបស់ខ្ញុំផ្ទាល់ ខ្ញុំបានសញ្ជឹងគិតអំពីភាពអស្ចារ្យនៃការបង្កើត និងការបំផុសគំនិតដែលបានកើតមានឡើង។ នៅពេលខ្ញុំបានឆ្លាក់ឈើ ខ្ញុំបានរៀបចំសំរាប់ការឡើងនិយាយរបស់ខ្ញុំ។

ការឆ្លាក់ឈើគឺជាភាពសុខសាន្តសំរាប់រូបខ្ញុំ។ ពេលខ្លះ នៅពេលខ្ញុំមានកង្វល់និងភាពធុញថប់បន្តិចបន្តួចណាមួយ ភរិយារបស់ខ្ញុំតែងតែនិយាយឡើងថា “បងគួរតែទៅឆ្លាក់រូបមួយទៀតទៅ”។

ខ្ញុំស្មានថា បើសិនជាការចងចាំ *វ៉យចំណាស់* របស់ខ្ញុំមានលក្ខណៈប្រសើរជាងនេះបន្តិច នោះខ្ញុំនឹងអាចចង្អុលទៅកាន់រូបចម្លាក់មួយនៅក្នុងចំណោមរូបចម្លាក់ទាំងនោះ ហើយអាចប្រាប់ថាតើការឡើងនិយាយមួយណា ជាតំណាងឱ្យរូបចម្លាក់នីមួយៗ។ ខ្ញុំបានរៀនថា នៅក្នុងពេលដ៏ស្ងប់ស្ងាត់នោះ ខ្ញុំអាចធ្វើនូវរឿងពីរយ៉ាងនៅក្នុងពេលតែមួយ។

ការច្រូតកាត់យកផលមកពីការបង្រៀន

ខ្ញុំពុំមានសមត្ថភាពនៅក្នុងការឆ្លាក់រូបចម្លាក់ទាំងនោះបានទៀតឡើយ។ កិច្ចការនោះគឺមានភាពប្រណិតខ្លាំងណាស់ចំពោះរូបខ្ញុំ ដោយមានការប្រើផ្ទុំកម្លាំងនៃចុងម្រាមដៃ ដែលឥឡូវដូចជារឹងបន្តិច ដោយសារតែរោគខួរឆ្អឹងខ្នងតាំងពីកុមារភាពមក។ ក្រៅពីនេះ ការកើនឡើងនូវសម្ពាធនៃការហៅរបស់ខ្ញុំ បានកំណត់ពេលវេលាដែលខ្ញុំអាចលះបង់ទាំងចំពោះការឆ្លាក់រូប និងរៀបចំការនិយាយ។

ឥឡូវនេះ សមត្ថភាពក្នុងការឆ្លាក់រូបភាគច្រើនបានបាត់បង់ពីរូបខ្ញុំទៅហើយ ប៉ុន្តែវាពុំបានបាត់បង់ចេញពីកូនចៅរបស់យើងឡើយ។ យើងបានបង្រៀនពួកគេកាលពីពួកគេនៅក្មេង។

រូបភាពនៃហ្វូងសេះដែលឈរនៅទីវាលនោះបានដក់ជាប់នៅជាមួយនឹងរូបខ្ញុំ។ ខ្ញុំបានគិតថា ប្រហែលជាខ្ញុំអាចគូររូបគំនូរអំពីហ្វូងសេះ ដែលកំពុងឈរនៅក្នុងទីវាលរបស់ប៊ីស្សព ដោយមានបង្ហៀរពាក់ជាប់នឹងនង្គ៉ល។

ខ្ញុំមានការស្ទាក់ស្ទើរយ៉ាងខ្លាំង ដោយសារអស់រយៈពេលប្រាំបួនឆ្នាំមកហើយចាប់តាំងពីខ្ញុំបានគូរគំនូរចុងក្រោយរបស់ខ្ញុំ។ ខ្ញុំមានមិត្តភក្តិពីរនាក់ ដែលមានទេពកោសល្យ និងការបំផុសគំនិតយ៉ាងអស្ចារ្យបានស្ម័គ្រចិត្តជួយខ្ញុំ នៅក្នុងការគូររូបគំនូរហ្វូងសេះរបស់ប៊ីស្សពនោះ ហេតុដូច្នេះហើយនៅខែ កក្កដា ខ្ញុំក៏បានចាប់ផ្តើមធ្វើនូវកិច្ចការនេះ។

ខ្ញុំបានរៀនសូត្រយ៉ាងច្រើនមកពីមិត្តរបស់ខ្ញុំទាំងពីរនាក់នោះ ពួកគេគឺស្ថិតនៅក្នុងរូបគំនូររបស់ខ្ញុំ។ ប៉ុន្តែ ខ្ញុំបានទទួលជំនួយយ៉ាងច្រើនមកពីកូនប្រុសរបស់ខ្ញុំពីរនាក់ទៀត។ កូនប្រុសម្នាក់របស់ខ្ញុំបានថតរូបភាពទីវាល ដែលបានភ្ជួរនោះយ៉ាងច្រើនពីព្រោះខ្ញុំព្យាយាមដើម្បីធ្វើឱ្យរូបនោះមើលទៅដូចធម្មជាតិ នៅពេលធ្វើការពិពណិនាអំពីអ្វីមួយនៅក្នុងការឆ្លាក់រូប ឬការគូរគំនូរ ឬការអត្ថាធិប្បាយមួយ។

នោះគឺជាមេរៀនមួយផ្សេងទៀត។ ខ្ញុំអាចរំញកឡើងនូវអតីតកាលនៃកូនចៅរបស់យើងអំពីអ្វីមួយ ដែលពួកគេបានរៀនកាលពីពួកគេនៅក្មេង។

កូនប្រុសរបស់ខ្ញុំម្នាក់ទៀតបានសំរេចចិត្តធ្វើរូបសំណាកមួយ អំពីហ្វូងសេះរបស់ប៊ីស្សពជាស្ពាន់ ដើម្បីធ្វើជាដៃគូនឹងរូបគំនូររបស់ខ្ញុំ។ យើងបានចំណាយពេលជាច្រើនម៉ោងនៅក្នុងការជួយគ្នាទៅវិញទៅមក។

គាត់បានយកអស្សាករណ៍មួយចំនួន ដែលបានភ្ជួរទុកចោលនៅក្នុងជង្រុកស្រូវរបស់យើងអស់ពេលជាង 50 ឆ្នាំមក។ ហើយគាត់បានបោសធូលីចេញពីអស្សាករណ៍ទាំងនោះ រួចក៏បានយកវាទៅផ្ទះ។ គាត់បានដាក់អស្សាករណ៍មួយនៅលើសេះដ៏ស្លូតមួយក្បាល។ សេះនោះបានឈរស្ងៀម នៅពេលគាត់រៀបចំដាក់អស្សាករណ៍ឱ្យត្រឹមត្រូវ និងរៀបចំប្លង់លំអិត។

អ្នកជិតខាងរបស់គាត់បានជ្រើសរើសនង្គ៉លចាស់ៗមួយចំនួនមកឱ្យគាត់។ នៅក្នុងចំណោមនង្គ៉លទាំងនោះ មាននង្គ៉យមួយត្រូវនឹងអ្វីដែលគាត់រៀបចំប្លង់គូរផងដែរ។

ហេតុដូច្នេះហើយ អ្វីដែលយើងបានផ្តល់ឱ្យកូនប្រុសទាំងពីរនាក់ នោះកាលពីនៅក្មេង ត្រូវបានផ្តល់មកឱ្យយើងវិញ។ ដូចគ្នានឹងកូនចៅដទៃទៀតផងដែរ ពួកគេបានអភិវឌ្ឍនូវអ្វីដែលយើងជាឱពុកម្តាយ បានបង្រៀនដល់ពួកគេកាលពីគេនៅក្មេង។ ហើយបើសិនជាយើងអាចរស់នៅបានយូរអង្វែងនៅលើផែដីនេះ នោះការច្រូតកាត់ជាលើកទីពីរនឹងកើតមានឡើង—គឺជាចៅរបស់យើង—និងប្រហែលជាមានការច្រូតកាត់ជាលើកទីបីផងដែរ។

ការចាប់ផ្តើមទេពកោសល្យដែលបានបោះបង់ចោលជាថ្មីឡើងវិញ

ខ្ញុំបានរៀនសារជាថ្មីនូវរឿងមួយផ្សេងទៀត។ នៅគ្រាមួយ ខ្ញុំបានគូររូបមួយ ដែលបានបំផុសគំនិតដោយពាក្យដែលខ្ញុំបានឮកាលពីនៅក្មេង។ ពាក្យនោះបានពិពណិនាអំពីកំពូលភ្នំវិលឡាដ។ ខ្ញុំធ្លាប់ឮថាពួកមនុស្សចាស់ពីដើមបាននិយាយសំដៅទៅលើកំពូលភ្នំទាំងនោះថាជា*គណៈប្រធាន* ។ កំពូលភ្នំដ៏ធំ ហើយរឹងមាំដែលមានកំពស់ទល់នឹងមេឃទាំងបីនេះ បានធ្វើតំណាងឱ្យពួកអ្នកដឹកនាំនៃសាសនាចក្រនេះ។

នោះគឺរឿងដែលកើតឡើងកាលពីប្រាំបួនឆ្នាំមុន។ កូនប្រុសរបស់ខ្ញុំបាននាំខ្ញុំទៅកាន់ វិលឡាដ រដ្ឋយូថាហ៍ ហើយបានថតយករូបភាពកំពូលភ្នំទាំងនោះ។ យើងបានត្រឡប់ទៅទីនោះម្តងទៀតជាលើកទីពីរ នៅពេលមានស្រមោល និងភាពខុសប្លែកនៅទីនោះនៅឡើយ។

បន្ទាប់ពីប៉ុន្មានឆ្នាំនោះមក ខ្ញុំបានចាប់ផ្តើមធ្វើជាថ្មីនូវអ្វីដែលបានបោះបង់ចោលពីមុនមក។ ពេលដំបូងវាមានការលំបាកខ្លាំងណាស់។ ខ្ញុំមានអារម្មណ៍ថាចង់លះបង់ចោលជាច្រើនលើក។ ប៉ុន្តែមានមិត្តរបស់ខ្ញុំម្នាក់បានលើកទឹកចិត្តខ្ញុំ ដោយនិយាយថាះ "បន្តធ្វើទៀតទៅ! នៅមានឱកាសជាច្រើនដែលខ្ញុំអាចធ្វើបានជានិច្ច"។

ខ្ញុំមិនបានចុះចាញ់ឡើយ ដោយសារភរិយារបស់ខ្ញុំមិនបានអនុញ្ញាតឱ្យខ្ញុំធ្វើដូច្នោះឡើយ។ ឥឡូវនេះខ្ញុំមានការត្រេកអរដែលខ្ញុំមិនបានចុះចាញ់ការណ៍នោះ។ ឥឡូវនេះ ដោយសារខ្ញុំមានអារម្មណ៍ចង់គូរគំនូរម្តងទៀត—នោះថាមិនបានឡើយ ប្រហែលជាខ្ញុំនឹងគូរគំនូរមួយផ្សេងទៀតនៅពេលណាមួយក៏ថាបាន។

ខ្ញុំសន្មត់ថា ការព្យាយាមត្រឡប់មករកការគូរគំនូរវិញ គឺវាមិនខុសគ្នានឹងមនុស្សម្នាក់ដែលមិនសូវសកម្មនៅក្នុងសាសនាចក្រអស់រយៈពេលជាច្រើនឆ្នាំ ហើយបានសំរេចចិត្តត្រឡប់មកកាន់ក្រោលចាស់វិញដូច្នោះដែរ។ ការទទួលបានមកវិញនូវអារម្មណ៍ចំពោះអ្វីដែលបានទុកចោល គឺត្រូវតែមានរយៈពេលនៃការលំបាក ប៉ុន្តែវានឹងមិនបាត់បង់ទាំងស្រុងនោះទេ។ ហើយការណ៍កាន់មានលក្ខណៈប្រសើរឡើងបើសិនជាមានមិត្តម្នាក់ ឬពីរនាក់។

នោះគឺជាគោលការណ៍នៃការរៀនសូត្រមួយទៀត—ជាមេរៀនអំពីការគូរគំនូរដែលបានដកស្រង់ចេញមកពីបទពិសោធន៍ដ៏សាមញ្ញនៅក្នុងជីវិត។

រូបគំនូរស្តីអំពី *ហ្វូងសេះរបស់ប៊ីស្សព* នោះនឹងបញ្ចប់នៅក្នុងពេលឆាប់ៗនេះហើយ។ រូបសំណាករបស់កូនប្រុសខ្ញុំ គឺស្ថិតក្នុងរោងស្មិត ដើម្បីធ្វើឱ្យក្លាយទៅជារូបស្ពាន់។

ជាយថាហេតុ រូបសំណាករបស់កូនប្រុសខ្ញុំ វាស្អាតជាងគំនូររបស់ខ្ញុំ។ នោះគឺជាអ្វីដែលគួរតែកើតឡើង។ ម្រាមដៃ និងគំនិតវ៉យក្មេងរបស់គាត់បង្កភាពងាយស្រួលនៅក្នុងធ្វើកិច្ចការនេះជាងខ្ញុំ។

នៅពេលយើងរំកិលទៅរក *វ៉យកណ្តាល* នោះយើងបានដឹងថា ឆ្អឹងដ៏ចាស់មិនអាចបត់បែនបានស្រួលឡើយ រីឯសន្លាក់ឆ្អឹងក៏មិនអាចផ្លាស់ប្តូរបានល្បឿនផងដែរ។ វាពុំមែនជាការងាយស្រួលទៀតឡើយនៅក្នុងការចង់ខ្សែស្បែកជើង នៅពេលអ្នកមានអាយុ 60 ឆ្នាំ—នោះស្បែកជើងនឹងត្រូវទុកចោលនៅលើឥដ្ឋហើយ។

ខ្ញុំសូមរំឭកម្តងទៀតអំពីមេរៀននោះថា ៖ “ឱ្យចេះមានព្រាជ្ញានៅក្នុងយុវវ័យរបស់កូនចុះ មែនហើយ ចូររៀននៅក្នុងយុវវ័យរបស់កូន ឱ្យចេះកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ”។[6]

“សិរីល្អនៃព្រះគឺជាបញ្ញា ឬក៏ម្យ៉ាងទៀត ជាពន្លឺ និងសេចក្តីពិត”។[7]

“យើងបានបញ្ជាដល់អ្នក ឱ្យចិញ្ចឹមកូនចៅរបស់ខ្លួននៅក្នុងពន្លឺ និងសេចក្តីពិត។[8]

អំណោយទានដ៏ទេវភាពនៃព្រះវិញ្ញាណបរិសុទ្ធ ត្រូវបានប្រគល់មកលើកូនចៅរបស់យើង នៅពេលពួកគេមានអាយុត្រាំបីឆ្នាំប៉ុណ្ណោះ។

“ព្រះដ៏ជាជំនួយគឺជាព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះវរបិតានឹងចាត់មកដោយនូវឈ្មោះខ្ញុំ ទ្រង់នឹង*បង្រៀន* អ្នករាល់គ្នាពីគ្រប់សេចក្តី*ទាំងអស់* ក៏ទីង*រំឭក* ពី *គ្រប់ទាំង* សេចក្តី ដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាដែរ”។[9]

សូមកត់ចំណាំនូវពាក្យ *បង្រៀន* និង*រំឭក*។

ការបង្រៀនកូនចៅនឹងនាំមកនូវរង្វាន់ដល់ខ្លួនឯង។ តើអ្នករាល់គ្នាមិនទាន់បានរៀននៅឡើយមែនឬ ថាកាលណាអ្នករាល់គ្នាបង្រៀន នោះអ្នកនឹងរៀនបានច្រើនមកពីការបង្រៀននោះ ជាងអ្វីដែលកូនចៅរបស់អ្នកបានរៀនទៅទៀត?

មានអនុស្សាវរីយ៍ខាងវិញ្ញាណ

ការទទួលចំណេះដឹងខាងលោកិយ គឺមានភាពខុសប្លែកគ្នាពីការទទួលចំណេះដឹងខាងវិញ្ញាណ។ សិស្សជាច្រើនបានរៀនរឿងនោះនៅថ្ងៃប្រលង។ វាគឺការពិតក្នុងណាស់នៅក្នុងរំលឹកចាំនូវអ្វីមួយ ដែលអ្នកមិនបានរៀនវាតាំងពីដំបូងមក។

នោះគឺជាការពិតនៃចំណេះដឹងខាងលោកិយ ប៉ុន្តែចំណេះដឹងខាងវិញ្ញាណវិញ យើងអាចទទួលបានការចងចាំមួយ ដែលកើតមានមុនកំណើតរបស់មនុស្សទៅទៀត។ យើងអាចអភិវឌ្ឍអារម្មណ៍មួយចំពោះរឿងទាំងឡាយ ដែលយើងមិនយល់ដឹងកាលពីនៅក្មេង។

អ្នកកវី វ៉ូដវ័ស បានទទួលអារម្មណ៍មួយស្តីអំពី ជីវិតមុនឆាកជីវិតនេះ ដោយគាត់បានសរសេរថា

កំណើតរបស់យើងគឺប្រៀបបាននឹងការដេកយ៉ាងលង់លក់ ហើយភ្លេចអ្វីៗទាំងអស់ ៖
ព្រលឹងដែលមាននៅក្នុងខ្លួនយើង គឺជាផ្កាយនៃជីវិតយើង
ធ្លាប់មានវត្តមាននៅទីកន្លែងមួយផ្សេងទៀត
គឺមកពីកន្លែងដ៏សែនឆ្ងាយ ៖
ដោយពុំមែនភ្លេចភ្លាំងទាំងស្រុងនោះឡើយ
ហើយក៏ពុំមានភាពអាក្រាតទាំងស្រុងនោះដែរ
ប៉ុន្តែយើងមកពីលើផ្ទៃមេឃនៃសិរីល្អដ៏ធំឡើងល្អើយ
ជាផ្ទះរបស់យើង ជាទីកន្លែងដែលមានព្រះគង់នៅទីនោះ ។[10]

ខ្ញុំបានរំឭកចាំពាក្យទាំងនេះចេញមកពីការចងចាំរបស់ខ្ញុំ ដែលខ្ញុំបានផ្ទុកវាកាលពីរៀនថ្នាក់អង់គ្លេសនៅក្នុងសាកលវិទ្យាល័យ

មេរៀនដ៏សំខាន់បំផុតកើតមានឡើងបានមកពីព្រឹត្តិការណ៍សាមញ្ញនៅក្នុងជីវិត។

មានមនុស្សមួយចំនួនរង់ចាំទទួលបទពិសោធន៍ខាងវិញ្ញាណ ដើម្បីបញ្ជាក់ដល់ទីបន្ទាល់របស់ខ្លួន។ វាពុំមែនកើតឡើងតាមរយៈប្បបនោះឡើយ។ វាគឺជាការបំផុសនិងអារម្មណ៍ដ៏ស្ងៀមស្ងាត់នៃរឿងសាមញ្ញៗទាំងឡាយ ដែលផ្តល់ឱ្យយើងនូវការបញ្ជាក់ស្តីអំពីអត្តសញ្ញាណរបស់យើង ក្នុងនាមជាកូនចៅនៃព្រះ។ យើងនឹងរស់ពីក្រោមឯកសិទ្ធិរបស់យើង បើសិនជាយើងខិតខំស្វែងរកសញ្ញា ហើយមើល “ហួសទិសដៅ” ចំពោះព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងនោះ។[11]

យើងគឺជាកូនចៅនៃព្រះ ដោយសារយើងបានរស់នៅជាមួយទីងទ្រង់នៅជីវិតមុនឆាកជីវិតនេះ។ បន្តិចម្តងៗរាំងនននោះត្រូវបានរហែកជាផ្នែកតូចៗ។ ហើយការណែនាំស្តីអំពីថាតើយើងជានរណា និងអំពីទីកន្លែងរបស់យើងនៅក្នុងផែនការដ៏អស់កល្បជានិច្ច ទីងកើតមានឡើងចំពោះយើង។ សូមរំឭកនូវការចងចាំឬចំណេះដឹងខាងវិញ្ញាណនោះ វាគឺជាទីបន្ទាល់មួយនៅក្នុងចំណោមទីបន្ទាល់ទាំងនោះដែលថ្លែងថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្តពិត។ វិវរណៈបែបនេះកើតមាននៅពេលយើងបង្រៀន។

នៅគ្រាមួយខ្ញុំបានឮប្រធាន ម៉ារ៉ុន ជេ រ៉ូមនី (1897–1988) មានប្រសាសន៍ថា ៖ “ជានិច្ចកាល ខ្ញុំដឹងនៅពេលខ្ញុំកំពុងនិយាយដោយស្ថិតនៅក្រោមឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ដោយសារខ្ញុំបានរៀននូវអ្វីមួយចេញពីអ្វីដែលបាននិយាយនោះជានិច្ច”។

ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកអែលឌើរថា ៖

“អ្នករាល់គ្នាពុំមែនត្រូវបានចាត់ឱ្យទៅទទួលការបង្រៀនទេ ប៉ុន្តែឱ្យទៅដើម្បីបង្រៀនកូនចៅមនុស្សពីអ្វីៗ ដែលយើងបានដាក់ក្នុងដៃរបស់អ្នក ដោយព្រះចេស្តានៃព្រះវិញ្ញាណរបស់យើងវិញ

“ហើយអ្នករាល់គ្នាត្រូវបានទទួលការបង្រៀនមកពីស្ថានលើ។ ចូរញែកខ្លួនចេញជាបរិសុទ្ធចុះ ហើយអ្នករាល់គ្នានឹងត្រូវបានទទួលអំណោយទានដោយព្រះចេស្តាប្រយោជន៍ឱ្យអ្នករាល់គ្នាអាចបង្រៀន ដូចជាយើងបានមានបន្ទូលមក”។[12]

សូម្បីតែការច្រូតកាត់នៃពួកអ្នកឆ្លាស់ប្រែចិត្តជ្រើរុំមានលក្ខណៈគ្រប់គ្រាន់ ចំពោះពួកអ្នកផ្សព្វផ្សាយសាសនាក៏ដោយ ក៏ព្រះចេស្តាខាងវិញ្ញាណកើតមានឡើងចំពោះពួកគេ និងចំពោះសាសនាចក្រផងដែរ ដោយសារពួកគេរៀនតាមរយៈការបង្រៀនរបស់ពួកគេ។

ប្រធានក្រុមឌីកុនគឺត្រូវអង្គុយនៅក្នុងក្រុមប្រឹក្សា ហើយបង្រៀនសមាជិកក្រុមឌីកុនរបស់ខ្លួន។[13] ប្រធានក្រុមនៃពួកអែលឌើរត្រូវបង្រៀនសមាជិកនៃក្រុមរបស់ខ្លួនឱ្យស្របទៅតាមសេចក្តីសញ្ញាទាំងឡាយ។[14]

ប៉ុល បានប្រាប់ ធីម៉ូថេ ថា “អស់ទាំងសេចក្តីដែលអ្នកបានឮអំពីខ្ញុំ នៅមុខស្មរបន្ទាល់ជាច្រើននោះក៏ត្រូវផ្ទេទុកនឹងមនុស្សស្មោះត្រង់ ដែលអាចនឹងបង្ហឹកបង្រៀនតទៅអ្នកឯទៀតដែរ”។[15]

គាត់បានពន្យល់ជាពាក្យត្រាំបួនម៉ាត់ អំពីរបៀបដែលការបង្រៀនប្រែក្លាយទៅជារង្វាន់ផ្ទាល់ខ្លួននោះថា ៖

“*ដូច្នេះ អ្នកឯងដែលបង្រៀនគេ តើមិនបង្រៀនដល់ខ្លួនឯងទេឬអី?* អ្នកឯងដែលប្រដៅថា កុំឱ្យលួចគេ តើអ្នកលួចឬទេ?

“អ្នកឯងដែលថា កុំឱ្យផិតគ្នា តើអ្នកផិតឬទេ?”[16]

ការមានឆន្ទៈធ្វើជាអ្នករៀន

កាលពីប៉ុន្មានថ្ងៃមុន ខ្ញុំបានទទួលសំបុត្រសុំទោសមួយ ដូចដែលខ្ញុំធ្លាប់ទទួលបានជាច្រើនលើកច្រើនគ្រាមកហើយ។ សំបុត្រនោះគឺមកពីបុគ្គលម្នាក់ដែលខ្ញុំពុំស្គាល់។ សំបុត្រនោះបានរៀបរាប់អំពីទំហំនៃការតូចចិត្ត និងកំហឹងដែលបានកើតមានចំពោះសមាជិកមកលើរូបខ្ញុំ អស់រយៈពេលជាយូរមកហើយ ដោយសារតែសុន្ទរកថាដែលខ្ញុំបានលើកឡើង។ សំបុត្រនេះបានរៀបរាប់សុំឱ្យខ្ញុំការអភ័យទោសឱ្យ។

ខ្ញុំជាមនុស្សដែលងាយនឹងអត់ឱនទោសដល់មនុស្សដទៃ។ ខ្ញុំគ្រាន់តែជាគ្មាត់ងារមួយរូបទាំងនៅក្នុងការផ្តល់សុន្ទរកថា និងនៅក្នុងការផ្តល់ឱ្យនូវការអត់ឱនទោសប៉ុណ្ណោះ។

ព្រះគម្ពីរមានសេចក្តីយោងជាច្រើនដែលបានបើកសម្តែងអំពីទំហំនៃការ“ពិបាក”[17] ដើម្បីទទួលយកការបង្រៀនរបស់ពួកព្យាការី និងពួកសាវកដែលកើតមានចំពោះសាសន៍អ៊ីស្រាអែល និងសាសន៍ឯទៀតៗ។ វាគឺជាការងាយស្រួលបំផុតនៅក្នុងការបដិសេធ ចំពោះការបង្រៀន និងការមិនសប្បាយចិត្តចំពោះគ្រូបង្រៀនទាំងនោះ។ ការណ៍ទាំងនោះបានកើតឡើងចំពោះពួកព្យាការី និងពួកសាវកជាច្រើនតាំងពីដំបូងមកម្ល៉េះ។

ពាក្យនៃភាពក្បេមក្បាន្តមួយ នៅក្នុងចំណោមពាក្យនៃភាពក្បេមក្បាន្តទាំងឡាយបានបង្រៀនថា ៖

“អ្នករាល់គ្នាមានពរ ក្នុងកាលដែលគេជេរ ប្បៀតប្បៀន ហើយនិយាយបង្កាសគ្រប់ទាំងសេចក្តីអាក្រក់ពីអ្នករាល់គ្នាដោយព្រោះខ្ញុំ។

“ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ ត្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅស្ថានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នាបែបដូច្នោះដែរ”។[18]

ជាទូទៅ សំបុត្រសុំទោសទាំងនោះបានសរសេរថា ៖ “ខ្ញុំពុំយល់អំពីហេតុផលដែលអ្នកបានធ្វើឱ្យខ្ញុំទទួលអារម្មណ៍នៃការឈឺចាប់ និងអារម្មណ៍នៃការធ្វើខុសនោះឡើយ”។ បន្ទាប់ពីដើមចេញពីភាពស្មុគស្មាញរបស់ពួកគេមក នោះចំណេះដឹងការបំផុសគំនិត ការយល់ដឹងអំពីបុព្វហេតុ និងអត្ថប្រយោជន៍ក៏កើតមានឡើង។ នៅទីបំផុត ពួកគេបានរកឃើញ ហើយយល់អំពីហេតុផលដែលដំណឹងល្អមានដំណើរការយ៉ាងដូច្នោះ។

ខ្ញុំសូមលើកឡើងអំពីប្រធានបទមួយនៅក្នុងចំណោមប្រធានបទមួយចំនួន។ មានបងស្រីម្នាក់ នៅទីបំផុតបានយល់អំពីហេតុផលដែលយើងសង្កត់ធ្ងន់ អំពីសារៈសំខាន់ចំពោះវត្តមានរបស់ម្តាយមើលថែទាំកូននៅក្នុងផ្ទះ នៃការស្នាក់នៅក្នុងផ្ទះរបស់ម្តាយជាមួយនឹងកូនចៅរបស់ខ្លួននោះ។ គាត់បានយល់ថា គ្មានការបំរើណាមួយប្រៀបស្មើ និងការដុសខាត់ដ៏លើកតំកើង ដែលកើតចេញពីភាពមិនអត្នាឱយមរបស់ម្តាយនោះឡើយ។ ឬក៏គាត់ត្រូវធ្វើដោយគ្មានការដុសខាត់ខាងបញ្ញា ឬខាងប្រពៃណី ឬខាងសង្គមនោះឡើយ។ កិច្ចការទាំងនោះត្រូវរាប់បញ្ចូលគ្នា—តាមពេលវេលាដ៏ត្រឹមត្រូវ—ពីព្រោះកិច្ចការទាំងនោះផ្តោតការយកចិត្តទុកដាក់លើគុណធម៌ដ៏អស់កល្បជានិច្ច ដែលកើតចេញមកពីការបង្រៀនដល់កូនចៅ។

គ្មានការបង្រៀនណាដែលមានសមត្ថភាព មានរង្វាន់ខាងវិញ្ញាណ ឬរុងរឿងជាងអ្វីដែលម្តាយម្នាក់ បង្រៀនដល់កូនរបស់នាងនោះទេ។ ម្តាយម្នាក់អាចទទួលអារម្មណ៍ថា គាត់គ្មានចំណេះគ្រប់គ្រាន់អំពីព្រះគម្ពីរ ដោយសារតែគាត់ជាប់រវល់បង្រៀនកូនចៅរបស់ខ្លួន។ គាត់នឹងនៅតែទទួលបានរង្វាន់ដ៏ច្រើនដដែល។

ប្រធាន ក្រាន្ត ប៉ាងហ្គើរធើរ បានមានការសន្ទនាខាងគោលលទ្ធិជាមួយនឹងប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ដែលបានមកធ្វើទស្សនកិច្ចនៅបេសកកម្មរបស់គាត់ក្នុងប្រទេសប្រេស៊ុល។ ស៊ិស្ទើរ ប៉ាងហ្គើរធើរ បានស្តាប់នៅការសន្ទនានោះ ហើយក្រោយមកបានសួរថា “ប្រធាន ស្ម៊ីធ ខ្ញុំមានការរវល់នៅក្នុងការចិញ្ចឹមកូនចៅ ហើយពុំមានពេលគ្រប់គ្រាន់ ដើម្បីក្លាយទៅជាអ្នកចេះដឹងខាងព្រះគម្ពីរមួយរូប ដូចជាគាត់នោះឡើយ។ តើខ្ញុំនឹងបានទៅឯនគរសេឡេស្ទាលជាមួយនឹងក្រាន្តដែរឬទេ?”

ប្រធាន ស្ម៊ីធ បានសញ្ជឹងគិតយ៉ាងស្ងៀមស្ងាត់មួយសន្ទុះ ហើយក៏បានមានប្រសាសន៍ថា ៖ “ប្រហែលជាអាច បើសិនជាអ្នកធ្វើទំនាយឱ្យគាត់”។

បុរសម្នាក់នឹងមានការខិតខំយ៉ាងលំបាក ដើម្បីឱ្យមានរង្វាស់ស្មើនឹងរង្វាស់នៃការដុសខាត់ខាងវិញ្ញាណនោះ ដែលកើតមានពីធម្មជាតិចំពោះភរិយារបស់ខ្លួន នៅពេលនាងបង្រៀនកូនចៅរបស់ខ្លួន។ ហើយបើសិនជាគាត់យល់អំពីដំណឹងល្អឱ្យបានច្បាស់ នោះគាត់នឹងដឹងថា គាត់មិនអាចត្រូវបានលើកតំកើងដោយគ្មានភរិយារបស់គាត់បានឡើយ។[19] សេចក្តីសង្ឃឹមដ៏ល្អបំផុតរបស់គាត់គឺត្រូវដឹកនាំ ក្នុងនាមជាដៃគូដែលមានការតាំងចិត្ត និងមានការទទួលខុសត្រូវ នៅក្នុងការបង្រៀនកូនចៅរបស់ខ្លួន។

ពរជ័យចំពោះពួកគ្រូបង្រៀន

ឥឡូវនេះ សូមពិចារណាចំពោះការសន្យានេះ ៖

“ចូរអ្នករាល់គ្នាព្យាយាមបង្រៀន ហើយព្រះគុណរបស់យើងនឹងនៅជាមួយ*អ្នក* [ជាគ្រូបង្រៀន] ដើម្បីឱ្យអ្នក [ជាគ្រូបង្រៀន ជាឪពុកម្តាយ]អាចត្រូវបានបង្គាប់ឱ្យបានល្អទៅទៀត អំពីច្រើស្តី អំពីគោលការណ៍ អំពីគោលលទ្ធិ អំពីក្រិត្យវិន័យនៃដំណឹងល្អ អំពីគ្រប់ទាំងអស់ដែលទាក់ទងទៅនិងនគរព្រះ ដែលជាការចាំបាច់សំរាប់ឱ្យអ្នក [ជាឪពុកម្តាយ] យល់”។[20]

សូមកត់សំគាល់ថាការសន្យានេះ គឺសំដៅចំពោះគ្រូបង្រៀនជាជាងចំពោះកូនសិស្ស។

“ចូរអ្នករាល់គ្នាព្យាយាមបង្រៀន ហើយព្រះគុណរបស់យើងនឹងនៅជាមួយអ្នក [ដែលបង្រៀនកូនចៅរបស់អ្នក ឬអ្នកដែលបង្រៀនថ្នាក់បឋមសិក្សា សាលាថ្ងៃអាទិត្យ ថ្នាក់យុវជនយុវនារី បព្វជិតភាព សិក្ខាសាលា សមាគមសង្គ្រោះ] ដើម្បីអ្នកអាចត្រូវបានបង្គាប់ឱ្យបានល្អទៅទៀត ៖

“អំពីរបស់ទាំងឡាយនៅលើទាំងស្ថានសួគ៌ និងនៅលើផែនដី និងនៅក្រោមផែនដីផង របស់ទាំងឡាយដែលនឹងកើតឡើងនៅពេលឆាប់ៗ របស់ទាំងឡាយដែលនៅក្នុងផ្ទះ របស់ទាំងឡាយនៅក្នុងស្រុកផ្សេង សង្គ្រាមទាំងឡាយ និងការច្របូកច្របល់នៃសាសន៍ទាំងឡាយ និងសេចក្តីជំនុំជំរះទាំងឡាយដែលនៅលើផែនដី និងដំណើរអំពីស្រុកទាំងឡាយ និងនគរទាំងាឡាយផង—

“ដើម្បីឱ្យអ្នករាល់គ្នា [ដែលជាគ្រូបង្រៀន]អាចបានរៀបចំទូវត្រាប់ទាំងអស់ ក្នុងកាលយើងនឹងចាត់អ្នកម្តងទៀត ឱ្យទៅដើម្បីដំកើងការហៅដែលយើង បានហៅអ្នករួចហើយនោះ និងបេសកកម្មដែលយើងបានអនុញ្ញាតដល់អ្នក”។[21]

ប៉ុល បានព្យាករទៅកាន់ ធីម៉ូថេ វ័យក្មេងថា ៖ “នៅដាន់ក្រោយបង្អស់នឹងមានគ្រាលំបាកណាស់”។[22] គាត់បានបន្ថែមទៀតថា “ពួកអាក្រក់ និងពួកឆបោក គេនឹងមានជំឡើរឡើងទៅខាងសេចក្តីអាក្រក់កាន់តែខ្លាំងឡើង ទាំងនាំមនុស្សឱ្យវង្វេង ហើយត្រូវវង្វេងខ្លួនឯងផង”។[23]

ប៉ុន្តែយើងនៅតែអាចមានសុវត្ថិភាពដដែល។ សេចក្តីសុខសាន្តរបស់យើងគឺមាននៅក្នុងការបង្រៀនកូនចៅថា ៖

“ចូរបង្ហាត់កូនក្មេងឱ្យប្រព្រឹត្តតាមផ្លូវដែលគួរឱ្យប្រព្រឹត្ត នោះវានឹងមិនលះបង់ពីផ្លូវនោះដរាបដល់ចាស់”។[24]

ប៉ុល បានទូន្មានដល់ ធីម៉ូថេ ថា ៖

“ចូរឱ្យអ្នកទៅជាប់ក្នុងសេចក្តីដែលអ្នកបានរៀន ហើយជឿជ្រាកដរិញាដោយដឹងថា អ្នកបានរៀនសេចក្តីនោះពីអ្នកណា

“ហើយថាតាំងពី*វ័យកុមារ* មក អ្នកបានស្គាល់*បទគម្ពីរ* ទាំងប៉ុន្មាន ដែលអាចនឹងនាំឱ្យអ្នកមានប្រាជ្ញាដល់ទីសង្គ្រោះ ដែលបានដោយសេចក្តីជំនឿដល់ព្រះគ្រីស្ទយេស៊ូវផង”។[25]

សាសនាចក្រនេះគឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ។ សាសនាចក្រនេះគឺជាសាសនាចក្ររបស់ទ្រង់។ ទ្រង់គឺជាគំរូរបស់យើង ជាព្រះអង្គជ្រាសលោះរបស់យើង។ យើងត្រូវបានបញ្ជាឱ្យធ្វើ “ដូចជាទ្រង់”។[26]

ទ្រង់គឺជាគ្រូបង្រៀននៃក្មេងទាំងឡាយ។ ទ្រង់បានបញ្ជាដល់ពួកសិស្សរបស់ទ្រង់ នៅឯយេរូសាឡិមថា ៖ “ទុកឱ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ត្បិតនគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវារាល់គ្នា”។[27]

នៅក្នុងដំណើរឈ្មឹងនៃការបំរើរបស់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមសាសន៍នីហ្វៃ យើងអាចមើលឃើញ អំពីទឹកព្រះទ័យដ៏ជ្រាលជ្រៅរបស់ទ្រង់ជាងកន្លែងណាៗទាំងអស់ ៖

“ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានបញ្ជាឱ្យនាំកូនក្មេងតូចៗមករកព្រះអង្គ។

“ម្ល៉ោះហើយ គេបាននាំកូនក្មេងតូចៗមកអង្គុយនៅលើទីដ៏ជុំវិញព្រះអង្គ ហើយព្រះយេស៊ូវទ្រង់ឈរនៅកណ្តាល ហើយហ្វូងមនុស្សបានថយចេញ ទុកកន្លែងឱ្យគេនាំកូនក្មេងតូចៗទាំងអស់មក . . .។

“. . . ទ្រង់ព្រះកន្សែង ហើយបណ្តាជនបានធ្វើបន្ទាល់ពីការណ៍នេះ ហើយទ្រង់បានយកកូនក្មេងរបស់ពួកគេម្តងម្នាក់ៗ ហើយបានប្រទានពរដល់ពួកវា ហើយបានអធិស្ឋានដល់ព្រះវរបិតាសំរាប់ពួកវា។

“ហើយកាលទ្រង់បានធ្វើការនេះចប់ហើយ នោះទ្រង់ក៏ព្រះកន្សែងឡើត

“ហើយទ្រង់មានព្រះបន្ទូលទៅហ្វូងមនុស្សថា ៖ មើលន៏ កូនតូចៗរបស់អ្នករាល់គ្នា។

“ហើយនៅពេលពួកគេក្រឡេកមើលទៅ នោះពួកគេបានសម្លឹងមើលទៅលើផ្ទៃមេឃ ហើយឃើញផ្ទៃមេឃបើកចំហរ ហើយពួកគេឃើញពួកទេវតាហោះចុះមកពីស្ថានសួគ៌ ហាក់បីដូចជានៅកណ្តាលភ្លើង ហើយពួកទេវតាក៏ចុះមក ហែរហមជុំវិញពួកកូនក្មេងទាំងនោះ រីឯភ្លើងក៏ព័ទ្ធជុំវិញពួកវា ហើយពួកទេវតាបានធ្វើការងារបំរើដល់ពួកកូនក្មេង។

“ហើយហ្វូងមនុស្សបានឃើញ បានឮ ហើយបានធ្វើបន្ទាល់ ហើយពួកគេដឹងថាទីបន្ទាល់របស់ពួកគេគឺពិត ត្បិតគេទាំងអស់គ្នាបានទាំងឃើញ ហើយក៏ឮដោយខ្លួនគេផ្ទាល់”។[28]

ខ្ញុំដឹងថាកំណត់ហេតុនោះពិត។ ខ្ញុំសូមធ្វើទីបន្ទាល់អំពីទ្រង់ ហើយសូមប្រទានពរដ៏ឃ្យដល់អ្នករាល់គ្នា ដែលបានបង្រៀនកូនចៅនៅក្នុងព្រះទាមរបស់ទ្រង់។

ដកស្រង់ចេញមកពីសុន្ទរកថាមួយ ដែលត្រូវបានធ្វើឡើងនៅឯការប្រជុំធម្មនិដ្ឋានសព្វាហ៍នៃការអប់រំរបស់ សាកលវិទ្យាល័យព្រិកហាំ យ៉ង នៅថ្ងៃទី 17 ខែ សីហា ឆ្នាំ 1999 (សូមមើល *Ensign* ខែ កុម្ភៈ ឆ្នាំ 2000 ទំព័រ 10–17)។

កំណត់ចំណាំ

1. អាលម៉ា 37:35។
2. គោលលទ្ធិ និងសេចក្តីសញ្ញា 68:25។
3. “The Bishop and His Counselors” *Ensign* ខែ ឧសភា ឆ្នាំ 1999 ទំព័រ 57។
4. គោលលទ្ធិ និងសេចក្តីសញ្ញា 84:85។
5. គោលលទ្ធិ និងសេចក្តីសញ្ញា 84:88។
6. អាលម៉ា 37:35។
7. គោលលទ្ធិ និងសេចក្តីសញ្ញា 93:36។
8. គោលលទ្ធិ និងសេចក្តីសញ្ញា 93:40។
9. យ៉ូហាន 14:26 អក្សរក្រទុតត្រូវបានគេបន្ថែម។
10. “Ode: Intimations of Immortality” កថាខណ្ឌទី 5។
11. យ៉ាកុប 4:14។
12. គោលលទ្ធិ និងសេចក្តីសញ្ញា 43:15–16។
13. សូមមើល គោលលទ្ធិ និងសេចក្តីសញ្ញា 107:85។
14. សូមមើល គោលលទ្ធិ និងសេចក្តីសញ្ញា 107:89។
15. ធីម៉ូថេ 2 2:2។
16. រ៉ូម 2:21–22 អក្សរក្រទុតត្រូវបានគេបន្ថែម។
17. សូមមើល យ៉ូហាន 6:60 នីហ្វៃទី 1 16:2 នីហ្វៃទី 2 9:40 ហេលេមិន 14:10។
18. ម៉ាថាយ 5:11–12 សូមមើលផងដែរ លូកា 21:12 យ៉ូហាន 15:20 នីហ្វៃទី 3 12:12។
19. សូមមើល គោលលទ្ធិ និងសេចក្តីសញ្ញា 131:1–4, 132:19–21។
20. គោលលទ្ធិ និងសេចក្តីសញ្ញា 88:78 អក្សរក្រទុតត្រូវបានគេបន្ថែម។
21. គោលលទ្ធិ និងសេចក្តីសញ្ញា 88:79–80។
22. ធីម៉ូថេ 2 3:1។
23. ធីម៉ូថេ 2 3:13។
24. សុភាសិត 22:6។
25. ធីម៉ូថេ 2 3:14–15 អក្សរក្រទុតត្រូវបានគេបន្ថែម។
26. យ៉ូហាន 1 3:7។
27. ម៉ាថាយ 19:14។
28. នីហ្វៃទី 3 17:11–12, 21–25។

ការណែនាំកូនទៅពេលដែលពួកគេធ្វើការសំរេចចិត្ត

15

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមគំរូរការ និងកាលៈទេសៈរបស់អ្នកផ្តាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬពីរ។

- ទៅក្នុងផ្នែកកិច្ចការសំរាប់អានដូចខាងក្រោមនេះ អែលឌើរ អិម រ័សុល បាឡឺដ បានផ្តល់ការណែនាំបួនយ៉ាង ដើម្បីជួយយើង “ស្តាបនាបន្ទាយនៃសេចក្តីជំនឿមួយទៅក្នុងគេហដ្ឋានរបស់យើង ហើយ . . . រៀបចំយុវវ័យរបស់យើងឱ្យមានភាពស្អាតបាត មានគុណធម៌ និងមានគំនិតបរិសុទ្ធ ដើម្បីមានភាពសក្តិសមដ៏ល្អឥតខ្ចោះទៅក្នុងការចូលទៅកាន់ព្រះវិហារបរិសុទ្ធ”។ សូមមើលឡើងវិញនូវការណែនាំរបស់លោក ហើយបន្ទាប់មករៀបចំផែការដ៏ជាក់លាក់មួយចំនួន ដើម្បីធ្វើតាមការណែនាំទាំងនេះទៅក្នុងគេហដ្ឋានរបស់អ្នក។
- សូមពិចារណាអំពីការសំរេចចិត្តទាំងឡាយដែលក្មេងម្នាក់ៗ ទៅក្នុងគ្រួសាររបស់អ្នកអាចជួបប្រទះនៅឯសាសនារៀន ទៅក្នុងគេហដ្ឋាន និងនៅក្នុងមជ្ឈដ្ឋានផ្សេងៗទៀត។ សូមពិចារណាអំពីអ្វីដែលអ្នកអាចធ្វើដើម្បីជួយក្មេងម្នាក់ៗ ជ្រើសរើសនូវការសំរេចចិត្តមួយដ៏សុចរិត។

កិច្ចការសំរាប់អាន

ចូរសិក្សាអត្ថបទដូចខាងក្រោម។ បើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ ចូរអាន និងពិភាក្សាអត្ថបទខាងក្រោមនេះ ជាមួយនឹងប្តី ឬ ប្រពន្ធរបស់អ្នក។

ដូចជាអណ្តាតភ្លើងដែលមិនចេះរលត់

អែលឌើរ អិម រ័សុល បាឡឺដ
នៃក្រុមនៃពួកសាវក 12 នាក់

សេចក្តីអំណរនៃការរៀបអាពាហ៍ពិពាហ៍ទៅក្នុងព្រះវិហារបរិសុទ្ធ

ខ្ញុំបានមានឱកាសជាញឹកញាប់ ដើម្បីធ្វើជាអធិបតីទៅក្នុងព្រះវិហារបរិសុទ្ធ នៅពេលយុវវ័យដែលមានភាពសក្តិសមពីរូប បានរៀបការ ហើយបានផ្សាភ្ជាប់នៅក្នុងជំណាក់នៃព្រះអម្ចាស់។ ជានិច្চកាល នេះគឺជាពេលវេលាដ៏ពិសេសចំពោះក្រុមគ្រួសារ និងមិត្តភក្តិ។ អារម្មណ៍ដែលកើតមានទៅពេលនោះគឺជាអារម្មណ៍ដ៏ផ្អែមល្ហែម ហើយរីករាយដែលគួបផ្សំនឹងសុភមង្គលនៅលើផែនដី និងសេចក្តីអំណរដ៏នៅអស់កល្បជានិច្চដែលកើតមាន ដែលធ្វើឱ្យម្តាយសំរក់ទឹកភ្នែក ដោយបានអធិស្ឋានអស់ពីចិត្តសុំឱ្យហេតុការណ៍នៅថ្ងៃនេះកើតមាន។ អ្នកអាចមើលឃើញអារម្មណ៍ទាំងនោះនៅក្នុងកែវភ្នែករបស់ឪពុក ដែលបានគិតអំពីអ្វីមួយក្រោពីគ្រាន់តែជាមធ្យោបាយបង់ថ្លៃចំណាយជារៀងរាល់ខែប៉ុណ្ណោះ។ ប៉ុន្តែភាគច្រើន អ្នកអាចរកឃើញអារម្មណ៍ទាំងនេះ នៅក្នុងកែវភ្នែកនៃគូស្វាមីភរិយាដ៏សុចរិត ដែលបានខិតខំរស់នៅស្របតាមការបង្រៀននៃដំណឹងល្អ ដោយខិតខំគេចចេញពីការល្បួងទាំងឡាយនៃពិភពលោក។ អារម្មណ៍ដ៏ពិសេសមួយ ហើយក៏ជាអារម្មណ៍ដែលមិនអាចប្រកែកបាន ដែលនឹងកើតមានចំពោះអស់អ្នកទាំងឡាយណា ដែលបន្តមានភាពស្អាតស្អំ បរិសុទ្ធ និងសុចរិត។

បទដ្ឋានសីលធម៌គឺមានភាពជាក់លាក់

មានយុវជន និងយុវនារីជាច្រើនកំពុងបង្ហោនខ្លួនទៅតាមសម្តាធដែលកើតមានទៅក្នុងពិភពលោក ដែលកំពុងលិចលង់ទៅដោយសារលិខិតអាក្រក់ៗ និងឥរិយាបទអសីលធម៌។ លូស៊ីហ្វើរ កំពុងធ្វើសង្គ្រាមជាមួយនឹងព្រលឹងនៃមនុស្សទាំងក្មេងទាំងចាស់ ហើយចំនួនសរុបនៃអ្នករងគ្រោះកំពុងតែមានការកើនឡើង។ បទដ្ឋាននៃពិភពលោកមានការផ្លាស់ប្តូរដូចជាវាលខ្សាច់ដែលត្រូវបានខ្យល់បក់ពោកដូច្នោះដែរ។ បទដ្ឋាននោះគឺជាការផ្លាស់ប្តូរដែលពុំធ្លាប់បានឮ ឬត្រូវបានគេបដិសេធកាលពីមុនមកទេ ប៉ុន្តែវាគឺជារឿងដ៏សាមញ្ញនាបច្ចុប្បន្ននេះ។ ពិភពលោកកំពុងមានទស្សនវិស័យផ្លាស់ប្តូរយ៉ាងខ្លាំង រហូតដល់ពួកអ្នកដែលជ្រើសរើស ដើម្បីឱ្យមានបទដ្ឋានខាងសីលធម៌ត្រូវបានគេមើលមកថា ជាមនុស្សចម្លែក ជាងនេះទៅទៀតពួកគេត្រូវការពារបំណងព្រាថ្នារបស់ពួកគេ ដើម្បីគោរពព្រះបញ្ញត្តិទាំងឡាយនៃព្រះ។

ប៉ុន្តែមានរឿងមួយដែលមានភាពជាក់លាក់គឺថា ៖ ព្រះបញ្ញត្តិទាំងឡាយពុំមានការផ្លាស់ប្តូរឡើយ។ ចូរអ្នកទាំងអស់គ្នាកុំយល់ខុសអំពីបញ្ហានេះឡើយ។ អ្វីដែលត្រឹមត្រូវនៅតែត្រឹមត្រូវជានិច្ច។ អ្វីដែលខុសគឺនៅតែខុស មិនថាមានការការពារចំពាំងយ៉ាងប៉ិនប្រសប់ដ៏គួរឱ្យស្ងើចសរសើរ ឬភាពត្រឹមត្រូវខាងនយោបាយប៉ុណ្ណោះទេ។ យើងជឿលើភាពបរិសុទ្ធពីមុនអាពាហ៍ពិពាហ៍ និងភាពស្មោះត្រង់ជារៀងរហូត។ បទដ្ឋាននោះគឺបទដ្ឋាននៃសេចក្តីពិតដ៏ពេញលេញមួយ។ វាគឺជាប្រធានបទចំពោះការឆ្មោះឆ្មៃតជាសាធារណៈ ឬក៏ការរួមបញ្ចូលទៅលើស្ថានការណ៍ ឬកាលៈទេសៈណាមួយ។ គឺពុំចាំបាច់ធ្វើការពិភាក្សាអំពីប្រធានបទនេះ ឬបទដ្ឋាននៃដំណឹងល្អដទៃទៀតនោះទេ។

ការស្តាបនាបន្ទាយនៃសេចក្តីជំនឿទៅក្នុងគេហដ្ឋាន

ប៉ុន្តែចំពោះឪពុកម្តាយ ពួកអ្នកដឹកនាំ និងពួកគ្រូបង្រៀនមានទូរគំរូរការដែលគួរឱ្យព្រួយបារម្ភមួយ ទៅក្នុងការជួយយុវវ័យរបស់យើងឱ្យរៀនយល់ដឹង រៀនស្រឡាញ់ រៀនអំពីតម្លៃ និងរៀនរស់នៅតាមបទដ្ឋាននៃដំណឹងល្អ។ ឪពុកម្តាយ និងយុវវ័យទាំងឡាយត្រូវតែក្រោកឈរឡើងរួមគ្នា ទៅក្នុងការការពារប្រឆាំងនឹងមាសត្រូវដ៏ឈ្លាសវៃ ហើយមានល្បិចកល។ យើងត្រូវមានការលះបង់ ប្រសិទ្ធភាព និងភាពរឹងមាំទៅក្នុងកិច្ចខិតខំរបស់យើងដើម្បីរស់នៅតាមដំណឹងល្អ ទៅពេលដែលមាសត្រូវរបស់យើងបានខិតខំបំផ្លាញកិច្চការទាំងនេះ—ព្រមទាំងរូបយើងផងដែរ។

ឧបសគ្គទៅចំពោះមុខយើងរាល់គ្នាគឺមានភាពធំធេងខ្លាំងណាស់។ គ្រោះថ្នាក់ដែលនឹងកើតមានឡើងគឺជាព្រលឹងអមតៈ នៃអ្នកជាទីស្រឡាញ់របស់យើង។ ខ្ញុំសូម

ណែនាំនូវរបៀបបួនយ៉ាង ដែលយើងអាចស្តាបនាបន្ទាយនៃសេចក្តីជំនឿមួយ នៅក្នុងគេហដ្ឋានរបស់យើង ហើយជាពិសេសគឺការរៀបចំយុវវ័យរបស់យើងឱ្យមានភាពស្អាតបាត មានគុណធម៌ និងមានគំនិតបរិសុទ្ធ ដើម្បីមានភាពសក្តិសមដ៏ល្អឥតខ្ចោះនៅក្នុងការចូលទៅកាន់ព្រះវិហារបរិសុទ្ធ។

បង្រៀនកូនចៅអំពីដំណឹងល្អ

ចំណុចទីមួយ គឺព័ត៌មានអំពីដំណឹងល្អ។ ព័ត៌មានដ៏សំខាន់បំផុត ជាព័ត៌មាននៃការផ្លាស់ប្តូរដែលមាននៅក្នុងជីវិតនេះ ដែលខ្ញុំបានយល់ដឹង គឺជាចំណេះដឹងស្តីអំពីនិស្ស័យដ៏ពិតប្រាកដរបស់យើង ក្នុងនាមជាកូនចៅនៃព្រះជាព្រះវរបិតាដ៏អស់កល្ប។ រឿងនេះពុំមែនគ្រាន់តែជាភាពត្រឹមត្រូវខាងគោលលទ្ធិប៉ុណ្ណោះនោះទេ ប៉ុន្តែវាគឺជារឿងដ៏សំខាន់ខាងវិញ្ញាណផងដែរ។ នៅក្នុងការអធិស្ឋានទូលអង្វរដ៏អស្ចារ្យរបស់ទ្រង់ ព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលថា ៖ “នេះគឺជាជីវិតដ៏នៅអស់កល្បជានិច្ច គឺឱ្យគេបានស្គាល់ដល់ទ្រង់ដ៏ជាព្រះពិតតែមួយ និងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានចាត់ឱ្យមកផង” (យ៉ូហាន 17:3)។ ដើម្បីស្គាល់ព្រះវរបិតាសួគ៌ ហើយយល់ដឹងអំពីទំនាក់ទំនងរបស់យើងជាមួយនឹងទ្រង់ ដែលជាព្រះបិតា និងជាព្រះរបស់យើង នោះគឺយើងត្រូវស្វែងយល់អំពីអត្ថន័យនៅក្នុងជីវិតនេះ និងសេចក្តីសង្ឃឹមសំរាប់ជីវិតក្រោយទៀត។ ក្រុមគ្រួសាររបស់យើងត្រូវដឹងថា ទ្រង់មានព្រះជន្មរស់ ថាយើងពិតជាបុត្រាបុត្រីរបស់ទ្រង់ ហើយកូនចៅដែលទ្រង់មាននៅពេលនេះ និងជារៀងរហូត។ ការមានសេចក្តីសុខសាន្តនៅក្នុងការយល់ដឹងនោះ សមាជិកគ្រួសារនឹងកាត់បន្ថយចំពោះការបង្អែរបង្អង់ធ្វើអំពើអាក្រក់ ហើយខិតខំស្វែងរកព្រះ ព្រមទាំងដើរតាមទ្រង់ផងដែរ (សូមមើល ជនគណនា 21:8)។

សូមរស់នៅតាមសេចក្តីសញ្ញា ពុំមែនរស់នៅឱ្យមានភាពងាយស្រួលនោះឡើយ

ទោះជាមានអ្វីមួយកើតឡើងក៏ដោយ ក៏យើងត្រូវបំពេញដួងចិត្តរបស់យើងនូវទីបន្ទាល់ដ៏អស្ចារ្យ ស្តីអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដូចជាពួកអ្នកត្រួសត្រាយផ្លូវកាលពីសម័យដើមផងដែរ។ សូមចងចាំនៅពេលដែលទីក្រុមណៅវ៉ូត្រូវបានបំផ្លាញចោលក្នុងខែ កញ្ញា ឆ្នាំ 1846 និងស្ថានភាពដែលមិនទ្រាំទ្រ បានរបស់ពួកបរិសុទ្ធនៅក្នុងជំរំដ៏កំសត់នោះ។ នៅពេលព័ត៌មាននេះត្រូវបានលេចឲដល់វិនទើរ ខួរទើរ្យ នោះលោក ព្រិកហាំ យ៉ង់បានប្រមូលផ្តុំបងប្អូនប្រុសមួយរំពេច។ បន្ទាប់ពីការពន្យល់អំពីស្ថានការណ៍នោះ និងការរំពឺកដល់ពួកគេអំពីសេចក្តីសញ្ញា ដែលបានធ្វើនៅក្នុងព្រះវិហារបរិសុទ្ធណៅវ៉ូថា ត្មានរណាម្នាក់ដែលបានធ្វើដំណើរមកកាន់ទីនេះ នឹងត្រូវបានគេបោះបង់ចោលនោះឡើយ ទោះបីជាមានភាពក្រខ្សត់យ៉ាងណាក៏ដោយ គាត់បានផ្តល់នូវការសាកល្បងដ៏អស្ចារ្យនេះដល់ពួកគេ ៖

គាត់បាននិយាយថា ៖ “ឥឡូវនេះគឺជាពេលសំរាប់យើងចេញទៅធ្វើកិច្ចការ។ *ចូរឱ្យភ្លើងនៃសេចក្តីសញ្ញា* ដែលអ្នកបានធ្វើនៅក្នុងដំណាក់នៃព្រះអម្ចាស់ *ដុតរោលនៅក្នុងដួងចិត្តរបស់អ្នក ដូចជាអណ្តាតភ្លើងដែលមិនចេះរលត់* ” (ជូនចំពោះក្រុមប្រឹក្សាជាន់ខ្ពស់ស្តីអំពីគោលបំណងរបស់ក្រុមប្រឹក្សា ថ្ងៃទី 27 ខែ កញ្ញា ឆ្នាំ 1846 លិខិតរបស់លោក ព្រិកហាំ យ៉ង់ បណ្ណាសាររបស់ការិយាល័យផ្នែកប្រវត្តិសាស្ត្រ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ 1 អក្សរទ្រេតត្រូវបានបន្ថែម)។ នៅក្នុងរយះពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ មានរទេះសេះជាច្រើនបានធ្វើដំណើរទៅកាន់ទិសបូពា៌ ដើម្បីជួយសង្គ្រោះពួកបរិសុទ្ធនៅក្នុងជំរំដ៏កំសត់នៅតាមដងទន្លេម៊ីស៊ីស៊ីពី ទោះជាមានភាពក្រីក្រនៅក្នុងវិនទើរ ខួរទើរ្យក៏ដោយ។

ជាញឹកញាប់ យើងបានឲ្យអំពីការរងទុក្ខ និងការលះបង់របស់ពួកបរិសុទ្ធទាំងនោះ ដែលបានស៊ូទ្រាំ ហើយយើងបានសួរដល់ខ្លួនឯងថា តើពួកគេបានធ្វើកិច្ចការនេះ ដោយរបៀបណា? តើអ្វីទៅដែលផ្តល់ឱ្យពួកគេនូវកំលាំងនៅក្នុងការធ្វើកិច្ចការនេះ? ចំលើយមួយផ្នែកគឺស្ថិតនៅក្នុងប្រសាសន៍ដ៏មានឥទ្ធិពលរបស់ប្រធានយ៉ង់។ ពួកបរិសុទ្ធថ្ងៃចុងក្រោយទាំងនោះ បានចុះសេចក្តីសញ្ញាជាមួយនឹងព្រះ ហើយសេចក្តីសញ្ញាទាំងនោះ បានដុតរោលដួងចិត្តរបស់ពួកគេប្រៀបបានដូចជាភ្លើងដែលមិនចេះរលត់។

ពេលខ្លះយើងត្រូវបានល្បួងដែលបណ្តាលឱ្យជីវិតរបស់យើង ស្ថិតនៅក្រោមការគ្រប់គ្រងដោយភាពងាយស្រួល ជាជាងដោយសេចក្តីសញ្ញា។ ជានិច្ចកាល វាពុំមែនជាការងាយស្រួលនៅក្នុងការរស់នៅតាមបទដ្ឋាននៃដំណឹងល្អ ហើយក្រោកឈរឡើងដើម្បីសេចក្តីពិត និងការធ្វើទីបន្ទាល់អំពីការស្តារឡើងវិញនោះឡើយ។ ជាទូទៅ វាពុំមែនជាការងាយស្រួលនៅក្នុងការចែកចាយដំណឹងល្អជាមួយនឹងមនុស្សដទៃទេ។ ជានិច្ចកាល វាពុំមែនជាការងាយស្រួលដើម្បីឆ្លើយតបចំពោះការហៅនៅក្នុងសាសនាចក្រឡើយ ជាពិសេសគឺជាការហៅមួយ ដែលពង្រីកនូវសមត្ថភាពរបស់យើង។ ឱកាសបំរើដល់មនុស្សដទៃតាមរបៀបដ៏មានន័យ នៅពេលយើងចុះសេចក្តីសញ្ញាថាយើងនឹងធ្វើកិច្ចការនោះ ប៉ុន្តែវាមានតិចតួចណាស់ ដែលការណ៍នេះកើតឡើងនៅក្នុងពេលដ៏សមស្របនោះ។ ប៉ុន្តែនៅក្នុងការរស់នៅដោយភាពងាយស្រួល គឺពុំមាននូវអំណាចខាងវិញ្ញាណឡើយ។ អំណាចនោះកើតឡើងនៅពេលយើងរក្សានូវសេចក្តីសញ្ញារបស់យើង។ នៅពេលយើងសម្លឹងមើលអំពីជីវិតរបស់ពួកបរិសុទ្ធនៅសម័យនោះ យើងឃើញថា សេចក្តីត្រូវការរបស់ពួកគេ គឺជាកត្តាដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់ពួកគេ។ គំរូ និងទីបន្ទាល់របស់ពួកគេ គឺមានភាពអស្ចារ្យគ្រប់គ្រាន់ ដើម្បីមានអនុភាពទៅលើកូនចៅរបស់ខ្លួនពីមួយជំនាន់ទៅមួយជំនាន់។

បង្រៀនកូនចៅអំពីសីលធម៌

នៅពេលកូនចៅរបស់យើងធំពេញវ័យ ពួកគេត្រូវការព័ត៌មានដែលបានបង្រៀនដោយឱពុកម្តាយយ៉ាងច្បាស់លាស់ អំពីអ្វីដែលត្រឹមត្រូវ និងអ្វីដែលមិនត្រឹមត្រូវ។ ឱពុកម្តាយត្រូវបង្រៀនកូនចៅឱ្យជៀសវាងពីរូបភាព ឬរឿងអាសគ្រាម។ ក្មេង និងយុវវ័យទាំងឡាយត្រូវយល់ដឹងពីឱពុកម្តាយថា នៅគ្រប់រូបភាពអាសគ្រាមគឺជាឧបករណ៍របស់អារក្ស ហើយប្រសិនបើនរណាម្នាក់ប្រឡែងលេងនឹងវា នោះវានឹងមានអំណាចដើម្បីអូសទាញធ្វើឱ្យយើងល្ងិតល្ងង់ ហើយព្រមទាំងបំផ្លាញវិញ្ញាណមនុស្សទៀតផង។ ពួកគេត្រូវទទួលការបង្រៀនដោយ កុំឱ្យប្រើពាក្យសំដីថោកទាប និងមិនត្រូវប្រើព្រះនាមរបស់ព្រះអម្ចាស់ជាអសារឥតការនោះឡើយ។ រឿងកំប្លែងថោកទាបដែលបានឲមិនគួរត្រូវបាននិយាយចេញទេ។ សូមបង្រៀនសមាជិកគ្រួសារកុំឱ្យស្តាប់តន្ត្រី ដែលធ្វើឱ្យមានភាពត្រេកត្រអាលខាងផ្លូវភេទ។ សូមនិយាយជាមួយនឹងពួកគេអំពីបញ្ហាផ្លូវភេទ និងការបង្រៀននៃដំណឹងល្អ ដែលទាក់ទងនឹងភាពបរិសុទ្ធ។ ចូរឱ្យព័ត៌មាននេះកើតចេញមកពីឱពុកម្តាយនៅក្នុងគេហដ្ឋាន តាមរបៀបដ៏សមរម្យមួយ។ សមាជិកគ្រួសារគ្រប់រូបត្រូវយល់ដឹងអំពីច្បាប់ និងត្រូវបានការពារខាងវិញ្ញាណ ដើម្បីឱ្យពួកគេអាចគោរពតាមច្បាប់ទាំងនោះ។ ហើយនៅពេលកំហុសបានកើតមានឡើង នោះដង្វាយធួនដ៏អស្ចារ្យរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានយល់ដឹង ហើយនឹងត្រូវបានទទួលតាមរយះដំណើរការដ៏ពេញលេញ ហើយជួនកាលជាដំណើរការដ៏ការប្រែចិត្ត ការអភ័យទោស និងការបន្តមានសេចក្តីសង្ឃឹមដ៏លំបាកចំពោះអនាគតដែលអាចទទួលបាន។ យើងមិនលះបង់ការស្វែងរកជាបុគ្គល និងជាគ្រួសារសំរាប់ជីវិតដ៏នៅអស់កល្បជានិច្ចឡើយ។

ជាអកុសល មានឪពុកម្តាយជាច្រើនទៅក្នុងពិភពលោកសព្វថ្ងៃនេះ ដែលបានបោះបង់ចោលការទទួលខុសត្រូវក្នុងការបង្រៀនអំពីតម្លៃទាំងនេះ និងគោលចិត្តសាសនាចក្រដទៃទៀតដល់ក្រុមគ្រួសាររបស់ខ្លួន ដោយជឿជាក់ថាមនុស្សដទៃទៀតនឹងធ្វើកិច្ចការនេះដូចជា ៖ ក្រុមយុវវ័យ សាលារៀន ពួកអ្នកដឹកនាំ និងពួកគ្រូបង្រៀនទៅក្នុងសាសនាចក្រ ឬសូម្បីតែចំពោះប្រព័ន្ធផ្សព្វផ្សាយដទៃទៀតផងដែរ។ ជារៀងរាល់ថ្ងៃកូនចៅរបស់យើងកំពុងរៀនសូត្រ ដោយចំពេញទៅក្នុងគំនិត និងក្នុងដួងចិត្តរបស់ពួកគេនូវបទពិសោធន៍ និងទស្សនៈដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លាចំពោះតម្លៃផ្ទាល់ខ្លួន។

ពង្រឹងគ្នាទៅវិញទៅមកប្រឆាំងនឹងអំពើទុច្ចរិត

បងប្អូនប្រុសស្រីទាំងឡាយ យើងត្រូវបង្រៀនគ្នាទៅវិញទៅមក ហើយបណ្តុះសេចក្តីជំនឿដ៏រឹងមាំទៅក្នុងដួងចិត្តរបស់យើង ដើម្បីពង្រឹងខ្លួនរបស់យើងនូវសេចក្តីក្លាហានទៅក្នុងការគោរពព្រះបញ្ញត្តិទាំងឡាយទៅក្នុងពិភពលោកមួយដែលអំពើទុច្ចរិតកំពុងតែរីករាលដាលឡើង។ យើងត្រូវផ្លាស់ប្តែចិត្តជឿយ៉ាងពិតប្រាកដចំពោះដំណឹងល្អនៃព្រះគ្រីស្ទ ដើម្បីឱ្យភ្លើងនៃសេចក្តីសញ្ញានោះនឹងដុតរោលទៅក្នុងដួងចិត្តរបស់អ្នក ដូចជាអណ្តាតភ្លើងដែលមិនចេះរលត់។ ហើយជាមួយនឹងសេចក្តីជំនឿបែបនោះ យើងនឹងធ្វើនូវអ្វីដែលចាំបាច់ទៅក្នុងការបន្តមានភក្តីភាព និងមានភាពសក្តិសម។

សូមមានការព្រាស្រ័យទាក់ទងនឹងកូនចៅដោយបើកចំហរ

ចំណុចទីពីរ គឺជាទំនាក់ទំនង។ ចំពោះទំនាក់ទំនងរវាងសមាជិកគ្រួសារគឺគ្មានអ្វីមួយ ដែលមានសារៈសំខាន់ជាងទំនាក់ទំនងដោយបើកចំហ និងដោយស្មោះត្រង់នោះឡើយ។ ជាពិសេស នេះគឺជាការពិតសំរាប់ឪពុកម្តាយទៅក្នុងព្យាយាមបង្រៀនគោលការណ៍ និងបទដ្ឋានទាំងឡាយ នៃដំណឹងល្អដល់កូនចៅរបស់ខ្លួននោះ។ សមត្ថភាពទៅក្នុងការទូន្មានដល់យុវវ័យរបស់យើង—ហើយប្រហែលជាចំណុចមួយដ៏សំខាន់ នោះគឺការយកចិត្តទុកដាក់ស្តាប់ចំពោះកង្វល់របស់ពួកគេ—សមត្ថភាពនេះគឺជាគ្រឹះដែលជាទំនាក់ទំនងដ៏ជោគជ័យមួយដែលបានស្ថាបនាឡើង។ ជាញឹកញាប់ អ្វីដែលយើងមើលឃើញនឹងភ្នែក និងអ្វីដែលយើងទទួលអារម្មណ៍នៅក្នុងដួងចិត្តនឹងធ្វើការទំនាក់ទំនងឆ្ងាយជាងអ្វីដែលយើងបានឮ ឬបាននិយាយ។ ពាក្យមួយឃ្លាចំពោះអ្នករាល់គ្នាដែលជាកូនចៅគឺ ៖ ចូរកុំឱ្យមានការមិនគោរពចំពោះឪពុកម្តាយអ្នកឡើយ។ អ្នករាល់គ្នាត្រូវរៀនស្តាប់ ជាពិសេសចំពោះពាក្យទូន្មានរបស់ឪពុកម្តាយអ្នក និងចំពោះការបំផុសគំនិតនៃព្រះវិញ្ញាណ។ យើងត្រូវសម្លឹងមើល ហើយក្តាប់យកឱកាសនៃការបង្រៀនដ៏ពិសេស ដែលជានិច្চកាលកើតឡើងទៅក្នុងទំនាក់ទំនងនៃគ្រួសាររបស់យើង ហើយយើងត្រូវរកដំណោះស្រាយ ទៅក្នុងពេលនេះដើម្បីមានអាត្រាជួបជុំក្រុមគ្រួសារទៅរៀងរាល់អាត្រាថ្ងៃច័ន្ទ។

តាមរយៈការអធិស្ឋានជាគ្រួសារឡើងទាត់ និងតាមរយៈការសិក្សាព្រះគម្ពីរជាគ្រួសារ នោះនឹងកើតមានឡើងនូវឱកាស នៃការព្រាស្រ័យទាក់ទងដ៏អស្ចារ្យ។ ព្រះគម្ពីរទាំងឡាយនឹងជួយកំណត់តម្លៃ និងគោលដៅរបស់ក្រុមគ្រួសារ ហើយការពិភាក្សារួមគ្នាអំពីបញ្ហាទាំងនោះ នឹងជួយសមាជិកគ្រួសារឱ្យរៀនការពារខ្លួនឯងទៅក្នុងភាពរឹងមាំខាងវិញ្ញាណ និងភាពខ្លួនទីពឹងខ្លួន។ ការណ៍នេះត្រូវការនូវពេលវេលា ហេតុដូច្នេះហើយ យើងត្រូវប្រឹក្សារួមគ្នាអំពីទំហំនៃការអនុញ្ញាតឱ្យមាន ចំពោះការមើលទូរទស្សន៍ ខ្សែភាពយន្ត ខ្សែវីដេអូ វីដេអូហ្គេម ការចំណាយពេលប្រើអ៊ិនធើរណែត ឬសកម្មភាពផ្សេងទៀតនៅខាងក្រៅផ្ទះ។

ឪពុកម្តាយ និងពួកអ្នកដឹកនាំទាំងឡាយគប្បីធ្វើអន្តរាគមន៍

ចំណុចទីបីគឺការធ្វើអន្តរាគមន៍។ កិច្ចការនេះគឺជាកាតព្វកិច្ចរបស់ឪពុកម្តាយនៅក្នុងការធ្វើអន្តរាគមន៍ នៅពេលពួកគេមើលឃើញការជ្រើសរើសខុសឆ្គង កំពុងតែកើតមានឡើងនោះ។ ការធ្វើបែបនេះពុំមានន័យថា ឪពុកម្តាយដកហូតយកអំណោយទាននៃសិទ្ធិជ្រើសរើសដ៏មានតម្លៃចេញពីកូនចៅនោះឡើយ។ ដោយសារតែសិទ្ធិជ្រើសរើស គឺជាអំណោយទានមកពីព្រះ នោះការជ្រើសរើសនូវអ្វីដែលពួកគេនឹងធ្វើ រប្យប់ដែលពួកគេនឹងប្រព្រឹត្ត និងអ្វីដែលពួកគេនឹងជ្រើជាក់នឹងនៅតែជាសិទ្ធិរបស់ពួកគេជានិច្ច។ ប៉ុន្តែក្នុងនាមជាឪពុកម្តាយ យើងត្រូវប្រាកដថា ពួកគេយល់អំពីវិធាបទដ៏សមរម្យ និងផលវិបាកដែលនឹងកើតឡើងចំពោះពួកគេ ប្រសិនបើពួកគេធ្វើតាមការជ្រើសរើសដ៏ខុសឆ្គងរបស់ពួកគេនោះ។ សូមចងចាំថា មិនត្រូវឱ្យមានន្ទរការរឹតបណ្តឹងខុសច្បាប់ណាមួយ កើតឡើងនៅក្នុងគេហដ្ឋានឡើយ។ ខ្សែភាពយន្ត ទស្សនាវដ្តី ទូរទស្សន៍ ខ្សែវីដេអូ អ៊ិនធើរណែត និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត គឺមានវត្តមាននៅទីនោះដូចជាភ្ញៀវ ហើយវាគួរស្វាគមន៍ នៅពេលវាមានលក្ខណៈសមរម្យសំរាប់ភាពរីករាយដល់គ្រួសារតែប៉ុណ្ណោះ។ សូមធ្វើឱ្យគេហដ្ឋានរបស់អ្នក ក្លាយទៅជាស្ថានសួគ៌នៃសេចក្តីសុខសាន្ត និងសេចក្តីសុចរិត។ សូមកុំអនុញ្ញាតឱ្យតុិពលអាក្រក់ បំពុលមជ្ឈដ្ឋានខាងវិញ្ញាណដ៏ពិសេសរបស់អ្នកឡើយ។ សូមមានសេចក្តីមេត្តា ចេះគិតគូរ សុភាពរាបសា និងចេះរិះគិតចំពោះអ្វីដែលអ្នកនិយាយ និងរប្យប់ដែលអ្នកនឹងប្រព្រឹត្តចំពោះមនុស្សដទៃ។ នោះគោលដៅជាគ្រួសារគឺបានផ្តែកទៅលើបទដ្ឋានដំណឹងល្អ នឹងធ្វើឱ្យមានភាពងាយស្រួលទៅក្នុងធ្វើការសំរេចចិត្តដ៏ល្អ។

ចំពោះអ្នករាល់គ្នាដែលជាប៊ីស្សព គ្រូបង្រៀន និងពួកអ្នកដឹកនាំដទៃទៀតក្នុងសាសនាចក្រ គោលការណ៍ដូចគ្នានេះអាចអនុវត្តបានចំពោះអ្នករាល់គ្នា នៅពេលអ្នកខិតខំទៅក្នុងការជួយជ្រាមជ្រែងដល់ក្រុមគ្រួសារទាំងឡាយ។ អ្នករាល់គ្នាមិនត្រូវឈរដោយព្រងើយកន្តើយ ចំពោះអស់អ្នកទាំងឡាយណា ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់អ្នក កំពុងធ្វើការជ្រើសរើសខុសខាងសីលធម៌នោះឡើយ។ នៅពេលមានយុវវ័យម្នាក់ធ្វើអំពើខុសឆ្គងខាងសីលធម៌ ជានិច្চកាលត្រូវមានមនុស្សម្នាក់—ដូចជាឪពុកម្តាយ អ្នកដឹកនាំ គ្រូបង្រៀន—ជាអ្នកដែលអាចធ្វើឱ្យមានភាពខុសប្លែកកើតមានឡើង តាមរយៈការធ្វើអន្តរាគមន៍ដោយសេចក្តីស្រឡាញ់ និងដោយសេចក្តីមេត្តា។

ចូរធ្វើជាគំរូល្អដល់កូនចៅ

ចំណុចទីបួន គឺជាគំរូ។ វាគឺជាការលំបាកណាស់ចំពោះអ្នក វាជារឿងគួរឱ្យឡើយហាត់ណាស់ នៅពេលដែលមានមនុស្សម្នាក់ស្វែងរកផ្លូវរបស់ខ្លួនឆ្លងកាត់សមុទ្រដែលពុំធ្លាប់ស្គាល់ ដោយគ្មានជំនួយពីគ្រិវែស័យនោះ រីឯក្មេង យុវវ័យទាំងឡាយក៏ដូចគ្នាផងដែរ គឺជាពួកគេកំពុងស្វែងរកផ្លូវឆ្លងកាត់សមុទ្រនៃជីវិតរបស់ខ្លួនដោយពិបាក បើគ្មានពន្លឺគំរូល្អដឹកនាំនោះទេ។ យើងមិនអាចរំពឹងទុកឱ្យពួកគេផ្សះផ្សាវាងការណ៍ដែលមិនត្រឹមត្រូវទាំងនោះបានឡើយ ប្រសិនបើពួកគេមើលឃើញឪពុកម្តាយរបស់ខ្លួនធ្វើតាមគោលការណ៍ទាំងនោះ ហើយបារម្ភយទៅក្នុងការរស់នៅតាមដំណឹងល្អ។

ទៅក្នុងនាមជាឪពុកម្តាយ ពួកគ្រូបង្រៀន និងពួកអ្នកដឹកនាំ វាគឺជាកាតព្វកិច្ចដ៏សំខាន់របស់យើងទៅក្នុងធ្វើជាគំរូផ្ទាល់ខ្លួន និងគំរូដ៏មានឥទ្ធិពលនៃកំលាំងសុចរិត សេចក្តីក្លាហាន ការលះបង់ ការបំរើដោយមិនអត្មានិយម និងការគ្រប់គ្រងលើខ្លួនឯង។ ទាំងនេះគឺជាលក្ខណៈដែលនឹងជួយយុវវ័យរបស់យើងឱ្យកាន់ជំបងដែកនៃដំណឹងល្អ ហើយនៅតែដើរលើផ្លូវត្រង់និងចង្អៀត។

ការរស់នៅតាមជំណឹងល្អផ្តល់ឱ្យផ្សេងពីកំហុសទាំងឡាយ

ខ្ញុំសូមប្រាប់អ្នករាល់គ្នាថា ការផ្តោតអារម្មណ៍ទៅលើព័ត៌មាន ការប្រាស្រ័យទាក់ទង អត្តរាគមន៍ និងគំរូ ជានិច្চកាលនឹងនាំមកនូវលទ្ធផលជាគ្រួសារដ៏ល្អឥតខ្ចោះមួយ ដោយមានកូនចៅដ៏ល្អឥតខ្ចោះ ដែលពុំធ្លាប់ឃ្លាតឆ្ងាយចេញពីបទដ្ឋានជំណឹងល្អឡើយ។ ប៉ុន្តែជាអកុសល នោះពុំមែនជាបញ្ហាចំបងឡើយ។ ប៉ុន្តែក្រុមគ្រួសារដែលជឿង បង្រៀន រស់នៅតាមគោលការណ៍ និងបទដ្ឋានទាំងឡាយនៃជំណឹងល្អគឺ ភាគច្រើនអាចបង្កាខ្លួនឱ្យផ្សេងផុតពីការឈឺចាប់នៃកំហុសដ៏ធ្ងន់ធ្ងរ។ នៅពេលគំរូនៃការប្រាស្រ័យទាក់ទងជាវិជ្ជមាន ត្រូវបានបង្កើតឡើង និងគំរូដ៏ស្មោះត្រង់បានទទួលដោគជ័យ នោះវានឹងមានភាពងាយស្រួលជាងនៅក្នុងការប្រឹក្សារួមគ្នា ស្តីអំពីបញ្ហាផ្តាល់ខ្លួន តាមរយៈការផ្លាស់ប្តូរដ៏ចាំបាច់ដែលនឹងប្រទានពរដល់សមាជិកគ្រួសារគ្រប់រូប។

សូមស្តាប់ពាក្យទូន្មានដ៏មានសារៈសំខាន់របស់ស្តេចបេនយ៉ាមីន ៖

“យើងពុំអាចប្រាប់អ្នករាល់គ្នាឱ្យរស់នូវការណ៍ទាំងឡាយ ដែល [អ្នករាល់គ្នា] អាចប្រព្រឹត្តអំពើបាបនោះទេ ព្រោះមានផ្លូវ និងបែបផ្សេងៗគ្នា គឺមានជាច្រើនណាស់ ដែលយើងពុំអាចរៀបរាប់បានឡើយ។

“ប៉ុន្តែ យើងអាចនិយាយប្រាប់អ្នកតែប៉ុណ្ណោះថា បើសិនជាអ្នករាល់គ្នាពុំប្រយ័ត្នខ្លួន ទាំងគំនិតរបស់ខ្លួន និងពាក្យសំដីរបស់ខ្លួន និងកិច្চការរបស់ខ្លួន ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ និងបន្តនៅក្នុងសេចក្តីជំនឿជឿដល់អ្វី ដែលអ្នករាល់គ្នាបានឮ អំពីការយាងមកនៃព្រះអម្ចាស់របស់យើងរហូតដល់ថ្ងៃចុងក្រោយនៃជីវិតខ្លួនទេ នោះអ្នករាល់គ្នានឹងវិនាស។ ហើយឥឡូវនេះ ឱមនុស្សលោកិយអើយ សូមចងចាំ ហើយកុំវិនាសបង់ឡើយ” (ម៉ូសាយ 4:29–30)។

បងប្អូនប្រុសស្រីរបស់ខ្ញុំ សូមឱ្យព្រះប្រទានពរដល់យើងគ្រប់ៗគ្នា ដើម្បីឱ្យភ្លើងនៃសេចក្តីសញ្ញារបស់យើង អាចឆេះឡើងនៅក្នុងដួងចិត្តរបស់យើង ដូចជាអណ្តាតភ្លើងដែលមិនចេះរលត់។ សូមឱ្យយើងរៀបចំខ្លួនខាងវិញ្ញាណ ដើម្បីរំឭកឡើងវិញនូវសេចក្តីសញ្ញាដ៏ពិសិដ្ឋរបស់យើងជារៀងរាល់សប្តាហ៍ នៅពេលយើងទទួលទានសាក្រាម៉ង់។ ដើម្បីយើងនឹងមានទូវការគោរពដល់ព្រះអម្ចាស់ ហើយយើងនឹងមានភាពអន្ទះសារដើម្បីធ្វើនូវកិច្চការរបស់យើង នៅក្នុងថ្ងៃដ៏រីករាយ និងមហិមាទាំងនេះ ដើម្បីស្ថាបនាសាសនាចក្ររបស់ទ្រង់ ដោយការពង្រឹងក្រុមគ្រួសាររបស់យើង នេះគឺជាការអធិស្ឋានដ៏រាបសាររបស់ខ្ញុំ។

ដកស្រង់ចេញមកពីសុន្ទរកថា ដោយអែលឌើរ ពាឡឺដ នៅក្នុងសន្និសីទទូទៅនៃសាសនាចក្រ ខែ មេសា ឆ្នាំ 1999 (សូមមើល Conference Report ខែ មេសា ឆ្នាំ 1999 ទំព័រ 111–15 ឬ *Ensign* ខែ ឧសភា ឆ្នាំ 1999 ទំព័រ 85–87)។

ការអធិស្ឋានជាក្រុមគ្រួសារ ការសិក្សាព្រះគម្ពីរជាក្រុមគ្រួសារ និង រាត្រីជួបជុំក្រុមគ្រួសារ

16

យោបល់សំរាប់ការអនុវត្តន៍

ដោយស្របទៅតាមតំរូវការ និងកាលះទេសះរបស់អ្នកផ្ទាល់ សូមធ្វើតាមយោបល់ទាំងនេះឱ្យបានមួយ ឬច្រើន។

- ប្រសិនបើគ្រួសាររបស់អ្នកធ្វើការអធិស្ឋានជាគ្រួសារ ការសិក្សាព្រះគម្ពីរ និង រាត្រីជួបជុំក្រុមគ្រួសារជាទៀងទាត់ សូមពិចារណាប្រកបដោយការអធិស្ឋានអំពីរបៀបដែលអ្នកអាចធ្វើឱ្យបរិយាកាសទាំងនោះមានលក្ខណះកាន់តែប្រសើរឡើង។ ប្រសិនបើគ្រួសាររបស់អ្នកមិនអាចធ្វើនូវកិច្ចការទាំងនេះ សូមពិចារណានូវអ្វីដែលអ្នកនឹងធ្វើ ដើម្បីជួយស្ថាបនាសកម្មភាពទាំងនេះ នៅក្នុងគេហដ្ឋានរបស់អ្នក។
- សូមមើលឡើងវិញនូវឯកសារ នៅក្នុងសៀវភៅ *Teaching, No Greater Call (ត្មានការហៅណាមួយមហិមាជាងការបង្រៀនឡើយ)* (36123) ទំព័រ 137–39 ។

កិច្ចការសំរាប់អាន

ចូរសិក្សាអត្ថបទដូចខាងក្រោមនេះ។ ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍ សូមអានហើយពិភាក្សាអត្ថបទនេះជាមួយនឹងស្វាមីភរិយារបស់អ្នក។

ពរជ័យនៃការអធិស្ឋានជាគ្រួសារ

ប្រធាន ហ្គរដុន ប៊ី ហ៊ុងគ្លី
ទីប្រឹក្សាទីមួយក្នុងគណះប្រធានទីមួយ

សាវក ប៉ុល បានប្រកាសទៅកាន់ ធីម៉ូថេ ថា ៖

“ចូរឱ្យដឹងថា នៅជាន់ក្រោយបង្អស់នឹងមានគ្រាលំបាកណាស់។

“ត្បិតនៅគ្រានោះមនុស្សនឹងស្រឡាញ់តែខ្លួនឯង ទាំងស្រឡាញ់ប្រាក់ អួតអាងគយរ មានឬកខ្ពស់ ប្រមាថមើលងាយ មិនស្តាប់បង្គាប់ឪពុកម្តាយ រមិលគុណ មានចិត្តមិនបរិសុទ្ធ

“មិនស្រឡាញ់តាមធម្មតា មនុស្សគ្មានសេចក្តីអធ្យោគ និយាយបង្កាច់គេ មិនចេះទប់ចិត្ត មានចិត្តសាហាវ មិនចូលចិត្តនឹងការល្អ

“ក្សត់គេឥតបើគិត មានចិត្តធំ ហើយចូលចិត្តនឹងល្បែងលេងជាជាងព្រះ” (ធីម៉ូថេទី 2 3:1–4)។

ចំពោះសេចក្តីទៀងត្រង់ បុគ្គលិកលក្ខណះ និងសេចក្តីសុចរិតនៅក្នុងជីវិតយើងតំរូវឱ្យមានការបញ្ជាក់ជាថ្មី។ លុះត្រាតែយើងសាងម្តងទៀត ទៅក្នុងសរសៃរជីវិតយើងនូវគុណធមិដែលជាព្រលឹង នៃអរិយធមិពិតនឹងផ្លាស់ប្តូរនូវដំណើរជីវិតរបស់យើង។ សំណួរដែលយើងត្រូវប្រឈមមុខនោះគឺ យើងគួរចាប់ផ្តើមពីកន្លែងណា?

ខ្ញុំមានចិត្តរីករាយខ្លាំងណាស់ដោយដឹងថា ការណ៍នេះត្រូវបានចាប់ផ្តើមឡើងដោយមានអំណរគុណ ចំពោះព្រះជាព្រះវរបិតាដ៏អស់កល្បជានិច្ចរបស់យើង ចំពោះទំនាក់ទំនងរបស់យើងជាមួយនឹងទ្រង់ក្នុងនាមជាកូនចៅរបស់ទ្រង់ ដោយមានការប្រាស្រ័យទាក់ទងជាមួយនឹងទ្រង់ដោយការដឹងគុណ ស្តីអំពីតួនាទីដ៏ទេវភាពរបស់ទ្រង់ និងដោយមានការអង្វរប្រចាំថ្ងៃនូវការដឹកនាំរបស់ទ្រង់នៅក្នុងកិច្ចការរបស់យើង។

ខ្ញុំសូមធ្វើការណែនាំថា ការត្រឡប់ទៅរកគំរូចាស់នៃការអធិស្ឋាន ដែលជាការអធិស្ឋានជាគ្រួសារនៅក្នុងគេហដ្ឋានជាមួយគ្នា គឺជាថ្នាំព្យាបាលដ៏សំខាន់ដែលនឹងព្យាបាលជម្ងឺដ៏គួរឱ្យភ័យខ្លាច ដែលកំពុងចុះស៊ីនូវឥរិយាបទនៃសង្គមរបស់យើងបាន។ យើងមិនអាចរំពឹងឱ្យកើតមានអព្ភូតហេតុនៅក្នុងរយះពេលតែមួយថ្ងៃនោះទេ ប៉ុន្តែយើងត្រូវរំពឹងទុកថានឹងមានអព្ភូតហេតុកើតមាននៅជំនាន់មួយ។

កាលពីមួយ ឬពីរជំនាន់កន្លងទៅ ការអធិស្ឋានជាគ្រួសារនៅក្នុងគេហដ្ឋានរបស់ពួកអ្នកគ្រីស្ទាននៅជុំវិញពិភពលោក គឺកើតមានជាផ្នែកមួយនៃសកម្មភាពជាប្រចាំ ក៏ដូចជាការបរិភោគអាហារដូច្នោះដែរ។ នៅពេលការអនុវត្តន៍នោះ ត្រូវបានគេកាត់បន្ថយ ការពុកផុយខាងសីលធមិដែលបានប្រឹក្សាដោយសាវកប៉ុលបានកើតមានឡើង។

ខ្ញុំមានសេចក្តីអំណរដោយហេតុផលថា ត្មានការជំនួសឱ្យណាមួយមានលក្ខណះគ្រប់គ្រាន់ចំពោះការលុតជង្គង់រួមគ្នានៅពេលព្រឹក និងពេលយប់—ដោយមានឪពុក ម្តាយ និងកូនចៅនោះឡើយ។ ការណ៍នេះគឺសំខាន់ជាងការមានព្រំទន់វាំងនន្រស់ស្អាត និងការលាបពណិបានយ៉ាងល្អទៅទៀត ការណ៍នេះគឺជារឿងមួយដែលនឹងធ្វើឱ្យប្រសើរឡើង និងមានភាពស្រស់ស្អាតនៅក្នុងគេហដ្ឋាន។

នៅគ្រប់ទិដ្ឋភាពនៃការលុតជង្គង់គឺមាននូវអ្វីមួយ ដែលបានលុបបំបាត់ចោលនូវឥរិយាបទដែលបានរៀបរាប់ដោយ ប៉ុល ថា ៖ “អួតអាង . . . ឥតបើគិត មានចិត្តធំ”។

នៅរាល់ការអនុវត្តន៍របស់ឪពុកម្តាយ ព្រមទាំងកូនដោយការលុតជង្គង់នោះ គឺមាននូវអ្វីមួយ ដែលលុបបំបាត់ចោលនូវអាកប្បរិយាទាំងនោះដែលគាត់បានរៀបរាប់ថា ៖ “មិនស្តាប់បង្គាប់ឪពុកម្តាយ . . . មិនស្រឡាញ់តាមធម្មតា”។

នៅក្នុងសកម្មភាពនៃការនិយាយទៅកាន់ព្រះអាទិទេព គឺមានអ្វីមួយដែលទូទាត់សងនិន្នាការឆ្ពោះទៅរកពាក្យបណ្តាសា និងឆ្ពោះទៅរកការប្រែចិត្តទោទន់ទៅរកល្បែងលេងជាជាងព្រះ។

ការខិតចូលទៅរកភាពមិនបរិសុទ្ធ ដូចដែល ប៉ុល បានរៀបរាប់ថាជា ការរមិលគុណនោះ គឺត្រូវបានលុបចោល នៅពេលសមាជិកគ្រួសារថ្លែងអំណរគុណ ដល់ព្រះអម្ចាស់ចំពោះជីវិត និងសេចក្តីសុខសាន្តដែលពួកគេមានរួមគ្នានោះ។ ហើយនៅពេលថ្លែងអំណរគុណដល់ព្រះអម្ចាស់ឱ្យគ្នាទៅវិញទៅមក នោះការថ្លែង អំណរគុណថ្មីមួយ ទិដ្ឋភាពថ្មីមួយ និងឥទ្ធិពលមួយចំពោះគ្នាទៅវិញទៅមក នឹងត្រូវ បានបង្កើតឡើងនៅក្នុងគ្រួសារនោះ។

ព្រះគម្ពីរបានប្រកាសថា ៖ "អ្នកត្រូវថ្វាយអំណរគុណដល់ព្រះអម្ចាស់ ជាព្រះនៃ អ្នកនៅគ្រប់ការណ៍ទាំងអស់" (គ. និង ស. 59:7)។ ហើយជាថ្មីម្តងទៀត ៖ "មនុស្សមិនដែលជំទាស់ព្រះក្នុងការណ៍ណាមួយឡើយ ឬក៏សេចក្តីក្រោធរបស់ទ្រង់ មិនទាស់នឹងនរណាមួយទេ លើកលែងតែអស់អ្នកណាដែលមិនទទួលស្គាល់ព្រះហស្ត របស់ទ្រង់" (គ. និង ស. 59:21)។

នៅក្នុងការចងចាំរួមគ្នាចំពោះព្រះអម្ចាស់នូវអ្នកក្រីក្រ អ្នកខ្វះខាត និងអ្នកដែល ត្រូវបានគេរំលោភបំពាន នោះសេចក្តីស្រឡាញ់ចំពោះមនុស្សដទៃជាងខ្លួនឯង ការ គោរពចំពោះអ្នកដទៃ និងបំណងប្រាថ្នាដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នកដទៃ នឹងត្រូវបានអភិវឌ្ឍដោយស្ម័យប្រវត្តិ ប៉ុន្តែវាមានភាពប្រាកដនិយម។ បុគ្គលម្នាក់មិន អាចទូលសុំដល់ព្រះឱ្យជួយអ្នកជិតខាងដែលកំពុងមានទុក្ខព្រួយ ដោយពុំមាន អារម្មណ៍ភ្ញាក់រលឹកធ្វើអ្វីមួយដោយខ្លួនឯង ដើម្បីជួយអ្នកជិតខាងរូបនោះបានឡើយ។ អព្ភូតហេតុជាច្រើន នឹងកើតមានឡើងនៅក្នុងជីវិតរស់នៅរបស់ក្មេងទាំងឡាយក្នុង ពិភពលោកនេះ ប្រសិនបើពួកគេទុកចោលភាពអត្មានិយមរបស់ខ្លួនមួយអន្លើរ ហើយ ខិតខំបំរើដល់មនុស្សដទៃនោះ។ គ្រាប់ពូជកើតចេញពីទីជំរកនោះ និងដើមឈើផ្តល់ ផ្លែអាចរីកធំធាត់ គឺជាការប្រសើរដែលត្រូវបានដាំ និងថែទាំនៅក្នុងការអង្វរជា រៀងរាល់ថ្ងៃរបស់ក្រុមគ្រួសារនោះ។

ខ្ញុំមិនបានដឹងអំពីរបៀបណាដែលប្រសើរណាជាង ការអភិវឌ្ឍន៍សេចក្តីស្រឡាញ់ ចំពោះមាតុភូមិជាង ឱពុកម្តាយដែលអធិស្ឋាន នៅចំពោះមុខកូនចៅរបស់ខ្លួន ឱ្យប្រទេសដែលពួកគេរស់នៅ ដោយអំពាវនាវដល់ពរជ័យ នៃព្រះដ៏មានមហិទ្ធិឬទ្ធី មកលើប្រទេសនោះ ដើម្បីឱ្យសេរីភាព និងសេចក្តីសុខសាន្តកើតមាននោះឡើយ។ ខ្ញុំមិនបានដឹងអំពីរបៀបណាដែលប្រសើរជាងការស្ថាបនានៅក្នុងដួងចិត្តកូនចៅរបស់ យើងនូវការគោរពចំពោះពួកអ្នកមានសិទ្ធិអំណាចជាង ការចងចាំពួកអ្នកដឹកនាំ ក្នុងជួររដ្ឋាភិបាលនៅក្នុងការអធិស្ឋានជាគ្រួសាប្រចាំថ្ងៃនោះឡើយ។

ខ្ញុំចងចាំដោយមើលឃើញនៅលើផ្ទាំងប្រកាសដែលសរសេរថា ៖ "ប្រជាជាតិ មួយដែលមានការអធិស្ឋាន គឺជាប្រជាជាតិមួយដែលមានសេចក្តីសុខសាន្ត"។ ខ្ញុំជឿ ថា វាគឺដូច្នោះមែន។

ត្មានអ្វីមួយដែលមានប្រយោជន៍ច្រើនជាងការផ្តល់ភាពងាយស្រួលនៅក្នុង ការពង្រឹងគ្រួសារ គាមរបៀបដ៏ឈ្លាសវៃមួយដែលនឹងនាំមកនូវការគោរពដល់ឱពុក ម្តាយ រួចហើយនាំទៅរកការគោរពប្រណិបត្តិ ដែលនឹងជះឥទ្ធិពលខាងវិញ្ញាណធ្វើ ឱ្យមានការប្រែចិត្ត ដែលនឹងលុបបំបាត់ចោលទាំងស្រុងនូវការវិនាសនៃគេហដ្ឋាន ជាងការអធិស្ឋានរួមគ្នា ការសារភាពនូវភាពទន់ខ្សោយរួមគ្នាចំពោះព្រះអម្ចាស់ និង ការអំពាវនាវឱ្យមានពរជ័យរបស់ព្រះអម្ចាស់មកលើគេហដ្ឋាននោះ និងពួកអ្នកដែល ស្នាក់នៅក្នុងនោះឡើយ។

ខ្ញុំបានមានចំណាប់អារម្មណ៍ជាយូរមកហើយ ជាមួយនឹងដំណើររៀងមួយដែល លើកឡើងដោយបុរសម្នាក់ ដែលបានទទួលមរណភាពជាយូរមកហើយ។ លោក ជេមស៍ អេជ ម៉យល៍ បានសរសេរទៅកាន់ចៅ អំពីការអធិស្ឋានជាគ្រួសារនៅក្នុង គេហដ្ឋានរបស់គាត់ផ្ទាល់។ គាត់បាននិយាយថា ៖ "យើងមិនបានចូលដំណេកពីមុន ការលុតជង្គង់អធិស្ឋាន ដើម្បីអង្វរសុំការដឹកនាំ និងការអនុមតិដ៏ទេវភាពនោះ ឡើយ។ ភាពខុសប្លែកផ្សេងៗគ្នានឹងកើតមានឡើងនៅក្នុងក្រុមគ្រួសារ ដែលមាន ការគ្រប់គ្រងបានយ៉ាងល្អ ប៉ុន្តែការណ៍ទាំងនោះនឹងរលាយបាត់ទៅវិញដោយ . . . វិញ្ញាណនៃការអធិស្ឋាន . . .។ ចិត្តវិជ្ជាទៅក្នុងដំណើរនេះមាននិន្នាការ ដើម្បីលើក កំពស់ដល់ជីវិតដ៏សុចរិតនៅក្នុងចំណោមមនុស្ស។ វាមាននិន្នាការចំពោះសាមគ្គីភាព សេចក្តីស្រឡាញ់ ការអភ័យទោស និងចំពោះការបំរើ"។

នៅក្នុងឆ្នាំ 1872 វរសេនីយឯក ថូម៉ាស អិល ខេន ជាមិត្តដ៏ល្អរបស់សមាជិក យើងនៅក្នុងគ្រានៃការរងទុក្ខរបស់ពួកគេនៅ អាយអូវ៉ា និងនៅគ្រាដែលកងទ័ពបាន ចូលទៅកាន់ជ្រលងភ្នំសលត៍ លេក គាត់បានមកកាន់ភាគខាងលិចម្តងទៀតជាមួយ នឹងភរិយា ព្រមទាំងកូនប្រុសពីរនាក់របស់គាត់។ ពួកគេបានធ្វើដំណើរទៅកាន់ សេន ចច ជាមួយលោកព្រិកហាំ យ៉ង់ ដោយមានការឈប់សំរាកនៅតាមផ្លូវជា រៀងរាល់យប់ នៅក្នុងគេហដ្ឋានរបស់សមាជិកសាសនាចក្រ។ អ្នកស្រ៏ ខេន បាន សរសេរសំបុត្រមួយចំនួនទៅកាន់ឱពុករបស់គាត់ ដែលរស់នៅឯហ្ចិឡាដេលហ្ឌៀ។ នៅក្នុងសំបុត្រមួយគាត់បាននិយាយថា ៖

"នៅគ្រប់ទីកន្លែងដែលយើងបានស្នាក់នៅក្នុងការធ្វើដំណើរនេះ យើងបាន អធិស្ឋានមួយរំពេច បន្ទាប់ពីការបរិភោគអាហារពេលល្ងាច ហើយអធិស្ឋានម្តងទៀត ពីមុនបរិភោគអាហារពេលព្រឹក។ ត្មាននរណាម្នាក់មានការអាក់ខាននោះ ឡើយ. . .។ ពួកមរមនទាំងអស់ . . . បានលុតជង្គង់ចុះរួមគ្នា ខណៈដែលមេគ្រួសារ ឬភ្សៀវកិត្តិយសបានធ្វើការអធិស្ឋានឲ្យ . . .។ ពួកគេបានចំណាយពេលតិចតួចបំផុត នៅក្នុងសួររកហេតុផលចំពោះព្រះ ប៉ុន្តែផ្ទុយទៅវិញ ពួកគេបានសុំនូវអ្វីដែលពួកគេ ត្រូវការ ហើយថ្លែងអំណរគុណចំពោះទ្រង់សំរាប់អ្វី ដែលពួកគេត្រូវបានប្រទានឱ្យ . . .។ [ពួកគេ] ជឿថាព្រះទ្រង់ស្គាល់ឈ្មោះរបស់យើង ហើយពួកគេនឹងសុំឱ្យមាន ពរជ័យមួយចំពោះ [បុគ្គលដ៏ជាក់លាក់ម្នាក់ដោយឈ្មោះ] . . .។ ខ្ញុំមានការចូលចិត្ត ចំពោះទង្វើរទាំងនេះ នៅពេលធ្វើវាម្តងហើយម្តងទៀត"។

អ្ហ៉ូ! ដើម្បីឱ្យយើងដែលជាប្រជាជនមួយក្រុមអាចអភិវឌ្ឍ ឱ្យបានពេញទំហឹងនូវ ការអនុវត្តន៍នេះ ដែលមានសារៈសំខាន់ចំពោះពួកអ្នកត្រួសត្រាយផ្លូវរបស់យើង កាលពីសម័យមុន ការអធិស្ឋានជាគ្រួសារ គឺជាផ្នែកដ៏សំខាន់មួយដូចគ្នានឹង ការថ្វាយបង្គំរបស់ពួកគេនៅក្នុងការប្រជុំទាំងឡាយ ដែលបានរៀបចំឡើងនៅក្នុង រោងឧបោសថជងដែរ។ ដោយមានសេចក្តីជំនឿ ដែលបានកើតមានឡើងមកពី ការអធិស្ឋានប្រចាំថ្ងៃទាំងនោះ ពួកគេបានសំអាតដីដែលមានស្មៅដុះពេញ បានជីក បង្ហូរទឹកទៅកាន់ដីដែលស្ងួត បានធ្វើសមុទ្រខ្សាច់មានភាពរីករាយ បានគ្រប់គ្រងក្រុម គ្រួសាររបស់ពួកគេដោយសេចក្តីស្រឡាញ់ បានរស់នៅដោយសេចក្តីសុខសាន្តជា មួយនឹងគ្នា និងបានធ្វើឱ្យឈ្មោះរបស់ពួកគេមានភាពអមតៈ នៅពេលពួកគេបាន លះបង់ខ្លួននៅក្នុងការបំរើនៃព្រះ។

គ្រួសារគឺជាអង្គភាពរបស់សង្គម។ ការអធិស្ឋានជាគ្រួសារគឺជាសេចក្តីសង្ឃឹមដ៏ ល្អប្រសើរមួយសំរាប់សង្គម។ "ចូរស្វែងរកព្រះយេហូវ៉ាក្នុងកាលដែលអាចនឹងរកទ្រង់ យើញ" (អេសាយ 55:6)។

តើយើងអាចធ្វើឱ្យគេហដ្ឋានរបស់យើងកាន់តែមានភាពស្រស់ស្អាតបានដែរឬ ទេ? ពិតជាបាន តាមរយៈការបង្ហាញខ្លួនរបស់យើង ក្នុងនាមជាគ្រួសារទៅកាន់ ប្រភពនៃភាពស្រស់ស្អាតដ៏ពិតទាំងនោះ។ តើយើងអាចពង្រឹងសង្គម ហើយធ្វើឱ្យវា ក្លាយជាកន្លែងដ៏ល្អប្រសើរមួយបានដែរឬទេ? ពិតជាបាន ដោយការពង្រឹងនូវ

គុណធម៌នៃជីវិតគ្រួសាររបស់យើង តាមរយៈការលុតជង្គង់ចុះរួមគ្នា និងការទូលអង្វរដល់ព្រះដ៏មានមហិទ្ធិឫទ្ធ នៅក្នុងព្រះនាមនៃព្រះរាជបុត្រាសំណប់។

ការអនុវត្តន៍នេះ ដែលជាការត្រឡប់មករកការថ្វាយបង្គំជាគ្រួសារវិញ កំពុងផ្សព្វផ្សាយជុំវិញពិភពលោក ទឹងត្រូវលើកតំកើងយ៉ាងខ្លាំងចំពោះទុក្ខសោក ដែលកំពុងចំផ្លាញយើង។ វានឹងស្តារឡើងវិញនូវសេចក្តីស្មោះត្រង់ ការគោរពជាទូទៅ និងវិញ្ញាណនៃការថ្លែងអំណរគុណនៅក្នុងជួងចិត្តរបស់មនុស្ស។

លោកចៅហ្វាយបានប្រកាសថា ៖ “ចូរសុំ នោះតែងនឹងឱ្យមកអ្នក ចូរកនោះតែងនឹងឃើញ ចូរគោះនោះតែងនឹងបើកឱ្យអ្នក” (ម៉ាថាយ 7:7)។

ខ្ញុំសូមធ្វើទីបន្ទាល់របស់ខ្ញុំចំពោះអ្នករាល់គ្នាថា ប្រសិនបើអ្នកធ្វើការអធិស្ឋានជាគ្រួសារដោយស្មោះត្រង់ នោះអ្នករាល់គ្នានឹងមិនបានយ្លោតទៅឆ្ងាយដោយពុំបានទទួលរង្វាន់នោះឡើយ។ ការផ្លាស់ប្តូរទាំងឡាយ អាចពុំមែនជាការមើលឃើញដោយងាយស្រួលនោះឡើយ។ វាអាចជាការរៀបចំទុកបានយ៉ាងល្អិតល្អន់។ ប៉ុន្តែវានឹងកើតមានឡើង ត្បិតព្រះ “ទ្រង់ប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់” (ហេព្រើរ 11:6)។

ចូរយើងមានភាពស្មោះត្រង់នៅក្នុងការធ្វើជាគំរូដល់ពិភពលោកនេះ នៅក្នុងការអនុវត្តន៍កិច្ចការនេះ និងនៅក្នុងការលើកទឹកចិត្តមនុស្សដទៃឱ្យធ្វើនូវរឿងដូចគ្នានេះដែរ។

ដកស្រង់ចេញមកពី *Ensign* ខែ កុម្ភៈ ឆ្នាំ 1991 ទំព័រ 2–5។

“ហេតុដូច្នេះហើយខ្ញុំត្រូវបានបង្រៀន”

អែលឌើរ អិល ថម ភែរី
នៃក្រុមនៃពួកសាវក 12 ទាក់

ឪពុកម្តាយដ៏ល្អ

ព្រះគម្ពីរមរមនផ្តើមដាមួយនឹងពាក្យសំដីទាំងនេះ ៖ “ខ្ញុំនីហ្វៃដោយបានកើតមកពីឪពុកម្តាយល្អ ហេតុដូច្នេះហើយ ខ្ញុំត្រូវបាន បង្រៀនខ្លះៗនូវអស់ទាំងចំណេះវិជ្ជារបស់ឪពុកខ្ញុំ” (នីហ្វៃទី1 1:1)។ ពិភពលោកមួយនឹងមានភាពខុសប្លែក ប្រសិនបើកំណត់ហេតុផ្ទាល់ខ្លួន នៃកូនចៅម្នាក់ៗរបស់ព្រះវរបិតាគង់នៅស្ថានសួគ៌របស់យើង អាចចាប់ផ្តើមឡើងដោយប្រយោគដូចគ្នានេះ—ជាការមានឪពុកម្តាយដ៏ល្អ និងការបង្រៀនដោយពួកគេទាំងពីរនោះ។

យើងកំពុងរស់នៅក្នុងសម័យកាលដ៏ពិសេសមួយនៃប្រវត្តិសាស្ត្រ ជាសម័យកាលមួយដែលដំណឹងល្អរបស់ព្រះអម្ចាស់ ត្រូវបានស្តារឡើងវិញយ៉ាងពេញលេញ។ អ្នកផ្សព្វផ្សាយសាសនារបស់យើងកំពុងបង្រៀនជាភាសាជាច្រើន ទៅកាន់ប្រជាជាតិជាច្រើនដែលពុំធ្លាប់មានពីមុនមក។ ខណៈដែលវួដ និងស្តេកកំពុងត្រូវបានគេស្ថាបនាឡើងនៅក្នុងផ្នែកជាច្រើននៃពិភពលោក នោះគំនិតច្នៃប្រឌិតជាច្រើន ត្រូវបានបំផុសនៅក្នុងការបង្កើតឧបករណ៍សំរាប់ការត្រាស្រ័យទាក់ទង ដែលអាចទាំយកការបង្រៀន នៃពួកព្យាការីទៅកាន់មនុស្សជាច្រើន។ ឥឡូវនេះ សារលិខិតដ៏សំខាន់នៃដំណឹងល្អអាចផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដើម្បីទាំមកនូវសេចក្តីសង្ឃឹមនៃសេចក្តីសុខសាន្តដ៏អស់កល្បជានិច្ចដល់ជួងចិត្តនៃមនុស្សលោក។

ជីវិតគ្រួសារនៅក្នុងវិបត្តិ

សារលិខិតដ៏អស្ចារ្យមួយនៃដំណឹងល្អ គឺគោលលទ្ធិនៃលក្ខណៈអស់កល្បជានិច្ចនៃក្រុមគ្រួសារ។ យើងសូមប្រកាសចំពោះពិភពលោក នូវតម្លៃនិងសារៈសំខាន់នៃជីវិតគ្រួសារ ប៉ុន្តែមាននូវការយល់ច្រឡំនិងការលំបាកជាច្រើន ដែលយើងរកឃើញថាមាននៅក្នុងពិភពលោកសព្វថ្ងៃគឺការណែនាំចំពោះការចុះអន់ខ្សោយនៃគ្រួសារ។ បទពិសោធន៍នៅក្នុងផ្ទះដែលកូនចៅត្រូវបានបង្រៀន និងហ្វឹកហ្វឺនតាមរយៈឪពុកម្តាយជាទីស្រឡាញ់គឺកំពុងតែដើរថយក្រោយ។

ជីវិតគ្រួសារដែលមានកូនៗនិងឪពុកម្តាយ បានត្រាស្រ័យទាក់ទងរួមគ្នានៅក្នុងការសិក្សារៀនសូត្រ ការលេងសប្បាយ និងជំនួសឱ្យអាហារពេលល្ងាចឆាប់រហ័ស និងការនៅមុខកញ្ចក់ទូរទស្សន៍នាពេលល្ងាច។ នៅក្នុងឆ្នាំ 1991 សមាគមជាតិនៃក្រុងធំៗជាច្រើនបានជួបប្រជុំនៅក្នុងទីក្រុង សលត៍ លេក គិតចំពោះភាពខ្វះខាតនៃការគ្រប់គ្រងនៅក្នុងផ្ទះបានឈានទៅរកចំណុចមួយ នៃការប្រែក្លាយទៅជាវិបត្តិក្នុងប្រទេសជាតិយើង ហើយបានចំណាយពេលវេលាជួបប្រជុំពិភាក្សានូវកង្វល់របស់ពួកគេ។ ពួកគេបានកំនត់ឡើងនូវដំហានមូលដ្ឋានចំនួនប្រាំ ដែលអាចបង្កើននូវឱកាសរបស់ក្រុមគ្រួសារសំរាប់ភាពជោគជ័យ។

ទីមួយគឺពង្រឹងទំនាក់ទំនងតាមរយៈសកម្មភាពនានាជាលក្ខណៈគ្រួសារ ទីពីរ បង្កើតនូវច្បាប់ទំលាប់និងការរំពឹងទុកដ៏សមរម្យ ទីបីគឺសាងនូវទំនុកចិត្តលើខ្លួនឯង ទីបួនដាក់នូវគោលដៅដែលអាចធ្វើបាន និងទីប្រាំគឺវាយតម្លៃ ចំពោះភាពរឹងមាំនិងតំរូវការរបស់គ្រួសារជាឡើងទាត់។

ភ្លាមៗសម្លេងដាស់តឿននៃពួកព្យាការីរបស់យើងតាំងពីដើមដំបូងមកមានសារៈសំខាន់ជាពិសេស។ ដូចដែលយើងបានទទួលការប្រឹក្សា និងការលើកទឹកចិត្ត យើងត្រូវតែប្រុងស្មារតីចំពោះក្រុមគ្រួសាររបស់យើងផ្ទាល់ និងបង្កើនល្បឿននៃកិច្ចការអ្នកផ្សព្វផ្សាយសាសនារបស់យើង ដើម្បីទាំអ្នកដទៃទៅកាន់ចំណេះដឹងនៃសេចក្តីពិតនិងសារៈសំខាន់នៃក្រុមគ្រួសារ។

អ័ដាម និងអេវ៉ាបានរៀនអំពីករណីយកិច្ចជាឪពុកម្តាយ

តាំងពីដើមដំបូងមក ការណែនាំរបស់ព្រះអម្ចាស់ចំពោះអ័ដាម និងអេវ៉ាបានបញ្ជាក់យ៉ាងច្បាស់ អំពីការទទួលខុសត្រូវរបស់ពួកគេក្នុងនាមជាឪពុកម្តាយ។ តួនាទីរបស់គេត្រូវបានកំណត់យ៉ាងច្បាស់។ ក្រោយពីពួកគេបានទទួលការណែនាំពីព្រះអម្ចាស់ យើងឃើញថាពួកគេធ្វើតាមការទូន្មានរបស់ទ្រង់ហើយនិយាយថា ៖

“ហើយនៅថ្ងៃនោះ អ័ដាមបានថ្វាយពរដល់ព្រះ ហើយបានពោរពេញ ហើយបានចាប់ផ្តើមព្យាករ អំពីក្រុមគ្រួសារទាំងអស់នៅលើផែនដីថា សូមឱ្យព្រះនាមនៃព្រះបានប្រកបដោយព្រះពរ ត្បិតព្រោះតែការរំលងរបស់ខ្ញុំ នោះភ្នែកខ្ញុំបានភ្លឺឡើង ហើយនៅក្នុងជីវិតនេះខ្ញុំនឹងមានសេចក្តីអំណរ ហើយនៅក្នុងសាច់ឈាមនោះខ្ញុំនឹងឃើញព្រះទៀត។

“ហើយនាងអេវ៉ាជាប្រពន្ធគាត់បានឮគ្រប់ការណ៍ទាំងនេះ ហើយមានចិត្តរីករាយដោយពោលថា បើសិនជាពុំមែនដោយសារ ការរំលងរបស់យើងទេនោះ យើងក៏នឹងមិនមានពូជសោះ ហើយនឹងមិនដឹងខុសត្រូវនិងសេចក្តីអំណរអំពីសេចក្តីព្រោសលោះរបស់យើងនិងជីវិតដ៏អស់កល្បជានិច្ចដែលព្រះទ្រង់ បានប្រទានដល់មនុស្សទាំងអស់ដែលគោរពតាមដែរ។

"ហើយអ័ដាម និងនាងអេវ៉ាថ្វាយពរដល់ព្រះនាមនៃព្រះ ហើយពួកគេបានប្រាប់គ្រប់ការណ៍ទាំងអស់ដល់ពួកកូនប្រុសកូនស្រីរបស់គេ" (ម៉ូសេ 5:10–12)។

បង្រៀន និងប្រៀនប្រដៅដល់កូនចៅ

មែនហើយ ចាប់តាំងពីដើមដំបូងឡើយ ការទទួលខុសត្រូវរបស់ឱពុកម្តាយក្នុងការបង្រៀនកូនចៅរបស់ខ្លួន គឺមាននៅក្នុងការណែនាំដែលព្រះអម្ចាស់ បានផ្តល់ដល់ឱពុកម្តាយនៅលើផែនដីដំបូងរបស់យើង។

វិវរណៈជាច្រើនបានទទួលពេលដែលសាសនាចក្រ ត្រូវបានសាងឡើងវិញនៅជំនាន់នេះបានទូន្មានឱពុកម្តាយម្តងទៀត ក្នុងកាតព្វកិច្ចរបស់គេដើម្បីបង្រៀន និងប្រៀនប្រដៅកូនចៅរបស់ខ្លួន។ នៅក្នុងកណ្ឌទីកៅសិបបីនៃគោលលទ្ធិ និងសេចក្តីសញ្ញា យើងរកឃើញថាព្រះអម្ចាស់ធ្វើទោសដល់បងប្អូនប្រុសមួយចំនួន ដោយសារតែការមិនបានយកចិត្តទុកដាក់ចំពោះការទទួលខុសត្រូវ នៃគ្រួសាររបស់ខ្លួន។ បទគម្ពីរអានថា ៖

"ប៉ុន្តែយើងបានបញ្ជាដល់អ្នក ឱ្យចិញ្ចឹមកូនចៅរបស់ខ្លួននៅក្នុងពន្លឺនិងសេចក្តីពិត . . .។

"អ្នកពុំបានបង្រៀនកូនចៅរបស់ខ្លួនពីពន្លឺ និងសេចក្តីពិតតាមព្រះបញ្ញត្តិទាំងឡាយនោះឡើយ ហើយអាកំណាចនោះវាមានអំណាច នៅលើអ្នកនៅឡើយ នេះហើយជាហេតុនៃសេចក្តីវេទនារបស់អ្នក។

ហើយឥឡូវនេះ យើងប្រទានព្រះបញ្ញត្តិមួយដល់អ្នក—បើសិនជាអ្នកនឹងត្រូវបានរំដោះឱ្យរួច នោះអ្នកនឹងត្រូវតាំងគេហដ្ឋានរបស់ខ្លួនឱ្យមានរបៀបរៀបរយ ត្បិតមានការណ៍ជាច្រើនដែលពុំទាន់បានត្រឹមត្រូវនៅក្នុងគេហដ្ឋានរបស់អ្នកនៅឡើយទេ" (គ. និង ស. 93:40, 42–43)។

សារៈសំខាន់នៃរាត្រីជួបជុំក្រុមគ្រួសារ

ប៉ុន្មានឆ្នាំមុនសាសនាចក្របានទូន្មានដល់ឱពុកម្តាយទាំងអស់ ឱ្យធ្វើនូវរាត្រីជួបជុំក្រុមគ្រួសារជារៀងរាល់សប្តាហ៍។ បច្ចុប្បន្ទនេះ សេចក្តីណែនាំនោះត្រូវបានបង្កើតឡើងក្នុងផ្ទះនៃសមាជិកសាសនាចក្រ។ យប់ថ្ងៃច័ន្ទត្រូវបានញែកចេញជារាត្រី ដើម្បីឱ្យក្រុមគ្រួសារនៅជួបជុំគ្នា។ គ្មានសកម្មភាពសាសនាចក្រ ឬការចាត់តាំងសង្គមណាមួយគប្បីធ្វើឡើងនៅយប់នេះឡើយ។ យើងត្រូវបានសន្យានូវពរជ័យដ៏អស្ចារ្យជាច្រើន ប្រសិនបើក្រុមគ្រួសាររបស់យើងនឹងស្មោះត្រង់នៅក្នុងកិច្ចការនេះ។

មានម្តងនោះប្រធាន ហារូល ប៊ីលីបានណែនាំយើងថា ៖

"ឥឡូវ សូមពិចារណអំពីរឿងនេះ នៅពេលបេសកកម្មរបស់អេលីយ៉ា ត្រូវបានគេយល់ដ៏ងយ៉ាងច្បាស់លាស់ថា ដួងចិត្តរបស់កូននឹងបង្វែរទៅឯឱពុក ហើយចិត្តឱពុកមកឯកូនវិញ។ ការណ៍នេះនឹងអនុវត្តនៅលើផែនដីនេះ ក៏ដូចជានៅឯជ្រុងម្ខាងទៀតនៃវាំងនទជងដែរ។ ប្រសិនបើយើងមានការធ្វេសប្រហែសចំពោះក្រុមគ្រួសាររបស់យើងនៅទីនេះ នៅក្នុងការមានរាត្រីជួបជុំក្រុមគ្រួសារ ហើយយើងបរាជ័យនៅក្នុងការទទួលខុសត្រូវរបស់យើងនៅទីនេះ តើស្ថានសួគិនឹងមានទិដ្ឋភាពបែបណាទៅ ប្រសិនបើយើងបានបាត់បង់សមាជិកទាំងនោះ ដោយសារតែការធ្វេសប្រហែសរបស់យើងនោះ? ស្ថានសួគិនឹងពុំមានលក្ខណៈជាស្ថានសួគិនោះឡើយ ដរាបណាយើងមិនបានធ្វើនូវអ្វីៗគ្រប់បែបយ៉ាងដែលយើងអាចធ្វើបាន ដើម្បីសង្គ្រោះអស់អ្នកដែលព្រះអម្ចាស់ បានបញ្ជូនមកនៅក្នុងគ្រួសាររបស់យើងនោះទេ"។

ក្រោយមកគាត់បានបន្តទៀតថា ៖

"ដូច្នេះ ដួងចិត្តរបស់អ្នកដែលជាឱពុកម្តាយត្រូវបែរទៅកាន់កូនៗរបស់អ្នក*នៅពេលឥឡូវនេះ* ប្រសិនបើអ្នកមានទូវវិញ្ញាណរបស់ អេលីយ៉ា ពិតប្រាកដ ហើយកុំគិតថាវាគ្រាន់តែសំរាប់អស់អ្នកណាដែលនៅផ្នែកម្ខាងទៀតនៃព្រះសាណិយាប៉ុណ្ណោះ។ ចូរឱ្យដួងចិត្តអ្នកបែរទៅរកកូនៗរបស់អ្នក ហើយបង្រៀនពួកគេ ប៉ុន្តែអ្នកត្រូវធ្វើការណ៍នេះពេលពួកគេនៅក្មេង ដើម្បីទទួលនូវការសិក្សាដ៏ត្រឹមត្រូវមួយ។ ហើយប្រសិនបើអ្នកមិនយកចិត្តទុកដាក់ចំពោះរាត្រីជួបជុំគ្រួសាររបស់អ្នក នោះអ្នកកំពុងមិនយកចិត្តទុកដាក់ចំពោះការចាប់ផ្តើមនៃបេសកម្មរបស់អេលីយ៉ាយ៉ាងពិតប្រាកដ ដូចជាអ្នកមិនយកចិត្តទុកដាក់ចំពោះការស្រាវជ្រាវរបស់អ្នកនូវកិច្ចការនៃពង្សាវល្លីអញ្ចឹងដែរ"។ (នៅក្នុង *Relief Society Courses of Study, 1977–78* [1977] ទំព័រ 2 អក្សរទ្រេតត្រូវបានបន្ថែម)។

ជាញឹកញាប់ខ្ញុំតែងតែគិតពីពេលវេលាដ៏រីករាយដែលយើងមាន ពេលគ្រួសាររបស់យើងនៅក្មេងខ្ចី ហើយកូនៗរបស់យើងនៅឯផ្ទះ។ ខ្ញុំបានរំឲកឡើងវិញនូវថ្ងៃទាំងនោះ ហើយគិតពិចារណាការកែប្រែដែលខ្ញុំអាចធ្វើក្នុងការរៀបចំ និងដឹកនាំគ្រួសារយើង ប្រសិនបើយើងមានឱកាសរស់នៅក្នុងអំឡុងពេលនោះម្តងទៀត។ មានតំបន់ពីរដែលខ្ញុំបានកំណត់ចង់ធ្វើឱ្យប្រសើរឡើង ប្រសិនបើអាទិភាពនោះត្រូវបានផ្តល់ឱ្យខ្ញុំមានទូវកូនចៅនៅក្នុងផ្ទះរបស់យើងម្តងទៀត។

សេចក្តីប្រាថ្នាទីមួយប្រាកដជាដើម្បីចំណាយពេលឱ្យបានច្រើនក្នុងនាមជាស្វាមីនិងភរិយានៅក្នុងការប្រជុំរៀនសូត្រ ក្នុងគណៈកម្មការប្រតិបិត្តគ្រួសារ ការប្រាស្រ័យទាក់ទង ការដាក់ផែនការ និងការរៀបចំឱ្យប្រសើរឡើងក្នុងការបំពេញតួនាទីរបស់យើងក្នុងនាមជាឱពុកម្តាយ។

សេចក្តីប្រាថ្នាទីពីរដែលខ្ញុំចង់បាន ប្រសិនបើខ្ញុំអាចមានឆ្នាំទាំងនោះម្តងទៀត ខ្ញុំនឹងចំណាយពេលវេលាច្រើនជាមួយនឹងក្រុមគ្រួសារ។ នេះរួមបញ្ចូលទាំងរាត្រីជួបជុំក្រុមគ្រួសារជាទៀងទាត់ និងមានអត្ថន័យបំផុត។

ការចូលរួមចំណែករបស់យុវវ័យដើម្បីនាំមកនូវជោគជ័យ

បន្ទុកដ៏ធ្ងន់នៃការដាក់ផែនការ និងការរៀបចំសំរាប់រាត្រីជួបជុំក្រុមគ្រួសារមិនគួរគប្បីទុកឱ្យឱពុកម្តាយតែម្នាក់ឯងនោះទេ។ វិធីសាស្ត្រដែលមានជោគជ័យបំផុតដែលខ្ញុំបានឃើញ គឺពេលដែលយុវវ័យនៃគ្រួសារទទួលចំណែកក្នុងសកម្មនេះ។

ខ្ញុំសូមនិយាយទៅកាន់អ្នកដែលជា ឌីកិន គ្រូបង្រៀន និងសង្ឃដ៏អស្ចារ្យ និងពួកយុវនារីដូចជា យុវនារី ប៊ីហៃ ម៉ៃម៉ៃត និង ឡូរ៉ល ដើម្បីចូលរួមចំណែកដ៏ធំមួយក្នុងភាពជោគជ័យ នៃរាត្រីជួបជុំក្រុមគ្រួសាររបស់អ្នក។ នៅក្នុងគេហដ្ឋានជាច្រើនអ្នកអាចជាមនសិការនៃក្រុមគ្រួសារ។ ជាចុងក្រោយបង្អស់ អ្នកអាចទទួលនូវអ្វីជាច្រើនអំពីបទពិសោធន៍នេះ។ ប្រសិនបើអ្នកចង់រស់នៅក្នុងពិភពលោកដែលមានសន្តិភាពសុវត្ថិភាព និងកាលានុវត្តន៍ភាព គ្រួសារដែលអ្នកបានចូលរួមចំណែកអាចបន្ថែមនូវសុភមង្គល មែនហើយ សូម្បីតែពិភពលោកទាំងមូល។

ខ្ញុំចងចាំអំពីគំរូនៃបទពិសោធន៍នេះ ដែលបានកើតឡើងនៅថ្ងៃបុណ្យគ្រីស្ទម៉ាសឆ្នាំមុន នៅពេលដែលចៅៗរបស់យើងបានធ្វើដំណើរកំសាន្តជាមួយយើង។ ដើម្បីធ្វើឱ្យការធ្វើដំណើរកំសាន្តមានភាពស្មិតស្មាលជាមួយគ្នាយ៉ាងពិតប្រាកដ យើងបានរៀបចំឡានធុនទេសចរណ៍មួយទុកសំរាប់ធ្វើដំណើរកំសាន្ត។ នៅក្នុងឡានមានលោកតា លោកយាយ កូនប្រុសខ្ញុំ និងកូនបីនាក់របស់គាត់។ ភរិយារបស់កូនប្រុសខ្ញុំ បាននៅចាំផ្ទះជាមួយនឹងសមាជិកក្មេងៗនៃគ្រួសារ។ ពេលដែល

ដល់វេនរបស់ខ្ញុំត្រូវបើកបរ ភរិយាខ្ញុំមកអង្គុយទៅជិតខ្ញុំ ដើម្បីធ្វើជាអ្នកព្រាប់ផ្លូវឱ្យពួកយើង។ ខ្ញុំបានឮ ម៉ារត្រេ ជាចៅច្បងដែលអង្គុយទៅខាងក្រោយ កំពុងពិភាក្សាជាមួយនឹងឪពុករបស់នាង។ នាងបានឌិយាយថា ៖ “ប៉ា គោលដៅរបស់យើងទៅក្នុងឆ្នាំនេះ គឺត្រូវបញ្ចប់ព្រះគម្ពីរមរមនក្នុងការសិក្សាជាគ្រួសាររបស់យើង។ នេះគឺជាថ្ងៃចុងក្រោយនៃឆ្នាំនេះ។ ហេតុអ្វីបានជាយើងមិនបញ្ចប់វាឥឡូវនេះទៅ ដើម្បីយើងនឹងធ្វើឱ្យត្រូវតាមកាលវិភាគ?”

វាជាបទពិសោធដ៏ពិសេសមួយ ទៅពេលដែលបានស្តាប់កូនប្រុសរបស់ខ្ញុំ និងកូនទាំងបីរបស់គាត់ ដែលពួកគេម្នាក់ៗបានដាក់វេនគ្នាដើម្បីអានខ្លះៗដល់ពួកចុងក្រោយរបស់មរ៉ូណៃ និងការបំពេញនូវគោលដៅនៃការអានព្រះគម្ពីរមរមនទាំងអស់របស់ពួកគេ។ ចូរចងចាំថា នេះគឺជាក្មេងស្រីម្នាក់ ដែលបានធ្វើការណែនាំ ពុំមែនជាឪពុកម្តាយរបស់នាងនោះទេ។

បញ្ហាប្រឈមចំពោះយុវវ័យ

អ្នករាល់គ្នាគឺជាជំនាន់ដ៏អស្ចារ្យមួយ—ដែលត្រូវរក្សាទុកសំរាប់ពេលវេលាដ៏ពិសេសនៅក្នុងប្រវត្តិសាស្ត្រមនុស្សលោក។ ប្អូនៗមាន អ្វីៗច្រើនណាស់ដែលត្រូវផ្តល់ឱ្យ ដើម្បីបន្ថែមទៅលើការរីកលូតលាស់ និងការអភិវឌ្ឍន៍នៃគ្រួសាររបស់ប្អូនៗ។ ខ្ញុំលើកទឹកចិត្តប្អូនៗឱ្យបោះជំហានទៅមុខនៅក្នុងក្រុមគ្រួសាររបស់ប្អូនៗ ជាមួយនឹងស្នាវតីដ៏មោះមុត ហើយពិសេស ដើម្បីធ្វើឱ្យដំណឹងល្អរស់នៅក្នុងគេហដ្ឋានរបស់ប្អូនៗបានយ៉ាងពិតប្រាកដ។ ចូរចងចាំនូវដំបូន្មានរបស់ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ នៅពេលដែលលោកបានមានប្រសាសន៍ថា ៖

“ខ្ញុំចង់ឱ្យកូនៗរបស់ខ្ញុំ ព្រមទាំងក្មេងៗទាំងអស់នៅក្នុងសិយ៉ូនដ៏ឯងថា ពុំមានអ្វីនៅក្នុងលោកយើងនេះដែលមានតម្លៃច្រើនបំផុតសំរាប់ពួកគេ ដូចដែលចំណេះដឹងនៃដំណឹងល្អត្រូវបានកសាងឡើងវិញនៅលើផែនដីក្នុងថ្ងៃចុងក្រោយទាំងនេះ តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ឡើយ។ ពុំមានអ្វីដែលអាចសង្កត្រឡប់មកវិញនូវការបាត់បង់របស់ដំណឹងល្អទេ។ ពុំមានអ្វីទាំងអស់នៅលើផែនដីនេះ ដែលអាចប្រៀបធៀបជាមួយនឹងភាពល្អអស្ចារ្យនៃចំណេះដឹងរបស់ព្រះយេស៊ូវឡើយ។ ហេតុដូច្នេះហើយ ចូរឪពុកម្តាយទាំងអស់នៅក្នុងសិយ៉ូនថែរក្សាកូនៗ និងបង្រៀនពួកគេអំពីគោលការណ៍នៃដំណឹងល្អ ហើយតស៊ូស៊ូតស្វាញឱ្យពេញទំហឹង ដើម្បីឱ្យពួកគេបំពេញនូវតួនាទីរបស់ខ្លួន ពុំមែនដោយស្ងប់ប្រវត្តិ ប៉ុន្តែព្យាយាមបំផុសគំនិតចូលក្នុងដួងចិត្តរបស់កូនៗនូវវិញ្ញាណនៃសេចក្តីពិត និងការរស់នៅដោយក្តីស្រឡាញ់ចំពោះដំណឹងល្អ ដើម្បីឱ្យពួកគេពុំគ្រាន់តែបំពេញនូវតួនាទីរបស់ខ្លួន ដោយសារតែវាជាការពេញចិត្តពីសំណាក់ឪពុកម្តាយរបស់ពួកគេតែប៉ុណ្ណោះទេ ប៉ុន្តែដោយសារតែវាជាការពេញចិត្តរបស់ខ្លួនផងដែរ” (រៀបរៀងដោយ Brian H. Stuy នៅក្នុង *Collected Discourses Delivered by President Wilford Woodruff, His Two Counselors, the Twelve Apostles, and Others* វ៉ុលទី 5 [ឆ្នាំ 1987–92], 5:436)។

ការធ្វើឱ្យរាត្រីជួបជុំក្រុមគ្រួសារមានជីវិតឡើងវិញ

រាត្រីជួបជុំក្រុមគ្រួសារគឺសំរាប់មនុស្សគ្រប់គ្នា ទោះជានៅក្នុងផ្ទះដែលមានឪពុកម្តាយទាំងពីរនាក់ ឪពុកម្តាយទោល ឬនៅក្នុងក្រុមគ្រួសារដែលជាសមាជិកតែម្នាក់ឯងក៏ដោយ។ ត្រូបង្រៀនតាមផ្ទះ យើងសូមហៅអ្នកទាំងអស់គ្នានៅក្នុងការចុះសួរសុខទុក្ខ ជាធម្មតារបស់អ្នក ដើម្បីលើកទឹកចិត្ត និងធ្វើឱ្យមាននូវការធ្វើរាត្រីជួបជុំក្រុមគ្រួសារ។

ព្យាការីបច្ចុប្បន្នរបស់យើង ប្រធាន រ៉ៃសម៉ា ចាហ្វ ប៊ែនសិន បានរំឭកយើងម្តងទៀតពីភាពចាំបាច់នៃការធ្វើរាត្រីជួបជុំក្រុមគ្រួសារ និងត្រៀមផ្សំផ្សងៗដែលបង្កបង្កើតទៅជាមនុស្សមានដោគជ័យម្នាក់។ គាត់បានមានប្រសាសន៍ថា ៖

“រាត្រីជួបជុំក្រុមគ្រួសារត្រូវបានធ្វើឡើងដើម្បីពង្រឹងនិងការពារគ្រួសារ កម្មវិធីរាត្រីជួបជុំ [ក្រុមគ្រួសារ] របស់សាសនាចក្រធ្វើឡើងទៅរាត្រីមួយរៀងរាល់សប្តាហ៍ ដែលត្រូវបានញែកចេញសំរាប់ឪពុកនិងម្តាយ ដើម្បីជួបជុំកូនប្រុសស្រីរបស់គេទៅក្នុងគេហដ្ឋានរួមគ្នា។ ការអធិស្ឋាន ត្រូវបានធ្វើឡើង ចម្រៀងទំនុកតំកើង និងចម្រៀងជាទៃទៀតត្រូវបានច្រៀង ព្រះគម្ពីរត្រូវបានអាន ប្រធានបទគ្រួសារត្រូវបានពិភាក្សា ទេពកោសល្យត្រូវបានបង្ហាញ គោលការណ៍នៃដំណឹងល្អត្រូវបានបង្រៀន និងជារឿយៗល្បែងកំសាន្តត្រូវបានលេង ព្រមទាំងអាហារ និងភេសជ្ជៈដែលធ្វើទៅផ្ទះត្រូវបានបំរើ ”(នៅក្នុង Conference Report, Philippine Islands Area Conference ឆ្នាំ 1975 ទំព័រ 10)។

នេះគឺជាក្តីសង្ឃឹមរបស់យើងថាអ្នករាល់គ្នាអាចសរសេរនូវរាល់ការណែនាំទាំងនោះ ដែលបានធ្វើឡើងដោយព្យាការី ដែលរាត្រីជួបជុំក្រុមគ្រួសារមួយគួរតប្បីមាន។

ក្រោយមកគាត់បានបន្តទៀតថា ៖ “ឥឡូវនេះគឺជាពរជ័យដែលបានសន្យាដោយព្យាការីរបស់ព្រះចំពោះអស់អ្នកដែលនឹងធ្វើរាត្រីជួបជុំក្រុមគ្រួសារជារៀងរាល់សប្តាហ៍ ៖ ប្រសិនបើពួកបរិសុទ្ធគោរពប្រណិបត្តិការទូន្មាននេះ យើងសូមសន្យាថាពរជ័យដ៏ធំនឹងត្រូវបានតបស្នងមកវិញ។ សេចក្តីស្រឡាញ់ក្នុងផ្ទះ និងការគោរពប្រណិបត្តិចំពោះឪពុកម្តាយនឹងកើនឡើង។ សេចក្តីជំនឿនឹងត្រូវបានអភិវឌ្ឍក្នុងដួងចិត្តនៃយុវវ័យរបស់អ៊ីស្រាអែល ហើយពួកគេនឹងទទួលបានទូរអំណាចដើម្បីប្រឆាំងតបនឹងឥទ្ធិពលអាក្រក់និងការល្បួងដែលប្រេតប្រេទពួកគេ”(នៅក្នុង Conference Report, Philippine Islands Area Conference 1975 ទំព័រ 10 សូមមើលផងដែរ *Improvement Era* ខែ មិថុនា ឆ្នាំ 1915 ទំព័រ 734)។

យើងសូមលើកទឹកចិត្តអ្នករាល់គ្នាឱ្យធ្វើតាមពាក្យទូន្មាននៃព្យាការីរបស់យើង។ នៅក្នុងក្រុមគ្រួសារទាំងអស់នៃសាសនាចក្រ ចូរវិភាគឡើងវិញម្តងទៀតនូវការរីកចំរើនដែលអ្នកកំពុងធ្វើ ដើម្បីមានរាត្រីជួបជុំក្រុមគ្រួសារជាប្រចាំ។ ការអនុវត្តន៍នៃកម្មវិធីនេះ នឹងក្លាយជាខែលការពារដល់អ្នកប្រឆាំងនឹងឥទ្ធិពលអាក្រក់នៃជំនាន់របស់យើង ហើយនឹងនាំមកឱ្យអ្នក ជាបុគ្គល និងសហគមន៍នូវសេចក្តីត្រេកអរដ៏ធំ ហើយអស្ចារ្យនាបច្ចុប្បន្ននេះ និងអស់កល្បជានិច្ចទៅពេលក្រោយ។

សូមព្រះប្រទានពរដល់យើងដើម្បីឱ្យយើង អាចបំពេញនិងពង្រឹងកម្មវិធីដ៏សំខាន់នេះ ពេលយើងប្រឹក្សារួមគ្នាជាសមាជិកគ្រួសារ។

ដកស្រង់ចេញពីការនិយាយដោយ រ៉ៃមលឌើរ ផែរី នៅក្នុងសន្និសីទទូទៅនៃសាសនាចក្រ ខែ មេសា ឆ្នាំ 1994 (សូមមើល Conference Report ខែ មេសា ឆ្នាំ 1994 ទំព័រ 47–51 ឬ *Ensign* ខែ ឧសភា ឆ្នាំ 1994 ទំព័រ 36–38)។

សាសនាចក្រនៃ

ព្រះយេស៊ូវគ្រីស្ទ

នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02363 57258 1
36357 258